ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក
# ការពិត



◆ គេហទំព័រទស្សនាវដ្តីស្វែងរកការពិត

◆ ការចូលចំណែកជួយរកយុត្តិធម៌ជូនជនរងគ្រោះគួរតែទទួលបានការគាំទ្រ

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ១៨៧ ខែកក្កដា ឆ្នាំ២០១៥

# ស្វែងរកការពិត

## ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ១៨៧ ខែកក្កដា ឆ្នាំ២០១៥


## មាតិកា


◆ គេហទំព័រទស្សនាវដ្តីស្វែងរកការពិត ..........១

### ផ្នែកឯកសារ

◆ សេចក្តីកំណត់ហេតុក្នុងចម្លើយសារភាព..........២

◆ ខឹម ឈុំ អនុលេខាតំបន់៤២ ភូមិភាគកណ្តាល ..........៨

### ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ

◆ អតីតកងការពារផ្ទាល់ និងជាចៅរបស់ សោ ភឹម..........១៧

◆ ចាប់ពីរបបខ្មែរក្រហមដល់ឧប្បត្តិហេតុ ហាំបាលី ..........២៦

### ផ្នែកច្បាប់

◆ សវនាការភ័ស្តុតាងស្តីពីការផ្តល់សក្ខីកម្មរបស់..........៣៦

◆ សវនាការស្តីពីការស្តាប់សក្ខីកម្មសាក្សី សំ សិទ្ធី..........៤០

◆ សវនាការស្តីពីការស្តាប់សក្ខីកម្មសាក្សី ទ័ត ធឿន..........៤៣

### វេទិកាពិភាក្សាសាធារណៈ

◆ កេរដំណែលនៃសាលាក្តីខ្មែរក្រហមសម្រាប់..........៤៧

◆ ការចូលរួមចំណែកជួយរកយុត្តិធម៌ជូនជនរងគ្រោះ ..........៥២

### ទំព័រស្រាវជ្រាវរកគ្រួសារ

◆ រសាត់តាមខ្យល់ ..........៥៣

◆ ដំណើរភៀសខ្លួនឆ្លងដែនពីរបបកម្ពុជាប្រជាធិបតេយ្យ ..........៥៧





ទស្សនាវដ្តីស្វែងរកការពិត បោះពុម្ពលើកទី១ ខែមករា ឆ្នាំ២០០០


## រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា



អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ០២៩១ពម.៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

**ស្នេរលេខនេះ ៖** យី ភក្ត្រា, អេង កុកថាយ, ជិន ដួងចន្ទ្រាកែវលក្ខ្មីនារីរតន៍, ប៉ុក ប៉ុនសូម៉ាដ, ជា សីហា **អ្នកនិពន្ធនិងស្រាវជ្រាវ ៖** ទាវ សារៈមុនិន្ទ និង ឌី សុជាតា **អ្នកបកប្រែ ៖** សុភ័ក្ត្រ ភាណា និង សាយ សូលីដា **និពន្ធនាយកទូទៅ ៖** ឆាំង យុ **ជំនួយការនិពន្ធនាយក ៖** សោម ប៊ុនថន **ក្រាហ្វិកកុំព្យូទ័រ ៖** សោម ប៊ុនថន **គ្រប់គ្រងការចែកផ្សាយ ៖** ផេង ពង្ស និង សន ល័ក្ខ Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiatribunal.org, www.cambodiasri.org, www.truthcambodia.com

# គេហទំព័រទស្សនាវដ្ដីស្វែងរកការពិត

ទស្សនាវដ្ដីស្វែងរកការពិត បានបង្កើតគេហទំព័រដែលដាក់ឈ្មោះថា www.truthcambodia.com ក្នុងគោលបំណងផ្សព្វផ្សាយ និងអប់រំឲ្យបានកាន់តែទូលំទូលាយអំពីរបបកម្ពុជាប្រជាធិបតេយ្យ ដើម្បីសម្រេចឲ្យបាននូវការចងចាំ យុត្តិធម៌ និងការផ្សះផ្សាជាតិ ក្នុងសង្គមដែលទទួលរងនូវការបែកបាក់ និងសង្គ្រាមជាច្រើនទសវត្សរ៍ ។ គេហទំព័រ www.truthcambodia.com ក៏ដើរតួនាទីដ៏សំខាន់ក្នុងការចែករំលែកព័ត៌មានអំពីដំណើរការសវនាការកាត់ទោសមេដឹកនាំខ្មែរក្រហមជាមួយសាធារណជន និងជួយសាលាក្ដីក្នុងការរំលែកព័ត៌មានទាក់ទងប្រវត្តិសាស្ត្រខ្មែរក្រហម នៅខណៈពេលអត្ថបទមួយចំនួននៅក្នុងគេហទំព័រនេះ ត្រូវបានយកទៅប្រើប្រាស់ជាភស្តុតាងដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហម ។

គេហទំព័រនេះបែងចែកជា៥ផ្នែកសំខាន់ គឺ១) ផ្នែកឯកសារ ២) ផ្នែកប្រវត្តិសាស្ត្រ ៣) ផ្នែកច្បាប់ ៤) ផ្នែកវេទិកាពិភាក្សាជាសាធារណៈ និង ៥) ផ្នែកស្រាវជ្រាវ ស្វែងរកក្រុមគ្រួសារដែលបានស្លាប់ ឬបាត់ខ្លួនក្នុងរបបខ្មែរក្រហម ជាពិសេស ក៏មានផ្ទុកនូវឯកសារជាវីដេអូ សំឡេង រូបថត និងឯកសារដើមខ្មែរក្រហម ។ អត្ថបទសម្រាប់ផ្នែកទី១) នឹងរៀបរៀងឡើងដោយស្មេរមជ្ឈមណ្ឌលឯកសារកម្ពុជា ដោយផ្អែកលើឯកសារដើមទាំងស្រុង ។ សរសេរឲ្យស្រួលអានគឺការសង្ខេបចេញពីឯកសារដើមមកជាអត្ថបទ ។ គោលបំណងនៃផ្នែកនេះ គឺចង់ជម្រាបជូនសាធារណជនថាតើមានឯកសារអ្វីខ្លះដែលតម្កល់នៅមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ផ្នែកទី២) គឺជាអត្ថបទវិភាគលើប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហម ។ អត្ថបទផ្នែកនេះគឺជាអត្ថបទចូលរួមមកពីអ្នកជំនាញជាន់ខ្ពស់លើប្រវត្តិសាស្ត្រខ្មែរក្រហម ហើយមានទិសដៅសម្រិតសម្រាំងប្រវត្តិសាស្ត្រនេះឲ្យមានភាពកាន់តែសុក្រិតទ្បើងទៀត ។ ផ្នែកទី៣) គឺជាផ្នែកច្បាប់ដែលធ្វើការវិភាគដោយមេធាវី ឬចៅក្រម ឬអ្នកជំនាញការច្បាប់អន្តរជាតិ ។ ការវិភាគនេះនឹងជួយជាគំនិតលើផ្នែកច្បាប់ថា តើឧក្រិដ្ឋកម្មអ្វីខ្លះដែលបានកើតឡើងក្នុងរបបខ្មែរក្រហម ហើយថាតើឧក្រិដ្ឋកម្មនីមួយៗត្រូវតែដោះស្រាយតាមនីតិវិធីបែបណាដើម្បីរកឲ្យបាននូវយុត្តិធម៌ពិតប្រាកដមួយដល់ជនរងគ្រោះ ។ ផ្នែកទី៤) គឺជាវេទិកាពិភាក្សា និង ផ្ដល់គំនិតនានាលើបញ្ហាខ្មែរក្រហម ។ អត្ថបទទីនេះ គឺជាវិភាគទានចូលរួមពីសំណាក់អង្គការក្រៅរដ្ឋាភិបាលនានា សមាជិករាជរដ្ឋាភិបាល គ្រូ សិស្សនិស្សិត ជាដើម ។ល ។ ថ្វីត្បិតតែផ្នែកនេះមានលក្ខណៈបើកទូលាយជាទូទៅយ៉ាងណាក៏ដោយ ក៏អត្ថបទវិភាគទានតម្រូវឲ្យមានលក្ខណៈវែកញែកប្រកបដោយសីលធម៌ គុណធម៌ និងសេចក្ដីថ្លៃថ្នូរដ៏ខ្ពស់បំផុត ដែលអាចធ្វើទៅបាន ។ វាគឺជាទំព័រ “ចូលរួម” ដើម្បី “ដោះស្រាយបញ្ហា” ក្នុងការស្វែងរកយុត្តិធម៌ និងក្នុងការជួយបំភ្លឺប្រវត្តិសាស្ត្រមួយសម្រាប់ជាការផ្សះផ្សារបួសផ្លូវចិត្ត និងការអប់រំទៅថ្ងៃអនាគត ។ ផ្នែកទី៥) គឺជាទំព័រស្រាវជ្រាវស្វែងរកក្រុមគ្រួសារដែលបានស្លាប់ ឬបាត់ខ្លួនក្នុងរបបខ្មែរក្រហម ឬការសាកសួររកព័ត៌មានអំពីមិត្តភក្ដិសាច់សារលោហិតដែលបានស្លាប់ដោយរបបខ្មែរក្រហម ។ ផ្នែកនេះនឹងជួយផ្សព្វផ្សាយរកព័ត៌មានជូនដល់សាធារណជនដោយសុទ្ធចិត្ត ហើយជាផ្នែកដែលរៀបរាប់អំពីការរកឃើញឡើងវិញនូវជីវិតថ្មីក្រោយរបបខ្មែរក្រហម ។ ផ្នែកនេះនឹងស្វាគមន៍គ្រប់សំណើស្ដីពីការស្វែងរកក្រុមគ្រួសារមកពីសាធារណជនទូទៅ ។

សរុបសេចក្ដីទៅ ផ្នែកទាំង៥ខាងលើនៃគេហទំព័រនេះនឹងបើកចំហជូនដល់ការចូលរួមស្វែងរកការពិតពីសាធារណជនគ្រប់ស្រទាប់ជាន់ថ្នាក់ ដោយមិនប្រកាន់ពណ៌សម្បុរ ភេទ អាយុ ឬនិន្នាការនយោបាយណាមួយឡើយ ក៏ដូចជាការបម្រើដល់សាធារណជន និងដើម្បីជួយជ្រោមជ្រែងស្វែងរកយុត្តិធម៌ជូនដល់ប្រជាជនកម្ពុជាគ្រប់រូប ។ គ្រប់លិខិត ឬអត្ថបទ ដែលផ្ញើមកកាន់គេហទំព័រនេះ សូមដាក់ឈ្មោះ មុខងារ អាសយដ្ឋាន និងលេខទូរស័ព្ទសម្រាប់ធ្វើសេចក្ដីបញ្ជាក់លើខ្លឹមសារនៃលិខិត ឬអត្ថបទមុនការចេញផ្សាយ ។ គេហទំព័រ www.truthcambodia.com សូមរក្សាសិទ្ធិក្នុងការកែលម្អពាក្យពេចន៍នៃលិខិតទាំងឡាយ ដោយថែរក្សានូវអត្ថន័យដើម និងចុះផ្សាយទាំងស្រុងចំពោះអត្ថបទចូលរួមទាំងឡាយ ។ **ឆាំង យុ**

# សេចក្តីកំណត់ហេតុក្នុងចម្លើយសារភាពរបស់ ហុក ថៃហេង និស្សិតគ្រឿងយន្តកសិកម្មមកពីប្រទេសរ៉ូមានី

*(ដកស្រង់ចេញពីឯកសារចម្លើយសារភាព D១៨០៤៩)*

ហុក ថៃហេង ភេទប្រុស អាយុ៣១ឆ្នាំ ជាគ្រូបង្ហាត់កីឡាផ្នែកប៉េងប៉ុង និងជានិស្សិតជាប់អាហារូបករណ៍បានទៅសិក្សានៅប្រទេសឆេកូស្លូវ៉ាគីផ្នែកគ្រឿងយន្តកសិកម្ម តែក្រោយមកបានប្តូរទៅសិក្សានៅប្រទេសរ៉ូមានីវិញ ។ ថៃហេង កើតនៅភូមិប្រមូលផ្តុំ ឃុំស្មោង ស្រុកកំចាយមារ ខេត្តព្រៃវែង ។ ឪពុកឈ្មោះ ហុក ឈាង ម្តាយឈ្មោះ លឹម លាត អ្នកទាំងពីរជាឈ្មួញទិញស្រូវពីកំពង់ចាមយកទៅលក់នៅស្រុកកំណើត ។ បន្ទាប់ពីបញ្ចប់ការសិក្សានៅប្រទេសរ៉ូមានី ថៃហេង ក៏បានវិលត្រឡប់មកប្រទេសកម្ពុជាវិញនៅថ្ងៃទី២០ ខែសីហា ឆ្នាំ១៩៧៧ តាមផែនការចាត់តាំងរបស់ សេ.អ៊ី.អា អាមេរិក ។ បន្ទាប់មកក៏ត្រូវបានអង្គការចាប់ខ្លួននៅថ្ងៃទី២១ ខែសីហា ឆ្នាំ១៩៧៧ ក្រោយពេលចូលមកដល់ស្រុកខ្មែរបានតែមួយថ្ងៃប៉ុណ្ណោះ ហើយបានបញ្ជូនខ្លួនមកមន្ទីរឃុំឃាំងស-២១ ដើម្បីសួរចម្លើយ ។

**អំពីប្រវត្តិសកម្មភាពនយោបាយ**



ជនរងគ្រោះដែលត្រូវបានឆ្មាំគុកធ្វើទារុណកម្ម និងសម្លាប់នៅមន្ទីរសន្តិសុខស-២១ ប្តុកកុទូលស្វែង

ឆ្នាំ១៩៥៤ ថៃហេង បានរស់នៅជាមួយឪពុកម្តាយ ។ ក្រោយមកបានផ្លាស់ប្តូរទីលំនៅ មករស់នៅភូមិទួលស្បូវក្នុងក្រុងកំពង់ចាម ។ ចំណែកឪពុកម្តាយរបស់ ថៃហេង តែងចេញចូលទៅមកនាំស្រូវទៅលក់នៅស្រុកកំណើត ។ នៅឆ្នាំ១៩៥៥ ថៃហេង បានចូលសិក្សានៅសាលាជីដុះក្នុងក្រុងកំពង់ចាមចាប់ពីថ្នាក់អទិកដ្ឋានរហូតដល់ឆ្នាំ១៩៦០ ទើបប្រឡងចូលថ្នាក់ទី៦ នៃវិទ្យាល័យព្រះសីហនុ កំពង់ចាម ។ រាល់ពេលឈប់សម្រាក ថៃហេង តែងចូលលេងនៅវិហារសាសនាគ្រឹះប្រូតេស្តង់ ហើយស្តាប់ការទេសនារបស់អាចារ្យនៅទីនោះ ។ ក្រោយមកបានស្គាល់ជនជាតិបារាំងម្នាក់ឈ្មោះ ហ្សង់ក្លាវូ ជាអាចារ្យនៅព្រះវិហារនេះ ហើយក៏ជាមេ សេ.អ៊ី.អា ម្នាក់បន្ទាប់ពីមេធំឈ្មោះ អេដវ៉ា (ជនជាតិអាមេរិកាំង) ។ អេដវ៉ា ជាអាចារ្យនៅព្រះវិហារនេះ ដែលបានទទួលអប់រំមនុស្សឲ្យចូលចិត្តរបបលោកសេរី និងស្អប់ខ្ពើមរបបកុម្មុយនីស្ត ។ បន្ទាប់មក ហ្សង់ក្លាវូ បានចាត់តាំងឲ្យ ថៃហេង ប្រមូលសិស្ស និស្សិតមកស្តាប់ការខទ្ទេសនាមរបស់អាចារ្យ អេដវ៉ា ពីសាសនាគ្រិស្តប្រូតេស្តង់ ។

ឆ្នាំ១៩៦២ ថៃហេង រៀនដល់ថ្នាក់ទី៤ នៅសាលាព្រះសីហនុ ក្រុងកំពង់ចាម ។ បន្ទាប់ពីបានបបួលសិស្សឲ្យចូលរួមទទួលឥទ្ធិពលលោកសេរីបានមួយរយៈមក ហ្សង់ក្លាវូ ក៏បានបញ្ចូល ថៃហេង ឲ្យចូលជាភ្នាក់ងារ សេ.អ៊ី.អា នៅក្នុងការិយាល័យរបស់ អេដវ៉ា ដែលមាន អេដវ៉ា ផ្ទាល់ជាអ្នកទទួលស្គាល់ ។ ការបញ្ចូល សេ.អ៊ី.អា នេះ គឺគ្រាន់តែ ហ្សង់ក្លាវូ និង អេដវ៉ា ណែនាំហើយចុះខសន្យា និងចុះហត្ថលេខានៅចំពោះមុខ អេដវ៉ា ប៉ុណ្ណោះ ។ ភារកិច្ចសំខាន់ដែល ហ្សង់ក្លាវូ ប្រគល់ឲ្យ ថៃហេង ធ្វើ នៅពេលនោះគឺ៖

- ◆ នាំមិត្តភក្តិ និងសិស្ស និស្សិតមកទទួលយកឥទ្ធិពលលោកសេរីនៅព្រះវិហារប្រូតេស្តង់ ។
- ◆ នាំយកសៀវភៅវប្បធម៌លោកសេរីចែកតាមខ្សែរយៈ និងចែកដោយផ្ទាល់ដល់សិស្ស និស្សិត ។

ក្រោយមក ហ្សង់ក្លាវូ បានណែនាំ ថៃហេង ឲ្យស្គាល់ឈ្មោះ ប៉ិច ថេង សាស្ត្រាចារ្យគណិតសាស្ត្រនៅវិទ្យាល័យព្រះសីហនុ ។ ក្នុងករណី ថៃហេង មានការងារផ្សេងៗត្រូវទាក់ទងជាមួយឈ្មោះ ប៉ិច ថេង លើកលែងការងារសំខាន់ទើបឲ្យជួបជាមួយខ្លួនផ្ទាល់ ។ ក្រោយមកទៀត ថៃហេង បានស្គាល់ខ្សែ សេ.អ៊ី.អា មួយចំនួនតាមរយៈការណែនាំឲ្យស្គាល់ពី ហ្សង់ក្លាវូ នៅក្នុងពិធីជប់លៀងពិសេសមួយ ។ ខ្សែរយៈ សេ.អ៊ី.អា ទាំងនោះមានឈ្មោះ ង៉ោ ប៊ុនគ្រុយ សិស្សថ្នាក់ទី៤, ជីង គុយលី សិស្សថ្នាក់ទី៤, ទិន ទូច សិស្សថ្នាក់ទី៤, ខេង លាងស្រេង សិស្សថ្នាក់ទី៤, លាង ហាក់ សិស្សថ្នាក់ទី៤, នួន ឈុនលី សិស្សថ្នាក់ទី៣, ឌី ម៉ូនី សិស្សថ្នាក់ទី៤, ស៊ាង លី សិស្សថ្នាក់ទី៣, ម៉ា សុងសេង សិស្សថ្នាក់ទី៣, ហុង សាយ សិស្សថ្នាក់ទី៣, នី ប៊ុនហឺ គ្រូបង្រៀន, ឡៅ ណាំ សិស្សថ្នាក់ទី៤, អ៊ឹម វ៉េត សិស្សថ្នាក់ទី៤,និង យុក ម៉េង សិស្សថ្នាក់ទី៤ ។

ខែកញ្ញា ឆ្នាំ១៩៦២ ហេង រួមជាមួយឈ្មោះ ឡៅ ណាំ, នួន ឈុនលី, យុក ម៉េង, ង៉ោ ប៊ុនគ្រុយ, ជីង គុយលី, អ៊ឹម វ៉េត, ខេង លាងស្រេង បានទទួលផែនការពី ប៉ិច ថេង នៅវិទ្យាល័យព្រះសីហនុ កំពង់ចាម ដែលខ្លឹមសារនៃផែនការនោះគឺ ឲ្យទប់ទល់ឥទ្ធិពលរបស់កុម្មុយនីស្តនៅក្នុងមជ្ឈដ្ឋានសិស្ស និងយកសៀវភៅមនោគមវិជ្ជាលោកសេរី ទៅផ្សព្វផ្សាយឲ្យបានច្រើនដងនៅក្នុងសាលារៀន ។ ក្រោយពីទទួលបានផែនការហើយ ថៃហេង និងបក្ខពួកបានយកសៀវភៅមនោគមចក្រពត្តិពីផ្ទះ ហ្សង់ក្លាវូ ទៅចែកដល់សិស្ស និងប្រជាជនដែលធ្លាប់ស្គាល់គ្នាកន្លងមក ។ ក្រៅពីនេះ ថៃហេង បាននាំសិស្សទៅទទួលឥទ្ធិពលលោកសេរីនៅព្រះវិហារប្រូតេស្តង់ជាបន្តបន្ទាប់ តាមការណែនាំពី ហ្សង់ក្លាវូ និង ប៉ិច ថេង ។

ឆ្នាំ១៩៦៣ ស្របពេលមានភាពច្របូកច្របល់ដោយចលនាបដិវត្តន៍កើតមាននៅក្រុងសៀមរាប ពិសេសចលនានិស្សិតរកវាយប៉ូលីសនៅក្នុងអនុវិទ្យាល័យសៀមរាប ប៉ិច ថេង បានចាត់តាំង ថៃហេង និង អ៊ឹម វ៉េត ឲ្យមកទាក់ទងខ្សែរបស់ ហង់ ធុនហាក់ ឈ្មោះ អ៊ឹម រុន សាស្ត្រាចារ្យ វិទ្យាល័យសៀមរាប, ឈ្មោះ អុង ប៊ុនហាន បច្ចុប្បន្នជាវិស្វករនៅប្រទេសយូហ្គោស្លាវី និងឈ្មោះ ពក ស្រ៊ាង ។ ការទាក់ទងគ្នានេះគឺដើម្បីក្តាប់សភាពការណ៍នៅក្នុងក្រុងសៀមរាប ពិសេស នៅក្នុងមជ្ឈដ្ឋានសិស្ស និងគ្រូ ដើម្បីបំបាត់និន្នាការក្រហមក្នុងមជ្ឈដ្ឋានសិស្សដោយប្រើវិធីបង្កើនការផ្សាយសៀវភៅលោកសេរីក្នុងសាលារៀន ។ នៅពាក់កណ្តាលឆ្នាំ១៩៦៣ ប៉ិច ថេង បានចាត់តាំង ថៃហេង និង ទិន ទូច ឲ្យទៅទាក់ទងខ្សែរបស់ ហង់ ធុនហាក់ នៅសាលាសហជន និងនៅសាលាព្រះសីហនុដែលធ្លាប់ទៅបង្រៀនសិស្សនៅជីហែ និងក្រូចឆ្មារ ដើម្បីពង្រឹងសកម្មភាពផ្សព្

ផ្សាយឥទ្ធិពលលោកសេរីនៅក្នុងស្រុកក្រូចឆ្មារ និងជីហែ ដើម្បីធ្វើយ៉ាងណាដណ្តើមយកមូលដ្ឋាននេះឲ្យបានមុនចលនាបដិវត្តន៍ ។ អ្នកដែល ថៃហេង ទាក់ទងជាមួយមានឈ្មោះ ប្ងង់ គីនសៀវ សាស្ត្រាចារ្យវិទ្យាល័យព្រះសីហនុ, យឹម ម៉េង សាស្ត្រាចារ្យវិទ្យាល័យព្រះសីហនុ និង នួន ថន សាស្ត្រាចារ្យអក្សរសាស្ត្រ នៅវិទ្យាល័យព្រះសីហនុ ។ ក្រោយពីបានទាក់ទងអ្នកទាំងបីខាងលើមក ថៃហេង និងបក្ខពួកមួយចំនួនទៀត មានឈ្មោះ ទិន ទូច, យុក ម៉េង, អ៊ឹម រ៉េត និង ហុង សាយ តាមការចាត់តាំងរបស់ ប៊ិច ថេង ឲ្យទៅផ្សាយពីសៀវភៅរបស់លោកសេរីនៅសាលាជីហែ និងនៅតាមទីកន្លែងដែលប្រជាជនធ្លាប់ស្គាល់ ដោយឃោសនាឲ្យប្រជាជនស្អប់ខ្មែរក្រហម ហើយបែរមកស្រឡាញ់គាំទ្ររបបសេរីវិញ ។

ឆ្នាំ១៩៦៤ ហ្សង់ក្លាវ៉ូ ត្រូវទៅក្តាប់ផ្នែកសាសនាព្រះវិហារប្រូតេស្តង់នៅសៀមរាប ។ ពេលនោះ ហ្សង់ក្លាវ៉ូ ក៏បានប្រគល់ការងារ សេ.អ៊ី.អា នៅក្រុងកំពង់ចាមឲ្យមក ប៊ិច ថេង ចាត់ចែងជំនួសខ្លួនទាំងអស់ ។ កាលណោះពេលដែលចលនាបដិវត្តន៍ផុលផុសខ្លាំងក្នុងមជ្ឈដ្ឋាននិស្សិតនៅកំពង់ចាម ប៊ិច ថេង បានហៅសមាជិក សេ.អ៊ី.អា ទាំងអស់មកប្រជុំរៀបចំផែនការនៅផ្ទះ ជិង គុយលី ។ អ្នកដែលបានចូលរួមប្រជុំនៅពេលនោះមានឈ្មោះ ង៉ោ ប៊ុនគ្រុយ, ទិន ទូច, ជិង គុយលី, ខេង លាងស្រេង, លាង ហាក់, នួន ឈុនលី, អ៊ឹម រ៉េត, ស៊ាង លី, ឌី ម៉ូនី, ឡោ ណាំ, យុក ម៉េង, ហុង សាយ និង ម៉ា សុងសេង ។ ខ្លឹមសារនៅក្នុងអង្គប្រជុំគឺ ឲ្យផ្អាកការផ្សាយមនោគមចក្រពត្តិតាមទស្សនាវដ្តី ហើយប្តូរមកផ្សាយតាមខ្សែភាពយន្តរបស់លោកសេរីឲ្យខ្លាំង ទៅគ្រប់ទីកន្លែងដោយយកភាពយន្តពីក្រសួងឃោសនាការអាមេរិកមកផ្សាយនៅភ្នំពេញ ។ ប៊ិច ថេង បានចែកភារកិច្ចឲ្យចុះអនុវត្តតាមផែនការរបស់ ហ្សង់ក្លាវ៉ូ តាមមុខព្រួញដីដុះ ទួលស្បូវមាន ថៃហេង, អ៊ឹម រ៉េត, លាង ហាក់, យុក ម៉េង ជាអ្នកទទួលកិច្ចការតាមដានចលនាបដិវត្តន៍នៅមុខព្រួញនេះ ។ ផ្នែកមុខព្រួញផ្សារកំពង់ចាម មានឈ្មោះ ជិង គុយលី, ង៉ោ ប៊ុនគ្រុយ ទទួលខុសត្រូវ ។ ផ្នែកជ្រោយថ្ម មានដូចជាឈ្មោះ ទិន ទូច, ខេង លាងស្រេង ផ្នែកទួលថ្ម និងវាលវង់ មានឈ្មោះ ឡោ ណាំ, ម៉ា សុងសេង, និង ហុង សាយ ។ គ្រប់ផ្នែកមានភារកិច្ចស៊ើតរកចលនាបដិវត្តន៍ពិសេសរួមគ្នាធ្វើសកម្មភាពក្នុងសាលាកំពង់ចាម ។

ខែមិថុនា ឆ្នាំ១៩៦៤ ថៃហេង ត្រូវបាន ប៊ិច ថេង ចាត់តាំងឲ្យទៅទាក់ទងខ្សែរបស់ ហង់ ធុនហាក់ មានឈ្មោះ អ៊ឹង ប៉េងសួរ នៅស្គន់ ជាចាងហ្វាងសាលាបឋមសិក្សាស្គន់ ដែលត្រូវជាបងថ្លៃរបស់ ថៃហេង ដើម្បីយកខ្សែភាពយន្តមកផ្សាយឲ្យសិស្សមើល ដើម្បីពង្រីកឥទ្ធិពលចក្រពត្តិនៅទីនោះ ។ បន្ទាប់មក ថៃហេង ត្រូវបានបងថ្លៃនាំឲ្យស្គាល់ខ្សែរយៈម្នាក់ទៀតឈ្មោះ ប៊ិច អ៊ីងឆេង ជាសាស្ត្រាចារ្យគណិតសាស្ត្រ ហើយបានធ្វើការទាក់ទងគ្នាក្នុងការផ្សព្វផ្សាយមនោគមលោកសេរី ។ ក្រៅពីនេះ ថៃហេង នៅបានធ្វើការទាក់ទងជាមួយខ្សែចាស់ក្រោមការដឹកនាំរបស់ ប៊ិច ថេង ធ្វើសកម្មភាពបំផុសឲ្យនិស្សិត និងគ្រូប្រឆាំងនឹងរបបកុម្មុយនីស្ត ។

ឆ្នាំ១៩៦៥ ហេង បានទទួលការណែនាំពី ហ្សង់ក្លាវ៉ូ ឲ្យខិតខំរៀនសូត្របន្ថែមទៀត ព្រោះមានអាហារូបករណ៍សម្រាប់ចេញទៅរៀននៅប្រទេសឆេកូស្លូវ៉ាគី ។ បន្ទាប់មក ថៃហេង បានមករៀននៅភ្នំពេញដើម្បីរង់ចាំអាហារូបករណ៍ចេញទៅប្រទេសឆេកូស្លូវ៉ាគី ។ មុនពេលមកភ្នំពេញ ហ្សង់ក្លាវ៉ូ បានណែនាំឲ្យទាក់ទងឈ្មោះ កេង វ៉ាន់សាក់ សាស្ត្រាចារ្យតំណាងឲ្យអក្សរសាស្ត្រ និងឈ្មោះ ភូ ស៊ីអ៊ុយ ជានាយកមហាវិទ្យាល័យវេជ្ជសាស្ត្រ ដើម្បីទទួលផែនការ សេ.អ៊ី.អា ចេញទៅធ្វើសកម្មភាពនៅក្រៅប្រទេស ។ ក្រៅពីនេះ ថៃហេង និងបក្ខពួកបានតាមដានអ្នកតស៊ូបដិវត្តន៍ឈ្មោះ យាង ជួន នៅវិទ្យាល័យព្រះសីហនុ ដើម្បីមានវិធានការចាប់ តែចាប់មិនបានព្រោះមិនមានភស្តុតាងច្បាស់លាស់ គ្រាន់តែឃើញបង្រៀនជារបៀបបដិវត្តន៍ដល់សិស្ស ។

ប្រហែលខែមិថុនា ឬខែកក្កដា ឆ្នាំ១៩៦៦ ហេង បានទទួលផែនការពី កេង វ៉ាន់សាក់ និង ភូ ស៊ីអ៊ុយ នៅមហាវិទ្យាល័យវេជ្ជសាស្ត្រភ្នំពេញ ឲ្យទៅរួមកម្លាំងគ្នាជាមួយភ្នាក់ងារ សេ.អ៊ី.អា ជានិស្សិតខ្មែរនៅប្រទេសឆេកូស្លូវ៉ាគី ដើម្បីដណ្តើមនិស្សិតខ្មែរនៅឆេកូស្លូវ៉ាគីពីនិន្នាការកុម្មុយនីស្ត ឲ្យចូលមកខាងលោកសេរី ហើយ កេង វ៉ាន់សាក់ បានខទ្មេសមានឲ្យទាក់ទងជាមួយឈ្មោះ សំបូរ ជាហិរញ្ញិកទូតខ្មែរប្រចាំនៅប្រទេសឆេកូស្លូវ៉ាគី ជាមេ សេ.អ៊ី.អា នៅក្នុងចំណោមនិស្សិតខ្មែរ ហើយបានធ្វើដំណើរចុះឡើងៗ ទៅសហរដ្ឋអាមេរិក ។ ខែកញ្ញា មុនចេញដំណើរមួយថ្ងៃ ហេង បានជួប ហ្សង់ក្លាវ៉ូ ម្តងទៀត ។ ពេលនោះ ហ្សង់ក្លាវ៉ូ បានណែនាំឲ្យធ្វើការទាក់

ទងជាមួយឈ្មោះ សំបូរ ជាអ្នកធ្វើការនៅទូតខ្មែរប្រចាំប្រទេសឆេកូស្លូវ៉ាគី (បច្ចុប្បន្ននៅសហរដ្ឋអាមេរិក) ពេលទៅដល់ក្រុងប្រាក និងបានដឹងពីការងារដែលត្រូវធ្វើបន្តទៅថ្ងៃមុខទៀតពី សំបូរ ជាមិនខាន ។

ខែកញ្ញា ឆ្នាំ១៩៦៦ ហេង បានធ្វើដំណើរទៅបន្តការសិក្សានៅប្រទេសឆេកូស្លូវ៉ាគី ។ នៅទីនោះ និស្សិតត្រូវបានបែងចែកជាបីក្រុមគឺ ទី១) និស្សិតមាននិន្នាការខាងកុម្មុយនីស្ត ទី២) និស្សិតមាននិន្នាការខាងលោកសេរី និងទី៣) និស្សិតមិនមាននិន្នាការខាងកុម្មុយនីស្ត ហើយក៏មិនមាននិន្នាការខាងលោកសេរីដែរ គឺនៅចន្លោះកណ្តាល ។ នៅប្រទេសឆេកូស្លូវ៉ាគី ថៃហេង បានជួប សំបូរ ហើយបានយកផែនការដែល ហ្សង់ក្លារូ និង កេង វ៉ាន់សាក់ មកប្រាប់សំបូរ ។ ពេលនោះដែរ សំបូរ បានណែនាំ ថៃហេង ឲ្យបានស្គាល់ភ្នាក់ងារ សេ.អ៊ី.អា មួយចំនួនមានឈ្មោះ ពត ឡុងឌី និស្សិតផ្នែកសិល្បៈ, ទីវ អ៊ិន និស្សិតផ្នែកកីឡា ត្រឡប់មកកម្ពុជាវិញនៅឆ្នាំ១៩៦៧, ពិតថា និស្សិតផ្នែកគីមីសាស្ត្រ ត្រឡប់មកកម្ពុជាវិញនៅឆ្នាំ១៩៦៦, តឹក លាង និស្សិតផ្នែកគ្រឿងយន្តត្រឡប់មកកម្ពុជាវិញ នៅឆ្នាំ១៩៦៦, សឹម ឈាវឡោ និស្សិតផ្នែកម៉ាស៊ីនគិតលេខ នៅប្រទេសអាល្លឺម៉ង់, យុក គឹមអ៊ូ និស្សិតផ្នែកគំនូរ នៅប្រទេសអាល្លឺម៉ង់ និងឈួង ម៉េងសាន និស្សិតផ្នែកថតរូប ទៅទីក្រុងប៉ារីស ហើយបានប្រគល់ឲ្យ ថៃហេង ទាក់ទងអ្នកដែលមានរាយឈ្មោះខាងលើដើម្បីរួមគ្នាធ្វើសកម្មភាពឃោសនាបំផុសដណ្តើមនិស្សិតទាំងអស់នៅឆេកូស្លូវ៉ាគី ឲ្យចូលមកខាងលោកសេរី ។

ចុងឆ្នាំ១៩៦៦ សំបូរ ត្រូវចេញទៅធ្វើការនៅប្រទេសអង់គ្លេស ។ សំបូរ បានណែនាំ និងប្រគល់ភារកិច្ចឲ្យ ថៃហេង និងបក្ខពួកបន្តការទាក់ទងគ្នាឲ្យជាប់ រីឯគម្រោងផែនការយ៉ាងណាៗ នោះត្រូវរង់ចាំទទួលពី កេង វ៉ាន់សាក់ នៅប៉ារីស ។ ថៃហេង និងបក្ខពួកបានធ្វើសកម្មភាពឃោសនាប្រឆាំងនឹងលទ្ធិកុម្មុយនីស្តជាបន្តបន្ទាប់រៀងមក ។



សាកសពជនរងគ្រោះដែលត្រូវបានគាស់យកមកថែរក្សា និងរាប់ចំនួន នៅសារមន្ទីរប្រល័យពូជសាសន៍បឹងជើងឯក

ឆ្នាំ១៩៧០ ថៃហេង បានទទួលផែនការពី កេង វ៉ាន់សាក់ ឲ្យរកវិធីបង្កើតជាអង្គការនិស្សិតរណសិរ្សខ្មែរដោយប្រើរូបភាពគាំទ្រការតស៊ូបដិវត្តន៍ខ្មែរ តែជាគោលការណ៍របស់ សេ.អ៊ី.អា ហើយដាក់ពាក្យសុំទៅប៉េកាំងនៅការិយាល័យនយោបាយឲ្យសម្រេច ។ ការបង្កើតជាអង្គការនិស្សិតរណសិរ្សនេះ ក្នុងគោលបំណងទៅអនាគត គឺបង្កប់ខ្លួនធ្វើវិទ្ធង្សនាក្នុងចលនាបដិវត្តន៍ ។ ក្រោយពីបានទទួលផែនការសម្ងាត់ពី កេង វ៉ាន់សាក់ ហើយ ថៃហេង រួមជាមួយ សឹម ឈាវឡោ, យុក គឹមអ៊ួ បានទាក់ទង ឡុង នរិន និង ប៊ូ យិន ជានិស្សិតខ្មែរ និងជាភ្នាក់ងារ សេ.អ៊ី.អា របស់ ហង់ ធុនហាក់ កាលនៅភ្នំពេញ និងទាក់ទងឈ្មោះ អ៊ី ស៊ុបគន្ធី ធ្វើការនៅស្ថានទូតខ្មែរ ជាអ្នកគាំទ្រអង្គការនិស្សិតនេះ ដោយចាត់តាំងឲ្យ ឡុង នរិន និង ប៊ូ យិន ជាប្រធាន ។ រូបភាពចំហនៃអង្គការនិស្សិតរណសិរ្សនេះ គឺគាំទ្រការតស៊ូបដិវត្តន៍នៅស្រុកខ្មែរ តែរូបភាពសម្ងាត់គឺដើម្បីបម្រើផលប្រយោជន៍ឲ្យ សេ.អ៊ី.អា ទៅអនាគត ។

ខែសីហា ឆ្នាំ១៩៧១ ថៃហេង ត្រូវបានដេញចេញពីប្រទេសឆេកូស្លូវ៉ាគីឈប់ឲ្យរៀនតទៅទៀត ដោយហេតុកើតមានទំនាស់ជាមួយ ពត ឡង់ឌី ពីរឿងប្រជែងគ្នារកស៊ីប្តូរប្រាក់ដុល្លារ ហើយកើតរឿងប្តឹងផ្តល់គ្នា ពិសេស ពត ឡង់ឌី បានប្តឹងពីរឿងធ្វើនយោបាយផង ។ បន្ទាប់ពីកើតរឿងមក ថៃហេង បានចាកចេញពីប្រទេសឆេកូស្លូវ៉ាគី មកប្រទេសរ៉ូមានីតាមរយៈ អ៊ី ស៊ុបគន្ធី ជា សេ.អ៊ី.អា និងជាទូតរណសិរ្សនៅឆេកូស្លូវ៉ាគី ។ ពេលនោះ អ៊ី ស៊ុបគន្ធី បានណែនាំឲ្យ ថៃហេង ស្គាល់ឈ្មោះ ហួត សម្បត្តិ ទូតនៅរ៉ូមានី ។

ឆ្នាំ១៩៧២ ថៃហេង បានទាក់ទង ហួត សម្បត្តិ បង្កើតជាអង្គការនិស្សិតរណសិរ្ស ដោយប្រមូលនិស្សិតមកពីប៉ារីសចូលជាសមាជិកផង ។ ភ្នាក់ងារ សេ.អ៊ី.អា ដែលបង្កប់នៅក្នុងជួរនិស្សិតរណសិរ្សមានឈ្មោះ នួន ថោងគីរី និស្សិតនៅរ៉ូមានី, ហម ហ៊ុយ និស្សិតចូលមកស្រុកខ្មែរឆ្នាំ១៩៧៤, ង៉ោ ចន្ទ្រា និស្សិតចូលមកស្រុកខ្មែរឆ្នាំ១៩៧៦, នុត ប៊ុនសុង និស្សិតចូលមកស្រុកខ្មែរឆ្នាំ១៩៧៤, ស៊ិន ផល្លា និស្សិតចូលមកស្រុកខ្មែរឆ្នាំ១៩៧៣, ញ៉ែង ឡូវ៉ា និស្សិតនៅប៉ារីស, ស៊ិន លាងហេង និស្សិតចូលមកស្រុកខ្មែរឆ្នាំ១៩៧៥, ប៉ែក ឆៃយ៉ាន និស្សិតនៅរ៉ូមានី, ថោង គុណវ៉ាឌី និស្សិតនៅរ៉ូមានី, គុយ ជឿន និស្សិតចូលមកស្រុកខ្មែរឆ្នាំ១៩៧៦ និង ង៉ោ តាំងទីត្រី និស្សិត ចូលមកស្រុកខ្មែរឆ្នាំ១៩៧៦ ។ ក្រៅពីនេះ សឹម ឈាវឡោ និង យុក គឹមអ៊ួ ក៏ជា សេ.អ៊ី.អា នៅឆេកូស្លូវ៉ាគីមកប្រទេសរ៉ូមានីដែរ កាលនៅប្រទេសរ៉ូមានី ថៃហេង បានទាក់ទងជាមួយឈ្មោះ គ្រិន លាន និង ជា ខន នៅម៉ូស្គូ តាមរយៈឈ្មោះ ប៊ូ យិន ក្នុងពេលប្រជុំនិស្សិតទាំងមូលនៅអឺរ៉ុបក្នុងគោលបំណងប្រមូលអង្គការនិស្សិតទាំងអស់ឲ្យមកនៅតែមួយក្រោមការត្រួតត្រារបស់ សេ.អ៊ី.អា ។ ការប្រជុំនេះ ថៃហេង បានចូលរួមបីដងតាមរយៈ ប៊ូ យិន និង ឡុង នរិន ។ បន្ទាប់មក ថៃហេង បានមកជួប ហួត សម្បត្តិ ។ ហួត សម្បត្តិ ក៏បានណែនាំឲ្យស្គាល់អាមេរិកម្នាក់ដែលជាភ្នាក់ងារ សេ.អ៊ី.អា នៅអឺរ៉ុប និងជាមិត្តភក្តិរបស់ ហ្សង់ ក្លាវូ ឈ្មោះ ហង់រីប្រេក្រាស៊ីយ៉េ ។ ចាប់តាំងពីពេលនោះមក ថៃហេង បានភ្ជាប់ការទាក់ទងជាមួយ ហង់រីប្រេក្រាស៊ីយ៉េ និង ហួត សម្បត្តិ ជាបន្តបន្ទាប់ក្នុងការក្តាប់យកសភាពការណ៍នយោបាយនៅប្រទេសកម្ពុជា ។ ក្រៅពីនេះ ថៃហេង និងភ្នាក់ងារ សេ.អ៊ី.អា នៅក្នុងនិស្សិតរណសិរ្សទាំងអស់ធ្វើសកម្មភាពឃោសនា ញុះញង់ បំបែកបំបាក់ជួរនិស្សិតនៅរ៉ូមានីធ្វើឲ្យនិស្សិតរត់ចេញពីជួររណសិរ្សជាបន្តបន្ទាប់ ។

ឆ្នាំ១៩៧៥ ថៃហេង បានដាច់ការទាក់ទងជាមួយ ហ៊ួត សម្បត្តិ ព្រោះ ហួត សម្បត្តិ ទៅប៉េកាំង ។ ហេតុនេះ ថៃហេង និងបក្ខពួកបានបន្តធ្វើសកម្មភាពបំបែកបំបាក់ផ្ទៃក្នុង ក្នុងជួររណសិរ្សនិស្សិតនៅទីនោះតទៅទៀត ហើយបានមកជួប ហង់រីប្រេក្រាស៊ីយ៉េ នៅក្រុងប៊ុយកា ដើម្បីក្តាប់ស្ថានការណ៍នយោបាយរបស់ប្រទេសកម្ពុជា ។

ឆ្នាំ១៩៧៦ ថៃហេង បានជួប ហង់រីប្រេក្រាស៊ីយ៉េ នៅសណ្ឋាគារក្នុងប្រទេសរ៉ូមានី ។ ពេលនោះ ហង់រីប្រេក្រាស៊ីយ៉េ បានចាត់តាំងឲ្យ ថៃហេង ចូលមកប្រទេសកម្ពុជាតាមផែនការរបស់ សេ.អ៊ី.អា តែ ថៃហេង មិនទាន់មកភ្លាមទេ ដោយសុំពន្យាពេលនៅរៀនសូត្រឲ្យបានចប់សព្វគ្រប់នៅឆ្នាំ១៩៧៧ សិន ទើបចូលស្រុកជាក្រោយ ។

ខែកក្កដា ឆ្នាំ១៩៧៧ ហង់រីប្រេក្រាស៊ីយ៉េ បានឲ្យភ្នាក់ងាររបស់ខ្លួនម្នាក់ជាជនជាតិអាមេរិកស្បែកខ្មៅឈ្មោះ ហ្សក នាំផែនការមកឲ្យ ថៃហេង ដើម្បីចូលមកកម្ពុជា ។

## ខ្លឹមសារផែនការរបស់អាមេរិក

អាមេរិកមានបំណងវាយយកតំបន់ដីភាគខាងជើងកម្ពុជា

មានខេត្តកំពង់ធំ, ខេត្តព្រះវិហារ និងខេត្តសៀមរាប តាមរយៈប្រទេសសៀម ដើម្បីធ្វើជាឈ្នាន់សម្រាប់វាយលុកយកប្រទេសកម្ពុជានៅពេលអនាគត ហើយភារកិច្ចរបស់ ថៃហេង គឺមកកម្ពុជាដើម្បីសម្រេចផែនការខាងលើ៖

១) ពេលចូលមកកម្ពុជា ត្រូវរកជួប កុយ ធួន និង ទីវ អុល ដើម្បីឲ្យអ្នកទាំងពីរបង្ហាញពីស្ថានការណ៍ទូទៅនៅក្នុងប្រទេសកម្ពុជា ពិសេសតំបន់ដីខាងជើងកម្ពុជា ។ បើមិនបានជួប កុយ ធួន និង ទីវ អុល ទេ ផែនការនេះត្រូវបរាជ័យ ។

២) ពេលចូលមកភ្នំ មិនត្រូវចូលមកសំដៅរក កុយ ធួន និង ទីវ អុល ភ្លាមទេ ត្រូវទាក់ទងរកខ្មែរ សេ.អ៊ី.អា ចាស់ដែលធ្លាប់ស្គាល់នៅអឺរ៉ុបដូចគ្នា ពេលប្រើសញ្ញាដឹងស្គាល់គ្នាហើយ ទើបនាំឲ្យទៅជួប កុយ ធួន និង ទីវ អុល ។

៣) សញ្ញាទាក់ទង គឺប្រើពាក្យៈ អ្នកទី១និយាយថា "មកពីឆ្ងាយ" អ្នកទី២និយាយថា "ខ្ញុំនឿយហត់" អ្នកទី១បន្តថា "អឺរ៉ុបខាងកើត" ។ ចំពោះសញ្ញានេះ ដឹងបានតែភ្នាក់ងារណាដែលទទួលផែនការដូចគ្នា ទោះចូលមកមុនឬក្រោយក៏ដោយ ឯភ្នាក់ងារធម្មតាមិនដឹងពាក្យសម្ងាត់នេះទេ ។ ការសន្និដ្ឋានរបស់អាមេរិកចំពោះភ្នាក់ងារដែលចូលមកមុនៗសុទ្ធតែមាននាទីសំខាន់ទាំងអស់ ។

៤) ពេលបានជួប កុយ ធួន និង ទីវ អុល ហើយ ត្រូវប្រាប់ពីគោលបំណងរបស់អាមេរិក

◆ តើសភាពការណ៍ប្រជាជននៅតំបន់ខាងជើងកម្ពុជា មានសៀមរាប ព្រះវិហារ កំពង់ធំ មានការគាំទ្ររបបថ្មីឬប្រឆាំងនឹងរបបគ្រប់គ្រងថ្មីកម្រិតណា?

◆ តើសេដ្ឋកិច្ច ប្រជាជនសម្បូរ ឬអត់ឃ្លាន?

◆ តើមូលដ្ឋានទ័ពសំខាន់ៗ របស់បដិវត្តន៍នៅត្រង់ណាខ្លះ? បើអាមេរិកចូល តើឲ្យចូលតាមណា និងប្រើវិធីយ៉ាងម៉េច?

◆ បើសិនមានការបះបោរមួយកម្រិតហើយ សុំឲ្យកុយ ធួន និង ទីវ អុល ដំឡើងសកម្មភាពនៅតំបន់ទាំងបីខាងលើនេះឲ្យខ្លាំងដល់កម្រិតងាយស្រួលអាមេរិកយកលេសវាយលុក ។

◆ សុំឲ្យ កុយ ធួន និង ទីវ អុល បញ្ជាក់បង្ហាញឲ្យច្បាស់គ្រប់បញ្ហាដើម្បីចក្រពត្តិអាមេរិកធ្វើការប៉ាន់ និងកំណត់ពេលវេលាឲ្យច្បាស់ រួចហើយឲ្យអ្នកទាំងពីរបញ្ជូន ថៃហេង តាមផ្លូវសម្ងាត់ទៅតំបន់ដីខាងជើងពិនិត្យភូមិភាគ និងរកផ្លូវចេញទៅក្រៅតាមប្រទេសសៀម ដើម្បីទៅរាយការណ៍ឲ្យ ហង់រី ហ្រ្គោស្ស៊ីយ៉េ វិញ ។

## វិធីដោះស្រាយ

ពេលរកខ្មែរមិនឃើញ មិនសម្រេចផែនការ ត្រូវនៅបង្កប់ខ្លួនក្នុងចំណោមប្រជាជន បង្កទំនាស់ផ្សេងៗឲ្យមានភាពច្របូកច្របល់ និងឆ្លៀតរកផ្លូវចេញបើមានឱកាសល្អ ទៅតាមប្រទេសសៀម ឡើងទៅរាយការណ៍ឲ្យ សេ.អ៊ី.អា វិញ ។ ចំពោះផែនការដែល ហង់រី ហ្រ្គោស្ស៊ីយ៉េ កំណត់ឲ្យ ថៃហេង មក មានតែរយៈពេល ៥ខែទេ បើផុតពី៥ខែគ្មានដំណឹងត្រឡប់ទៅវិញ នោះចាត់ទុកថាបដិវត្តន៍កម្ពុជាចាប់ខ្លួនបាន ហើយខាង សេ.អ៊ី.អា នឹងរកវិធីផ្សេងៗដើម្បីបញ្ជូនភ្នាក់ងារផ្សេងមកបន្តទៀត ។ ភ្នាក់ងារ សេ.អ៊ី.អា ដែលត្រៀមខ្លួនចូលមកប្រទេសកម្ពុជាបន្ទាប់ពី ថៃហេង មានចំនួនបីនាក់ទៀតឈ្មោះ ថោង គុណវ៉ាឌី, អុង ប៊ុងហ៊ាន និង ប៉ែក ឆៃយ៉ាន ។ ចំណែកភ្នាក់ងារដែលចូលមកប្រទេសកម្ពុជាមុន ថៃហេង មករកទាក់ទងមានឈ្មោះ អ៊ិន សូកាន ប្រធានរណសិរ្សនៅប៉ារីស, ទ្រីម៉េងហ៊ួត, ងៅ ហាក់ទាម, តាន់ ម៉េង, សារី វុធ, គាត ឈន់, លី អុន, ឡុង នរិន ។

ថៃហេង បានមកដល់ប្រទេសកម្ពុជានៅថ្ងៃទី២០ ខែសីហា ឆ្នាំ១៩៧៧ តាមការចាត់តាំងរបស់ភ្នាក់ងារ សេ.អ៊ី.អា អាមេរិក ។ ថៃហេង ត្រូវអង្គការចាប់ខ្លួនបាននៅថ្ងៃទី២១ ខែសីហា ឆ្នាំ១៩៧៧ បន្ទាប់ពីចូលមកដល់ស្រុកខ្មែរបានតែមួយថ្ងៃប៉ុណ្ណោះ ។ នៅមន្ទីរ ស-២១ ថៃហេង បានឆ្លើយសារភាពអំពីគោលបំណងរបស់ខ្លួនដែលបានចូលមកស្រុកខ្មែរ និងបានឆ្លើយពីសកម្មភាពរបស់ខ្លួននិងបក្សពួកនៅបរទេស ។

កំណត់ហេតុអំពីប្រវត្តិ និងសកម្មភាពដែលបានដកស្រង់ចេញពីចម្លើយសារភាពរបស់ ថៃហេង មានចំនួន២២ទំព័រ ។ អ្នកធ្វើកំណត់ហេតុសួរចម្លើយ ថៃហេង មានឈ្មោះ ស្រ៊ឹម និង ផេន ធ្វើឯកសារកំណត់ហេតុចប់នៅថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ១៩៧៧ ។ យោងតាមបញ្ជីឈ្មោះអ្នកទោសដែលបានកម្ទេចនៅមន្ទីរស-២១ ហុក ថៃហេង ត្រូវអង្គការកម្ទេចចោលនៅថ្ងៃទី៩ ខែធ្នូ ឆ្នាំ១៩៧៧ ក្រោយពីបានសួរចម្លើយរួចរាល់ហើយ ។

**ឆេង ខ៊ាង**

# ខឹម ឈុំ អនុលេខាតំបន់៤៣ ភូមិភាគកណ្តាល

*(ដកស្រង់ចេញពីឯកសារចម្លើយសារភាព D៤១២៧១)*

ខឹម ឈុំ មានអាយុ៣៥ឆ្នាំ ភេទប្រុស មានស្រុកកំណើតនៅភូមិដំណាក់ស្នួល ឃុំស្រែ ស្រុកឈូក តំបន់៣៥ ភូមិភាគនិរតី ។ ឈុំ បានចូលបម្រើបដិវត្តន៍ខ្មែរក្រហមតាំងពីឆ្នាំ១៩៦១ និងបានទទួលតួនាទីជាបន្តបន្ទាប់ជាអនុលេខាតំបន់៤៣ ភូមិភាគកណ្តាល រហូតដល់អង្គការចាប់ខ្លួន នៅថ្ងៃទី១៣ ខែសីហា ឆ្នាំ១៩៧៨ ។

នៅក្នុងឯកសារចម្លើយសារភាពរាប់សិបទំព័រ ឈុំ បានរៀបរាប់ពីសកម្មភាពគាត់ជាហូរហែ ចាប់តាំងពីគាត់ទាក់ទងជាមួយបដិវត្តន៍ដំបូង ប៉ុន្តែយើងមិនដឹងថាការសារភាពរបស់គាត់ពិតប្រាកដយ៉ាងណានោះទេ ព្រោះគាត់ត្រូវរងទារុណកម្មពីអ្នកសួរចម្លើយ ។

ខាងក្រោមនេះជាសេចក្តីសង្ខេបដែលដកស្រង់ចេញពីចម្លើយសារភាពរបស់សាមីខ្លួនផ្ទាល់ៈ

ខ្ញុំមានឪពុកឈ្មោះ ខឹម កែម (ស្លាប់) និងម្តាយឈ្មោះ គឹម ហែន (ស្លាប់) ។ ខ្ញុំមានបងប្អូនបង្កើតចំនួន៤ នាក់ គឺ ប្រុស៣ និងស្រី១ ។ នៅក្នុងឆ្នាំ១៩៥៩ ខ្ញុំបានសឹកពីសង្ឃមករកស៊ីកាប់ឈើលក់នៅផ្ទះវិញ ។ នៅពេលនោះ ខ្ញុំបានជួបជាមួយ ចិន ជាប្រធានភូមិដំណាក់ស្នួល និង ឆែម ជាអនុប្រធាន ។ អ្នកទាំងពីបានសួរខ្ញុំថា តើអន្ទិតឯងចង់បានលុយចាយច្រើនអត់ បើចង់បានលុយចាយច្រើនលុះត្រាតែអន្ទិតឯងធ្វើជាគិញ ដើម្បីស៊ើបការណ៍ពីខ្មែរក្រហម ។ ដោយមានមនោសញ្ចេតនាជំពាក់ជំពិនទៅលើអ្នកទាំងពីរ ខ្ញុំក៏សម្រេចចិត្តយល់ព្រម ។ នៅពេលនោះដែរ ក៏មានកម្លាំងគិញផ្សេង



កសិករនៅតាំងគោកកំពុងធ្វើទំនប់ដើម្បីនាំទឹកពីស្ទឹងជីនិត មកស្រោចស្រពស្រែនៅវាលសរសៃ វាលពន្រ្ទ និងវាលស្វាយទង

ទៀតដែរ ដូចជា កប, ជឹន, អ៊ឹម, ជុត និង ចេន ដែលមានតួនាទីនៅតាមតំបន់ផ្សេងៗគ្នា ។

នៅក្នុងឆ្នាំ ១៩៦១ ចិន និង ឆែម បាននាំ ខ្ញុំ និង កប ទៅជួបជាមួយមេគិញពីររូប គឺឈ្មោះថា និង វ៉ាន់ ជាខ្មែរយៈសក្តិ៤ ទុំនារា និង កែវ នៅក្រុមប៉េអេះ ភ្នំពេញ ។ ចិន បានណែនាំមេគិញទាំងពីរឲ្យស្គាល់ ខ្ញុំ និង កប ជាគិញសម្ងាត់ ។

នៅឆ្នាំ១៩៦៣ ខ្ញុំ កប ចេន ជឹន នុត ឆែម និង ចិន បាននាំទាហានទៅបន្ទាយអូបុតដើម្បីកម្ទេចកន្លែង តាម៉ុក និងកន្លែង បងហុក បងគ្រិន នៅត្រពាំងតាព្រំ បានចំនួន៣លើក ។

មកដល់ចុងឆ្នាំ១៩៦៣ ចិន ឆែម និងខ្ញុំបានយកសំបុត្រខ្ទេសនាមរបស់អាសក្តិ៤ ទុំនារា និង កែវ ទៅឲ្យ ប៊ុត និង តាស៊ី ប៉ុន្តែមិនបានជួបអ្នកទាំងពីរនាក់ទេ ដូច្នោះយើងរង់ចាំអស់រយៈពេលមួយថ្ងៃទើប តាស៊ី មកពីភ្នំពេញវិញ ។ តាស៊ី បានសួរយើងថា ម៉េចហើយសភាពការណ៍ទាក់ទិននឹងការស៊ើបការណ៍ខ្មែរក្រហម? ហើយ តាស៊ី ក៏បានណែនាំឲ្យកសាងកម្លាំងគិញបន្ថែមទៀត ។ បន្ទាប់ពីបានជួបជាមួយ តាស៊ី មក ខ្ញុំកសាងបានកម្លាំង៣នាក់ នៅភូមិដំណាក់ស្នួល រួមមានឈ្មោះ គេង ញ៉ឹម និង ជឿន ដែលអ្នកទាំងបីនាក់នេះជាបងប្អូនជីដូនមួយនឹងគ្នា ។

នៅដើមឆ្នាំ១៩៦៨ កុប្បកម្មមួយបានផ្ទុះឡើងនៅគ្រានោះ សក្តិ៤ ទុំនារា បានចាត់កម្លាំងគិញឲ្យបង្កប់ខ្លួនក្នុងក្រុមបដិវត្តន៍ និងឲ្យ តាស៊ី ហៅខ្ញុំ, ចិន, ឆែម, នុត ទៅជួបគាត់នៅវត្តស្រែចែង ។ នៅពេលជួបជុំគ្នាអស់ហើយ តាស៊ី បាននិយាយថា យើងជួបជុំគ្នានេះ គឺដើម្បីរៀបចំខ្សែគិញធ្វើការក្នុងជួរបដិវត្តន៍ឲ្យបានល្អប្រសើរជាងនេះ ព្រោះតាមខ្ញុំពិនិត្យសកម្មភាពការងារកន្លងមក ធ្វើបានល្អ និងសកម្មភាពក៏ល្អគ្រប់គ្រាន់ហើយដែរ រួចហើយគាត់ក៏បញ្ចូលខ្ញុំជា សេ.អ៊ី.អា ដោយតម្រូវឲ្យគោរពទង់ សេ.អ៊ី.អា និងត្រូវសូត្រប្រវត្តិរូបខ្លួនឯងទៀត ។

នៅឆ្នាំ១៩៦៨ ដដែល ខ្មែរក្រហមធ្វើកុប្បកម្មនៅបន្ទាយអូរបុត នៅពេលនោះតា ស៊ី បានចាត់ តាំងខ្ញុំ ចិន ឆែម ប៊ុត ជឹន និង កប បន្ទំខ្លួនក្នុងកុប្បកម្មនោះ និងមួយចំនួនទៀត មានដូចជា ចេន និង នុត ទៅបង្កប់ខ្លួននៅបន្ទាយវត្តស្រែក្នុង ។ សកម្មភាពរបស់ខ្ញុំ គឺប្រឆាំងនឹងក្បួនកុប្បកម្ម ដោយធ្វើឲ្យចលាចល ។ ក្រោយពីកុប្បកម្មបញ្ចប់រួចរាល់ ខ្ញុំបន្តបង្កប់ខ្លួនក្នុងមន្ទីរស្នាក់ការតំបន់៣៥ នៅត្រពាំងឃ្លាំង ។

នៅឆ្នាំ១៩៦៨ តាស៊ី បានចេញពីមន្ទីរវល្លិ៍ជាមួយ បងដែន មិត្តណយ មិត្តរិន មកនៅមន្ទីរស្ទឹងឈើទាលពក ។ តាស៊ី បាននិយាយថា គាត់នឹងបែងចែកក្រុមមួយចំនួនមកធ្វើការនៅក្នុងព្រៃ រីឯមួយចំនួនទៀតគឺធ្វើការនៅក្នុងភូមិដើម្បីផ្តល់ជាដំណឹង ។ តាស៊ី បានចាត់ មិត្តវ៉ាន ចេន នុត ទៅនៅក្នុងជួរបដិវត្តន៍ នៅមន្ទីរដើមអំពិល ភ្នំតាម៉ៅ ។ រីឯ ខ្ញុំ ចិន ឆែម ជឹម នៅមន្ទីរត្រពាំងឃ្លាំង ហើយ មិត្តដែន រិន ណយ នៅជាមួយគាត់ ។

បន្ទាប់ពីរដ្ឋប្រហារឆ្នាំ១៩៧០ អគ្គការឲ្យកម្មាភិបាល និងយុទ្ធជនចុះមកភូមិឃុំវិញ ។ នៅពេលនោះ តាចាប ក៏ចុះមកពីភ្នំឱរ៉ាល់ ហើយមកសង់មន្ទីរនៅភ្នំស្ទឹក ខាងលិចវត្តស្រែចែង ។ តាចាប បានឲ្យ ខ្ញុំ បងដែម បងវ៉ាន ឆែម នុត ពូ មិត្តរិន មិត្តណយ និងមិត្តយុត ទៅជួបគាត់ ។ តាចាប បាននិយាយថា គាត់ឲ្យយើងទាំងអស់គ្នាមកទីនេះ ពីព្រោះគាត់ចង់ឲ្យអ្នកទាំងអស់គ្នាស្គាល់គ្នាទៅវិញ ទៅមកដើម្បីងាយស្រួយទទួលផែនការយកទៅធ្វើតាមមុខព្រួញនីមួយៗ គឺការកសាងកម្លាំង សេ.អ៊ី.អា ដើម្បីបង្កប់ក្នុងបដិវត្តន៍ក្នុងជួរកម្មាភិបាលចាប់ពីភូមិ-ឃុំឡើងទៅ ។

ក្រោយពីទទួលផែនការរួច នៅខែ៧ ឆ្នាំ១៩៧០ ដដែល ខ្ញុំបានកសាងកម្លាំងបានពីរនាក់គឺឈ្មោះ ញ៉ិប និង មឿន ។ ទន្ទឹមនេះដែរ ខ្ញុំអប់រំឲ្យប្រជាជនតាមភូមិនីមួយៗស្រលាញ់របបចាស់ និងឲ្យស្អប់បដិវត្តន៍ ។

ប្រហែលជាខែ១០ ឆ្នាំ១៩៧០ តាចាប ហៅខ្ញុំប្រជុំនៅផ្ទះបងដែនរួមទាំង មិត្តយុត ចេន គុម សៀង និង សាន ក្នុងគោលបំណងឲ្យយើងរាយការណ៍ពីសកម្មភាពកន្លងមក ។ នៅពេលរាយការណ៍ចប់សព្វគ្រប់ហើយ តា ចាប បានប្រាប់ដែន ថា ត្រូវតែបន្តការទាក់ទងជាមួយយួន បើមានប្រជាជនណាចង់ទៅយួន ឲ្យយួនអនុញ្ញាតឲ្យទៅចុះ ហើយឲ្យ ដែន បន្តកសាងកម្លាំងបន្ថែមទៀត ។

នៅឆ្នាំ១៩៧១ ខ្ញុំបានកសាងកម្លាំងបានពីរនាក់ឈ្មោះ ជួប និង ក្លា ។ ខ្ញុំបានធ្វើសកម្មភាពជាមួយ តាមឿន តាញ៉ិប តាក្លា និង ជួប បង្អត់អាហារប្រជាជននៅឃុំស្ទឹងកែវ ។ នៅក្នុងឆ្នាំ១៩៧១ នេះដែរ ខ្ញុំចាត់តាំង តាក្លា ឲ្យទៅបំផុសប្រជាជននៅខាងតាកែនឲ្យ

ធ្វើចោរព្រៃបានចំនួន១៥នាក់ និងបានធ្វើការទាក់ទងជាមួយចោរព្រៃឈ្មោះ ព្រំ-សាន់ ដើម្បីឲ្យអុកឡុកលួចគោក្របី មាន់ ទា អង្ករ របស់ប្រជាជន ។

នៅខែកុម្ភៈ ឆ្នាំ១៩៧១ តាចាប មកផ្ទះខ្ញុំ ហើយបានប្រាប់ខ្ញុំពីគម្រោងផែនការដែលអង្គការឲ្យធ្វើទំនប់គ្រប់ឃុំស្រុក ទូទាំងតំបន់៣៥ ដូច្នោះគាត់បានឲ្យខ្ញុំចុះទៅធ្វើនៅតំបន់អូរអៅ និងតំបន់អូរអន្ទ្រង ។ បន្ទាប់ពីបានផែនការពី តាចាប មក ខ្ញុំក៏ចាត់តាំងឲ្យ តាមឿន តាជួប តាក្លា និង តាញ៉ិប ទៅក្តាប់ ហើយបានចាត់កម្លាំងប្រជាជនចំនួន៥០០០នាក់ ទៅធ្វើទំនប់នោះ ។ នៅខែវិច្ឆិកា ឆ្នាំ១៩៧១ បងផែន បងតុំ និងសៀង បានឆ្លៀតមកជួបខ្ញុំនៅកោះស្លា ហើយបានសួរពីសកម្មភាពកន្លងមករបស់ខ្ញុំ ខ្ញុំឆ្លើយថាកន្លងមកខ្ញុំអត់ដែលបានទាក់ទងខ្មែរខាងតំបន់៣៥ទេ ហើយកន្លែង តាចាប ក៏អត់ដែរ ។ នៅពេលនោះបងផែនឲ្យខ្ញុំជូនទៅកន្លែងតាចាប នៅភ្នំស៊្លក ក៏ឃើញមិត្តណយ មកដែរ ។ តាចាប បានសួរថ្ងៃនេះហេតុអ្វីមានគេមកផ្ទះខ្ញុំច្រើនម្ល៉េះ បងផែន ក៏ឆ្លើយថាមកជម្រាបតាពីរឿង មិត្តតុំ មិត្តសៀង និងមិត្តសាន់ ដើម្បីឲ្យតាបានស្គាល់ និងរាយការណ៍ជូនតា ។ ខ្ញុំក៏បានរាយការណ៍អំពីសកម្មភាពខ្ញុំបានធ្វើនៅទំនប់អូរត្រាក់ទ័រ និងអូរអន្ទ្រង ។ តាចាប បានណែនាំ ខ្ញុំ និងមិត្តណយ ថា ត្រូវតែរួបរួមកម្លាំងគ្នាដើម្បីប្រឆាំងនឹងការធ្វើទំនប់នៅស្ទឹងកោះស្លា តែយើងទៅធ្វើនៅស្ទឹងពាមវិញដើម្បីពន្យារពេលកុំឲ្យបានទឹកប្រើឆាយ ។ រីឯខាង មិត្តផែន មានភារកិច្ចរកវិធីសម្លាប់ តាម៉ុក ដោយទាក់ទងជាមួយមិត្តជា ។ បន្ទាប់មក តាចាប ក៏បានខទ្វេសនាមកម្លាំងឲ្យដឹងបន្ថែមទៀតនៅតំបន់២៥ នឹងភូមិភាគបស្ចិមរួមមាន ៖ ១) សៀន ២) ផុន ៣) បូ(នារី) ៤) អោប ៥) ជឹម ៦) លន ៧) ញ៉ឹក ៨) ហម ៩) សាត់ ១០) កែវ ១១) ម៉ែន ១២) ខែត ១៣) កប និង ១៤) ចាន់ ។

ក្រោយមក បងផែន ទៅជួបខ្ញុំនៅទំនប់ និងបានណែនាំពីរបៀបធ្វើទ្វារទឹកមិនបាច់ជីកគ្រឹះ ។ ខ្ញុំក៏យកផែនការណ៍នេះទៅប្រាប់បងប្អូនចាក់ដីសើរៗលើដីតែម្តង ។ ចំណែកឯព្រែកជីក ខ្ញុំឲ្យ ពូចេន អ៊ំនុត ជីកព្រែកចោតខ្លាំងធ្វើឲ្យបាក់កិនប្រជាជនស្លាប់ និងបាក់ដៃបាក់ជើងទៀតផង ។

រហូតមកដល់ខែកុម្ភៈ ឆ្នាំ១៩៧២ ខ្ញុំបានទៅផ្ទះបងផែន ហើយគាត់ក៏បានសួរពីសកម្មភាពរបស់ខ្ញុំនៅទំនប់កោះស្លា ខ្ញុំបានឆ្លើយថាទំនប់នេះមិនទាន់បានធ្វើរួចទេពីព្រោះវាបានបាក់ៗ គាត់ក៏សួរខ្ញុំទៀតថា តើមិត្តឯងដែលជួប តាស៊ី ទេ? ខ្ញុំថាអត់ដែលបានជួបទេ ជួបតែ តាចាប ខ្ញុំក៏សួរគាត់ទៅវិញថាចុះបងឯងដែលទាក់ទងខាងបស្ចិមទេ គាត់ថាខ្សែបស្ចិម ដែលគាត់ទាក់ទងជាមួយ តាស៊ី គឺមានគ្រប់ស្រុកទាំងអស់ឲ្យតែលេខាស្រុក ប៉ុន្តែលេខាតំបន់៣១ គឺមិត្ត សាវុន មិនមែននៅខាងយើងទេ រីឯនៅតំបន់៣៤ មិត្តញ៉ឹក កោះកុង មិត្តរ៉ន គឺជាកម្លាំងនៅខាងយើង ។ ខ្ញុំបានសួរទៀតថាចុះផែនការសម្លាប់ តាម៉ុក តើយើងគួរធ្វើយ៉ាងម៉េចដែរ បងផែន ថាកន្លងមក តាម៉ុក មកផ្ទះខ្ញុំមិនដែលហូបបាយសោះ ពេលដែលខ្ញុំកាប់ដូងឲ្យគាត់ គាត់អត់ហូបទេ គាត់កាប់ហូបដោយខ្លួនឯង ហើយការធ្វើដំណើររបស់គាត់មិនទៀងទេ ។ បងផែន បានណែនាំខ្ញុំទៀតថា មិត្តឯងក៏រកវិធីសម្លាប់គាត់ដែរ អ៊ីចឹងយើងអាចលបបាញ់គាត់នៅទំនប់កោះស្លា ព្រោះគាត់ទៅទីនោះញឹកញាប់ ។

ក្រោយពីជួប បងផែន មក នៅក្នុងខែកុម្ភៈ ឆ្នាំ១៩៧២ ដដែលខ្ញុំ និងតាសឿ បានទៅទាក់ទងអាសក្កិ៣ សាខន នៅបន្ទាយរោចក្រស៊ីម៉ង់មកកៀរប្រជាជនចាមនៅភូមិព្រៃឲ្យចូលបន្ទាយចក្រីទីង បានចំនួន៥០គ្រួសារ និងក្របី៥០នឹម ។ នៅក្នុងឆ្នាំនោះ ខ្ញុំកសាងកម្លាំងបានឈ្មោះ ជឿន ជាអតីតកូនសិស្សថ្នាក់ទី២ បច្ចុប្បន្នជាអនុប្រធានរោងម៉ាស៊ីនអារឈើនៅតំបន់៣៥ និងឈ្មោះ យឿង ជាអតីតអ្នករកស៊ីលក់ជ្រូក ។

នៅខែមីនា ឆ្នាំ១៩៧២ បងរ៉ន បងអាន ចុះពីអមលាំងវិញមករកគ្រាប់កាំភ្លើងនៅកន្លែង តាចាប ហើយក៏បានហៅខ្ញុំ ពូចេន បងផែន និងមិត្តណយ ទៅជួប ។ តាស៊ី និយាយថា សូមជម្រាបមិត្តទាំងអស់ឲ្យស្គាល់ មិត្តអាន ដែលយើងកសាងបានតាំងពីឆ្នាំ១៩៦៤ មក តែឥឡូវយើងឲ្យគាត់មកធ្វើការនៅនៅតំបន់២៤ ហើយគាត់បានបន្តថា យើងត្រូវបន្តកសាងកម្លាំងឲ្យបានច្រើន ដូច្នោះយើងត្រូវទាក់ទងគ្នាជាប់ពីតំបន់២៥ ទៅ តាកែវ កំពត ឬទៅភូមិភាគបស្ចិម ។

នៅខែកក្កដា និងខែសីហា ខ្ញុំបង្វែងមាគ៌ា ធ្វើស្រែមិនដាក់ជីរ មិនលើកភ្លឺ ។ ខ្ញុំបានទៅរកពូជស្រូវនៅផ្ទះ មិត្តណយ ក៏ជួប បងផែន មករកអំបិលនៅផ្ទះមិត្តណយដែរ ។ គាត់ក៏សួរមិត្ត ណយ ថាសភាពការណ៍ទាក់ទងសក្កិ៤ សំអុល នៅកំពតយ៉ាងម៉េចហើយ មិត្តណយ

រាយការណ៍ថា បានចាត់តាំងមិត្តជួប ទៅទាក់ទងសំអុល ហើយ ។ នៅពេលបងផែន ត្រឡប់ទៅវិញ គាត់ផ្តាំខ្ញុំថា ឯង និងមិត្តណយ ត្រូវទាក់ទងលោកសក្តិ៤ សំអុល ជាមួយកម្លាំងដែលខ្ញុំកសាងបាន ។

ខែវិច្ឆិកា ឆ្នាំ១៩៧២ កងទ័ពបដិវត្តន៍វាយបន្ទាយចក្រីទីង ខ្ញុំបានចាត់ តាសឿ ឲ្យទៅប្រាប់ អាសាខន ដកខ្លួនរត់ទៅស្រុកកំពត ហើយឲ្យមិត្តណយ ទាក់ទង ចាន់ សំអុល ផ្លោងគ្រាប់ដាក់ ។ នៅថ្ងៃទី០៥ ខែមិថុនា នៅម៉ោង៤ មុនពេលចូលសមរភូមិ តាចាប មកដាក់ផែនការឲ្យខ្ញុំសម្លាប់អ្នករបួស ចំណែក មិត្តរិន បញ្ជាសមរភូមិចាំដកថយពេលខ្មាំងបាក់ទ័ព ឬអស់គ្រាប់ ។

នៅឆ្នាំ១៩៧៣ ខែមីនា អង្គការបានធ្វើសន្និបាតនៅមន្ទីរភូមិភាគត្រពាំងជ ហើយខ្ញុំក៏ចូលរួមសន្និបាតនោះដែរ ។ ពេលនោះ បងផែន ក៏បានហៅខ្ញុំទៅជួបជាមួយ បងជា បងអាន និង បងសៀន នៅក្រោមដើមឈើមួយ យើងបានជជែកគ្នាពីនេះពីនោះ ។ បន្ទាប់មក តាចាប ប្រាប់ខ្ញុំថា ឲ្យខំកសាងកម្លាំងបង្កប់តាមភូមិ-ឃុំ ដើម្បីឲ្យងាយស្រួលនៅពេលអង្គការចាត់តាំងនរណាម្នាក់ យើងនឹងមានមនុស្សស្រាប់ ។

ចប់សន្និបាត ខ្ញុំក៏ត្រឡប់មកកោះស្លាវិញ ។ នៅដើមឆ្នាំ១៩៧៣ អង្គការបានលើកផែនការឲ្យស្រុកកោះស្លា ទាំងមូលចាត់តាំងធ្វើសហករណ៍ ដូច្នោះ ខ្ញុំក៏ហៅ តាញឹប តាក្លា តាយឿន តាជួប មិត្តដៃ តាសឿ និងមិត្តសារឹម មកដាក់ផែនការណ៍ឲ្យទៅបំផុសប្រជាជនតាមឃុំ កុំឲ្យប្រជាជនធ្វើជាសហករណ៍ ។ ក្រោយមកទៀត ខ្ញុំមិនឲ្យប្រជាជនធ្វើស្រែដីខ្សាច់ ហើយនាំប្រជាជនទៅធ្វើលើដីក្រហមគ្មានជីជាតិវិញ និងឲ្យប្រជាជនយកស្រូវពូជហូប ។ ដូច្នោះ ក្នុងស្រុកកោះស្លាបានទទួលផលស្រូវតែ១៨ម៉ឺនថាំងប៉ុណ្ណោះ អត់បានសម្រេចតាមផែនការរបស់អង្គការ ២៨ម៉ឺនថាំងទេ ប្រជាជនត្រូវហូបបបរទាំងព្រឹក ទាំងល្ងាច ។

នៅខែតុលា ឆ្នាំ១៩៧៣ ខ្ញុំបានចាត់តាំង តាសឿ ឲ្យយកស្រូវ១០០០ថាំង និងគោ៥ក្បាលទៅឲ្យសក្តិ៣ សាខន នៅបន្ទាយរោងចក្រស៊ីម៉ង់ត៍ចក្រីទីង ។ នៅខែមករា ឆ្នាំ១៩៧៤ ខ្ញុំ និងពូចេន បានទទួលសំបុត្រពី តាចាប យកទៅឲ្យ តាស៊ី នៅអមលាំង ។ ពេលយើងទៅដល់អត់បានជួប តាស៊ី ទេ ខ្ញុំក៏សួរនីរសារគាត់ថា តាស៊ី ទៅណាហើយ? នីរសារគាត់ឆ្លើយថា គាត់បានទៅបាត់ហើយ ខ្ញុំក៏ឲ្យសំបុត្រនោះទៅនីរសារគាត់ទៅ ។ ពេល តាស៊ី ត្រឡប់មកវិញ គាត់បានឲ្យនីរសារគាត់ហៅខ្ញុំ និងពូចេន ទៅជួបគាត់នៅមន្ទីរភូមិភាគ ។ គាត់សួរយើងពីសភាពការណ៍នៅខាងកំពតយ៉ាងណាដែរ? ខ្ញុំបានរាយការណ៍ប្រាប់គាត់ថា ក្នុងឆ្នាំ១៩៧៣នេះ តាចាប ដាក់ផែនការឲ្យខ្ញុំ និងមិត្តណយ ទៅទាក់ទងទាហាននៅបន្ទាយក្រុងកំពត ។ ពេលខ្ញុំរាយការណ៍ចប់ បងស៊ី ក៏បានប្រាប់ខ្ញុំថា មិត្តឈុំឯង(ខ្ញុំ) ទៅវិញកុំភ្លេចប្រាប់ មិត្តចាប ឲ្យទៅទាក់ទង មិត្តជា ហើយឲ្យ មិត្តជា បន្តខ្សែទាក់ទងខាងភូមិភាគបូព៌ាជាមួយ មិត្តឈាន ព្រោះមិត្តឈាននៅភូមិភាគបូព៌ាស្រាប់ ហើយ មិត្តជា ក៏ត្រូវទាក់ទងជាមួយយួន និងត្រូវប្រាប់ មិត្តផែន ឲ្យបន្តទាក់ទងយួនដែរ ។ ពេល តាស៊ី ប្រាប់ហើយ យើងក៏ត្រឡប់ជួបនឹង តាចាប នៅមន្ទីរតំបន់ នៅត្រពាំងស្តៅ និងប្រាប់គាត់ពីរឿងទាក់ទងយួន ។

នៅខែវិច្ឆិកា ឆ្នាំ១៩៧៤ អង្គការបានលើកផែនការវាយក្រុងកំពត ពេលនោះ តាចាប បានហៅ បងជា បងផែន ខ្ញុំ មិត្តណយ មិត្តរិន មិត្តចន មិត្តដៃ ទៅជួបនៅមន្ទីរយោធាតំបន់២៥ នៅភូមិម៉ាកប្រាង ។ តាចាប បានចែកភារកិច្ចឲ្យធ្វើសកម្មភាពដូចជា មិត្តជា មិត្តផែន មិត្តណយ រួមទាំងខ្ញុំ ទទួលទាក់ទងទាហាន ចាន់ សំអុល នៅក្រុងកំពត ។ មិត្តរិន មិត្តដៃ និង មិត្តចន ទទួលខាង ប៉េ.សេ.អ៊ី កំពត ដោយឲ្យផ្លោងដាក់យោធាភូមិភាគកំពត រីឯពីខាងកើត ខ្ញុំ បងផែន បងជា មិត្តណយ ឲ្យ ចាន់ សំអុល ផ្លោងដាក់នៅក្រុងកំពត ។

នៅឆ្នាំ១៩៧៥ តាចាប ឲ្យ អ៊ឹនុត ចេន មិត្តផែន បងជា ទៅជួបនៅកន្លែង មិត្តណយ មន្ទីរស្រុកកំពត ។ តាចាប បាននិយាយថា ឥឡូវសភាពការណ៍ទូទាំងប្រទេសច្បាស់ជាដណ្តើមបានជ័យជម្នះលើលន់ នល់ ដូច្នោះយើងទាំងអស់គ្នាត្រៀមទស្សនៈឲ្យបានច្បាស់លាស់ ។ តាចាប បានបន្ថែមថា យើងត្រូវតែត្រៀមស្បៀង អាវុធ គ្រាប់រំសេវឲ្យហើយ យើងនិងផ្ទុះអាវុធពេលដែលបដិវត្តន៍រំដោះ ។ យើងមានបង្អែកពីយួន ទាំងអាវុធ ទាំងមនុស្ស បើយើងវាយមិនឈ្នះបដិវត្តន៍ទេ យើងនឹងរត់ចូលព្រៃជាមួយយួន ។

ក្រោយមក តាចាប ឲ្យខ្ញុំទៅជួប បងផែន ពេលទៅដល់ខ្ញុំបាននិយាយថា តាចាប ឲ្យខ្ញុំមកប្រាប់បងឯងអំពីផែនការទប់ទល់នឹងអង្គការទូទាំងប្រទេស នៅចុងឆ្នាំ១៩៧៥នេះ ។ បងផែន ក៏សួរខ្ញុំថា ផែនការទប់ទល់និងអ្វីខ្លះ? ខ្ញុំបានប្រាប់ទៅគាត់ថា តាចាប និយាយ

ថាកុំឲ្យផ្ដល់ស្បៀងអាហារទៅឲ្យសមរភូមិមុខគ្រប់គ្រាន់ ទាំងអង្ករ បន្លែ បើអង្គការត្រូវការកម្លាំងកងទ័ពគ្គី ដឹកជញ្ជូនសម្ភារគ្គី យើងកុំផ្ដល់ឲ្យអង្គការទាំងអស់អី ។ យើងត្រូវតែប្រឆាំងនឹងផែនការដែលអង្គការជកប្រជាជនចេញពីក្រុង ហើយយើងកុំភ្លេចត្រៀមលួចវាយកងទ័ពបដិវត្តន៍ពីក្រោយខ្នង ។

នៅខែមីនា ឆ្នាំ១៩៧៥ ដដែល អង្គការបានវាយក្រុងកំពតម្ដងទៀត តាចាប បានហៅខ្ញុំ មិត្តណយ មិត្តរិន ទៅដាក់ផែនការឲ្យកងទ័ពស្រុកកោះស្លា នៅជាមួយកងទ័ពភូមិភាគនិរតីខាងជើង កងទ័ពស្រុកកំពតនៅខាងត្បូងជាមួយកងទ័ពភូមិភាគ ដោយមិត្តរិន ទទួលផែនការផ្ទោងគ្រាប់ដាក់កងទ័ពនិរតី ពេលដែលសម្រុកចូលក្រុងកំពត ។ ក្រោយពីបានផែនការហើយ ខ្ញុំក៏បានចាត់តាំង តាឃឿន ឲ្យដឹកនាំកងទ័ពស្រុកមួយកងអនុសេនាតូច ដើម្បីត្រៀមចូលទៅខ្សែត្រៀមជាមួយនឹងកងភូមិភាគដែរ ដើម្បីបាញ់កងទ័ពភូមិភាគនិរតី ។

ក្រោយមកបានប្រហែលជាង១០ថ្ងៃ ក៏រំដោះទូទាំងប្រទេស អង្គការលើកផែនការរៀបចំរដ្ឋអំណាចបដិវត្តន៍ តាំងពីភូមិ ឃុំ ស្រុកឡើងទៅ ហើយឲ្យដកពួកទាហានរដ្ឋការចេញពីបដិវត្តន៍ ។

នៅខែសីហា ឆ្នាំ១៩៧៥ តាចាប ឲ្យខ្ញុំទៅជួបគាត់នៅមន្ទីរក្រុងកំពត ដោយមានប្រសាសន៍ថា តាម តាស៊ី ប្រាប់នៅខែកញ្ញា ឆ្នាំ១៩៧៥ បក្សកុម្មុយនីស្តកម្ពុជាត្រូវធ្វើជាមីទ្ទីងអបអរកំណើតកងទ័ពបដិវត្តន៍កម្ពុជា ។ នៅថ្ងៃនោះខាងភូមិភាគខត្តរធ្វើរដ្ឋប្រហារ ដូច្នេះមិត្តឯងទៅជួបនឹងមិត្តផែន ឲ្យប្រាប់ មិត្តជា និងមិត្តអាន ទាក់ទងនឹងមិត្ត ឈាន នៅខាងភូមិភាគបូព៌ាផង ។

ខ្ញុំបានទៅជួប បងផែន នៅមន្ទីរស្រុកអង្គជ័យ បងផែនបានសួរខ្ញុំថា មិត្តឃុំ ឯងទៅណា? ខ្ញុំបានឆ្លើយថា ខាងយើងនឹងធ្វើរដ្ឋប្រហារបក្សនៅថ្ងៃបុណ្យកំណើតកងទ័ពបដិវត្តន៍កម្ពុជា ។ តាចាប បានប្រាប់ថា ឲ្យបងឯងត្រៀមអាវុធ កងទ័ព និងស្បៀងឲ្យស្រេច ។ នៅថ្ងៃរដ្ឋប្រហារបក្ស បងផែន បងជា និង បងអាន ក៏ចាត់តាំង បងគុំ និងបងសៀង ឲ្យចាំបាញ់ តាម៉ុក ពេលដែល តាម៉ុកឡើងថ្លែងការណ៍ ។

នៅខែវិច្ឆិកា ឆ្នាំ១៩៧៥ តាចាប បានប្រាប់ខ្ញុំថា ការធ្វើរដ្ឋប្រហារបក្សត្រូវបានខកខានហើយ តែគាត់បន្តថា ត្រូវតែពង្រឹងនៅក្នុងសហករណ៍គ្រប់រូបភាពទៀត ។ ខ្ញុំក៏យកផែនការនោះមកដាក់ឲ្យគ្រប់ទីកន្លែងនៅឃុំលបើកធ្វើ ។ ខ្ញុំបានចាត់តាំង តាឃឿន ឲ្យបាញ់ឡានភ្ញៀវបរទេស៣ដង ហើយបានបាញ់ឡានចិនម្ដង ធ្វើឲ្យរបួស ១នាក់ ស្លាប់២នាក់ ។

រហូតដល់ចុងឆ្នាំ១៩៧៥ តាចាប បានហៅខ្ញុំ មិត្តណយ មិត្តយុត បងផែន ពូចេន មិត្តរិន ទៅជួបនៅមន្ទីរតំបន់ក្រុងកំពត ដោយឲ្យមិត្តទាំងអស់រាយការណ៍ពីសកម្មភាពប្រជាជនគ្រប់កន្លែង ។ តាចាប បានបន្តថាយើងត្រូវទាក់ទងគ្នាឲ្យជាប់ និងខិតសាងកម្លាំងយើងឲ្យច្រើនតទៅទៀត ហើយរួមគ្នាធ្វើសកម្មភាពបំផ្លាញឃ្លាំងអាវុធគ្រាប់រំសេវ និងបំផ្លាញគ្រឿងម៉ាស៊ីនឡាន ។ ខ្ញុំបានចែកការកិច្ច ឃឿន តាក្លា តាសឿ ទទួលបាញ់ឡានភ្ញៀវ នឹងបំផ្លាញឃ្លាំងគ្រាប់រំសេវ និងឃ្លាំងសម្ភារ ក្រណាត់ ។ តាញឹប មិត្តបឿន មិត្តដៃ ទទួលខាងបំផ្លាញរបស់របរសហករណ៍ តាមឿន មិត្តសារឹម ទទួលបំផ្លាញសហករណ៍ដែរ ។ ពេលដាក់ផែនការរួច តាឃឿន តាសឿទៅដុតឡានស្រែអំបិល អស់២គ្រឿង ។ នៅចុងខែ១ ឆ្នាំ ១៩៧៦ តាចាប ឲ្យខ្ញុំ មិត្តណយ ទៅជួប បងផែន នៅអង្គជ័យ ដើម្បីឲ្យគាត់ពិនិត្យតាមព្រំដែន ។ ខ្ញុំសួរបងផែនថា កន្លែងបងឯងយ៉ាងណាទៅហើយ? បងផែនថា កន្លងមកខ្ញុំឲ្យ មិត្តគុំ មិត្តសៀង ចាប់យុវជនយុវនារីខូចសីលធម៌អស់១០នាក់ យកទៅសម្លាប់ចោល និងចាប់ប្រជាជនរត់ពីការដ្ឋាន២០នាក់ទៀតទៅវាយបង្អត់ អាហារ ចងហាលថ្ងៃ ។

នៅខែកុម្ភៈ ឆ្នាំ១៩៧៦ អង្គការបានលើកផែនការឲ្យតំបន់៣៥ ធ្វើទំនប់កោះស្លាឲ្យហើយក្នុងឆ្នាំ១៩៧៦ ចំពេលដែលអង្គការត្រូវផ្លាស់បង អាន ពីតំបន់២៥ មកធ្វើគណៈអចិន្ត្រៃយ៍តំបន់៣៥ដែរ ។ នៅពេលនោះ តាចាប បានហៅបងអានខ្ញុំ មិត្តណយ មិត្តយុតទៅប្រជុំនៅមន្ទីរកោះស្លា គាត់បានលើកឡើងថា យើងត្រូវរកវិធីទប់ទល់កុំឲ្យផែនការនេះបានសម្រេចឲ្យសោះ ។ រីឯប្រជាជនវិញមិនបាច់គិតគូរពីជម្រក សុខភាព អនាម័យអីទេ ។ រួចមក តាចាប បានបញ្ជាមិត្តអាន មិត្តឃុំ មិត្តណយ មិត្តយុត ទទួលធ្វើសកម្មភាព ។ ក្រោយមក តាចាប បែងចែកការកិច្ចគ្នាធ្វើ ខ្ញុំទទួលខាងទំនប់ ឯមិត្តណយ និងមិត្តយុត ទទួលខាងព្រែកដឹក ខាងបងអាន បញ្ជាជាងឲ្យធ្វើទ្វារទឹកទាំង៣ ហើយបើប្រជាជនណាមកមិនទាន់ម៉ោងត្រូវដាក់ទារុណកម្ម ។

នៅខែមីនា ឆ្នាំ ១៩៧៦ បងអាន និងខ្ញុំបានទៅផ្ទះ មិត្តរិន

នៅឫស្សី ក្នុងស្រុកកំពង់ត្រាច ។ ទៅដល់មិត្តរិន បានសួរថា តើបងទៅណា? បងអាន ឆ្លើយថា មកកន្លែងមិត្តឯងចង់ដឹងពីសភាពការណ៍នៅកន្លែងមិត្តឯង និងនៅតាមព្រំដែន តើយ៉ាងណាដែរ មិត្តរិន បានឆ្លើយថា សភាពការណ៍នៅតាមព្រំដែនវៀតណាម និងយើងមានការបាញ់គ្នាខ្លះដែរ តែខ្ទឹមសារយួន និងយើងដូចបងបងប្អូនបង្កើតអីចឹង មិនបាច់ព្រួយបារម្ភទេ ។ លុះត្រឡប់ពីកន្លែងមិត្តរិន វិញ ខ្ញុំ និងបងអាន ចូលទៅទាក់ទង តាជឹម នឹងតាជឿន នៅក្រុងកំពតទៀត ។ តាជឿន ប្រាប់ថាសភាពការនៅកន្លែងនេះ គ្មានការព្រួយបារម្ភទេ ភាគច្រើនសុទ្ធតែកម្លាំងយើងទាំងអស់ ទន្ទឹមនឹងនេះ ខ្ញុំមានចលនាយុទ្ធជនយុទ្ធនារីទាក់ទងគ្នាប្រសេកប្រសាចពេញទីក្រុង ។

ក្រោយមក បងដែន និងបងគុំ បានមកជួបនឹង បងអាន នៅទំនប់កោះស្លា បងអាន សួរថា មិត្តដែន អញ្ជើញមកពីណាវិញ បងដែន ឆ្លើយថា មកពីជួបនឹង តាចាប នៅកំពត ។ បងដែន ក៏សួរថា ម៉េចបងទំនប់ធ្វើហើយឬទេ បងអាន ឆ្លើយថា ធ្វើមិនឲ្យហើយទេ ដូច្នេះប្រជាជននឹងលែងមានជំនឿលើអង្គការ ។ ពេលនោះ បងដែន ក៏លាទៅវិញ រីឯបងអាន ក៏និយាយជាមួយខ្ញុំ និងមិត្តណយ ថា ឥឡូវនេះយើងនៅទំនប់ យើងកសាងកម្លាំងបានឆាយណាស់ ។ ចាប់តាំងពីខែ៣ ដល់ ខែ៦ ឆ្នាំ១៩៧៦ បងអាន ឲ្យខ្ញុំប្រមូលទាហានទុកមួយដុំនៅទំនប់កោះស្លា ហើយបងអាន ឲ្យខ្ញុំអប់រំទាហានឲ្យធ្វើសកម្មភាពប្រឆាំងនឹងបដិវត្តន៍ ។ ក្រោយមកខ្ញុំបានចាត់តាំងឲ្យធ្វើសកម្មភាពលួចដុតជង្រុកស្រូវ លួចទម្លាយទំនប់ ធ្វើឲ្យលិចស្រូវ៤០ ហិកតា លួចដុតចម្ការធូរេននៅស្ទឹងអស់មួយចម្ការ លួចកាប់គោស៊ីអស់១០ក្បាល និងលួចមាន់ប្រជាជនអស់ជិត២០០ក្បាល ។

នៅចុងឆ្នាំ ១៩៧៦ តាចាប ប្រាប់ខ្ញុំថា យើងត្រូវរៀបចំកម្លាំង ត្រៀមអាវុធគ្រាប់រំសេវ និងស្បៀងឲ្យហើយស្រេច ព្រោះតាម តាស៊ី ប្រាប់នៅពេលចម្រូតនេះ យើងត្រូវផ្ទុះអាវុធ ។ ក្រោយពីជួប តាចាប មក ខ្ញុំបានឲ្យ តាញ៉ិប តាក្លា និង តាយឿន រៀបចំកងទ័ពគ្រាប់រំសេវ និងស្បៀងអាហារ ។ ដោយនៅមិនសុខ ខ្ញុំក៏ទៅជួបនឹង បងអាន នៅមន្ទីរកុកកញ្ឆាន់ រួចខ្ញុំសួរ បងអាន ថា សព្វថ្ងៃនេះខ្ញុំឃើញកម្លាំងបដិវត្តន៍ច្រើនណាស់ យើងអាចវាយឈ្នះឬទេ? បងអាន និយាយថាកម្លាំងយើងក៏មិនតិចដែរ នៅគ្រប់ភូមិភាគ គ្រប់តំបន់ ហើយនៅក្នុងកងទ័ពក្រសួងភ្នំពេញក៏មានដែរ ។ ម្យ៉ាងទៀតយើងត្រូវមានជំនឿលើបក្សពលករ តែយើងត្រូវតែប្រុងប្រយត្ន័ផង ពីព្រោះទាហានមិនសូវចេះរក្សាការសម្ងាត់ទេ ។ ពេលខ្ញុំត្រឡប់មកកន្លែងវិញ ខ្ញុំកសាងទាហានបាន១០នាក់ទៀត ។

មកដល់ខែមីនា ឆ្នាំ១៩៧៧ អង្គការកំណត់ឲ្យប្រជាជនទាំងចាស់ទាំងថ្មី ទូទាំងតំបន់៣៥ ហូបបាយរួម តែកាលនោះ តាចាប និយាយប្រាប់ខ្ញុំនៅទឹកឈូកថា បដិវត្តន៍សង្គមនិយមមិនមែនសំដៅត្រង់ហូបរួមទេ ហូបឯកជនក៏បានដែរ ពីព្រោះការហូបរួមវាលំបាកណាស់ ។ ក្រោយមក ខ្ញុំយកមកធ្វើនៅតាមផ្លូវជាតិលេខ៣ ខ្ញុំបានចាត់ឲ្យប្រជាជនហូបរួម ផ្ទះបាយមួយឲ្យហូបពី១៥០គ្រួសារទៅ៥០០គ្រួសារ ធ្វើឲ្យប្រជាជនលំបាកដើរមកហូប និងកើតទៅជាទំនាស់ ។ ពេលហូបម្តងៗ ចាប់ពីម៉ោង៩ព្រឹក រហូតដល់ពេលរសៀល ពេលយប់ដល់ម៉ោង១១យប់ ទើបហូបចប់ ខ្ញុំធ្វើនេះឲ្យប្រជាជនស្អប់ដែនការហូបរួមរបស់បក្ស ។

ដល់ថ្ងៃ១១ ខែមីនា ឆ្នាំ១៩៧៧ អង្គការឲ្យខ្ញុំមកធ្វើការនៅភូមិភាគឧត្តរ ។ មុនពេលចាកចេញ ខ្ញុំហៅ តាញ៉ិប តាក្លា តាជួប តាសឿ មិត្តជឿន មិត្តសារឹម មិត្តដៃ នឹងមិត្តបោយ ឲ្យបន្តធ្វើការនិងទាក់ទងខ្សែលើធ្វើការ គឺមិត្តណយ ស្រុកកំពតពូចេន ស្រុកឈូក និងអ៊ឹនុត ស្រុកស្រែក្នុង ។ បន្ទាប់មក តាចាប ខ្ញុំ មិត្តយុត បងអាន និងមិត្តយើងទាំងអស់ធ្វើដំណើរមកភូមិភាគឧត្តរ ដោយសម្រាកនៅភ្នំពេញពីរយប់ ។ដល់ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ១៩៧៦ ទើបយើងទៅដល់កំពង់ចាម ។ មកដល់កំពង់ចាម ទើបតាចាប បែងចែកភារកិច្ចនៅកន្លែងនោះថា មិត្តឆាយ នៅកំពង់ធំ និង មិត្តយុត មិត្តអាន នៅកំពង់ចាម រីឯខ្ញុំគឺនៅសៀមរាប ។

នៅចុងខែមីនា ឆ្នាំ១៩៧៧ ខ្ញុំបានទៅសៀមរាប ហើយទៅមន្ទីរ តាចាប ។ តាចាប សួរខ្ញុំថា មិត្តឈុំ ឯងមានការអី? ខ្ញុំបានឆ្លើយថា ចង់ទៅលេងអង្គរវត្ត ហើយចង់មកជួបតាផង ។ ខ្ញុំក៏ទៅអង្គរវត្ត ហើយពេលដែលខ្ញុំត្រឡប់មកវិញ តាចាប ហៅខ្ញុំទៅនិយាយថា យើងធ្វើការត្រូវធ្វើឲ្យស្របនឹងសភាពការណ៍ គឺទាហានបែកមុខប្រជាជនស្គាល់ទៅហើយកុំទុកអី តែបើទាហានណាដែលមិនស្គាល់ច្រើន ទុកវាកសាង ។ ដល់ខែមេសា ឆ្នាំ១៩៧៧ ឈ្មោះ ចន លេខាតំបន់៤៣ ហៅខ្ញុំទៅទំនប់វិច្ចិកា ទៅដល់ឃើញប្រជាជនធ្វើទំនប់មិនគាស់ឈើ មិនយកស្មៅចេញ មិនបាចដីល្បាប់ចេញ ។ ប៉ុន្តែបងចន

ធ្វើអត់ដឹងឮអ្វីទាំងអស់ ទុកឲ្យប្រជាជនធ្វើតាមចិត្ត ។ ក្រោយមក នៅទំនប់វិច្ឆិកា ត្រូវបាក់អស់២ដង និងប្រេះក្រហែង ដាក់ទឹកទឹក មិនបានទេ ។

ដល់ខែ៥ ឆ្នាំ១៩៧៧ តាចាប បានចេញពីសៀមរាប ទៅព្រះវិហារ ហើយគាត់ចូលមកផ្ទះខ្ញុំនៅស្ទោង ។ គាត់ប្រាប់ខ្ញុំថា ឥឡូវនេះតាម តាស៊ី ឲ្យដឹងថា នៅភូមិភាគឧត្តរនេះនៅមានខ្មែរយើងនៅឡើយ ខ្ញុំសួរនៅឯណាខ្លះ? តាចាប ថានៅកំពង់ធំឈ្មោះ ចន លេខាតំបន់៤៣ និងនៅក្នុងកងទ័ពមានមិត្ត សី ជាប្រធានកងពលភូមិភាគឧត្តរ ។ ដូច្នេះ មិត្តឈុំ ឯងទាក់ទងជាមួយឈ្មោះ ចន ទៅ ឯមិត្ត ភាន់ ចាំខ្ញុំប្រាប់ឲ្យទាក់ទងជាមួយនឹងមិត្ត សី ។ បន្ទាប់មក ខ្ញុំបានមកជួបនឹង បងចន បងចន បានសួរខ្ញុំថា មកពីណា ខ្ញុំឆ្លើយថាមកពីស្ទោង ។ បងចន នៅស្ងៀមមួយសន្ទុះ ទើបខ្ញុំនិយាយថា ពួកយើងដែលមកពីនិរតីមាន មិត្តឆាយ មិត្តយុត បងអាន និងមិត្តទី ហើយខ្ញុំទទួលខាងស្ទោង រីឯមិត្តឆាយ ធ្វើប្រធានមន្ទីរតំបន់៤៣ និងមានភារកិច្ចទាក់ទងខាងក្រៅទៀត ។ បន្ទាប់ពីបានជួប បងចន ហើយ ខ្ញុំកសាងកម្លាំងបានពីរនាក់ គឺឈ្មោះ សាញ់ នឹងអ្នក ហើយខ្ញុំឲ្យប្រជាជនព្រោះស្រែលើអស់២០០ហិកតា ដែលអង្គការហាមឃាត់ និងលែងគោឲ្យស៊ីអស់២០០ហិកតាទៀត នៅភូមិកំពង់ចិន ។

នៅខែមិថុនា ឆ្នាំ១៩៧៧ អង្គការបានហៅប្រជុំនៅកំពង់ចាម ពេលទៅទីនោះ ខ្ញុំក៏ហួសទៅដេកកន្លែង បងអាន ក៏ជួបមិត្ត ទី នៅទីនោះដែរ ។ ខ្ញុំបានសួរ បងអាន ថា បងអត់ទៅប្រជុំទេ បងអាន ឆ្លើយថា មិនទាន់ទៅទេ ។ បងអាន បន្តថា នៅក្នុងតំបន់៤១ កន្លងមកកុំឲ្យនរណាធ្វើខុសអីបន្តិច គឺត្រូវកម្ទេចចោលទាំងអស់ ។ ខ្ញុំសួរ បងអាន ថា តាចាប ដែលមកកន្លែងបងឯងទេ? បងអាន ឆ្លើយថា តាចាប ដែលមកពីរដង លើកទី១) គាត់មកខ្ទេសនាមឲ្យស្គាល់មិត្តសី លើកទី២) គាត់ប្រាប់ខ្ញុំឲ្យទៅទាក់ទងខាងភូមិភាគបូព៌ាផង ។ បន្ទាប់មក បងអាន សួរខ្ញុំថាម៉េចទៅខាងកំពង់ធំ? ខ្ញុំឆ្លើយថា ខាងខ្ញុំបានទាក់ទងជាមួយនឹង បងចន ហើយនៅក្នុងមន្ទីរតំបន់៤៣ ខ្ញុំបានចាត់តាំង មិត្តចិត្ត ឲ្យឡើងផ្ទះនារីដោយយកលេសចោទកងទ័ពភូមិភាគឲ្យកើតជាទំនាស់មិនឈប់ឈរ ។ នៅស្ទោងខ្ញុំបង្កើតទំនាស់ខាងនេសាទភូមិភាគ និងនេសាទសហករណ៍ ។

ក្រោយមក បងចន លើកផែនការនៅថ្ងៃ៣០ ខែកញ្ញា ឆ្នាំ១៩៧៧ បើផ្ទុះអាវុធនៅកំពង់ចាម យើងត្រៀមវាយនៅកំពង់ធំដែរ ។ ខ្ញុំសួរ បងចន ថា ចុះនៅកំពង់ចាមគ្នាយើងមានប៉ុន្មាននាក់ ហើយអ្នកណាបញ្ជា? បងចន ឆ្លើយថា ក្រោយពីអង្គការចាប់មិត្តសី មក គឺខ្ញុំទទួលខុសត្រូវដូច្នេះថ្ងៃបុណ្យនេះ បងពក ហៅខ្ញុំទៅហើយ ហើយខ្ញុំបានដាក់ផែនការឲ្យមិត្តរៀបចំនៅតាមក្រសួងទាំងអស់ ។ គាត់បន្តថា កម្លាំងយើងនៅគ្រប់ក្រសួង និងមន្ទីររបស់ភូមិភាគទាំងអស់ ។ តែផែនការនេះត្រូវអាកខាន ហើយពេល បងពក មកវិញក៏ចាប់ ចន តែម្តង ។ ក្រោយពីចាប់បងចន ស្អែកឡើង ខ្ញុំមកជួប តាចាប នៅសៀមរាប ។ តាចាប បាននិយាយថា កម្លាំងយើងមានតែប៉ុណ្ណឹងធ្វើការមិនខ្លាំងទេយើងយកទាហាននៅតាមភូមិឲ្យបានច្រើនមិនខ្វះទេ ។

នៅខែតុលា ឆ្នាំ១៩៧៧ ខ្ញុំបានទៅជួបមិត្ត ដន នៅចម្ការកៅស៊ូ ភូមិភាគកណ្តាល តាមការខ្ទេសនាមរបស់ បងផែន ។ ខ្ញុំឡើងទៅលើផ្ទះ ខ្ញុំនិយាយថា នៅខាង មិត្តដន ឯងក្តាប់បានសភាពការណ៍យ៉ាងណាដែរ? ដន ឆ្លើយថា តាមពូជឹម ប្រាប់យួនវាយចូលចម្ងាយ៣០ គីឡូម៉ែត្រ ហើយ ដន បន្តថាឲ្យតែយួនចូលដល់កម្លាំងគាត់នឹងសហការណ៍ជាមួយយួនវាយនៅកំពង់ចាម ។

មិត្តដន សួរខ្ញុំថា ចុះបងឯងរៀបចំយ៉ាងណាដែរ? ខ្ញុំឆ្លើយថា ខ្ញុំរៀបចំកងទ័ពអស់ហើយ ខ្ញុំអត់ទៅគិតអីទេគិតតែដើរស៊ីផឹកលេងបៀរ ។ ខ្ញុំនិយាយប៉ុណ្ណោះក៏ត្រឡប់មកវិញ មកដល់កំពង់ធំខ្ញុំចូលប្រាប់ មិត្តឆាយ ថាឥឡូវនេះសភាពការណ៍យួនវាយលុកក្នុងភូមិភាគបូព៌ាចូលជ្រៅណាស់ហើយ ។ មិត្តឆាយ ឆ្លើយថា នៅកន្លែងនេះឆ្ងាយទេ ព្រោះបងពកអត់នៅ ។

នៅខែមករា ឆ្នាំ១៩៧៨ អង្គការដាក់ឲ្យស្រុកស្ទោង ធ្វើទំនប់៣០កញ្ញា នឹងដាក់ឲ្យដាំពោត និងស្រូវ ២.២០០ហិកតា ហើយតម្រូវឲ្យធ្វើកន្លុយទ្វារទឹកថែមដើម្បីកុំឲ្យបាក់ ។ ពេលនោះ បងផែននិយាយថា ត្រូវឲ្យយុវជន៤០នាក់ទៅវាយវិហារវត្តដូង យកថ្ម និងដីថ្មមកចាក់ តែក្នុងពេលវាយធ្វើឲ្យបាក់កិនយុវជនស្លាប់ ៣នាក់ និងរបួស ១៧នាក់ទៀត ។

ថ្ងៃក្រោយមក បងផែន និងខ្ញុំ ទៅផ្ទះ បងអាន ម្តងទៀត ។ បងអាន សួរខ្ញុំថា យ៉ាងម៉េចទំនប់៣០កញ្ញា? ខ្ញុំក៏បានរាយការណ៍

ថា សភាពការណ៍ទំនប់៣០ កញ្ញា ជូន បងអាន ហើយខ្ញុំក៏សួរគាត់ថា ម៉េចទៅសភាពការណ៍នៅខាងនេះ? បងអាន និយាយថា សភាពការណ៍នៅកន្លែងនេះឥឡូវនេះឃើញថា មានការលំបាកបន្តិច ព្រោះតាមដឹងយួនវាយលុកចូលកម្ពុជានៅក្នុងភូមិភាគបូព៌ា ឥឡូវត្រូវកងទ័ពបដិវត្តន៍វាយខ្ទាត់ខ្ទាយដល់ព្រំដែនអស់ហើយ មួយទៀតការចេញចូលនៅខាងភូមិភាគបូព៌ាត្រូវអាក់ខានយូរដែរហើយ ។ តែមិត្តឈុំ ឯងត្រូវរៀបចំកម្លាំងឲ្យហើយពេលមានផែនការយើងវាយតែម្ដង ។

នៅខែមេសា ឆ្នាំ១៩៧៨ តាចាប បានហៅបងផែន មិត្តយុត បងអាន មិត្តលន មិត្តកាន អ៊ឹសិន និងខ្ញុំទៅប្រជុំនៅកន្លែងគាត់នៅសៀមរាប ។ ពេលប្រជុំ តាចាប លើកអំពីផែនការនៅខែមេសា ឆ្នាំ១៩៧៨ និងសភាពការណ៍យួន ចំណែកបូព៌ាយើងសង្ឃឹមខ្លាំងណាស់ដែរ តែឥឡូវនេះយើងអត់សង្ឃឹមប៉ុន្មានទេ ។ តាម បងញឹម លើកផែនការនៅថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៨ យើងត្រូវផ្ទុះអាវុធពីកន្លែងទី១) យើងផ្ទុះនៅត្រឹមកំពង់ធំមកសៀមរាប ។ ទី២) យើងផ្ទុះពីពោធិ៍សាត់ មកបាត់ដំបង ទាំងពីផ្លូវយើងចាប់ដៃជាមួយនឹងថៃ ។ ខាងកំពង់ធំយើងត្រូវរៀបរំមីន គ្រាប់បែក សម្រាប់កាត់ផ្លូវលេខ៦ ពីកំពង់ចាម ហើយ តាចាប ថា ខាងកំពង់ធំយោធាមួយវរសេនាធំប៉ុណ្ណោះ យើងទប់ទល់បានហើយ ព្រោះកម្លាំងខាងយោធាភូមិភាគកណ្ដាលរវល់តែជាប់ដៃជាមួយយួន ។ ដោយឡែក នៅខាងមិត្តផែន ត្រូវតែរកវិធីសម្លាប់មិត្តពក លេខាភូមិភាគកណ្ដាល ។

នៅថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៨ ពេលជិតដល់ថ្ងៃផ្ទុះអាវុធ ឃើញនីរសារ តាចាប យកសំបុត្រមកប្រាប់ បងអាន ថា ផែនការបរាជ័យហើយ ព្រោះមេបញ្ជាការខាងកងទ័ព និងគណៈបញ្ជាការ ត្រូវអង្គការចាប់មួយចំនួន ។ តែយើងនៅតែត្រៀមកម្លាំង និងស្បៀងជានិច្ច ។

នៅដើមខែមិថុនា ឆ្នាំ១៩៧៨ បងផែន បានទៅផ្ទះខ្ញុំ គាត់ហៅខ្ញុំទៅនិយាយថា ធ្វើបដិវត្តន៍សង្គមនិយម គេមិនសំដៅហូបបាយរួម ដាក់របស់របរួមនោះទេ តែគេសំដៅត្រង់តែសប្បុរសប្បាយតែប៉ុណ្ណោះ ។ ដូច្នេះយើងកុំតឹងពេក យើងឲ្យប្រជាជនរកស៊ីខ្លះទៅ ។ ក្រោយពីការណែនាំមកខ្ញុំហៅ មិត្តសៀន ទៅបំផុសប្រជាជននៅឃុំកំពង់ចិនខាងត្បូង ឃុំកំពង់ចិនខាងជើង នឹងឃុំម្សាក្រង ឲ្យប្រជាជនរកស៊ីឯកជនវិញ ។ ក្នុងខែមិថុនា ឆ្នាំ១៩៧៨ ខ្ញុំបានបំផុសប្រជាជនធ្វើចលនានេះសុសសាយពាសពេញទាំងស្រុកស្ទោង ។ ម៉្យាងវិញទៀតខ្ញុំបានឲ្យប្រជាជនពង្រីកដីភូមិជុំវិញផ្ទះ ហើយគ្រួសារនីមួយៗត្រូវមានដីស្រែម្នាក់មួយពីរសម្រាប់ស្ទូងយកផល និងបានណែនាំឲ្យចាស់ៗថែរក្សាព្រះ បោសជ្រះវិហារ ទុកវិហារ កុដសាលាជាច្រើនមិនឲ្យប្រជាជនរុះរើទេសម្រាប់បង្កើតសាសនាវិញ ។

នៅពាក់កណ្ដាលខែមិថុនា ឆ្នាំ១៩៧៨ បងអាន អ៊ឹសិន ខ្ញុំបានទៅជួបគ្នានៅកន្លែង បងផែន នៅមន្ទីរតំបន់៤៣ កំពង់ធំ ។ បងអាន និយាយថា សភាពការណ៍ឥឡូវនេះតឹងតែងណាស់ ក្រោយពីអង្គការចាប់ខាងភូមិភាគបូព៌ាអស់ និងចាប់ បងញឹម និង តាស៊ីមក ។ យើងអស់ក្បាលម៉ាស៊ីនដឹកនាំធំៗ មិនដឹងត្រូវដោះស្រាយដោយពិធីណាទេ ។ ខ្ញុំនិយាយថា ចាំទៅជួប តាចាប តែម្ដង ហើយសួរគាត់ពីក្បាលម៉ាស៊ីនដឹកនាំ ។ បងផែន ថាបើយើងទៅទាក់ទងជាមួយនឹងយួនក៏លំបាកដែរព្រោះយួនសព្វថ្ងៃត្រូវចាញ់កម្លាំងទៅហើយ តែម៉្យាងទៀតវាដាច់ខ្សែទាក់ទងគ្នាអស់ ។ អ៊ឹសិន បន្ថែមថា និយាយគ្នាអី គិតតែពីរឿងស៊ីផឹកលេងបៀរទៅ ។ បងផែន ក៏លើកបាយ មាន់ស្ងោរ មាន់ឆា មកដាក់ឲ្យក្នុងវង់អាប៉ោង ហើយ បងអាន ក៏ទាញបៀរសាប់ឲ្យគេ ដោយពេលនោះ បងផែន ថា បើមានលុយចាក់ឲ្យបះជើងតែម្ដង ហើយនាំគ្នាលេងផងស៊ីផឹកផង ។ បងអាន ថាចុះ នារីកែវ យើងនោះនៅឯណា? បងផែន ថាមិនមែនមានតែមួយពីទេ មានតែគ្រប់គ្នា ស៊ីផឹកលេងបៀររួច គាត់នាំទៅលេងនារីនៅខាងជើងផ្ទះគាត់ ដោយបងអាន ជាមួយនឹង នារីកែវ អ៊ុំសិន ជាមួយ នារីថុន ខ្ញុំជាមួយ នារីឌី បងផែន ជាមួយ នារីទូច ។

នៅចុងខែមិថុនា ឆ្នាំ ១៩៧៨ បងផែន ឲ្យខ្ញុំ និង មិត្តឆាយ ទៅជួបគាត់នៅមន្ទីរតំបន់៤៣ បងផែន និយាយថា ឥឡូវនេះខ្ញុំហៅមិត្តមកដើម្បីពិនិត្យការងារនៅក្នុងស្រុកស្ទោង និងកម្លាំងនៅក្នុងមន្ទីរតំបន់៤៣ ។ ខ្ញុំបានរាយការណ៍ពីការកសាងបានមិត្តមិន មិត្តរុន មិត្តសាញ់ មិត្តវង់ មិត្តអ្នក មិត្តសៀន មិត្តវៀន មិត្តនារីទូច មិត្តនារីយ៉ែម មិត្តគឹម មិត្តខុន បងភាត និងបងសាំ និងបានបំផុសប្រជាជនឲ្យនៅឯកជន និងបំផ្លាញស្រូវ ។

នៅដើមខែ៧ ឆ្នាំ ១៩៧៨ បងអាន បងផែន អ៊ឹសិន មិត្ត

យុន ទៅផ្ទះ តាចាប នៅមន្ទីរភូមិភាគសៀមរាប ។ តាចាប សួរថា ម៉េចទៅសភាពការណ៍តំបន់៤១ និងតំបន់៤៣ ។ តាចាប បន្តថា សភាពការណ៍ឥឡូវនេះគឺងតែងណាស់មិនងាយធ្វើការបានស្រួលទេ តែបើនៅខាងខ្ញុំវិញ ខ្ញុំបានទាក់ទងជាមួយនឹងសៀម ឯពួក អ៊ិនតាំ ដែលនៅតាមព្រំប្រទល់យកជាកម្លាំងមិនបានទេ ។ ចំណែកខាងភូមិភាគបូព៌ាត្រូវអង្គការចាប់ ខាងភូមិភាគពាយ័ព្យត្រូវអស់ ខាងបស្ចិមក៏អស់ទៀត ។ បងអាន សួរ តាចាប ថាតើយើងត្រូវបន្តសកម្មភាពតទៅទៀតឬយ៉ាងណា ។ តាចាប ថាលទ្ធភាពគឺមានតែផែនការសម្លាប់មិត្តពក ទេទើបមានផ្លូវ ព្រោះបើខ្សែរយៈទាក់ទងខាងភ្នំពេញក៏អស់ ។ ឥឡូវយើងត្រឡប់ទៅវិញ យើងត្រូវធ្វើសកម្មភាពរារាំងក្នុងសហករណ៍ក្រសួងមន្ទីរ ។ ឯបញ្ហាផ្សេងទៀតមានការអីខ្ញុំឲ្យដំណឹងតាមក្រោយនិយាយគ្នាហើយក៏បែកគ្នាទៅកន្លែងរៀងៗខ្លួន ។

នៅថ្ងៃទី១ ខែសីហា ឆ្នាំ១៩៧៨ បងពក បានហៅខ្ញុំទៅមើលទំនប់៣០កញ្ញា ពេលទៅដល់ទំនប់ បងពក សួរខ្ញុំពីបញ្ហាទំនប់ពីនេះពីនោះជាប់ជាមួយនឹងគាត់ ធ្វើឲ្យអាកខានផែនការសម្លាប់ ។ នៅថ្ងៃបន្ទាប់មក ខ្ញុំបានចាត់តាំង បងភាត បងសាំ ឲ្យកាប់ទម្លុះទំនប់ ៣០ កញ្ញា មួយកន្លែងបាក់អស់ទទឹង១០០ម៉ែត្រ ជម្រៅ១០ម៉ែត្រ បណ្តាលឲ្យលិចស្រូវខាងស្រុកកំពង់ស្វាយ ស្រុកស្ទោង និងរលួយស្រូវ ចំនួន ៣.៥០០ហិកតា ។ នៅឃុំសាគ្រាម មិត្តសៀន មិត្តវង់ មិត្តទៀន បានលួចដុតស្រូវក្នុងចម្ការអស់ ៦០ហិកតា ។ ខាងមិត្តរុន ខាងសន្តិសុខ ខ្ញុំបានចាត់តាំងឲ្យចាប់អ្នកខូចសីលធម៌ចំនួន១០នាក់មកវាយចោល និងចាប់អ្នកលួចបន្លែបង្កាបន្តិចបន្តួចមកវាយធ្វើបាបឲ្យដេកត្រាំទឹកអស់៣ថ្ងៃ ទើបលែងទៅផ្ទះវិញ ។ នៅខាងបន្ទាយស្ទោង មិត្តទៀន មិត្តវង់ បានលួចលែងក្របីក្នុងក្រោលឲ្យស៊ីស្រូវដែលកំពុងតែចេញផ្លែអស់៤០ហិកតា និងលួចកាប់កែងគោក្របីទៅឃុំស្ទោងអស់២០ក្បាល ។

ថ្ងៃទី៥ ខែសីហា ឆ្នាំ១៩៧៨ ខ្ញុំបានទៅជួប បងផែន នៅមន្ទីរតំបន់៤៣ ទៅដល់ខ្ញុំឃើញ មិត្តដន បងអាន មិត្តកាន នៅកំពុងតែស៊ីផឹកនៅផ្ទះ បងផែន ។ បងផែន បានហៅខ្ញុំឲ្យចូលទៅស៊ីផឹកដែរ លុះស៊ីផឹកហើយ មិត្តដន ទាញបៀរពីក្នុងស្បោងមកលេងបានបីម៉ោង ក៏បានទៅលេងនារីនៅកន្លែង បងផែន នៅ នារីនោះគឺនារីលើកមុន ហើយ បងអាន ឲ្យ នារីឌី ទៅមិត្តកាន នារីកែវ ទៅមិត្តដនបងអានយកនារីថុនឯខ្ញុំយកនារីទូច ។ ពេលនោះបងផែនអត់ទៅលេងទេ ។ លុះលេងហើយខ្ញុំរាយការណ៍ជូន បងផែន អំពីផែនការសម្លាប់ បងពក ត្រូវបរាជ័យ បងអាន និយាយថារឿងសម្លាប់ បងពក ពីថ្ងៃនេះទៅមុខត្រូវធ្វើឲ្យបាន ។ មិត្តឃុំឯងថ្ងៃក្រោយធ្វើយ៉ាងណាលួចសម្លាប់ឲ្យបាន បើបែកមុខយើងរត់ទៅខាងភូមិភាគឧត្តរទៅ ។

នៅថ្ងៃទី៨ ខែសីហា ឆ្នាំ១៩៧៨ ខ្ញុំហៅមិត្តអួក មិត្តសាញ់ មិត្តសៀន មិត្តវង់ មិត្តរុន មិត្តទៀន មិត្តគីម មិត្តសាំ មិត្តភាត និងគ្រួសារខ្ញុំចូលរួមប្រជុំ ។ ពេលប្រជុំខ្ញុំលើកពិសោធន៍ការងារកន្លងមក និងលើកផែនកាបន្តធ្វើសកម្មភាពបំផ្លាញសហករណ៍ ហើយក៏មានជប់លៀងមាន់ស្ងោរ ស្រា៥ដប ដែលមិត្តដនយកមកពីចម្ការកោះសូ ។ នៅថ្ងៃទី១០ ខ្ញុំបានចាត់តាំងមិត្តរុន ម្តងទៀតឲ្យចាប់ពួកទាហានយកមកបោសសម្អាតក្នុងនោះខ្ញុំក៏ចលនាទាហានឲ្យរត់ទៅស្រុកសៀមអស់៦០គ្រួសារ ។ រហូតដល់ថ្ងៃទី១៣ ខែសីហា ឆ្នាំ១៩៧៨ អង្គការចាប់ខ្លួនខ្ញុំតែម្តង ។ **ឃី ភ័ក្រា**



ឆ្អឹងរបស់ជនរងគ្រោះដែលនៅសេលសល់ក្រោយរបបខ្មែរក្រហមដួលរលំ

# អតីតកងការពារផ្ទាល់ និងជាចៅរបស់ សោ ភឹម លេខាភូមិភាគបូព៌ា សេសសល់ពីការចាប់ខ្លួន



ស៊ិន អ៊ីង

ស៊ិន អ៊ីង មានស្រុកកំណើត នៅភូមិសង្គម ឃុំគគីរសោម ស្រុករំដួល ខេត្តស្វាយរៀង។ សព្វថ្ងៃ អ៊ីង មានអាយុ៥៨ឆ្នាំ ធ្វើជាមេភូមិសង្គម ។ អ៊ីង ត្រូវជាចៅ និងជាកងការពារផ្ទាល់របស់ សោ ភឹម លេខាភូមិភាគបូព៌ា ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ អ៊ីង បានរស់ជីវិតរហូតមកដល់សព្វថ្ងៃ ដោយសារតែគាត់រត់គេចខ្លួនពីការតាមឡោមព័ទ្ធចាប់ខ្លួនពីសំណាក់កងទ័ពមជ្ឈិម នៅអរិយក្សត្រ ។

អ៊ីង មានឪពុកឈ្មោះ យស សារី ស្លាប់នៅឆ្នាំ១៩៦៩ នៅខេត្តបាត់ដំបង និងម្តាយឈ្មោះ ស៊ិន ប៉ែន។ ក្រោយមកម្តាយរបស់គាត់បានយកប្តីក្រោយ (ឪពុកចុង) ឈ្មោះ មាយ ស៊ីម ។ កាលនៅកុមារ អ៊ីង បានចូលរៀននៅសាលាគគីរសោម បានត្រឹមថ្នាក់ទី១០ "ពីសង្គមចាស់" ក៏ឈប់រៀននៅឆ្នាំ១៩៦៩ ។ នៅអំឡុងពេលនោះ ខ្មែរក្រហមបានមកព័ទ្ធចាប់ឪពុកចុងរបស់គាត់យកទៅ ដោយចោទថា គិញសម្ងាត់របស់សម្តេច សីហនុ និងគំរាមបោកគ្រាប់បែកសម្លាប់មួយគ្រួសារទៀត ។ ហេតុដូច្នេះហើយ ទើបធ្វើឲ្យម្តាយគាត់ផ្លាស់ទៅរស់នៅតាមប្អូនប្រុស ដែលមានប្រពន្ធនៅឃុំពានា ស្រុកស៊ីធរកណ្តាល ខេត្តព្រៃវែងវិញ ។ នៅទីនោះ ម្តាយរបស់ អ៊ីង បានជួលដីប្រជាជនធ្វើផ្ទះស្នាក់នៅ និងជួលដីសម្រាប់ធ្វើស្រែ ។ ម្តាយរបស់ អ៊ីង បានជួបការលំបាកយ៉ាងខ្លាំងក្នុងជីវភាពរស់នៅ ។

នៅឆ្នាំ១៩៧២ អ៊ីង និងម្តាយ បានត្រឡប់មករស់នៅស្រុកកំណើតនៅភូមិសង្គម ឃុំគគីរសោម ស្រុករំដួល ខេត្តស្វាយរៀងវិញ ។ តែគ្រួសារគាត់បានជួបប្រទះការភ័យខ្លាចម្តងទៀតគឺ ការទម្លាក់គ្រាប់បែក ។ យន្តហោះអាមេរិកាំងបានទម្លាក់គ្រាប់បែកត្រូវគោក្របី និងប្រជាជន ដូចជា គ្រួសារតាឡឹក នៅភូមិត្បែង ក្នុងឃុំគគីរសោម ក្បែរភូមិរបស់ អ៊ីង ត្រូវយន្តហោះទម្លាក់គ្រាប់ចំបណ្តាលឲ្យស្លាប់អស់មួយគ្រួសារ ។ ទន្ទឹមនឹងនោះ ក៏មានកងទ័ពវៀតកុង (វៀតណាមខាងជើង) ដើរកាត់ភូមិដែរ ហើយនៅពេលយន្តអាមេរិកទម្លាក់គ្រាប់កាន់តែច្រើនឡើង កងទ័ពវៀតកុងទាំងនោះ បានរត់ចូលមកបន្ទំលាក់ខ្លួនជាមួយប្រជាជនតែម្តង ។ យន្តហោះទម្លាក់គ្រាប់ម្តងៗ ប្រមាណពី១០ ទៅ២០ គ្រាប់ នៅអំឡុងពេលពាក់កណ្តាលអធ្រាតអស់រយៈពេលពី២-៣ម៉ោងទើបឈប់ ។ ដូច្នេះ គ្រប់ផ្ទះរួមទាំងផ្ទះរបស់ អ៊ីង សុទ្ធតែមានជីករណ្តៅត្រង់សេសម្រាប់ការពារៀងខ្លួន ។

អ៊ីង នឹងម្តាយគាត់បានប្រកបរបរធ្វើស្រែ រហូតដល់ឆ្នាំ១៩៧៥ ទើបគាត់ត្រូវបានរើសបញ្ចូលទៅក្នុងកងចល័ត ។ អ៊ីង ត្រូវដើរជីកដី រែកដី គ្រប់ភូមិ នៅឃុំគគីរសោម ស្រុកប្រសូត្រ ដែលមាន ឈ្មោះ សាលីវ និងឈ្មោះ សាម៉ែន ជាគណៈស្រុក ។ អ៊ីង ធ្វើការ នៅក្នុងកងចល័តបានមួយឆ្នាំ គឺរហូតដល់ដល់ខែឧសភា ឆ្នាំ១៩៧៦ ទើប សោ ភឹម លេខាភូមិភាគបូព៌ា (ត្រូវជាតារបស់ អ៊ីង ព្រោះម្តាយរបស់ អ៊ីង ត្រូវជាក្មួយ សោ ភឹម) ឲ្យកម្មាភិបាលនៅក្នុងមន្ទីររបស់គាត់មកជ្រើសរើស អ៊ីង ដែលពេលនោះមានអាយុទើបតែ១៩ឆ្នាំ រួមជាមួយសាច់ញាតិរបស់ សោ ភឹម មួយចំនួនទៀតទៅរស់នៅជាមួយគាត់ ។ សោ ភឹម មានឈ្មោះដើម ប្រាក់ ចាម មានឪពុកឈ្មោះ ប្រាក់ និងម្តាយឈ្មោះ ម៉ុំ ។ សោ ភឹម មានបងប្អូន ៤នាក់ គឺ ទី១) ប្រាក់ ជុំ ប្រុស ទី២) ប្រាក់ ឈុន ស្រីទី៣) ប្រាក់ ចាម (សោ ភឹម) និង ទី៤) ប្រាក់ ឌុល (ហៅ ទិត) ក្នុងរបបខ្មែរក្រហមធ្វើជាគណៈស្រុកឆ្លូង ។ សោ



សោ ភឹម

ភឹម មានប្រពន្ធឈ្មោះ យាយការ៉ូ មានស្រុកកំណើតនៅភូមិជ្រៅ ឃុំ ក្រពៅ ស្រុកកំចាយមារ ខេត្តព្រៃវែង ។

អ្នកដែលត្រូវបានជ្រើសរើសឲ្យទៅរស់នៅជាមួយ សោ ភឹម នៅពេលនោះមានគ្នា៩នាក់ ប៉ុណ្ណោះ គឺមកពីភូមិសង្គមជាមួយ អ៊ឹង ៦នាក់ និងមកពីភូមិត្បែង៣នាក់ ។ ក្នុងចំណោមយុវជនទាំងនេះ ក្រោយរបបខ្មែរក្រហម នៅរស់តែពីនាក់ប៉ុណ្ណោះ គឺ អ៊ឹង និង ប្រាក់ ជឿន អ្នកបើកឡាន កងការពារ និងអ្នកភ្ញាក់ម្ហូបឲ្យ សោ ភឹម ដែលបច្ចុប្បន្នរស់នៅភូមិគុម្ពោតទូក ឃុំគគីរសោម ។

អ៊ឹង បានដិះឡានផលិតនៅចិន ឆ្ពោះទៅមន្ទីរកសិដ្ឋានទួលសំរោង ចំថ្ងៃបញ្ចប់ពិធីការកូនស្រីរបស់ សោ ភឹម ឈ្មោះ ស៊ី និងកូនប្រុស រស់ ញឹម ហើយយប់នោះ អ៊ឹង សម្រាកនៅក្នុងរោងការដែលមិនទាន់រុះនោះតែម្តង ។ ដំបូង អ៊ឹង បានជួបជាមួយប្រពន្ធ សោ ភឹម ឈ្មោះយាយ ការ៉ូ ។ នៅទីនោះ អ៊ឹង ឃើញមានមនុស្សមកពីគ្រប់ស្រុកមកស្នាក់នៅ និងធ្វើចម្ការ ដោយព្រឹកឡើង ត្រូវឈូសឆាយព្រៃ និងរើសកម្ទេចឈើដុតដើម្បីយកដីដាំស្រូវ ។ អ៊ឹង ស្នាក់នៅមន្ទីរកសិដ្ឋានទួលសំរោង បានរយៈពេលប្រហែលជាង១០ថ្ងៃ ក៏មានកម្មាភិបាលមកពីមន្ទីរការពារ មកដឹកគាត់យកទៅសួង រួមជាមួយយុវជនទាំង៨នាក់ទៀតដែលមកពីស្រុកកំណើតជាមួយគ្នា ។ ទៅដល់ សោ ភឹម បាន ហៅ អ៊ឹង និងយុវជនទាំងនោះ មកសួរម្នាក់ម្តងដូចជា នៅភូមិណា? កូនរបស់អ្នកណា? បន្ទាប់ពីសួរនាំចប់ សោ ភឹម ណែនាំ «ឲ្យខំប្រឹងប្រែងធ្វើការ ព្រោះអស់ពីចាស់ៗមានតែក្មេងៗឡើងធ្វើតំណាងដូចជា ទំពាំងស្នងឫស្សី» ។

បន្ទាប់មក អ៊ឹង បានចូលហាត់រៀនពីរបៀបដោះកាំភ្លើង ហាត់បាញ់កាំភ្លើង ហាត់លូន ហាត់ក្រាប ដោយមានគ្រូឈ្មោះ ប្រាក់ ជឿក ត្រូវជាបងប្អូនជីដូនមួយរបស់ សោ ភឹម ជាអ្នកបង្ហាត់ ប៉ុន្តែមិនបានជាប់លាប់នោះទេ ។ ក្រៅពីធ្វើជាគ្រូបង្វឹក ជឿក ក៏ជាប្រធានកងការពារផ្ទាល់របស់ សោ ភឹម ដែរ ហើយនៅពេលចេញទៅក្រៅម្តងៗ បើ ជឿក មិនទាន់ចេញទៅត្រួតពិនិត្យផ្លូវជាមុនទេ ក៏ សោ ភឹម មិនហ៊ានចេញទៅដែរ ។

អ៊ឹង បានហាត់រៀនរយៈពេលពីរទៅបីខែ នៅក្នុងមន្ទីរការពារដែលមានសមាជិកសរុបទាំងអស់៦០នាក់ (សរុបទាំងគ្រួសារកងការពារ) ហើយភារកិច្ចគឺពេលយប់យាមក្នុងមួយម៉ោងប្តូរវេនគ្នាម្តង នៅខាងក្រោមផ្ទះដែល សោ ភឹម ស្នាក់នៅ និងពេលថ្ងៃដាំបន្លែ ។ ចំណែកកងការពារចាស់ៗ គឺ សោ ភឹម បានរំសាយឲ្យទៅធ្វើការនៅតាមមន្ទីរ ក្រសួង និងតាមមូលដ្ឋានវិញ គឺនៅសល់តែបីនាក់ប៉ុណ្ណោះ គឺឈ្មោះ យូន, សុង និង ស្រេង ។ សោ ភឹម ស្នាក់នៅមន្ទីរការពារ ដែលមានរបងជាប់នឹងមន្ទីរភូមិភាគ ហើយនៅពេលមានអ្នកដែលមកទាក់ទងធ្វើការងារជាមួយគាត់ គឺមកកន្លែងស្នាក់នៅរបស់គាត់ផ្ទាល់នៅមន្ទីរការពារតែម្តង ។ ចំណែកកិច្ចការប្រជុំជាមួយកងពល គឺ សោ ភឹម ទៅប្រជុំនៅឃុំរូងវិញ ។

នៅពេលនោះ កងការពារដែលជិតស្និទ្ធនឹង សោ ភឹម មានតែកងការពារក្មេងៗចំនួន៩នាក់ ប៉ុណ្ណោះដែលត្រូវជាបងប្អូនរបស់គាត់ ។ រីឯរបបអាហារ កងការពារហូបម្ហូបដូច សោ ភឹម ដែរ គឺសម្លកកូរ សម្លក់ និងប្រហើរ ដោយមានចុងភៅឈ្មោះ សុទ្ធ ជាអ្នកចម្អិន ។ ប៉ុន្តែកងការពារទាំងអស់ត្រូវហូប បន្ទាប់ពី សោ ភឹម ហូបរួច ។ ក្រៅពីហូបអាហារនៅក្នុងមន្ទីរ ក៏មានកម្មាភិបាលផ្ញើសាច់ប្រើស ឈ្លូស អណ្តើក ឲ្យ សោ ភឹម ហូបដែរ ។ ដោយឡែក អ៊ឹង នៅពេលនោះគាត់អាចដើរទៅហូបនៅមន្ទីរផ្សេងទៀតបាន ក្រៅពីមន្ទីរការពាររបស់គាត់ ។

ក្រៅពីការងារយាមនៅក្នុងមន្ទីរការពារ ពេលខ្លះអ្នកបើករថយន្ត បានហៅ អ៊ឹង ទៅដឹកសម្ភារនៅតាមភូមិជាមួយ ។ ចំពោះអ្នកប្រព្រឹត្តខុសសីលធម៌នៅក្នុងមន្ទីរ អង្គការបានទម្លាក់តួនាទី ឬយកទៅឃុំឃាំងនៅគុកស្រែស្តេ ជាមន្ទីរសន្តិសុខរបស់ភូមិភាគបូព៌ា ដែលមានឈ្មោះ សែន ជាប្រធាន ។

អ៊ឹង បានជូនដំណើរ សោ ភឹម ទៅជួបប្រពន្ធគាត់នៅកសិដ្ឋានទួលសំរោង រយៈពេល៣-៤ថ្ងៃ ឬមួយអាទិត្យ ជូនកន្លះខែទៅជួបម្តង ។ ពេលខ្លះ សោ ភឹម មិននៅសម្រាកនៅកន្លែងប្រពន្ធគាត់ទេ គឺទៅជួបហើយ គាត់ត្រឡប់មកមន្ទីរការពារភ្លាម ។ នៅពេលឮសំឡេងឡានរបស់ សោ ភឹម ទៅដល់មន្ទីរ អ្នកធ្វើការនៅទីនោះស្ងាត់មាត់ទាំងអស់ ព្រោះខ្លាចគាត់ ។

ក្រៅពីធ្វើកងការពារ អ៊ឹង ទទួលភារកិច្ចយកឯកសារសម្ងាត់ពី សោ ភឹម ទៅប្រគល់ឲ្យកងពលនៅតាមសមរភូមិ ដូចជា កងពលលេខ៥ ដឹកនាំដោយសមមិត្ត គឹម, កងពលលេខ៤ ដឹកនាំដោយសមមិត្ត រិន, កងពលលេខ៣ និងកងពលលេខ២ ដឹកនាំដោយ

សមមិត្ត តាត ដោយ ជិះម៉ូតូ សេ.អិល គ្នាពីរនាក់ និងមានកាំភ្លើងវៀងខ្លួន ។ ពេលខ្លះ អ៊ីង បាននៅហូបបាយជាមួយសមមិត្ត រិន ហើយសមមិត្ត រិន ក៏បានបេះផ្លែខ្នុរផ្ញើគាត់ទៀតផង ។ អ៊ីង មានការលំបាកយ៉ាងខ្លាំង នៅពេលគាត់ដឹកខ្នុរម្តងៗ ព្រោះផ្លូវលំបាក ។

នៅពេលនោះ អ៊ីង ក៏បានជូន សោ ភឹម ទៅជួបជាមួយតាសាឡាត់ ហៅ ស៊ឹម (ព្រោះប្រពន្ធរបស់ សោ ភឹម ត្រូវជាបងប្អូនប្រពន្ធរបស់ តាសាឡាត់) នៅស្ទឹង ក្នុងស្រុកពញាក្រែក បានបីដង ។ តែពេលទៅដល់ អ៊ីង ត្រូវនៅរង់ចាំខាងក្រោមផ្ទះ ចំណែក សោ ភឹម បានឡើងទៅពិភាក្សាការងារជាមួយ តាសាឡាត់ នៅលើផ្ទះតែពីរនាក់ប៉ុណ្ណោះ ។ បន្ថែមលើនោះ អ៊ីង ត្រូវ ជូនដំណើរ សោ ភឹម ចុះទៅធ្វើការតាមស្រុក និងតំបន់ទៀត រួមមានតំបន់ ២០, ២១, ២២, ២៣ និង២៤ ភូមិភាគបូព៌ា ។ សោ ភឹម បានប្រជុំជាមួយគណៈតំបន់ និងបានណែនាំពីផែនការដែលថ្នាក់លើដាក់មកឲ្យធ្វើ ។ នៅពេលចេញទៅធ្វើការម្តងៗ តែងតែមានចុងភៅម្នាក់ និងពេទ្យសម្រាប់ព្យាបាលម្នាក់ឈ្មោះ សែម អមទៅជាមួយ ព្រោះពេលខ្លះចុះទៅធ្វើការរយៈពេលមួយខែទើបត្រឡប់ មកមន្ទីរការពារវិញ ។ ក្នុងអំឡុងពេលនោះដែរ ក៏មានពេទ្យនៅភ្នំពេញធ្វើដំណើរតាមរថយន្ត និងតាមខ្ទម្កាចក្រនៅពេលផ្លូវលំបាក ទៅវាស់ឈាមបូមឈាម និងយកលាមករបស់ សោ ភឹម មកពិនិត្យនៅភ្នំពេញ ក្នុងរយៈពេលមួយអាទិត្យពីរដងជាប្រចាំដែរ ព្រោះ សោ ភឹម នៅពេលនោះមានជំងឺចុក ដៃជើង និងរាករូសច្រើន ។

ក្រៅពីការងារនៅក្នុងភូមិភាគបូព៌ា អ៊ីង បានជូន សោ ភឹម មកប្រជុំនៅមន្ទីរមួយនៅក្នុងវាំង ហើយពេលខ្លះជូនគាត់ទៅដាក់នៅវត្តខណ្ណាឡោម ដែលជាមន្ទីរនីសាររបស់ភូមិភាគបូព៌ា ទើបមានរថយន្តមកទទួលគាត់បន្តទៀត ។ បន្ទាប់ពីជូនរួច អ៊ីង ត្រូវនៅរង់ចាំនៅមន្ទីរនីសារនៅវត្តខណ្ណាឡោម ដែលមានឈ្មោះ អឿន ជាប្រធាន រហូតដល់ប្រជុំចប់ទើប អ៊ីង ទៅទទួល សោ ភឹម ត្រឡប់មកភូមិភាគវិញ ។ ប៉ុន្តែ បើ សោ ភឹម ប្រជុំមិនទាន់ចប់ ហើយត្រូវសម្រាកនៅភ្នំពេញ២-៣ថ្ងៃ អ៊ីង ត្រូវត្រឡប់ទៅមន្ទីរការពារនៅសួងវិញ រហូតដល់ថ្ងៃចប់ប្រជុំទើបគាត់ឡើងមកទទួល សោ ភឹម ។ អ៊ីង មានភារកិច្ចជូន សោ ភឹម មកប្រជុំនៅភ្នំពេញពីរដងក្នុងមួយខែ ដែលមានអ្នកបើកបរផ្ទាល់របស់គាត់ ឈ្មោះ គីម និង នីម (បច្ចុប្បន្នរស់នៅឃុំដូនតី) ដោយមកម្តងៗមានគ្នាចាប់ពីបួន ទៅ៦នាក់ និងឡានពីរគ្រឿងម៉ាក មែសឺដេស ពណ៌ស និងឡានសូឡេ ដោយក្នុងឡានមួយគ្រឿងជិះគ្នាពី២-៣នាក់ ។

នៅក្នុងមន្ទីររបស់ សោ ភឹម មានឡានប្រហែល៣០ គ្រឿង ហើយឡានមួយចំនួនត្រូវបានត្រួតពិនិត្យមុននឹងធ្វើដំណើរដូចជារថយន្តម៉ាកឡង់រ៉ូវែរ ជាដើម ព្រោះផ្លូវរលាក់ និងមានរណ្តៅច្រើន ដោយសារការទម្លាក់គ្រាប់បែកអំឡុងពេលសង្គ្រាម ហើយអ្នកបើកបរត្រូវចេញដំណើរពីម៉ោង៨ ព្រឹកពីសួង រហូតដល់ម៉ោង១២ ថ្ងៃត្រង់ ទើបទៅដល់ភ្នំពេញ ។

ចាប់ពីឆ្នាំ១៩៧៧-១៩៧៨ ជម្លោះរវាងខ្មែរក្រហម និងវៀតណាម ពីបញ្ហាព្រំដែនបានផ្ទុះឡើង អ៊ីង បានជូនដំណើរ សោ ភឹម ទៅប្រជុំជាមួយ កែ ពក ជាញឹកញាប់ និងចុះទៅសមរភូមិនៅស្ទឹង និងបានជួបជាមួយប្រធានកងពលដែលឈរជើងនៅតាមព្រំដែន និងចុះទៅដល់ខាងត្បូងផ្លូវជាតិលេខ៧ និងម្តុំក្របៅទៀត ។ កែ ពក លេខាភូមិភាគកណ្តាលក៏សម្រាកនៅមន្ទីរនីសាររបស់ អ៊ីង ដែរ ហើយថែមទាំងស្នើសុំ សោ ភឹម យក ប្រាក់ ជឿក ប្រធានមន្ទីរការពារ និង អ៊ីង ទៅនៅជាមួយគាត់ទៀត ។ ប៉ុន្តែ សោ ភឹម បានបដិសេធដោយនិយាយថា បើឲ្យ ជឿក និង អ៊ីង ទៅគឺគាត់គ្មានអ្នកប្រើនោះទេ ព្រោះ ជឿក ស្គាល់ទីតាំងភូមិសាស្ត្រច្បាស់លាស់ ។ រយៈពេលមួយអាទិត្យម្តង កែ ពក បានមកស្នាក់នៅមន្ទីរការពាររបស់ អ៊ីង នៅពេលមានព្រឹត្តិការណ៍វាយជាមួយវៀតណាមខ្លាំង ជាមួយកងទ័ពភូមិភាគកណ្តាលរបស់គាត់ដែលមានឯកសណ្ឋានពណ៌ស៊ីម៉ានី ខុសពីខោអាវកងទ័ពនៅខាងបូព៌ា កងទ័ពមជ្ឈិម កងទ័ពនិរតីស្លៀកពាក់ពណ៌ខ្មៅ ដែលមកបោះទីតាំងនៅទីនោះដែរ ។ ឯកសណ្ឋានកងទ័ពទាំងនោះទាល់តែមេបញ្ជាការរបស់គេវៀងខ្លួនទើបអាចចំណាំបាន ។

នៅអំឡុងពេលប៉ះទង្គិចគ្នានោះ អ៊ីង ឃើញ ប៉ុល ពត, នួន ជា, ជួន ជឿន, វន វ៉េត មកប្រជុំនៅមន្ទីរការពាររបស់ សោ ភឹម ដែរ ហើយអ្នកធំទាំងនោះតែងមកដល់នៅពេលយប់ ។ នៅអំឡុងឆ្នាំ ១៩៧៧ នួន ជា ធ្លាប់បានសម្រាកនៅមន្ទីរការពាររបស់គាត់នៅសួង ៤ដងដែរ ។ ពេល នួន ជា មកម្តងៗ គឺមានរថយន្តប្រមាណ២០-៣០ គ្រឿងអមមកជាមួយ និងមានអង្គរក្សជាច្រើននាក់មកការពារទៀត ។ ដោយឡែក ក៏មានភ្ញៀវមកពីប្រទេសគុយបា បារាំង និង



រូបពីស្តាំមកឆ្វេង ៖ សោ ភឹម, ប៉ុល ពត, នួន ជា, អៀង សារី និង វន វេត នៅក្នុងកិច្ចប្រជុំមហាសន្និបាតបក្សកុម្មុយនីស្តកម្ពុជា នៅទីក្រុងភ្នំពេញ

ជាពិសេសភ្ញៀវប្រទេសចិន បានចុះទៅធ្វើទស្សនកិច្ចនៅភូមិភាគបូព៌ាដែរ ហើយគណៈប្រភូតិចិនឈ្មោះ ឆឹង ជាងគុយ បាននៅសម្រាកមន្ទីរការពាររបស់ អ៊ីង តែម្តង ។

រហូតមកដល់ពេលអង្គការចោទខាងភូមិភាគបូព៌ាក្បត់ អ៊ីង សង្កេតឃើញ សោ ភឹម ផឹកស្រា តែម្នាក់ឯងរយៈពេលប្រមាណមួយខែ ។ អ៊ីង បានរៀបរាប់ថា នៅមុនការចោទប្រកាន់នោះក៏មានព្រឹត្តិការណ៍ចាប់កម្មាភិបាលនៅភូមិភាគឦសានដែរ កម្មាភិបាលមួយចំនួនត្រូវអង្គការចោទថា បានរត់ចូលមកខាងភូមិភាគបូព៌ា ។ ពេលនោះកម្មាភិបាលជាច្រើននៅភូមិភាគបូព៌ាក៏ត្រូវបានចាប់ខ្លួនទៀត ហើយ សោ ភឹម បានចេញពីមន្ទីរការពាររបស់គាត់នៅសួងមកនៅកសិដ្ឋានទួលព្រាប នៅឃុំដូនតី វិញ ។ បន្ទាប់មក សោ ភឹម បានទៅស្នាក់នៅជាមួយសមមិត្ត រិន នៅសេនាធិការរបស់ភូមិភាគបូព៌ា នៅទីរួមខេត្តព្រៃវែង ព្រោះសមមិត្ត រិន មានជំងឺ ត្រូវឡើងមកសម្រាកពេទ្យនៅទីនោះ ។ តែនៅពេលនោះ ក៏មានប្រធានកងពលដែលសល់ពីការចាប់ខ្លួន ដូចជា សមមិត្ត វណ្ណា, សមមិត្ត គឹម និងសមមិត្តមួយចំនួនទៀតដែល អ៊ីង មិនចាំឈ្មោះ ខស្សាហ៍ឡើងមកប្រជុំជាមួយ សោ ភឹម ញឹកញាប់ដែរ ។ មួយរយៈក្រោយមក សោ ភឹម បានប្រាប់សមមិត្ត រិន ថា គាត់ត្រូវឡើងទៅប្រជុំនៅភ្នំពេញដើម្បីដោះស្រាយពីរឿងដែលអង្គការចោទថា «ខាងភូមិភាគបូព៌ាក្បត់» ដោយបាន ផ្តាំផ្ញើសមមិត្ត រិន ថា «បើគាត់ (សោ ភឹម) ទៅរយៈពេលមួយអាទិត្យ មិនឃើញត្រឡប់មកវិញ ឯងត្រូវរត់ចូលព្រៃ និងប្រមូលអ្នកសេសសល់ទាំងប៉ុន្មានចូលព្រៃ ដើម្បីវាយជាមួយកងទ័ពរបស់ ប៉ុល ពត វិញ» ។

នៅអំឡុងបុណ្យចូលឆ្នាំខ្មែរឆ្នាំ១៩៧៨ រួចហើយ សោ ភឹម, អ៊ីង រួមទាំងអ្នកបើកបររថយន្ត អ្នកដាំបាយ កងការពារ និងនីរសារ សរុបទាំងអស់៩នាក់ បានចាកចេញពីមន្ទីរសេនាធិការ នៅទីរួមខេត្តព្រៃវែង ។ អ្នករួមដំណើរទាំងអស់មានកាំភ្លើងអាកាគ្រប់ដៃ ចំណែកកាំភ្លើងខ្លីរបស់ សោ ភឹម ដាក់នៅកន្ត្រកខោអាវគាត់ ដោយធ្វើដំណើរកាត់តាមស្វាយអន្ទរ ស្វាយពល ព្រែកតាមាក់ និងតាមបណ្តោយមាត់ទន្លេ ។ អ៊ីង បានមកដល់អរិយក្សត្រនៅពេលរសៀល និងបម្រុងឆ្លងតាមទូកចូលទៅក្នុងទីក្រុងភ្នំពេញ ។ ប៉ុន្តែដោយសារមានភ្ញៀវធ្លាក់ច្រើន ទន្ទឹមនឹងនោះ មានអ្នករត់គេចពីការចាប់ខ្លួនក្នុងក្រុងភ្នំពេញមករស់នៅក្នុងចម្ការនៅអរិយក្សត្រប្រាប់ថា «បងមិនចាំបាច់ទៅទេ តែទៅគេចាប់ខ្លួនហើយ ព្រោះគេចាប់អស់ហើយខាងភូមិភាគបូព៌ានៅក្នុងក្រុង» ទើប សោ ភឹម ឈប់នៅទីនោះ ។ ប៉ុន្តែ សោ ភឹម បានឲ្យស្មៀនរបស់គាត់ឈ្មោះ ចេងសរសេរសំបុត្រមួយច្បាប់ដែលមានខ្លឹមសារ «ខ្ញុំ (សោ ភឹម) មកដល់អរិយក្សត្រហើយ សូមសមមិត្តមកទទួលផង» ហើយបានបោះត្រាសម្គាល់ រួចឲ្យនីរសាររបស់គាត់យកទៅប្រគល់ឲ្យ ប៉ុល ពត នៅក្នុងក្រុងភ្នំពេញ និងឲ្យចាំយកសំបុត្រឆ្លើយតបត្រឡប់មកវិញ ។ ប៉ុន្តែរយៈពេលប្រមាណបីម៉ោងក្រោយមក ស្រាប់តែឃើញនីរសាររបស់គាត់ត្រឡប់មកវិញ ដោយមិនមានសំបុត្រឆ្លើយតបអ្វីទាំងអស់ ។ ដោយមិនអស់ចិត្ត សោ ភឹម បានផ្ញើសំបុត្រថ្មីមួយច្បាប់ទៀត ឲ្យនីរសារយកទៅប្រគល់ឲ្យ ប៉ុល ពត ទៀត ប៉ុន្តែសំបុត្រទីពីរនោះ ត្រូវបានបដិសេធដដែល ។ ដូច្នេះហើយ សោ ភឹម រួមជាមួយកងការពារ និងនីរសារបានសម្រាកនៅផ្ទះឈើក្នុងចម្ការទល់មុខរាជវាំងតែម្តង ។

នៅវេលាប្រហែលម៉ោង៧រំលងអធ្រាត អង្គការបានបញ្ជូនយោធាក្រុងប្រដាប់ដោយកាំភ្លើង អា.កា ស្វាយវែង និងសេ.កា.សេ ទៅឡោមព័ទ្ធចាប់ សោ ភឹម តែបានប៉ះទង្គិច និងបាញ់គ្នាជាមួយយោធាដែលរត់គេចពីការតាមចាប់ខ្លួននៅក្រុងភ្នំពេញ មកនៅចម្ការ ។ ដោយមិនអាចសម្គាល់យោធាទាំងនោះថា មកពីខាងណា

អ៊ីង ក៏បានបាញ់ទៅវិញចំនួនមួយគ្រាប់ ស្រាប់តែខាងយោធាក្រុង បាញ់ចេញពីគ្រប់ទិសត្រឡប់មកវិញ ។ ឃើញដូច្នេះ អ៊ីង ក៏ទៅឃាត់ក្រុមគាត់ឲ្យឈប់បាញ់ ។ ខណៈនោះមានកម្មាភិបាលម្នាក់ដែលធ្វើការនៅមន្ទីរនីរសារក្រុងភ្នំពេញ រត់មកលាក់ខ្លួននៅអរិយក្សត្រ បានប្រាប់ សោ ភឹម ថា “គាត់ដឹងថាមានច្រកចេញមួយ ហើយយើងមិនបាច់ជិះឡានរបស់អ៊ំទៅទេ តែជិះទៅ យោធាក្រុងចាប់មិនខានព្រោះឮស្គរឡាន” ។ ពេលដើរចេញពីផ្ទះប្រហែលបាន៥០ ម៉ែត្រ សោ ភឹម ឲ្យនីរសារគាត់ម្នាក់រត់ទៅមន្ទីរស្រុកល្វាឯម ដើម្បីយកឡានមកដឹកគាត់ចេញ ។ ស្រាប់តែដើរមកដល់ផ្លូវធំ ដែលមានដើមឈើធំៗចំនួនពីរដើម ក៏ឃើញយោធាក្រុងដែលពួននៅក្បែរនោះ ចេញមកចាប់ដៃកងការពាររបស់ សោ ភឹម ដែលដើរនៅខាងមុខឈ្មោះ ព្រឿង និងឈ្មោះ ភី និងអ្នកយួរកន្ត្រកខោអាវរបស់ សោ ភឹម ដែលដើរខាងក្រោយឈ្មោះ ផល ជាប់ រួចហើយបានស្រែកសន្ធាប់ពីរទៅបីដងឲ្យលើកដៃឡើងទាំងអស់គ្នា ។ តែភ្លាមនោះ អ៊ីង ក៏បានបាញ់សំដៅត្រូវចំយោធាក្រុងមួយចំនួនដួលនៅនឹងកន្លែង ហើយក្រុមរបស់ អ៊ីង ក៏បាញ់បន្តបន្ទាប់ទៀត ។ អ៊ីង បានរត់បកក្រោយ និងបានឱបការពារ សោ ភឹម នាំត្រឡប់មកផ្ទះនៅក្នុងចម្ការវិញ ។ មកដល់ផ្ទះ សោ ភឹម បានអង្គុយទុចនៅនឹងផ្ទះតែម្តង ហើយប្រាប់ថា គាត់ទៅណាលែងរួចហើយ ។ ខណៈនោះ សោ ភឹម បានទារយកកាំភ្លើងខ្លីរបស់គាត់នៅក្នុងកន្ត្រក ប៉ុន្តែ អ៊ីង មិនឲ្យ ព្រោះ អ៊ីង ដឹងថាគាត់ហត់ហើយ ។ រហូតដល់ស្គរផ្ទុះអាវុធស្ងប់ស្ងាត់បន្តិច អ៊ីង បានឲ្យឈ្មោះ ភី នៅយាមនៅផ្ទះ រួចគាត់រត់ទៅប្រាប់កងការពារនៅខាងមុខឲ្យឈប់បាញ់ ដោយប្រាប់ថា តា (សោ ភឹម) ត្រឡប់មកក្រោយវិញហើយ ដូច្នេះត្រឡប់មកការពារគាត់វិញ ។

បន្ទាប់មក អ៊ីង បាននាំអ្នកជំនាញបើកការណូតម្នាក់ចុះទៅមាត់កំពង់ដើម្បីពិនិត្យមើលប្រេង និងសាកបញ្ឆេះម៉ាស៊ីន ដើម្បីត្រៀមចាំដឹក សោ ភឹម គេចខ្លួន ។ អ៊ីង និងអ្នកបើកបរការណូតនោះបានបញ្ឆេះម៉ាស៊ីនរង់ចាំអស់រយៈពេលកន្លះម៉ោង ប៉ុន្តែមិនឃើញ សោ ភឹម ចុះមក ទើបអ្នកទាំងពីរពន្លត់ម៉ាស៊ីនវិញ ។ អ៊ីង បានដោះកាំភ្លើងដាក់លើក្បាលទូក រួចហើយមុជទឹកទាំងអារម្មណ៍នៅភិតភ័យ ស្រាប់តែពេលនោះគាត់ឃើញស្រមោលមនុស្សមកដល់មាត់កំពង់ជាបន្តបន្ទាប់ និងឮសំឡេងប៉ះទង្គិច ជាមួយធុងប្រេងដែលដាក់តម្រៀបគ្នានៅលើមាត់ច្រាំង ។ អ៊ីង បានប្រាប់អ្នកបើកការណូតនោះថា មានមនុស្ស ឮដូច្នេះអ្នកបើកការណូតក៏គេចខ្លួនបាត់ ។ អ៊ីង បានគិតក្នុងចិត្ត គាត់នឹងស្លាប់មិនខាន ព្រោះមិនស្គាល់ភូមិសាស្ត្រនៅទីនោះ ហើយគាត់ក៏ដើរពីកន្ទុយការណូត មកក្បាលកាណូតវិញ ដើម្បីស្ទៀកពាក់ និងលើកកាំភ្លើងតម្រង់ទៅយោធាក្រុងដែលក្រាបចាំនៅលើច្រាំងវិញ ។ អ៊ីង បានចុះទៅក្នុងទឹក ហើយឆ្លងពីកាណូតមួយទៅការណូតមួយទៀតដែលចតតម្រៀបគ្នានៅមាត់កំពង់ដើម្បីគេចខ្លួន ។ អ៊ីង ចេញផុតពីនោះបានប្រមាណ២០ម៉ែត្រ ក៏ឃើញយោធាក្រុងដើរចុះទៅការណូតរបស់គាត់ តែដោយមិនឃើញមានមនុស្សក៏ត្រឡប់ទៅវិញអស់ទៅ ។ ចំណែក សោ ភឹម បានដើរគេចតាមផ្លូវជាប់មាត់កំពង់ រួចមានឡានខាងមន្ទីរស្រុកល្វាឯម មកទទួលគាត់គេចចេញទៅបាត់នៅយប់នោះដែរ (ដែលហេតុការណ៍នោះ អ៊ីង ដឹងក្រោយពីបានជួបចៅហ្វាយស្រុកខ្សាច់កណ្តាល) ។

បន្ទាប់ពីគេចខ្លួនរួច អ៊ីង គិតថា សោ ភឹម និងកងការពារទាំងប៉ុន្មានរបស់គាត់ស្លាប់អស់ហើយ ដូច្នេះភ្លឺឡើងគាត់ក៏ត្រឡប់ទៅផ្ទះនៅក្នុងចម្ការវិញ ។ ប៉ុន្តែពេលទៅដល់ គាត់ឃើញយោធាប្រមាណ ២០០ ទៅ ៣០០នាក់ មកស្នាក់នៅពេញខាងក្រោម និងលើផ្ទះ ហើយខ្លះទៀតកំពុងដោះ និងលាងកាំភ្លើង ។ ដោយនឹកស្មានថាយោធាទាំងអស់នោះជាក្រុមរបស់ខ្លួន អ៊ីង ក៏ស្រែកប្រាប់ថា “ខ្ញុំមកយកឡាន (ឡានរបស់ សោ ភឹម ដែលទុកចោល) របស់ខ្ញុំវិញ” ។ ភ្លាមនោះ យោធាទាំងនោះស្រែកបញ្ជាឲ្យ អ៊ីង លើកដៃ ទើប អ៊ីង ដឹងថាជាយោធាក្រុង ។ ដោយគិតថាខ្លួននឹងស្លាប់ អ៊ីង ក៏បានបាញ់រះទៅលើយោធាក្រុងទាំងនោះ រួចហើយរត់គេចខ្លួន ។ យោធាក្រុង បានដេញតាមបាញ់ អ៊ីង ពីក្រោយតែបាញ់មិនត្រូវ ។ អ៊ីង រត់ចូលទៅពួននៅក្រោមកំប្លោកក្នុងបឹងមួយ ហើយយោធាក្រុងបានបាញ់សម្រុកទៅលើកំប្លោកប្រមាណ១០ម៉ែត្រ ៤ជ្រុងថែមទៀត ។ ដោយមិនអស់ចិត្តយោធាក្រុងទាំងនោះ បានចុះទៅរាវរក អ៊ីង និងកាំភ្លើងនៅក្នុងទឹកទៀត តែរកមិនឃើញ ព្រោះ អ៊ីង បានហែលទៅក្រាបនៅក្រោមស្លឹកកំប្លោកដែលត្រូវគ្រាប់កាំភ្លើងបាក់ធ្លាក់គ្របលើផ្ទៃទឹក ។ បន្ទាប់មកពីយោធាខ្មែរក្រហម

ចេញពីនោះអស់ អ៊ីង ក៏លូនទៅរកស្នូរដែលប្រជាជនធ្វើសម្រាប់ដួតទឹក រួចហើយក៏ងើបឡើង ស្រាប់តែយោធាខ្មែរក្រហមបាញ់សម្រុកមកម្តងទៀត ធ្វើឲ្យប្រជាជននៅទីនោះផ្អើលពេញភូមិ ។ អ៊ីង សម្ងឹងមើលនៅលើដងផ្លូវ ឃើញយោធាខ្មែរក្រហមជិះឡានរបស់ សោ ភឹម មកបន្ថែមទៀត ។ អ៊ីង ក៏ពួននៅអែបថ្នល់ម្ខាង រួចហើយក៏រត់ឆ្លងផ្លូវចូលទៅក្នុងផ្ទះទាម ហើយគេចចេញទៅតាមច្រកទ្វារក្រោយ ។ ចំណែកយោធាក្រុងទាំងនោះបែរជានៅព័ទ្ធជុំវិញផ្ទះនោះទៅវិញ ។

អ៊ីង បានរត់កាត់ចម្ការក្រោយផ្ទះប្រជាជន និងកាត់ព្រៃរយៈពេលបីថ្ងៃទើបទៅដល់វិហារសួរ ស្រុកខ្សាច់កណ្តាល ។ ប្រជាជននៅទីនោះក៏បានចាប់ អ៊ីង ចងផ្អោបនឹងសសរផ្ទះ ហើយដោយសារគាត់គ្រុន និងហត់ហេវដោយសារគ្មានអាហារហូបក៏ដេកលក់នៅពេលនោះ ។ ពេលដឹងខ្លួនឡើង អ៊ីង ឃើញប្រជាជន២-៣នាក់កាន់ផ្គាក់គ្រប់ដៃ បន្ទាប់មកមានមនុស្សម្នាក់រត់ទៅរាយការណ៍ប្រាប់គណៈស្រុកខ្សាច់កណ្តាលថា ចាប់បានខាងនិរតី ។ ប៉ុន្តែមិនបានជួបកម្មាភិបាលទេ គឺជួបតែខាងក្រុមសិល្បៈ ។ ពេលក្រុមសិល្បៈពេលដល់កន្លែងឃុំឃាំង ក៏ស្គាល់ អ៊ីង ជាអង្គរក្សរបស់ សោ ភឹម ទើបទៅស្រាយចំណងដោះលែង ហើយមេឃុំនៅទីនោះក៏ធ្វើការសុំទោស អ៊ីង ។

រហូតដល់ម៉ោងប្រមាណ៩ល្ងាច ចៅហ្វាយស្រុកឈ្មោះ សៀវ មកហៅ អ៊ីង ទៅមន្ទីរស្រុកខ្សាចកណ្តាល ហើយប្រាប់ អ៊ីង ថា សោ ភឹម នៅរស់ទេ និងកំពុងស្នាក់នៅព្រែកពោធិ៍ ស្រុកស្រីសន្ធរ ព្រោះគាត់ទៅប្រជុំជួប ។ សៀវ បានធ្វើសំបុត្រស្នើទៅ សោ ភឹម ដើម្បីសុំ អ៊ីង ឲ្យនៅធ្វើការនៅស្រុកខ្សាចកណ្តាលជាមួយគាត់ ។ អ៊ីង នៅមន្ទីរស្រុកបានប្រហែល៦ថ្ងៃ ក៏ឃើញប្រជាជនរត់មករាយការណ៍ជាញឹកញាប់ថា ខាងនិរតីចុះមកចាប់មេឃុំ ទាហាន កម្មាភិបាលនៅតាមមន្ទីរជិតៗនោះអស់ហើយ ។ ដោយសារភ័យខ្លាចយប់នោះ អ៊ីង បានលួចរត់ ដោយគាត់បបួលកម្មាភិបាលពីរនាក់ទៀតនៅក្រុមសិល្បៈទៅជាមួយដែរ ដោយបន្លំខ្លួនធ្វើជាប្រជាជន ។

បន្ទាប់ពីដឹងថា អ៊ីង រត់គេចខ្លួនហើយ កម្មាភិបាលនៅមន្ទីរស្រុកខ្សាច់កណ្តាលមួយចំនួនក៏រត់មកតាមក្រោយគាត់ដែរ ។ អ៊ីង បានធ្វើដំណើររយៈពេលប្រមាណ២-៣ថ្ងៃ ទើបទៅដល់ព្រែកពោធិ៍ រួចទៅសម្រាកនៅរោងចក្រផលិតតាំងហ៊ុន ។ នៅម៉ោងប្រមាណ៤-៥ល្ងាច ស្រាប់តែមានកងយោធាមជ្ឈិមបានមកភ្លង់និងឃាត់ក្រុមរបស់ អ៊ីង ដែលឈរនៅមាត់ផ្លូវ ក្នុងមានចម្ងាយប្រមាណ៣០០ម៉ែត្រ ពីកន្លែងគាត់ ទៅមន្ទីរស្រុកព្រែកពោធិ៍ (កន្លែង សោ ភឹម ស្នាក់នៅ) ដើម្បីបិទផ្លូវព័ទ្ធចាប់ សោ ភឹម ។ ប៉ុន្តែសំណាងល្អយោធាមជ្ឈិមទាំងនោះបានស្គាល់ក្រុមសិល្បៈដែលរត់គេចខ្លួនទៅជាមួយ អ៊ីង ព្រោះយោធាទាំងនេះពីមុននៅខាងសិល្បៈភូមិភាគដែរ តែក្រោយមកអង្គការបានបញ្ជូនទៅនៅយោធាមជ្ឈិម ។ យោធាទាំងនោះ បានប្រាប់ក្រុមសិល្បៈដែលស្នាក់នៅជាមួយ អ៊ីង ថា ពួកគេមិនបានចាប់ សោ ភឹម ទេ គឺ សោ ភឹម បានបាញ់សម្លាប់ខ្លួនឯង ។ ចំណែកកូនចៅរបស់ សោ ភឹម កងយោធារបស់ពួកគេមកពីនិរតី និងមកពីមជ្ឈិមកំពុងចាប់ចង ។ ពេលឮដូច្នេះ អ៊ីង បានទៅពួនអែបនឹងជញ្ជាំងថ្មបាក់បែក និងលបចាំស្តាប់ទៀត ។ បន្ទាប់ពីឮសំឡេងម៉ូតូកងយោធាមជ្ឈិមទាំងនោះចេញទៅអស់ អ៊ីង ក៏និយាយអង្វរករកងសិល្បៈដែលរត់មកជាមួយគាត់កុំឲ្យប្រាប់ពីប្រវត្តិរូបគាត់ បើមិនដូច្នេះទេគាត់ក៏នឹងត្រូវចាប់ខ្លួនដែរ ។ ចាប់តាំងពីពេលនោះមក អ៊ីង លែងទុកចិត្តក្រុមសិល្បៈទាំងអស់នោះរហូត ។

រយៈពេលបីថ្ងៃក្រោយមក អ៊ីង លួចរត់ចេញពីព្រែកពោធិ៍ ធ្វើដំណើរទៅរកាខ្ពប (ចម្ងាយប្រមាណ៥គីឡូពីក្រុងសួង) ជួបគាម្នាក់ដែលធ្វើការនៅក្រុមជាងដែលស្គាល់គាត់ រួចហើយក៏ពួនសម្ងំលាក់ខ្លួននៅផ្ទះរបស់គានោះតែម្តង ។ ចំណែកកងសិល្បៈដែលរត់ទៅដល់សួងតាមក្រោយគាត់ ត្រូវយោធាចាប់ខ្លួនទាំងអស់ រួចបណ្តើរកាត់តាមមុខផ្ទះដែល អ៊ីង លាក់ខ្លួនទៀត ។ ដោយឃើញការចាប់ខ្លួនកាន់តែច្រើន អ៊ីង ក៏សុំគានៅក្រុមជាងនោះត្រឡប់មកស្រុកកំណើតវិញ ដោយកុហកយោធា ដែលយាមនៅតាមផ្លូវថា គាត់មានជំងឺ ហើយទើបត្រឡប់មកពីព្យាបាលនៅមន្ទីរពេទ្យព-២ ។ អ៊ីង មកដល់ខាងជើងទីរួមខេត្តស្វាយរៀង ក៏ត្រូវយោធាខាងនិរតីចាប់យកទៅឃុំឃាំងនៅវត្តក្តីរំដួល (ស្ថិតនៅខាងលិចមន្ទីរស្រុករំដួល) ដោយចោទថា បក្ខពួកក្បត់របស់ សោ ភឹម ។ អ៊ីង នៅជាប់ឃុំរយៈពេលមួយខែ គឺរហូតដល់កងទ័ពវៀតណាមផ្លោងចូលមក ទើបគាត់រត់ត្រឡប់មកផ្ទះវិញ ។

**សោម ប៊ុនថន**

# ថ្នាក់រៀននៅទួលស្លែង

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតថ្នាក់រៀនសាធារណៈមួយនៅសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ។ ថ្នាក់រៀននេះត្រូវបានបង្កើតឡើងក្នុងខែវិច្ឆិកា ឆ្នាំ២០១១ ដោយមានកិច្ចសហការរវាងមជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ។ សារមន្ទីរទួលស្លែងគឺជាអតីតសាលារៀនដ៏ទំនើបមួយដែលបានសង់ឡើងជាលើកដំបូងនៅក្នុងឆ្នាំ១៩៦២ ។ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ខ្មែរក្រហមបានប្រែក្លាយសាលារៀននេះទៅជាគុកដ៏សម្ងាត់បំផុតមួយក្នុងចំណោមគុកចំនួន១៩៦ទូទាំងប្រទេស ។ អ្នកទោសភាគច្រើនដែលត្រូវបញ្ជូនទៅទួលស្លែង គឺជាកម្មាភិបាលខ្មែរក្រហមដែលត្រូវបានចោទប្រកាន់ពីបទប្រព្រឹត្តអំពើក្បត់ជាតិ ដូចជា ការសហការជាមួយរដ្ឋាភិបាលបរទេស ឬធ្វើជាអ្នកស៊ើបការណ៍ឲ្យសេ.អ៊ី.អា ឬ កា.ហ្សេ.បេ ជាដើម ។



ចាប់តាំងពីការប្រែក្លាយពីកន្លែងរៀនសូត្រមួយទៅជាកន្លែងដ៏គួរឲ្យរន្ធត់ និងមហន្តរាយមួយ ទួលស្លែងមិនដែលទទួលបានមុខងាររបស់ខ្លួនដូចកាលពីដើមវិញឡើយ ។ ទោះបីជាយ៉ាងនេះក្តី នៅពេលអនាគត ដើម្បីទាមទារមកវិញនូវកេរដំណែលអប់រំដែលមានលក្ខណៈវិជ្ជមានរបស់ទួលស្លែង និងដើម្បីបន្ថែមសមាសភាពអប់រំមួយទៅក្នុងសារមន្ទីរនេះ ថ្នាក់រៀននេះ ត្រូវបានបង្កើតឡើងដើម្បីផ្តល់ការបង្រៀន និងការពិភាក្សាដោយឥតគិតថ្លៃអំពីប្រវត្តិសាស្ត្ររបបខ្មែរក្រហម និងប្រធានបទដែលជាប់ទាក់ទង ដូចជា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ថ្នាក់រៀននេះ ក៏ជាវេទិកាសាធារណៈមួយសម្រាប់ឲ្យអ្នកមកទស្សនា និងអ្នកដែលនៅរស់រានមានជីវិតចែករំលែកព័ត៌មានគ្នាក្នុងការថែរក្សារយៈកាលនៃប្រវត្តិសាស្ត្រកម្ពុជាដ៏មានសារសំខាន់មួយទុកឲ្យអ្នកជំនាន់ក្រោយបានរៀនសូត្រ ។

បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ដែលមានសញ្ញាបត្រមកពីបរទេស និងបានទទួលវិញ្ញាបនបត្រពីក្រសួងអប់រំ យុវជន និងកីឡា ផ្នែកការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-៧៩) ព្រមទាំងមានការចូលរួមពីអ្នកជំនាញជាតិ និងអន្តរជាតិដែលមានជំនាញលើប្រវត្តិសាស្ត្រប្រទេសកម្ពុជា និងអ្នកដែលនៅរស់រានមានជីវិតពីមន្ទីរស-២១ នឹងបង្រៀននៅថ្នាក់រៀននេះ ។ ព័ត៌មានទាក់ទងនឹងថ្នាក់រៀននេះ សូមទាក់ទង ម៉ែន ពិចិត្រ តាមរយៈទូរស័ព្ទលេខៈ ០២៣ ២១១ ៨៧៥ ឬអ៊ីម៉ែលៈ truthpechet@dccam.org ។

**◆ ទីកន្លែង ៖ អគារ "ក" ជាន់លើ ◆ ពេលវេលា ៖ ច័ន្ទ ២-៣រសៀល, ពុធ ៩-១០ព្រឹក, សុក្រ ២-៣រសៀល**

# ការិយាល័យព័ត៌មានសាធារណៈ

"ការិយាល័យព័ត៌មានសាធារណៈ" របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូននិស្សិត អ្នកស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ចង់យល់ដឹងអំពីប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ និងព្រឹត្តិការណ៍វិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម ។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត ។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ ។ ប្រភេទឯកសារទីពីរគឺជាបទសម្ភាសដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសជាមួយជនរងគ្រោះនិងអតីតកម្មាភិបាលខ្មែរក្រហម ។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម ។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្ងាប់របស់ខ្មែរក្រហម និងឯកសារប្រភេទទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត ។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចអាននឹងស្រាវជ្រាវឯកសារទាំងនេះបាន ។ ឯកសារខ្លះទៀតរួមមាន ៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្ថនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍ ។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ ខាងកើតវិមានឯករាជ្យ ។ ការិយាល័យរបស់យើងបើកជូនសាធារណជនពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង៨ដល់ម៉ោង១២ និងពេលរសៀលពីម៉ោង២ដល់ម៉ោង៥ ។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង ជា ផល្លា តាមរយៈ ទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ឬអ៊ីម៉ែល *truthphalla.c@dccam.org* ។





















# ស្វែងយល់អំពីគេហទំព័រឃ្លាំមើលការវិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## www.cambodiatribunal.org

គេហទំព័រឃ្លាំមើលការវិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា www.cambodiatribunal.org គឺជាប្រភពឈានមុខគេនៃសារព័ត៌មានដំណឹងវិវឌ្ឍថ្មីៗ ព្រមទាំងបទអត្ថាធិប្បាយរបស់អ្នកជំនាញជាច្រើនទៅលើដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទាំងមូល ។ រយៈពេលកន្លងមកនេះព័ត៌មានយ៉ាងច្រើនត្រូវបានផ្សព្វផ្សាយ នៅលើគេហទំព័រនេះ ។ គេហទំព័រនេះបង្កលក្ខណៈងាយស្រួលបំផុតសម្រាប់សាធារណជនទាំងឡាយក្នុងការស្វែងយល់អំពីដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

សំណុំរឿងព្រហ្មទណ្ឌលេខ០០២ដែលទាក់ទិននឹងជនជាប់ចោទពីរនាក់ទៀតគឺ ខៀវ សំផន គណៈប្រធានរដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យ និង នួន ជា អនុលេខាបក្សនិងជាប្រធានរដ្ឋសភានៃរបបកម្ពុជាប្រជាធិបតេយ្យបានចាប់ផ្តើមបើកសវនាការកាលពីខែវិច្ឆិកា ឆ្នាំ២០១១ និងបានប្រកាសសាលក្រមលើកទីមួយកាលពីខែសីហា ឆ្នាំ២០១៤ ។

ដើម្បីជួយកាត់បន្ថយចំនួនអ្នកខកខានមិនបានតាមដានដំណើរការដោយផ្ទាល់ឲ្យមកនៅត្រឹមកម្រិតតូចមួយ គេហទំព័រឃ្លាំមើលការវិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា www.cambodiatribunal.org ត្រូវបានបង្កើតដោយមានផ្នែកជាច្រើនទាក់ទិននឹងរបាយការណ៍ប្រចាំថ្ងៃអំពីសវនាការ វីដេអូសវនាការទាំងមូលនិងយោបល់ផ្សេងៗរបស់ជនរងគ្រោះទាក់ទងនឹងសវនាការ សារព័ត៌មានផ្សេងៗជុំវិញតុលាការ របាយការណ៍របស់តុលាការ និងអង្គការក្រៅរដ្ឋាភិបាល ដំណើរការនីតិវិធីផ្សេងៗនៃអង្គជំនុំជម្រះ ប្រវត្តិសាស្ត្រ ប្រវត្តិរបស់តុលាការនេះ និងបទអត្ថាធិប្បាយរបស់អ្នកជំនាញ ។

គេហទំព័រនេះនឹងជួយបង្កលក្ខណៈងាយស្រួលគ្រប់គ្រាន់សម្រាប់និស្សិតគ្រប់គ្រឹះស្ថានសិក្សាដែលមានបំណងចង់សិក្សាស្វែងយល់អំពីដំណើរនីតិវិធីអង្គជំនុំជម្រះវិសាមញ្ញដែលជាដំណើរការមានលក្ខណៈចម្រុះជាតិ និងអន្តរជាតិ ។ ឧទាហរណ៍ ការយកទ្រឹស្តីច្បាប់មួយដែលមានលក្ខណៈស្មុគស្មាញ និងចម្រូងចម្រាសមកអនុវត្តដោយអង្គជំនុំជម្រះវិសាមញ្ញគឺទ្រឹស្តី "សហកម្មខក្រិដ្ឋកម្មរួម" ដែលភាសាអង់គ្លេសហៅថា "*Join Criminal Enterprise*" ដែលតាមរយៈទ្រឹស្តីនេះ ជនសង្ស័យអាចត្រូវបានដាក់ឲ្យទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះបទឧក្រិដ្ឋទាំងឡាយដែលប្រព្រឹត្តឡើងទៅតាម "ផែនការឧក្រិដ្ឋកម្មរួម" ដែលភាសាអង់គ្លេសហៅថា "*Common Criminal Plan*" ។ ដូច្នេះ យើងអាចចូលទៅរកដំណើរការនីតិវិធីផ្សេងៗនៃអង្គជំនុំជម្រះឬបទអត្ថាធិប្បាយរបស់អ្នកជំនាញដើម្បីស្វែងយល់ថាតើចៅក្រមបានសម្រេចយ៉ាងដូចម្តេចចំពោះការដែលយកទ្រឹស្តីនេះមកអនុវត្តនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ តើមានភាគីផ្សេងទៀតដែរឬទេដែលមានយោបល់ទៅលើបញ្ហានេះ?

ប្រសិនបើមិនចង់ចំណាយពេលវេលាច្រើនដើម្បីមើលវីដេអូសវនាការដែលប្រព្រឹត្តឡើងពេញមួយថ្ងៃដែលអាចចំណាយពេលពី៦ទៅ៨ម៉ោងនោះ សាធារណជនអាចចូលទៅក្នុងផ្នែករបាយការណ៍ប្រចាំថ្ងៃអំពីសវនាការ ។ ក្នុងផ្នែកនេះ យើងមានអ្នកឃ្លាំមើលសវនាការម្នាក់ដែលត្រូវបានបញ្ជូនឲ្យទៅអង្គុយនៅក្នុងបន្ទប់សវនាការផ្ទាល់ បន្ទាប់មកអ្នកឃ្លាំមើលនេះសរសេររបាយការណ៍ខ្លីមួយដែលរៀបរាប់អំពីខ្លឹមសារសំខាន់ៗទាំងឡាយទាក់ទិននឹងសវនាការពេញមួយថ្ងៃនោះតែម្តង ។ របាយការណ៍បែបនេះមានជាភាសាខ្មែរដែរ ។

**វ៉ាន់ថាន់ ពៅដារ៉ា**

# ចាប់ពីរបបខ្មែរក្រហម ដល់ឧប្បត្តិហេតុ ហាំបាលី៖ អត្តសញ្ញាណជនជាតិចាម នៅក្នុងយុគសម័យសកលភាវូបនីយកម្ម

***(តពីលេខមុន)***

*សំណួរបន្តទៅទៀតនេះគឺថា តើសាសនាអ៊ីស្លាមត្រូវបាន ខ្មែរក្រហមចាត់ថាជាសាសនាប្រតិកិរិយាដែរឬទេ? ម៉ាត់ លី គឺជា អតីតសមាជិកសភាប្រជាជននៃកម្ពុជាប្រជាធិបតេយ្យ និងជា អតីតសមាជិកអចិន្ត្រៃយ៍នៃគណកម្មការស្រុកត្បូងឃ្មុំនៅក្រោមការ គ្រប់គ្រងរបស់ខ្មែរក្រហម បានបង្ហាញថា នៅថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៧៥ (ប្រាំពីរខែមុនពេលដែលរដ្ឋធម្មនុញ្ញត្រូវបានអនុម័តិ) ប៉ុល ពត បានដឹកនាំសន្និសីទប្រជុំនៅទីក្រុងភ្នំពេញ ដើម្បីដាក់ចេញ ផែនការប្រាំបីចំណុច «១) ការបង្កើតសហករណ៍ពីថ្នាក់ក្រោមទៅ ថ្នាក់លើ ២) ការជម្លៀសប្រជាជនចេញពីទីក្រុងទៅតាមជនបទ និង ការបែងចែកប្រជាជនជាបីក្រុម ៣) ការបញ្ឈប់ការប្រើប្រាស់ រូបិយប័ណ្ណ ៤) ការបិទទីផ្សារ ៥) ការលុបបំបាត់សាសនាប្រតិ កិរិយាទាំងអស់ ៦) ការលុបបំបាត់សាលារៀន ៧) ការលុបបំបាត់ មន្ទីរពេទ្យ ៨) ការបោសសម្អាតសត្រូវផ្ទៃក្នុងដោយដឹកទាំងឫស» ។ សេចក្តីសម្រេចទាំងអស់របស់ ប៉ុល ពត បានបញ្ជាក់យ៉ាងច្បាស់ពី គោលបំណងរបស់ខ្មែរក្រហម ។ ទោះបីជាគ្មានភ័ស្តុតាងអ្វីមក បញ្ជាក់ពីចំណុចទាំងនេះក៏ដោយ ក៏ចំណុចទី៥ គួរឲ្យចាប់អារម្មណ៍ ចំណុចនេះ ហាក់ដូចជាជាប់ទាក់ទងយ៉ាងខ្លាំងទៅនឹងមាត្រាទី២០ ផ្នែក១៥ នៃរដ្ឋធម្មនុញ្ញដែលអនុម័តិនៅពេលក្រោយ នៅក្នុងឆ្នាំ ដដែលនោះ ។ នៅក្នុងរដ្ឋធម្មនុញ្ញនោះ ខ្មែរក្រហមបានសម្រេចថា រាល់សាសនាទាំងអស់ គឺជាសាសនាប្រតិកិរិយា ។ ដោយសារតែ ពាក្យប្រតិកិរិយាត្រូវបានភ្ជាប់ទៅនឹងកម្លាំងចលករសង្គម និងជា សត្រូវដែលខ្មែរក្រហមស្អប់បំផុត សាសនាអ៊ីស្លាមគឺត្រូវបានចាត់ ទុកថាមានគ្រោះថ្នាក់ និងធ្លប់តាំងតែពីដំបូង ។ សាសនា អ៊ីស្លាម ត្រូវបានបំផ្លិចបំផ្លាញចោលគ្មានសល់ ។ តាមពិតទៅការដាក់គំនាប ទៅលើសាសនាអ៊ីស្លាមកើតមាននៅភូមិចាម តាំងពីឆ្នាំ១៩៧៣ មកម្ល៉េះ ។*

## ***៣) ការមកដល់របស់ក្រុមកុម្មុយនីស្តនៅតាមភូមិចាមនានា***

*មានករណីជាច្រើនដែលថា ខ្មែរក្រហមបានកាន់កាប់ភូមិចាមជាច្រើន នៅជុំវិញប្រទេសកម្ពុជានៅឆ្នាំ១៩៧០ ដោយពឹងផ្អែកតំបន់ទាំងនោះ នៅពេលប្រយុទ្ធជាមួយទាហាន លន់ នល់ ពាសពេញផ្ទៃប្រទេស និងភូមិចាមជាច្រើនស្ថិតនៅទីប្រជុំជនសំខាន់ ឧទាហរណ៍ដូចជា នៅឳរ៉ូមខេត្តគឺស្ថិតនៅក្រោមការកាន់កាប់របស់ លន់ នល់ រហូតដល់ ឆ្នាំ១៩៧៥ ។ មានតំបន់ខ្លះត្រូវបានខ្មែរក្រហម កាន់កាប់ដោយ ប្រយោល តាំងពីមុនឆ្នាំ១៩៧០មកម្ល៉េះ ។ តំបន់ទាំងនោះរួមមាន*




*យុវនារីជនជាតិចាម ចូលរួមជាមួយបដិវត្តន៍ខ្មែរក្រហម*

ផ្នែកខ្លះនៃខេត្តកំពង់ចាម តាកែវ និងខេត្តកណ្តាល ។ ភូមិភាគឦសានត្រូវបានក្លាយជាតំបន់កាន់កាប់ដ៏រឹងមាំរបស់ខ្មែរក្រហម តាំងពីឆ្នាំ១៩៦៦ នៅពេលដែល ប៉ុល ពត បានប្តូរទីស្នាក់ការកណ្តាលរបស់ខ្លួនទៅកាន់ខេត្តរតនគិរី និងបន្ទាប់ពី ប៉ុល ពត បានកាន់កាប់បក្សកុម្មុយនីស្តកម្ពុជា ។ ខេត្តស្ទឹងត្រែង មណ្ឌលគិរី និងខេត្តក្រចេះ គឺជាខេត្តបីដែលស្ថិតនៅក្រោមការកាន់កាប់របស់ខ្មែរក្រហម មុនខេត្តដទៃផ្សេងទៀត ។ មានន័យថាតំបន់ជាច្រើនរបស់ជនជាតិអ៊ីស្លាមដែលស្ថិតនៅក្នុងខេត្តទាំងនេះ ក៏ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហមដែរ ។

ភូមិភាគឧត្តរដែលកាន់កាប់ដោយខ្មែរក្រហមបានក្លាយជាភូមិភាគកណ្តាលនៅឆ្នាំ១៩៧៧ ។ ភូមិចាមជាច្រើនបានធ្លាក់ក្នុងការកាន់កាប់របស់ខ្មែរក្រហមមុនគេផងដែរ ។ ឧទាហរណ៍ដូចជាភូមិចាមនៅចម្ការអណ្តូង (ចម្ការលើ) ត្រូវបានកាន់កាប់ដោយខ្មែរក្រហមនៅឆ្នាំ១៩៧០ ។ របាយប្រជាជនចាមដែលមានចំនួនច្រើនជាងគេនៅក្នុងភូមិភាគនេះ មានដូចជា ស្រុកបារាយណ៍ ខេត្តកំពង់ធំ ស្រុកស្ទឹងត្រង់ និងស្រុកចំការលើ ខេត្តកំពង់ចាម ។ ភូមិចាមតូចៗស្ថិតនៅពាសពេញភូមិភាគនេះ ។ មុនឆ្នាំ១៩៧៥ ភូមិភាគនេះ គឺជាភូមិភាគដែលមានចំនួនប្រជាជនចាមច្រើនជាងគេនៅប្រទេសកម្ពុជា ។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ មានជនជាតិចាមជាច្រើនមកពីភូមិភាគបូព៌ា ជាពិសេស មកពីស្រុកក្រូចឆ្មារ និងស្រុកត្បូងឃ្មុំ ត្រូវបានបញ្ជូនឆ្លងកាត់ទន្លេមេគង្គមកកាន់ភូមិភាគនេះ ។ ដោយសារតែភូមិភាគនេះស្ថិតនៅចន្លោះខេត្តកំពង់ចាម ទៅភាគខាងកើតទន្លេមេគង្គ និងខេត្តកំពង់ធំ ទៅភាគខាងលិច ភូមិចាមនានា នៅទីនេះបានធ្លាក់ក្នុងការកាន់កាប់របស់ខ្មែរក្រហម ស្រុកក្រូចឆ្មារ ឬតំបន់ខាងកើតទន្លេមេគង្គ ។ ភូមិចាមមួយចំនួនផ្សេងទៀតបានស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម តាំងពីមុនឆ្នាំ១៩៧៣ទៅទៀត ជាពិសេសគឺតំបន់ដែលស្ថិតនៅក្នុងស្រុកបារាយណ៍ ខេត្តកំពង់ធំ ។

បើតាម ឈិត ឈឿន ហៅ តាម៉ុក នៅភូមិភាគនីរតី ការគ្រប់គ្រងភូមិចាមរបស់ខ្មែរក្រហម គឺខុសប្លែកគ្នាអាស្រ័យលើទីតាំងដែលភ្ជាប់ទៅនឹងទីក្រុងធំៗ ដូចជាភ្នំពេញ តាខ្មៅ តាកែវ កំពត និងកំពង់ស្ពឺ ។

ភូមិភាគនិរតី គឺលាតសន្ធឹងពីទន្លេបាសាក់ទៅកាន់ផ្លូវជាតិលេខ៤ ។ ភូមិភាគនេះរួមមានខេត្តកំពតទាំងមូល និងខេត្តតាកែវ ស្រុកសំរោងទង និងស្រុកកងពិសី (ឬក៏ច្រើនជាងនេះ) ផ្នែកជាច្រើននៃខេត្តកំពង់ស្ពឺ និងស្រុកចំនួនប្រាំនៅភាគខាងលិចនៃខេត្តកណ្តាល ដែលស្ថិតនៅខាងកើតនៃទន្លេបាសាក់ រួមមាន ស្រុកកណ្តាលស្ទឹង កោះធំ កៀនស្វាយ និងលើកដែក ។ ចំនួនប្រជាជនចាមនៅក្នុងភូមិភាគនេះ ត្រូវបានពង្រាយពាសពេញស្រុកជាច្រើន ។ ខេត្តកំពង់ស្ពឺមានចំនួនប្រជាជនចាមតិចតួចណាស់ ចំណែកឯស្រុកកំពត នៃខេត្តកំពតវិញ មានចំនួនប្រជាជនមូស្លីមច្រើនជាងគេ ពោលគឺស្ថិតនៅលំដាប់ទីប្រាំក្នុងប្រទេសកម្ពុជា ។ ប៉ុន្តែ ៧០ភាគរយនៃប្រជាជនទាំងនោះគឺជាក្រុមជនជាតិជ្វា ។ ស្រុកកំពង់បាយ ខេត្តកំពត ក៏មានចំនួនប្រជាជនចាម ឬជ្វាជាច្រើនគួរសមដែរ ។ ស្រុកនេះធ្លាក់ក្នុងការគ្រប់គ្រងរបស់ខ្មែរក្រហមនៅចន្លោះឆ្នាំ១៩៧០ដល់ ៧៣ ។

ខេត្តកណ្តាលមានរបាយប្រជាជនចាមមិនស្មើគ្នាទេ ដូចជាស្រុកកោះធំ មានចំនួនប្រជាជនចាមច្រើនជាងគេ និងស្រុកពញាឮ មានចំនួនប្រជាជនច្រើនលំដាប់ទី២នៅក្នុងខេត្តនេះ ។ បន្ទាប់មកគឺស្រុកមុខកំពូល និងស្រុកស្អាង ។ គ្រាន់តែនៅក្នុងស្រុកពញាឮមួយមានជនជាតិជ្វាមូស្លីម រហូតដល់ចំនួន៨០ភាគរយ ។ ខេត្តតាកែវគឺជាខេត្តមួយដែលសំបូរជនជាតិជ្វា ដែលមានរហូតដល់៧០ភាគរយ ។ ប៉ុន្តែខេត្តតាកែវទាំងមូល មានរបាយប្រជាជនចាមជ្វាតិចតួច បើប្រៀបធៀបនឹងខេត្តផ្សេងៗ ។ នៅជិតទីប្រជុំជនតាខ្មៅ ខ្មែរក្រហមបានគ្រប់គ្រងស្រុកកោះធំរហូតដល់ឆ្នាំ១៩៧២ ។ នៅស្រុកកោះធំមានភូមិចាមពីរក្នុងស្រុកនេះគឺ ភូមិចាមលើ និងភូមិចាមក្រោម ។ ភូមិចាមទាំងពីរនេះគឺស្ថិតក្រោមការកាន់កាប់របស់ខ្មែរក្រហមនៅឆ្នាំ១៩៧២ ។ នៅខេត្តតាកែវ ការគ្រប់គ្រងរបស់ខ្មែរក្រហមទៅលើជនជាតិចាមមិនទាន់មានទេរហូតដល់ឆ្នាំ១៩៧២ ឬ ១៩៧៣ ។

នៅភូមិភាគបស្ចិមដែលស្ថិតក្រោមការកាន់កាប់របស់ ជូ ជេត មានភូមិចាមមួយចំនួន ។ នៅភូមិភាគនេះមានខេត្តដូចជាខេត្តកោះកុង និងកំពង់ឆ្នាំង និងភាគខ្លះនៃខេត្តកំពង់ស្ពឺខាងលិចផ្លូវជាតិលេខ៤ ។ ប្រជាជនចាមជាច្រើននៅក្នុងខេត្តកោះកុងសព្វថ្ងៃគឺជាជនចំណូលថ្មីភាគច្រើនមកពីខេត្តកំពង់ចាម ដែលផ្លាស់ទៅទីនោះដោយសាមូលហេតុសេដ្ឋកិច្ច ។ ក៏ប៉ុន្តែ នៅខេត្តកោះកុង ក៏មានភូមិ

ចាមជ្វាចាស់ៗ ត្រូវបានកសាងជាយូរយារមកហើយដែរ ពោលគឺ តាំងពីមុនសម័យខ្មែរក្រហមមកម្ល៉េះ ។ របាយប្រជាជនចាម ជ្វា ដែលមានចំនួនច្រើនជាងគេគឺនៅស្រុកស្មាច់មានជ័យ ខេត្តកោះកុង ។ ភាគខ្លះនៃខេត្តកំពង់ស្ពឺដែលជាផ្នែកមួយនៃភូមិភាគនេះមិនមានជនជាតិចាមរស់នៅទេ ។ ចំណែកឯខេត្តកកំពង់ឆ្នាំងមានចំនួនប្រជាជនចាមរស់នៅច្រើនគួរឲ្យកត់សម្គាល់ ដែលរស់នៅស្រុកកំពង់ត្រឡាច ជាស្រុកដែលមានចំនួនប្រជាជនចាមច្រើនជាងគេ លំដាប់ទី៣នៅប្រទេសកម្ពុជា ។ ស្រុកនេះរួមបញ្ចូលទាំងសមាជិកនៃក្រុមអ៊ីមាំសាន់ផងដែរ ។ នៅខេត្តកំពង់ឆ្នាំង មានស្រុកចំនួនបីផ្សេងទៀត ដែលមានប្រជាជនចាមរស់នៅច្រើន ដូចជាស្រុកសាមគ្គីមានជ័យ រលាប្អៀរ និងទឹកផុស ។ ស្រុកទាំងបីនេះត្រូវបានខ្មែរក្រហមគ្រប់គ្រងនៅឆ្នាំ១៩៧០ ។ ស្រុកស្មាច់មានជ័យស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហមនៅឆ្នាំ១៩៧៣ ។

ភូមិភាគពាយ័ព្យ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម ក្រោយពេលដែលខ្មែរក្រហមកាន់កាប់ខេត្តផ្សេងៗ ហើយភូមិភាគនេះគ្របដណ្តប់ទៅលើខេត្តពោធិ៍សាត់ និងខេត្តបាត់ដំបង ។ សហគមន៍ជនជាតិចាមសំខាន់ៗ នៅក្នុងតំបន់នេះមានទីតាំងស្ថិតនៅតាមបណ្តោយផ្លូវជាតិលេខ៥ ដែលរួមមានស្រុកក្រគរ និងស្រុកកណ្តៀង នៃខេត្តពោធិ៍សាត់ ព្រមទាំងស្រុកមោងឫស្សី ស្រុកសង្កែ និងស្រុកបាត់ដំបងនៃខេត្តបាត់ដំបង ។ ស្រុកទាំងនេះ បានធ្លាក់ក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម នៅក្រោយឆ្នាំ១៩៧៣ ។

ភូមិភាគបូព៌ា មានចំនួនប្រជាជនចាមច្រើនជាងគេនៅក្នុងប្រទេសកម្ពុជា ។ ភូមិភាគនេះរួមមាន ខេត្តព្រៃវែង និងខេត្តស្វាយរៀងទាំងមូល តំបន់នានានៃខេត្តកំពង់ចាម ដែលស្ថិតនៅខាងកើតទន្លេមេគង្គ ស្រុកឆ្លូង នៃខេត្តក្រចេះ និង ស្រុកចំនួនបីផ្សេងទៀតក្នុងខេត្តកណ្តាល ដូចជា ស្រុកខ្សាច់កណ្តាល ល្វាអែម និងស្រុកមុខកំពូល ។ ស្រុកដែលមានចំនួនប្រជាជនចាមច្រើនជាងគេមួយចំនួន គឺស្ថិតនៅក្នុងភូមិភាគនេះ រួមមាន ស្រុកត្បូងឃ្មុំ ក្រូចឆ្មារ តំបែរ ស្ទឹងត្រង់ ពញាក្រែក និងស្រុកមេមត់ ។ ខ្មែរក្រហមបានគ្រប់គ្រងតំបន់ជាច្រើនក្នុងខេត្តកំពង់ចាមដែលស្ថិតនៅខាងកើតទន្លេមេគង្គនៅឆ្នាំ១៩៧០ ឬក៏មុននេះទៅទៀត ។ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម បាននិយាយពីកន្លែងលាក់ខ្លួនរបស់ខ្មែរក្រហមមានឈ្មោះថា “ព្រៃនុយ” ដែលស្ថិតនៅព្រំប្រទល់នៃស្រុកក្រូចឆ្មារ និងស្រុកត្បូងឃ្មុំ ។ នៅឆ្នាំ១៩៧០ ពួកគេជារឿយៗតែងធ្វើដំណើរទៅកាន់ទីតាំងនោះដើម្បីចូលរួមក្នុងការធ្វើសង្គ្រាមរបស់ខ្មែរក្រហម ។ បន្តិចម្តងៗ ខ្មែរក្រហមបានចាប់ផ្តើមផ្លាស់ចេញពីតំបន់នេះ ដោយសារតែការវិវត្តនៃសង្គ្រាម ។

ខ្មែរក្រហមបានចាប់ផ្តើមគ្រប់គ្រងភូមិចាមនានានៅក្នុងខេត្តព្រៃវែងក្នុងឆ្នាំ១៩៧១ ។ ខេត្តនេះ មានភូមិចាមចំនួនបួន គឺ មេសប្រចាន់ កំពង់ប្រាង ស្ទឹងស្លូតវាមី និងខ្មែរអ៊ីស្លាម ។ ភូមិទាំងនេះស្ថិតនៅជិតព្រំដែនវៀតណាម និងស្រុកសំខាន់ពីរទៀតនៃខេត្តព្រៃវែង រួមមាន ស្រុកពារាំង និងកំពង់ត្របែក ។ នៅក្នុងខេត្តស្វាយរៀង ខ្មែរក្រហមបានកាន់កាប់ភូមិចាមនោះបានភ្លាមដែលបន្ទាប់ពីរដ្ឋប្រហាររបស់ លន់ នល់ នៅខែមីនា ឆ្នាំ១៩៧០ ។ ភូមិនេះហៅថា ភូមិតាកែវ ។

## ទង្វើរបស់ខ្មែរក្រហមមកលើជនជាតិចាមនៅពេលដំបូង

ការប្រព្រឹត្តរបស់ខ្មែរក្រហមទៅលើជនជាតិចាមដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហមមានភាពខុសប្លែកគ្នាទៅតាមតំបន់ ។ ជាទូទៅនៅមុនឆ្នាំ១៩៧៥ ការសម្លាប់នៅមានចំនួនតិចជាងនៅអំឡុងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ។ ជាពិសេស ការសម្លាប់កើតមានឡើងច្រើនបំផុត នៅអំឡុងឆ្នាំ១៩៧៧-៧៨ នៅពេលដែលមានការធ្វើបន្សុទ្ធកម្ម ។ នៅស្រុកក្រូចឆ្មារមានការតវ៉ាប្រឆាំង និងការប្រយុទ្ធតបខ្មែរក្រហមវិញ យ៉ាងហោចណាស់បីដងដែលប្រឆាំងនឹងការប្រព្រឹត្តដ៏ឃោរឃៅផ្តាច់ការ ។ ក្រោយមកឈានទៅរកការអនុវត្តអំពើឃោរឃៅ និងផ្តាច់ការនៅតំបន់ផ្សេងទៀតនៃភូមិភាគបូព៌ាភូមិភាគមជ្ឈិម និងប្រហែលទូទាំងប្រទេស ។

នៅឆ្នាំ១៩៧០ ក្នុងស្រុកក្រូចឆ្មារ ខ្មែរក្រហមបានបង្កើតគណៈកម្មការដឹកនាំស្រុក និងបានតែងតាំងជនជាតិចាមម្នាក់ឈ្មោះ គាយោគ ដើម្បីចាត់ចែងកិច្ចការនានារបស់មូស្លីម ។ ក្នុងឆ្នាំដដែលនេះដែរ ខ្មែរក្រហមបានតែងតាំងចាមម្នាក់ទៀតឈ្មោះ សុះ ម៉ាន់ ដើម្បីចាត់ចែងកិច្ចការផ្សេងៗរបស់ជនជាតិចាមនៅក្នុងភូមិភាគបូព៌ា ។ ការតែងតាំងតំណែងគឺស្របទៅតាមចំនួនប្រជាជនចាមនៅក្នុងភូមិភាគនេះ ។ សុះ ម៉ាន់ ជាឪពុករបស់ ម៉ាត់ លី ដែលបានក្លាយជាមេដឹកនាំមូស្លីមជាន់ខ្ពស់មួយរូបនៅទសវត្សរ៍ឆ្នាំ១៩៨០

និងឆ្នាំ១៩៩០ ។ សុះ ម៉ាន់ ធ្លាប់ធ្វើជាទាហានកុម្មុយនីស្តម្នាក់ដែលជាផ្នែកមួយនៃខ្មែរឥស្សរៈ ចាប់តាំងពីទសវត្សរ៍ឆ្នាំ១៩៥០ ។ នៅក្នុងឆ្នាំ១៩៧០ គាត់បានប្រចាំការនៅក្នុងភូមិអំពិល ឃុំប៊ឹស ស្រុកក្រូចឆ្មារ ។ សុះ ម៉ាន់ ដែលអ្នកភូមិស្គាល់ថា (តាម៉ាន់) ត្រូវបានតែងតាំងជា ហាជី អីទ្រេស (Haji Itres) ដែលជាជំនួយការផ្ទាល់ខ្លួនរបស់គាត់ក្នុងកិច្ចការគ្រប់គ្រងមូស្លីម ។ សុះ ម៉ាន់ ក៏បានតែងតាំង ហាគីម លី ដើម្បីគ្រប់គ្រងចាមនៅស្រុកឆ្លូង ដែលជាតំបន់ដែលមានចំនួនប្រជាជនចាមច្រើនជាងគេមួយក្នុងប្រទេស ។ ទាំង សុះ ម៉ាន់ និង ហាគីម លី ទទួលបានការគោរពយ៉ាងខ្លាំងពីសំណាក់អ្នកភូមិ ។ ពួកគេបានសាងកេរ្តិ៍ឈ្មោះជាមេដឹកនាំសាសនា និងនយោបាយយ៉ាងសមរម្យនៃសហគមន៍ចាប់តាំងពីទសវត្សរ៍ឆ្នាំ១៩៥០ និង១៩៦០មកម្ល៉េះ ។

ដោយយល់ឃើញថា ក្រុមកុម្មុយនីស្តគោរពសាសនាអ៊ីស្លាម សុះ ម៉ាន់ ក៏បានសំណូមពរទៅថ្នាក់ដឹកនាំខ្មែរក្រហមថា ការដឹកនាំសាសនាអ៊ីស្លាមគួរត្រូវបានបង្កើតឡើងដើម្បីគ្រប់គ្រងកិច្ចការអ៊ីស្លាមនៅទូទាំងតំបន់រំដោះ ដែលមានមុខងារដូចគ្នាទៅនឹងស្ថាប័នរបស់លន់ នល់ ដែលបានបន្សល់ទុកពីសម័យសង្គមរាស្ត្រនិយមរបស់សម្តេច ព្រះនរោត្តម សីហនុ ដែលបានបង្កើតក្រុមប្រឹក្សាជាន់ខ្ពស់សម្រាប់កិច្ចការងារអ៊ីស្លាម ដែលដឹកនាំដោយ គ្រេនមូហ្វទី រេសឡោះ (Grand Mufti Res Loh) ។ សុះ ម៉ាន់ បានផ្តល់ជាយោបល់ដោយស្នើថា មហាម៉ាត់ កាឈី (Mohammad Kachi) គឺជាបុគ្គលសក្តិសម ។ កាឈី គឺជាគ្រូសាសនាជាយូរមកហើយ និង មានប្រជាជនគោរពជាច្រើននៅក្នុងភូមិជំនីក ។

លើសពីនេះទៅទៀត មេដឹកនាំផ្នែករដ្ឋបាលនៅតាមភូមិនានាដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហមបានរក្សានៅដដែលដូចដែលធ្លាប់ស្ថិតក្រោមការគ្រប់គ្រងរបស់សម្តេចសីហនុ ។



ជនជាតិចាមមកទស្សនកិច្ចទីតាំងធ្វើទារុណកម្ម និងសម្លាប់មនុស្ស អតីតមន្ទីរសន្តិសុខស-២១ ឬគុកទួលស្លែង ដែលចំណោមជនរងគ្រោះទាំងនោះក៏មានជនជាតិដែរ

ភូមិនីមួយៗ មានអ្នកដឹកនាំសាសនាម្នាក់ ហាគីម *(Hakem)* ដែលរក្សាការប្រារព្ធពិធីផ្នែកសាសនាឲ្យបាន សមស្របទៅនឹងការរៀបចំពិធីបុណ្យ និងជំនឿផ្សេងៗ ដោយដើរតួរជាអាជ្ញាកណ្តាល និងជាអ្នកដែលផ្តល់យោបល់ដល់អ្នកផង នៅពេលមានរឿងរ៉ាវទាក់ទងសាសនានៅក្នុងភូមិ ។ ហាគីម ក៏បានរៀបចំរចនាសម្ព័ន្ធដឹកនាំភូមិជាក្រុមតូចៗ ដែលមានចំនួនគ្រួសារពី២០ ទៅ៣០ ដែលហៅថា ជុំអះ *(Chumah)* និងមានអ្នកដឹកនាំហៅថា មេជុំអះ *(me chum ah)* នៅក្នុងភូមិមួយមាន ទួន *(Tuons)* ជាច្រើនដែលទទួលខុសត្រូវក្នុងការបង្រៀនច្បាប់នានារបស់អ៊ីស្លាមទៅកាន់ក្មេងៗ នៅក្នុងភូមិ ។ រាល់រចនាសម្ព័ន្ធរៀបចំរបស់មូស្លីមទាំងអស់នេះរួមទាំងរចនាសម្ព័ន្ធនយោបាយរបស់ សុះ ម៉ាន់ ដើម្បីគ្រប់គ្រងកិច្ចការងាររបស់មូស្លីមត្រូវបានរំលាយចោលនៅត្រឹមឆ្នាំ១៩៧៣ ។ សុះ ម៉ាន់ ត្រូវបានឃុំឃាំងនៅក្នុងផ្ទះ និងសម្លាប់ (មានមនុស្សមួយចំនួនបាននិយាយថាគាត់ធ្វើអត្តឃាត) នៅឆ្នាំ១៩៧៤ ។

កាលពីដំបូង ជនជាតិចាមបានគាំទ្រខ្មែរក្រហមអស់ពីចិត្តក្នុងការវាយប្រឆាំងនឹង លន់ នល់ និងចង់ឲ្យសម្តេច សីហនុ យាងត្រឡប់មកស្រុកវិញ ។ កូនចៅរបស់ពួកគេស្ម័គ្រចិត្តចូលរួមជួយចលនាខ្មែរក្រហមកាលពីដំណាក់កាលដំបូងនៃរណសិរ្សបង្រួបបង្រួមជាតិ ។ ជនជាតិចាមបានចូលរួមក្នុងកិច្ចការផ្សេងៗជាច្រើននៅក្នុងកងនានារួមទាំង កងឈ្លប កងទ័ព អ្នកនាំសារ អ្នកបើកបរឡាន និងមេដឹកនាំជាដើម ។ កូនទាហានចាមទាំងនេះត្រូវបានបញ្ជូនឲ្យទៅជួយដោះស្រាយបញ្ហានានារបស់ចាមជួយអ្នកភូមិ ធ្វើស្រែចម្ការ នេសាទត្រី និងធ្វើកិច្ចការប្រចាំថ្ងៃផ្សេងៗ ។ អ្នកភូមិចាមម្នាក់បានឲ្យដឹងថា "នៅឆ្នាំ១៩៧១ ទាហានរណសិរ្សបានមកជួយខ្ញុំរែកទឹកដាក់ពាង និងជួយប្រូតកាត់ ។ ទាហានទាំងនោះបានរៀបចុកពារសមរម្យ និងហៅខ្ញុំថាពុក" ។ ជនជាតិចាមម្នាក់ទៀតបាននិយាយប្រាប់ថា "ខ្មែរក្រហមគឺជាមនុស្សល្អពីដំបូង ។ ខ្មែរក្រហមបានបែងចែកសម្លៀកបំពាក់ទៅអ្នកក្រីក្រ" ។

ទាំងនេះជាឧទាហរណ៍ច្រើនដែលបានបង្ហាញពីភាពមិនគិតពីប្រយោជន៍ផ្ទាល់ខ្លួន និងឧត្តមគតិរបស់កុម្មុយនីស្ត ដែលក្មេងគោរពចាស់ ប្រជាជនជួយគ្នាទៅវិញទៅមក ហើយគិតពីប្រយោជន៍សហគមន៍ច្រើនជាងប្រយោជន៍ផ្ទាល់ខ្លួន ។ គំនិតនេះស្របគ្នានឹងទស្សនៈចែករំលែក និងទស្សនៈសណ្តាប់ធ្នាប់ក្នុងសង្គមចាម ដែលជាសង្គមគោរពតាមអាយុ ។ ខ្មែរក្រហមទទួលបានការចូលចិត្តជាច្រើនពីចាម ។ ប៉ុន្តែ ឧត្តមគតិនេះមិនស្ថិតនៅជាប់ជាមួយចរិតលក្ខណៈរបស់ខ្មែរក្រហមយូរនោះទេ ។ សាសនាអ៊ីស្លាមត្រូវបានអនុញ្ញាតត្រឹមឆ្នាំ១៩៧៣ តែប៉ុណ្ណោះ ។

ដូចដែលបានរៀបរាប់ខាងដើមខ្មែរក្រហមបានគ្រប់គ្រងទឹកដីស្ទើរតែ៩០ភាគរយនៃប្រទេសកម្ពុជានៅឆ្នាំ១៩៧៣ ។ យើងអាចសន្និដ្ឋានបានថា ខ្មែរក្រហមមិនត្រូវការការគាំទ្រពីជនជាតិចាមទៀតនោះទេ ។ ដូច្នេះហើយ ទើបខ្មែរក្រហមបានប្រែជាមកអនុវត្តផែនការកម្ទាត់ចោលមេដឹកនាំចាមធំៗ នៅក្នុងសង្គមចាម និងធ្វើការឃោសនាប្រឆាំងនឹងសាសនាអ៊ីស្លាមទៅវិញ ។ នៅឆ្នាំ១៩៧៣ នៅស្រុកក្រូចឆ្មារ ខ្មែរក្រហមបានកោះហៅសមាជិកគណៈកម្មការ ហាគីម (ដែលរួមមាន ហាគីម និងជំនួយការប្អូនរូប) នៅក្នុងភូមិនានា មកបណ្តុះបណ្តាលវគ្គនយោបាយរយៈពេល៤០ថ្ងៃនៅឃុំរកាខ្ពស់ ។ យើងមិនដឹងពីចំនួនរបស់ហាគីម ដែលត្រូវបានខ្មែរក្រហមកោះហៅមកប្រជុំនោះទេ ។ ប៉ុន្តែ បីខែក្រោយមកសមាជិកជាច្រើននៃគណៈកម្មការហាគីម ត្រូវបានចាប់ខ្លួន ។

ខ្មែរក្រហមបានបន្តចាប់ខ្លួន ហាគីម ទួន ក្រុមមេដឹកនានានិងសមាជិកដែលសិក្សាពីសាសនាអ៊ីស្លាម ដូចជា ហាជី *(Hajis)* ទូទាំងភូមិភាគរំដោះ ។ ខ្មែរក្រហមក៏បានជ្រើសតាំងជនជាតិចាមម្នាក់ដែលគាំទ្រខ្លួនដើម្បីបញ្ចុះបញ្ចូលសហគមន៍ជនជាតិចាមទាំងនោះឲ្យលះបង់ចោលជំនឿលើសាសនាអ៊ីស្លាម ។ ជនទាំងនោះ គឺ គាយោគ ដែលជាអ្នកទទួលខុសត្រូវលើកិច្ចការមូស្លីមនៅក្នុងស្រុកក្រូចឆ្មារ ។ ខ្មែរក្រហមបានចាប់ផ្តើមបន្តុចបង្អាក់ប្រជាជនកុំឲ្យទៅវិហារ និងរៀបចំការបួងសួងជួបជុំគ្នានៅក្នុងសហគមន៍ ។ គម្ពីរគួរអាន ត្រូវបានគេប្រមូលទុក និងស្ត្រីចាមត្រូវបានលើកទឹកចិត្តឲ្យកាត់សក់ខ្លី ។ ខ្មែរក្រហមថែមមានបំណងឲ្យជនជាតិចាមចិញ្ចឹមជ្រូកទៀតផង ។ ប៉ុន្តែ ទង្វើទាំងនេះបានក្លាយជាគោលនយោបាយរបស់ខ្មែរក្រហម បន្ទាប់ពីខ្មែរក្រហមបានកាន់កាប់ទីក្រុងភ្នំពេញនៅខែមេសា ឆ្នាំ១៩៧៥ ។ អាយ យុប និយាយថា "មុនពេលខ្មែរក្រហមបានកាន់កាប់ក្រុងភ្នំពេញ ខ្មែរក្រហមមិនសូវជាតឹងរ៉ឹងប៉ុន្មានទេ ។ ជនជាតិចាមមិនបាច់បរិភោគសាច់ជ្រូកទេ ។ ក្រោយថ្ងៃ១៧

មេសា ខ្មែរក្រហមបានបង្ខំជនជាតិចាមឲ្យបរិភោគសាច់ជ្រូក ។ ជនជាតិចាមខ្លះមិនបានដឹងពីគោលបំណងពិតប្រាកដរបស់ខ្មែរក្រហមនោះទេ ។ ខ្មែរក្រហមព្យាយាមកម្ចាត់ទាហាន លន់ នល់ ។ ប៉ុន្តែក្រោយមក ជនជាតិចាម បានដឹងបន្ទាប់ពីខ្មែរក្រហមទទួលជ័យជន្នះ រួចហើយ ជីវិតរបស់ពួកគេកាន់តែដុនដាមទៅ» ។

ជនជាតិចាមម្នាក់ដែលរស់រានមានជីវិតបានឲ្យដឹងថា «ដើម្បីទទួលបាននូវការជឿទុកចិត្តពីសំណាក់ខ្មែរមូស្លីម សុះ ម៉ាន់ បានបន្តអនុវត្តជំនឿសាសនាអ៊ីស្លាម ដល់ឆ្នាំ១៩៧៣ ។ ទោះជាយ៉ាងនេះក្តី សុះ ម៉ាន់ និងមិត្តរួមការងារកុម្មុយនីស្តរបស់គាត់បានចាប់ផ្តើមបញ្ចុះបញ្ចូលពីលទ្ធិកុម្មុយនីស្តជាសាធារណៈ និងបើកឲ្យមានសាលារៀនអប់រំនយោបាយ និងរៀបចំសហករណ៍ ។ សំខាន់ជាងនេះទៅទៀត ខ្មែរក្រហមបានចាប់ផ្តើមប្រាប់ប្រជាជនថាប្រជាជនមូស្លីមចំណាយពេលច្រើនពេកក្នុងរឿងសាសនា និងមិនមានពេលគ្រប់គ្រាន់សម្រាប់បដិវត្តន៍» ។

ប្រហែលជាមានរឿងរ៉ាវផ្សេងៗទៀតក្រៅពីរឿងរ៉ាវទាក់ទងនឹងសាសនាអ៊ីស្លាមតែម៉្យាង ។ នៅឆ្នាំ១៩៧៣ ខ្មែរក្រហមបានចាប់ផ្តើមបោសសម្អាត ថ្នាក់ដឹកនាំបក្សដែលជាអតីតសមាជិកសកម្មក្នុងបក្សកុម្មុយនីស្តឥណ្ឌូចិនដែលមាន សុះ ម៉ាន់ ជាសមាជិកម្នាក់ដែរ ។ មានមនុស្សជាច្រើនដែលបានជាប់ទាក់ទងជាមួយបក្សនេះត្រូវបានសម្លាប់នៅពេលនោះ ។ ប៉ុន្តែ ការចាប់ខ្លួន និងសម្លាប់នៅក្នុងអំឡុងពេលនោះ បន្តឲ្យមានហេតុការណ៍តាមចាប់ខ្លួន ការសម្លាប់បន្ថែមជាច្រើនទៀត ហើយខ្មែរក្រហមបានបង្កើតឲ្យមានសត្រូវជាបន្តបន្ទាប់ ដែលចុងក្រោយនាំឲ្យមានការដឹកនាំការធ្វើបាតុកម្ម និងការក្រោកឡើងប្រឆាំង និងបង្កឲ្យមានការគាបសង្កត់ខ្លាំងឡើងៗ ព្រមទាំងភាពភ័យខ្លាចក្នុងចំណោមមេដឹកនាំខ្មែរក្រហម ។ ឃៀរនិន (Kiernan) បានផ្តល់ជាសម្មតិកម្ម ដោយលើកទ្រឹស្តីដូមិណូមួយ (A Domino Theory) ដូចខាងក្រោម៖

នៅពេលណាព្យាយាមដាក់ការគ្រប់គ្រងតឹងរ៉ឹងកាន់តែខ្លាំង និងកាន់តែមានជោគជ័យក្នុងការស្វែងរកកាន់តែច្រើន កាន់តែមានផលអាក្រក់យ៉ាងធ្ងន់ធ្ងរដល់អាយុជីវិតមនុស្ស ។ កាលណាមានចំនួនមនុស្សកាន់តែច្រើនទទួលរងការប៉ះពាល់នោះ នឹងនាំឲ្យមានការបើបម្រះកាន់តែខ្លាំង ។ ចុងក្រោយសត្រូវជាច្រើនត្រូវបានបង្កើតឡើងដោយសារខ្មែរក្រហមខ្លួនឯង ទាំងបរទេស និងក្នុងស្រុក ទាំងកងទ័ព និងជនស៊ីវិល ទាំងអ្នកអនុវត្តនយោបាយ និងអ្នករស់រានជីវិតធម្មតា ។ មនុស្សដែលលែងគាំទ្រ ដោយសារតែខ្មែរក្រហមមានបំណងចង់បំផ្លាញ ជនដែលខ្លួនចាត់ទុកជាសត្រូវ ហើយជនទាំងនោះជាអ្នកដែលធ្វើឲ្យរបបនេះដួលរលំ ។

ស្ថានភាពនេះ បានកើតឡើងទៅលើប្រជាជនចាមទូទាំងប្រទេសកម្ពុជា ។ ប៉ុន្មានឆ្នាំក្រោយមក ការប្រឆាំងបង្ហូរឈាមយ៉ាងតិចបីលើករវាងជនជាតិចាមជាមួយនឹងខ្មែរក្រហមបានកើតឡើង និងបានបង្កឲ្យមានការចាប់ខ្លួន និងសម្លាប់បន្ថែមទៀត ព្រមទាំងបានបង្កឲ្យមានការបង្កើតគម្រោងការជាក់លាក់ជាច្រើនដោយខ្មែរក្រហមដើម្បីលុបបំបាត់ជនជាតិចាម និងកម្ចាត់អត្តសញ្ញាណស្នូលរបស់ចាម ។

ការមិនពេញចិត្តរបស់ចាមទៅនឹងទង្វើរបស់ខ្មែរក្រហមបានធ្វើឲ្យជនជាតិចាមសម្រេចដឹកនាំក្រុមមួយដោយឡែកពីខ្មែរក្រហម ។ ក្រុមនោះត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៧៣ ដោយហៅខ្លួនឯងថា ខ្មែរស (White Khmer) ។ ក្រុមនោះ មានអ្នកដឹកនាំជាអតីតជនកុម្មុយនីស្តចាម ដែលបន្តគាំទ្រសម្តេចសីហនុ ។ ប៉ុន្តែក្រុមនោះប្រឆាំងនឹងការបង្កើតសមូហភាពនៃទ្រព្យសម្បត្តិ និងការបំផ្លាញសាសនា ដែលដាក់ចេញដោយខ្មែរក្រហម ។ ទង្វើនេះធ្វើឲ្យខ្មែរក្រហមរឹតតែមិនទុកចិត្តបន្ថែមទៀតចំពោះចាម និងបង្កឲ្យមានការកើនឡើងនូវអារម្មណ៍គ្មានសុវត្ថិភាពខ្លាំងឡើងៗ ។

## ក្រុមសាមគ្គី និងសហករណ៍

នៅឆ្នាំ១៩៧១ ខ្មែរក្រហមបានចាប់ផ្តើមអនុវត្តផែនការមួយហៅថា «ក្រុមសាមគ្គី» (Krom Samaki) នៅក្នុងតំបន់រំដោះនានា រួមទាំងតំបន់ដែលមានចាមរស់នៅ ជាពិសេសនៅក្នុងស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម ។ មុនពេលនេះ សហគមន៍ចាម ក៏ដូចជាសហគមន៍ដទៃទៀត នៅក្នុងប្រទេសកម្ពុជាដែរពឹងផ្អែកទៅលើប្រព័ន្ធពលកម្មមួយដែលអ្នកមាន និងម្ចាស់ដី ជួលកសិករក្រីក្រដោយផ្តល់ជាប្រាក់ឈ្នួល ឬផ្តល់ចំណែកខ្លះពីការប្រមូលផល ។ ប្រព័ន្ធថ្មីនេះបានបង្ហាញពីការជួយគ្នាទៅវិញទៅមក និងចែករំលែកពលកម្ម ។ ប៉ុន្តែភាពស្មើភាពគ្នាក្នុងការបែងចែកផលចំណេញមិនត្រូវបានបញ្ជាក់នោះទេ ។ ក្រុមសាមគ្គីមួយក្រុមមានសមាជិកពី

១០ទៅ១៥គ្រួសារ ។ ភូមិមួយអាចមាន១០ក្រុមសាមគ្គី អាស្រ័យទៅតាមទំហំរបស់វា ។ សមាជិកក្រុមអាចរក្សាកម្មសិទ្ធិដីរបស់ខ្លួន និងទ្រព្យសម្បត្តិនានា ប៉ុន្តែ ម្ចាស់ដីត្រូវតែ “ខ្ចី” កម្លាំងពលកម្មពីកសិករដទៃទៀតនៅក្នុងក្រុម ឲ្យជួយភ្ជួរស្រែនៅដើមរដូវ ដើម្បីប្រមូលផលនៅចុងរដូវ ។ ម្ចាស់ដីជាអ្នករក្សាផលិតផលរបស់ខ្លួន ដោយមិនបានបែងចែកក្នុងចំណោមសមាជិកក្រុមសាមគ្គីទេ ។

ក្រុមសាមគ្គីជាច្រើនត្រូវបានអនុវត្តដំបូងនៅឆ្នាំ១៩៧១ លទ្ធផលបង្ហាញថា ទិន្នផលដែលទទួលបានមានចំនួនតិច ដោយសារតែមូលហេតុមួយចំនួនដូចជា ទី១) សមាជិកនៃក្រុមសាមគ្គី មិនបានខិតខំប្រឹងប្រែងធ្វើការដើម្បីប្រមូលទិន្នផលឲ្យបានគ្រប់គ្រាន់សម្រាប់បែងចែកក្នុងចំណោមសមាជិក ។ ទី២) អ្នកដែលមានដីច្រើនមិនមានកម្លាំងពលកម្មគ្រប់គ្រាន់ដើម្បីដាំដុះនៅលើដីទាំងអស់ ដែលខ្លួនមាននោះទេ ។ ម្ចាស់ដីមិនចង់ធ្វើការច្រើនពេកនៅលើដីទំហំធំៗរបស់ខ្លួន ដោយសារខ្លាចសមាជិកដទៃទៀតនៅក្នុងក្រុមអាចចោទថាខ្លួនលោភលន់ ។

តាមពិតទៅ ពលករត្រូវបានខ្ចីកម្លាំងពលកម្ម និងសងមកវិញឲ្យស្មើភាពគ្នា ។ ប្រសិនបើការអនុវត្តផ្សេងពីនេះនឹងបង្កើតឲ្យមានភាពមិនស្មើគ្នា ។ ជាការពិតណាស់ ភាពមិនស្មើគ្នាពិតជាបានកើតឡើងមែន ។ ប្រសិនបើកសិករមានទំហំដីតូច និងត្រូវទៅដាំដុះលើដីដែលមានទំហំធំសម្រាប់អ្នកដទៃ គាត់សង្ឃឹមថានឹងទទួលបាននូវផលតបស្នងមកវិញ ស្របទៅតាមកម្លាំងពលកម្មរបស់គាត់ដែលបានផ្តល់ ដែលបានច្រើនជាងការប្រមូលផលនៅលើដីទំហំតូចរបស់គាត់ ។ ប៉ុន្តែ ខ្មែរក្រហមនៅតែបន្តការអនុវត្ត ក្រុមសាមគ្គីម្តងទៀតនៅឆ្នាំ១៩៧២ ហើយលទ្ធផលដែលទទួលបានគឺខ្សត់ខ្សោយ ដូចដែលបានរំពឹងទុក ។

ទោះជាយ៉ាងណាក្តី ប្រពន្ធ័នេះបានជំរុញឲ្យមានភាពស្និទ្ធស្នាលរវាងជនជាតិចាម និងការដឹកនាំរបស់ខ្មែរក្រហម ។ នៅក្នុងតំណាក់កាលនេះ ខ្មែរក្រហមបានណែនាំទាហាន និងសមាជិករបស់ខ្លួនឲ្យមកជួយអ្នកភូមិធ្វើការដាំដុះ និងធ្វើការងារផ្សេងៗទៀត ដើម្បីបង្ហាញពីឧត្តមគតិកុម្មុយនីស្តរបស់ខ្លួន ។ បន្ទាប់មក សាសនាអ៊ីស្លាម និងលទ្ធិកុម្មុយនីស្តត្រូវបានខ្មែរក្រហមផ្សាយថា តែមួយដូចគ្នា ។ នៅត្រង់ចំណុចនេះ ជនជាតិចាមទទួលបាននូវអត្តសញ្ញាណនយោបាយមួយ ។ ជនទាំងអស់នោះមិនត្រឹមតែជាជនជាតិចាមមូស្លីមប៉ុណ្ណោះទេ ថែមទាំងជាជនកុម្មុយនីស្តផងដែរ ។ នៅក្នុងពេលសង្គមមានភាពចលាចល និងមានការផ្លាស់ប្តូរអត្តសញ្ញាណនយោបាយសម្រាប់ជនជាតិចាមគឺអាចទទួលយកបានដរាបណា មិនមានការប៉ះពាល់ទៅដល់អត្តសញ្ញាណស្នូលរបស់ខ្លួន ។

នៅឆ្នាំ១៩៧៣ នៅខេត្តកំពង់ចាមខ្មែរក្រហមបានពង្រីកក្រុមសាមគ្គីទៅជាប្រព័ន្ធសហករណ៍ ។ សហករណ៍នៅពេលនេះរួមមានសមាជិក២៥គ្រួសារ ។ រាល់សមាជិកទាំងអស់ត្រូវលះបង់រាល់ទ្រព្យសម្បត្តិផ្ទាល់ខ្លួនទាំងអស់លើកលែងតែផ្ទះសម្បែង ។ សមាជិកគ្រប់រូបតម្រូវឲ្យធ្វើការជាមួយគ្នា មិនដូចនៅក្នុងក្រុមសាមគ្គីទេ ដែលទិន្នផលត្រូវចែករំលែកគ្នា ។ ទិន្នផលត្រូវបានទុកក្នុងផ្ទះរបស់ប្រធានសហករណ៍ ដែលជាអ្នកបែងចែកអាហារ និងរបស់របរចាំបាច់ផ្សេងៗជាប្រចាំ ។ ប្រជាជនចម្អិន និងបរិភោគអាហារដោយឡែកពីគ្នា ។ ក្រៅពីធ្វើស្រែចម្ការសកម្មភាពផ្សេងៗត្រូវបានអនុវត្ត ដើម្បីផ្គត់ផ្គង់តម្រូវការចាំបាច់នានាដូចជា នេសាទ រកអុស និងជំនួញ ។

ប្រព័ន្ធសហករណ៍មានគុណវិបត្តិជាច្រើន ។ គ្រួសារមួយមានមនុស្សពេញកម្លាំងធ្វើការ នៅតែទទួលបានចំណែកស្មើគ្នា និងគ្រួសារដែលមានកូនក្មេងតូចៗច្រើន ។ ច្បាស់ណាស់ថា សមាជិកខ្លះមិនមានជម្រើសច្រើនអំពីអ៊ីសម្រាប់ចម្អិនអាហារប្រចាំថ្ងៃនោះទេ ។ ការបែងចែកទាំងអស់អាស្រ័យទៅលើរបស់របរដែលមាននៅក្នុងឃ្លាំងសហករណ៍ ឧទាហរណ៍ ដូចជា តើមានត្រី សាច់ ឬបន្លែទេ ។ បញ្ហានេះបង្កឲ្យមានអំពើលួច និងសកម្មភាពផ្សេងៗទៀតដែលរំលោភច្បាប់នានានៅក្នុងសហករណ៍ ។ ទង្វើនេះបានបង្កឲ្យមានការចាប់ខ្លួន និងការដាក់ឃុំឃាំង ។ នៅក្នុងអំឡុងពេលនេះ ភូមិចាមជាច្រើនមិនទាន់ត្រូវបានខ្មែរក្រហមបំបែកនោះទេ ដូចនេះ អាហារដែលជាចំណូលចិត្ត និងអ៊ីដែលមាននៅក្នុងឃ្លាំងសហករណ៍ ក៏មិនបានប្រឆាំងនឹងសាសនាអ៊ីស្លាមនោះដែរ ។ ឧទាហរណ៍ ដូចជា សាច់ជ្រូកមិនដែលមាននៅក្នុងសហករណ៍នោះទេ ។

ជាដំបូង អ្នកភូមិដែលមានទ្រព្យសម្បត្តិច្រើនមិនត្រូវបានអនុញ្ញាតឲ្យចូលរួមក្នុងសហករណ៍ នៅពេលដែលចំណែកទ្រព្យសម្បត្តិរបស់អ្នកមានទាំងនោះមានចំនួនច្រើនជាងអ្នកដទៃ ហើយនៅក្នុងការ

គិតរបស់ខ្មែរក្រហម ការដាក់អ្នកមានទាំងនោះឲ្យនៅដោយឡែកពីប្រជាជនដទៃទៀតនោះចរិត"សក្តិភូមិ"របស់អ្នកមាននាំខ្មែរក្រហមងាយស្រួលនឹងកត់សម្គាល់ ។ នៅពេលដែលអ្នកមានត្រូវឲ្យចែករំលែកទ្រព្យសម្បត្តិរបស់ខ្លួន និងទទួលមកវិញនូវចំនួនស្មើនឹងចំណែកអ្នកផ្សេងទៀតនោះ ក្រុមអ្នកមានទាំងនោះត្រូវបានអនុញ្ញាតឲ្យចូលរួមនៅក្នុងសហករណ៍ ប៉ុន្មានខែបន្ទាប់ពីប្រព័ន្ធសហករណ៍បានចាប់ផ្តើមដំណើរការ ។ នេះប្រហែលជាកើតឡើងដោយសារលទ្ធផលនៃការបង្ខិតបង្ខំនៅឆ្នាំ១៩៧៣ ខ្មែរក្រហមចាប់ផ្តើមដកចេញសមាជិកសំខាន់ៗនៅតាមភូមិចាមជាច្រើន ។

នៅក្នុងប្រព័ន្ធសហករណ៍របស់ខ្មែរក្រហម "សហករណ៍ជំនួញ" ត្រូវការជាចាំបាច់ដែលធ្វើឲ្យប្រាកដថាសមាជិកសហករណ៍មានអ្វីដែលខ្លួនមិនអាចផលិតបាន ដូចជា សម្លៀកបំពាក់ ភេសជ្ជៈ ឧបករណ៍ប្រើប្រាស់ផ្សេងៗ លោហៈធាតុ និងថ្នាំពេទ្យ ។ សហករណ៍ជំនួញនឹងទទួលយកផលិតផលកសិកម្មសម្រាប់ជាការជួញដូរ ។ ការជួញដូរនេះជួនកាលធ្វើឡើងជាមួយអ្នកជំនួញដែលរស់នៅក្នុងតំបន់គ្រប់គ្រងរបស់ លន់ នល់ ។ ទោះជាយ៉ាងណាក្តី បន្ទាប់ពីខ្មែរក្រហមទទួលបានជោគជ័យ នៅក្នុងខែមេសា ឆ្នាំ១៩៧៥ អ្នកដែលទទួលខុសត្រូវរឿងជំនួញជួញដូរនេះត្រូវបានចាប់ខ្លួន ដោយចោទថា បានផ្តល់ទំនិញទៅឲ្យតំបន់កាន់កាប់របស់ លន់ នល់ ។

ខ្មែរក្រហមនៅតែបន្តពង្រីកទំហំសហករណ៍នានារបស់ខ្លួន ។ នៅអំឡុងឆ្នាំ១៩៧៤ ខ្មែរក្រហមបានបញ្ចូលសហករណ៍ពីរទៅជាសហករណ៍មួយដែលមានចំនួនប្រជាជនជាង៥០គ្រួសារ និងនៅឆ្នាំ១៩៧៥ សហករណ៍មួយត្រូវបានបញ្ចូលជាមួយសហករណ៍មួយផ្សេងទៀត ដែលមានចំនួនប្រជាជនកើនដល់១០០គ្រួសារ ឬក៏លើសពីនោះក៏មាន ។ ដោយសារតែចំនួនជនជាតិចាម ត្រូវបានបំបែកឲ្យបែកខ្ញែកគ្នា នៅក្រោយខែមេសា ឆ្នាំ១៩៧៥ សមាជិកសហករណ៍ជាច្រើនមានទាំងចាម និងសមាជិកនៃជនជាតិផ្សេងៗទៀត ។ នៅឆ្នាំ១៩៧៦ សហករណ៍ត្រូវបានពង្រីករហូតបញ្ចូលភូមិទាំងមូលតែម្តង ។ នៅក្នុងដំណាក់កាលនេះការបរិភោគរួមត្រូវបានអនុវត្ត ជំនួញសហករណ៍ត្រូវបានបោះបង់ចោល និងចាមត្រូវបានបង្ខំឲ្យបរិភោគសាច់ជ្រូកជាផ្លូវការ ។ ហ៊ឹម លី បាននិយាយថា "ក្រោយមកខ្មែរក្រហមបានបង្កើតសហករណ៍មួយធំជាងមុន ។ខ្មែរក្រហមបានសាងសង់រោងបាយរួមនៅក្នុងភូមិ" ។ នៅពេលថ្ងៃ ពួកគេបញ្ជាឲ្យពួកយើងធ្វើការ និងត្រឡប់មកហូបរួមគ្នាវិញនៅក្នុងរោងបាយរួម ។ អែល ម៉ាន់ បាននិយាយថា "ចំណីអាហារមិនសូវមានគ្រប់គ្រាន់នោះទេ ។ នៅពេលដែលមានសាច់ គឺមានតែសាច់ជ្រូក ។ ថ្ងៃមួយខ្មែរក្រហមបានស្ងោរស៊ុបសាច់ជ្រូកសម្រាប់សហករណ៍ និងបានបង្ខំខ្ញុំឲ្យហូបស៊ុបនោះ ។ ប៉ុន្តែ ខ្ញុំបដិសេធ ។ បន្ទាប់មកខ្មែរក្រហមបានដករបបអាហាររបស់ខ្ញុំចេញ និងបានឲ្យខ្ញុំចូលប្រជុំបំពាក់បំប៉នស្មារតីយ៉ាងយូរនៅយប់ដែលនោះ" ។

### ៤) ការតវ៉ា និងការបះបោររបស់ជនជាតិចាម

នៅចុងឆ្នាំ១៩៧៣ ការក្តោបក្តាប់ជនជាតិចាមបន្តិចៗម្តងរបស់ខ្មែរក្រហមបានចេញជារូបរាងច្បាស់លាស់ ជាហេតុធ្វើឲ្យចាមកាន់តែមិនពេញចិត្ត និងខឹងសម្បារនឹងខ្មែរក្រហមយ៉ាងខ្លាំង ។ ការមិនពេញចិត្តនេះបាននាំមកនូវការតវ៉ា និងបង្កឲ្យមានសកម្មភាពប្រឆាំងយ៉ាងអង់អាចមោះមុតផ្សេងៗ ដោយជនជាតិចាម ។ ការតវ៉ា និងការប្រឆាំងតបជាច្រើនបានកើតឡើងនៅតំបន់បីផ្សេងៗគ្នា នៅស្រុកក្រូចឆ្មារ ទ្រា កោះផល និងស្វាយឃ្លាំង ។ប៉ុន្តែមានករណីតវ៉ាតិចតួចណាស់បានកើតឡើងក្នុងរបបខ្មែរក្រហម ។ ការតវ៉ាទាំងនោះបានកើតឡើងនៅខេត្តកណ្តាល និងកំពង់សោម ប៉ុន្តែមានលក្ខណៈតូច ។ ចំណែកឯប្រជាជនខ្មែរបានងើបឡើងតវ៉ាប្រឆាំងតបយ៉ាងហោចណាស់ម្តងនៅស្រុកជីក្រែង ។

**(តទៅលេខក្រោយ)**

**អេង កុកថាយ**

## អានទស្សនាវដ្តីតាមគេហទំព័រ

ទស្សនាវដ្តីស្វែងរកការពិតទាំងអស់ត្រូវបានផ្សព្វផ្សាយតាមគេហទំព័ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ អ្នកអានអាចរកបានតាមៈ http://d.dccam.org/Projects/Magazines/Magazine_Searching.htm ។ព័ត៌មានបន្ថែម សូមទាក់ទង សោម ប៊ុនថន ទូរស័ព្ទលេខ ០១២ ៩៩៦ ៧៥០ ឬ ០២៣ ២១១ ៨៧៥ ។

# វេទិកាសាធារណៈ អំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ រ









# នៅឃុំស្រែសង្គម ខេត្តរតនគិរី ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៥











# សវនាការភ័ស្តុតាងស្តីពីការផ្តល់សក្ខីកម្មរបស់សាក្សីជំនាញ អេលីហ្សាបែត បេ៊ិកខ័រ

***(តចប់)***

*ឆ្លើយតបនឹងសំណួររបស់សហព្រះរាជអាជ្ញាអន្តរជាតិទាក់ទងនឹងជនជាតិចាម សាក្សីបានជម្រាបថា ចាមគឺជាជនជាតិភាគតិចមូស្លីម ។ នៅពេលដែលសាក្សីរស់នៅក្នុងទសវត្សរ៍ឆ្នាំ៧០ មានការរើសអើងពូជសាសន៍ ។ គេចាត់ទុកថា ជនជាតិចាមគឺជាអ្នកដែលខ្ជិល ។ ប្រទេសមូស្លីមនៅក្នុងតំបន់ ដូចជា ម៉ាឡេស៊ី និងឥណ្ឌូនេស៊ី មានយន្តការការពារជនជាតិបែបនេះនៅក្នុងសង្គ្រាម ហើយនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យជនជាតិចាមត្រូវបានគេកំណត់គោលដៅសម្លាប់ចោល ។ សហព្រះរាជអាជ្ញា បានអាននូវអត្ថបទសម្រង់ពីសៀវភៅដែលនិពន្ធដោយសាក្សីថា “គោលនយោបាយនៃការសម្លាប់ជនជាតិភាគតិចមួយចំនួនហើយ និងចង់ឲ្យមានជនជាតិថ្មី ហើយវាប៉ះពាល់ដល់ជនជាតិចាម ។ យើងឃើញគេសម្លាប់ចោលដោយសារប្រតិកិរិយារបស់អ្នកទាំងអស់នោះ ។ ពួកគេមិនអាចចូលក្នុងសាសនាព្រះពុទ្ធរបស់ខ្មែរបាន ។ គេចាត់ទុកថា ជនជាតិចាមគឺជាអ្នកវាយប្រឆាំងទៅនឹងប្រទេសកម្ពុជា ហើយជនជាតិចាមភាគច្រើនបានចូលរួមជាមួយខ្មែរក្រហម ។ នៅពេលក្រោយមក មានការបង្កើតសហករណ៍ ហើយកុម្មុយនីស្តបានប្រកាសថា ជនជាតិចាមមានជីវភាពរស់នៅដោយឡែក ហើយជាអ្នកប្រឆាំងនឹងបដិវត្តន៍ ។ ក្រោយជ័យជម្នះខ្មែរក្រហម គេវាយប្រហារទៅលើជនជាតិចាមក្នុងលក្ខណៈចំហ និងជាលក្ខណៈប្រព័ន្ធ ។ មេសហគមន៍ជនជាតិចាមត្រូវបានគេតាមសម្លាប់ចោល ។ មេដឹកនាំសាសនាត្រូវបានគេសម្លាប់ចោល ។ វិហារអ៊ីស្លាមជាច្រើនត្រូវគេកម្ទេចចោល ឬប្រមាថ ត្រូវប្រែក្លាយឲ្យទៅជាជង្រុកស្រូវ ទ្រុងជ្រូក ដូចវត្តអារាមពុទ្ធសាសនាដែរ ។ គេបានដុតគម្ពី*




*អេលីហ្សាបែត បេ៊ិលឃ័រ*

គូរ៉ាន់ចោល សាលារៀនរបស់ចាមត្រូវបិទទ្វារដូចសាលារៀនផ្សេងទៀតនៅទីដទៃគ្នា» ។ ចំណុចចុងក្រោយនៃការដកស្រង់ “ប៉ុន្តែពួកចាមបានបះបោរប្រឆាំង ភូមិចាមជាច្រើនបានចាប់កាន់អាវុធ ហើយត្រូវបានកម្ទេចដោយពួកខ្មែរក្រហម ។ ភូមិជាច្រើនទៀតដែលតវ៉ាប្រឆាំងដោយមិនចេញមុខ ក៏ត្រូវពួកកម្មាភិបាលខ្មែរក្រហមបំផ្លិចបំផ្លាញរាបដល់ដីដូចគ្នា ។ ពុំមានសហគមន៍ចាមណាមួយរួចផុតពីគ្រោះថ្នាក់ឡើយ ។ ពួកចាមត្រូវបានគេបំបែកយកទៅដាក់ភូមិផ្សេងៗដែលមានខ្មែរច្រើនលើសលប់ជាង ហើយត្រូវបង្ខំឲ្យខ្លួនដូចជាខ្មែរថែមទៀត ។ ភាគច្រើននៃភូមិចាមច្រើនស្ថិតនៅតាមមាត់ទន្លេមេគង្គក្នុងភូមិភាគបូព៌ា និងភូមិភាគនិរតី ព្រមទាំងក្នុងអតីតភូមិភាគឧត្តរផង» ។ ប៉ុន្តែការលើកឡើងនេះត្រូវមេធាវីអន្តរជាតិ កូប៉េ ធ្វើការកត់សម្គាល់ថា ការប្រព្រឹត្តលើជនជាតិចាមនេះ មិនត្រូវបានលើកឡើងនៅក្នុងប្រធានបទនេះទេ ។ លោកស្រីចៅក្រមអន្តរជាតិ ក្លូឌា ហ្វេនស៍ បានរំឭក ដល់សហព្រះរាជអាជ្ញាអន្តរជាតិដែរថា បញ្ហាចាម ជាផ្នែកនៃអង្គហេតុនៅក្នុងសំណុំរឿង០០២ដំណាក់កាលទី២ ដូច្នេះ ចៅក្រមបានស្នើឲ្យសហព្រះរាជអាជ្ញាធ្វើការកម្រិតសំណួរឲ្យបានចំនួនតិចដើម្បីកុំឲ្យមានការផ្តោតសំខាន់លើអង្គហេតុនេះ ។

## ការតាំងសំណួរដោយមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី

មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីអន្តរជាតិ ម៉ារី ហ្គីរូដ៍ បានសួរដេញដោលទាក់ទងនឹងការប្រព្រឹត្តទៅលើព្រះពុទ្ធសាសនា នៅក្នុងអំឡុងឆ្នាំ១៩៧៨ នៅពេលដែលសាក្សីបានមកទស្សនានៅកម្ពុជា ។ ជាការឆ្លើយតប សាក្សីបានជម្រាបជូនអង្គជំនុំជម្រះថា ខ្មែរក្រហមបានហៅពុទ្ធសាសនាថា ជាប្រតិកិរិយា ។ ចំណុចនេះ បានធ្វើឲ្យសាក្សីមានការភ្ញាក់ផ្អើលដោយសារតែគ្រប់គ្នាបានដឹងថា សាសនាព្រះពុទ្ធគឺជាសាសនាផ្លូវការមានមុខងារដំណើរការនៅក្នុងសង្គមកម្ពុជា ។ ប៉ុន្តែនៅក្នុងរបបខ្មែរក្រហមវិញបានបង្ខំអោយព្រះសង្ឃលាចាកសិក្ខាបទ ព្រមទាំងបានលុបចោលព្រះពុទ្ធសាសនា ។ នៅក្នុងសៀវភៅរបស់សាក្សីក៏បានរៀបរាប់ដែរថា “ខ្ញុំបានឃើញថាវប្បធម៌ព្រះពុទ្ធសាសនា ដែលជាមូលដ្ឋានគ្រឹះរបស់កម្ពុជា អស់រយៈពេលរាប់សតវត្សរ៍មកហើយនោះត្រូវបានលុបបំបាត់ចោលទាំងស្រុង ហើយបញ្ហានេះបានបន្សល់ឲ្យខ្ញុំនូវអារម្មណ៍មួយដែលថា ខ្ញុំបានស្ថិតនៅក្នុងប្រទេសមួយដែលបាត់បង់អ្វីៗ បាត់បង់នូវដួងព្រលឹងជាតិ» ។

## ការសួរដេញដោលដោយសហមេធាវីការពារក្តី

មេធាវីអន្តរជាតិ វិចទ័រ កូប៉េ តំណាងឲ្យជនជាប់ចោទ នួន ជា បានលើកសំណួរទាក់ទងនឹងសហការីរបស់សាក្សីម្នាក់ឈ្មោះ រីឆាត ឌុដម៉ាន ដែលបានធ្វើទស្សនកិច្ចមកកាន់ប្រទេសកម្ពុជាក្នុងរបបកម្ពុជាប្រជាធិបតេយ្យជាមួយសាក្សី ។ មេធាវីបានលើកឡើងទាក់ទងនឹងអត្ថបទមួយ ដែល លោក រីឆាត ឌុដម៉ាន បានចុះផ្សាយនៅក្នុងសារព័ត៌មានរបស់ញូវយ៉កថែម កាលពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៩០ ថា “ប៉ុល ពត កាចសាហាវ ពិតហើយ ប៉ុន្តែមិនមែនជាឃាតកសម្លាប់រង្គាលនោះឡើយ ។ ការស្អប់ ប៉ុល ពត ដោយមិនគិតអ្វីទាំងអស់ ធ្វើឲ្យអាមេរិកមានការផ្លាស់ប្តូរគោលនយោបាយដែលនាំទៅដល់ការបំផ្លាញកម្ពុជាទាំងស្រុងតាមរយៈការឈ្លានពានរបស់វៀតណាម ។ មុនពេលដែលយើងបោះបង់ចោលសម្ព័ន្ធមិត្ត យើងត្រូវពិនិត្យមើលថា តើមានការស្អប់ខ្ពើមដែរឬទេ ហើយនៅក្នុងសមាជគឺថា ប៉ុល ពត និង ខ្មែរក្រហម គឺមិនមែនជាអ្នកផ្តល់នូវការសម្លាប់រង្គាលនោះឡើយ ប៉ុន្តែជាអ្នកបង្កឲ្យមានបញ្ហា ។ ភ័ស្តុតាងបានបង្ហាញថា គឺរួមមានការមិនយល់ស្របជាមួយគ្នាទៅវិញទៅមក ។ វាមានឈ្មោះរបស់ខ្មែរក្រហមនៅក្នុងជំរុំប្រជាជនកម្ពុជា មិនបដិវត្តន៍របស់ ប៉ុល ពត មកពីវៀតណាមដែលបានចូលមកក្នុងប្រទេសកម្ពុជា» ។ សាក្សីបានឆ្លើយថា ខ្លួនមិនយល់ស្របជាមួយអត្ថបទនេះទេ ។ ត្រឹមឆ្នាំ១៩៩០ អ្វីៗទាំងអស់បានបង្ហាញច្បាស់នៅក្នុងសារមន្ទីរទួលស្លែង គេបើកជាសាធារណៈ ។ រីឆាត ឌុដម៉ាន បានលាឈប់ពីការងារយូរណាស់មកហើយ គាត់មិនដែលត្រឡប់មកកម្ពុជា នៅក្រោយឆ្នាំ១៩៧៨ វិញទេ ។ វាជាការល្អដែលគាត់សរសេរពីព័ត៌មានហ្នឹង ប៉ុន្តែព័ត៌មាននេះ គឺផ្ទុយនឹងភាពជាក់ស្តែង ។ អ្វីដែល រីឆាត ឌុដម៉ាន សរសេរគឺហួសសម័យទៅហើយ ។ គាត់មិនទាំងបានរៀបរាប់អំពីបណ្តុំសារដែលគេរកឃើញនៅពេលដែលវៀតណាម ចូលមកកម្ពុជានោះឡើយ ។ សាក្សីបានបន្តទៀតថា នៅពេលនេះមានភ័ស្តុតាងយ៉ាងច្រើនដែលផ្ទុយពីអ្វីដែល រីឆាត ឌុដម៉ាន សរសេរហើយសាក្សីមានការសោកស្តាយចំពោះការសរសេរបែបនេះ ។ សាក្សីក៏បានលើកឡើងទៀតថា

ខ្លួនមិនធ្វើការរិះគន់ លោក ឌុជម៉ាន ទេក្នុងនាមជាមនុស្សដូចគ្នា ប៉ុន្តែលោកស្រីជឿជាក់ថារបាយការណ៍របស់ខ្លួនត្រូវគេដកស្រង់យ៉ាងច្រើននាពេលកន្លងមក ។

សាក្សី បានជម្រាបជូនអង្គជំនុំជម្រះទាក់ទងគោលការណ៍នៃប្រជាធិបតេយ្យប្រមូលផ្តុំថា គឺជាគំនិតរបស់កុម្មុយនីស្ត ដែលអាជ្ញាធរស្ថិតនៅប្រមូលផ្តុំ។ គេហៅថាប្រជាធិបតេយ្យដោយសារប្រជាជនមានប្រជាធិបតេយ្យ ប៉ុន្តែពុំមែនមានការបោះឆ្នោតឲ្យនរណាម្នាក់ធ្វើការងារនោះទេ ហើយការចេញសេចក្តីសម្រេចធ្វើពីថ្នាក់លើទៅថ្នាក់ក្រោម ។ សហព្រះរាជអាជ្ញា ក៏បានលើកឡើងអំពីការសម្ភាសន៍រវាងសាក្សី និង អៀង ធីរិទ្ធ នៅក្នុងដំណើរទស្សនកិច្ចនោះពាក់ព័ន្ធនឹងមេដឹកនាំ ដែលមានដូចជា ប៉ុល ពត, នួន ជា, សោ ភឹម និង សុន សេន ។ សុន សេន ជាអ្នកទទួលបន្ទុកខាងសន្តិសុខ ហើយភូមិភាគជាអ្នករាយការណ៍ជូនគាត់ ។ ចំណែក អៀង សារី បាននិយាយពីបញ្ហាសន្តិសុខថា សន្តិសុខ គឺសំដៅលើសន្តិសុខជាតិនៅក្នុងផ្ទៃប្រទេសដែលពាក់ព័ន្ធនឹងកងទ័ពមិនពាក់ព័ន្ធនឹងនគរបាលនោះទេ ។ ការញែកចេញពីគ្នារវាងសន្តិសុខ ដែលទទួលបន្ទុកដោយប៉ូលិស និងកងទ័ព គឺមានលក្ខណៈខុសពីគ្នា ។

មេធាវី វិចទ័រ កូប៉េ បានសួរបញ្ជាក់ពីការចងចាំរបស់សាក្សីទាក់ទងនឹងបទសម្ភាសន៍ជាមួយ សម្តេចព្រះនរោត្តម សីហនុ ស្តីពីទស្សនៈរបស់ព្រះអង្គក្នុងសន្និសីទកាសែត នៅទីក្រុងប៉េកាំង កាលពីខែមករា ឆ្នាំ១៩៧៩ អំពីការភ័យខ្លាចការឈ្លានពានរបស់ប្រទេសវៀតណាម មកលើប្រទេសកម្ពុជាដោយការប្រៀបធៀបថា វៀតណាមកំពុងលេបត្របាក់កម្ពុជាបន្តិចម្តងៗ ។

នៅអំឡុងពេលកំពុងសួរដេញដោលដោយមេធាវីរបស់ខ្លួន នួន ជា បានចោទសំនួរផ្ទាល់ទៅកាន់សាក្សីជំនាញ លោកស្រី អេលីហ្សាប៊ែត បេកក័រ ថា «១) រដ្ឋាភិបាលអាមេរិកបានជ្រៀតជ្រែក និងឈ្លានពានកម្ពុជា ។ ជាពិសេសពីឆ្នាំ១៩៧០ ដល់ឆ្នាំ៧៣ បានទម្លាក់គ្រាប់បែកចំនួន ២០០ថ្ងៃ ២០០យប់ គិតទាំងអស់ប្រហែល៣លានតោន ហើយដែលបានសម្លាប់ប្រជាជនកម្ពុជាស្លូតត្រង់ និង កម្មេចភូមិករ ស្រែចម្ការ វត្តអារាមអស់ជាច្រើន ។ តើអ្នកជំនាញដឹងពីមូលហេតុអ្វីទេ?» អ្នកជំនាញបានឆ្លើយតបថា ហេតុផលដែលអាមេរិកអនុញ្ញាតឲ្យទម្លាក់គ្រាប់បែកជារួមនោះ គឺយុទ្ធនាការរបស់សាធារណរដ្ឋខ្មែរនេះ ។ ខ្ញុំសូមបកស្រាយថា ការទម្លាក់គ្រាប់បែកនោះ គឺទម្លាក់គ្រាប់បែកពីលើយន្តហោះ ហើយលោកបានលើកឡើងអំពីយុទ្ធនាការ នៅក្នុងឆ្នាំ១៩៧៣ គឺយុទ្ធនាការទម្លាក់ គ្រាប់បែកពីលើយន្តហោះ ។ ទាំងអស់នេះគឺវាចេញពីលទ្ធផលនៃការភ័យខ្លាច ដែលថារបបសាធារណរដ្ឋខ្មែរនឹងចាញ់នាពេលនោះ ។ ចំណុចទីពីរ គឺការជឿជាក់ដោយរដ្ឋបាលរបស់លោក និច សុន ថាបើសិនជាមានការទម្លាក់គ្រាប់បែកខ្មែរក្រហម នឹងមកចូលតុចរចា ។ នៅពេលនោះកិច្ចព្រមព្រៀងទីក្រុងប៉ារីស បានចុះហត្ថលេខាជាមួយនឹងវៀតណាមខាងជើង ហើយវាធ្វើឲ្យគោលនយោបាយសហរដ្ឋអាមេរិកនេះ គឺថាចូលរួមពាក់ព័ន្ធនៅក្នុងការទម្លាក់គ្រាប់បែក ដើម្បីឲ្យមានការដកទ័ពផងដែរនៅពេលនោះ ។ សាក្សីបន្តថា ខ្ញុំគ្រាន់តែជម្រាបអំពីហេតុផលដែលសហរដ្ឋអាមេរិកចូលពាក់ព័ន្ធក្នុងគោលបំណងចង់ឲ្យខ្មែរក្រហមចូលតុចរចា ប៉ុន្តែពុំអាចទៅរួច ។ សំណួរទីពីរ នួន ជា បានសួរថា តើអ្នកជំនាញគិតថា រដ្ឋាភិបាលអាមេរិកត្រូវទទួលខុសត្រូវលើសោកនាដកម្មដែលខ្លួនបានសាបព្រោះមកលើប្រជាជនកម្ពុជាឬទេ? ឬក៏អាងតែខ្លួនមានអំណាចដើរឈ្លានពានរំលោភប្រទេសតូចតាចតាមទំនើងចិត្ត? អ្នកជំនាញបានឆ្លើយថា វាជាការទទួលខុសត្រូវចំពោះសោកនាដកម្មលើការបំផ្លាញមនុស្សជាតិ និងបញ្ហាសម្ភារផ្សេងទៀត ។ ជាការពិតគឺត្រូវទទួលខុសត្រូវ ហើយមានការជជែកពិភាក្សាគ្នាទៅលើបញ្ហាហ្នឹង ។ លោក គីស៊ីងហ្គ័រ បានបង្ហាញជំហរ និងនិយាយពីបញ្ហានេះ ។ វាចោទជាបញ្ហាថាតើសហរដ្ឋអាមេរិកអាចជ្រៀតជ្រែកប្រទេសតូចតាចដែរឬទេ? តាមច្បាប់អន្តរជាតិគឺពុំអនុញ្ញាតឲ្យមានការជ្រៀតជ្រែកទៅលើប្រទេសតូចតាចនោះឡើយ ។

## មេធាវីការពារក្តី ខៀវ សំផន

មេធាវីអន្តរជាតិអង់គ្លា ហ្គីសសេ ការពារក្តីជនជាប់ចោទ ខៀវ សំផន បានបន្តការសួរដេញដោលរបស់ខ្លួនទាក់ទងនឹងការស្នាក់នៅក្នុងប្រទេសកម្ពុជារយៈពេលពីរឆ្នាំក្នុងនាមអ្នកកាសែត នៅមុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។ មេធាវីបានសួររំឭកដល់សាក្សីឡើងវិញ ទាក់ទងនឹងការរៀបចំទុកមុនចំពោះសុវត្ថិភាពរបស់ខ្លួននៅក្នុងពេលធ្វើទស្សនកិច្ចប្រទេសកម្ពុជាក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ សាក្សីបានបញ្ជាក់ថា ជាការពិតសហរដ្ឋអាមេរិក

មានភ្នាក់ងារគិញសម្ងាត់នៅប្រទេសដទៃៗ ដូច្នេះ តាមព័ត៌មានចារកម្មដែលទទួលបាននោះគឺថាក្រុមការងាររបស់សាក្សីនឹងមិនមានបញ្ហាអ្វីនោះទេ ដោយហេតុថា នៅដំណើរទស្សនកិច្ចរបស់អ្នកការសែតមុនៗ ទទួលបានការទទួលស្វាគមន៍ល្អ ហើយលោកស្រីបានគិតថាក្រុមរបស់ខ្លួននឹងទទួលបានដូចគ្នាដែរ ។ មេធាវីក៏បានលើកឡើងពីអ្វីដែលសាក្សីបានលើកឡើងនៅក្នុងសៀវភៅរបស់ខ្លួនថា «ជាផ្លូវការ តាមផ្លូវការសង្គ្រាមបានបង្កឲ្យមានមនុស្សស្លាប់ ២លាននាក់នៅខាង លន់ នល់ និង៦០០.០០០ នាក់នៅខាងខ្មែរក្រហម ហើយបង្កឲ្យមានរបួស ពិការជាច្រើនពាន់នាក់ផងដែរ» ។ សាក្សីបានបញ្ជាក់ពីប្រភពព័ត៌មានថា ចំនួនជនរងគ្រោះខាង លន់ នល់ លោកស្រីទទួលបានពីសាធារណរដ្ឋខ្មែរ ចំណែកខាងខ្មែរក្រហមទទួលបានពី យូ.អិន.ឌី.ភី ។ មេធាវីបានសុំឲ្យសាក្សីធ្វើការបំភ្លឺទាក់ទងនឹងអំណាចរបស់លេខាភូមិភាគ និងថ្នាក់មជ្ឈិម ។ សាក្សីបានបំភ្លឺថា ខ្លួនបានសិក្សាអំពីបញ្ហានេះទាំងមុននិងក្រោយពេលសម្ភាសន៍ជាមួយ អៀង សារី ការយកចិត្តទុកដាក់ចម្បងបំផុតមជ្ឈិមព្យាយាមគ្រប់គ្រងអំណាចត្រួតត្រាលើភូមិភាគ ។ នៅក្នុងសៀវភៅរបស់សាក្សីបាននិយាយអំពី នួន ជា ដែលបានលើកឡើងអំពីការបាត់ខ្សែអាត់នៅភូមិភាគឧត្តរ ។ ភូមិភាគឧត្តរស្ថិតនៅក្រោមការសង្ស័យរបស់មជ្ឈិម ។ ដូច្នេះការយកចិត្តទុកដាក់ក្នុងការវែកមុខបោសសម្អាត ដោយសារមានសមមិត្ត ជាតដែល នួន ជា បាននិយាយពីការបាត់បង់នូវខ្សែអាត់មួយ និងថាវាជាឧប្បត្តិហេតុមួយ និងជាកំហុសមួយដែលនាំឲ្យមានការបោសសម្អាត និងសម្លាប់ចោល ។ មជ្ឈិមបានយកចិត្តទុកដាក់ ព្រមទាំងចាប់ផ្តើមធ្វើការស្រាវជ្រាវ និងមានការបោសសម្អាត ។ ចំពោះភូមិភាគវិញ សាក្សីបានបំភ្លឺទៀតថា ភូមិភាគបូព៌ាមានភាពប្រសើរ ហើយដែលមានភស្តុតាងបង្ហាញថា មិនពាក់ព័ន្ធនឹងធនធានមនុស្ស ឬអំណាចទេ ។ សាក្សីជឿថា ភូមិភាគបូព៌ាមានបញ្ហាពាក់ព័ន្ធនឹងគោលនយោបាយ ហើយភូមិភាគផ្សេងទៀតនោះមិនច្បាស់ថាតើការប្រព្រឹត្តមកលើប្រជាជនយ៉ាងដូចម្តេច និងយកចិត្តទុកដាក់ប៉ុន្មានចំពោះគោលនយោបាយ ។ សាក្សីបន្តថា នៅភូមិភាគបូព៌ាមានការផ្ទុះឡើងនូវការរត់គេចខ្លួន ដែលកម្មាភិបាលមួយចំនួនចូលទៅក្នុងប្រទេសវៀតណាម នៅមុនពេលវៀតណាមឈ្លានពានចូលមកកម្ពុជា ។ មេធាវីបានបន្តទៅប្រធានបទមួយទៀតទាក់ទងនឹងការឈ្លានពានរបស់វៀតណាម ក៏ដូចជា គោលបំណងលេបត្របាក់ប្រទេសកម្ពុជា និងការមានគំនិតចង់គ្រប់គ្រងឥណ្ឌូចិនទាំងមូលរបស់ប្រទេសវៀតណាម ។ សាក្សីជំនាញបានឆ្លើយថា វាជាសោកនាដកម្មមួយនៅដើមសង្គ្រាម ប្រទេសវៀតណាមបានជួយដល់ខ្មែរក្រហមក្នុងការវាយប្រយុទ្ធ ប្រមូលកម្លាំង ហើយខ្មែរក្រហមបានចូលកាន់កាប់ប្រទេសកម្ពុជាតែម្តងបន្ទាប់ពីក្រុងវ៉ាស៊ីនតោនសម្រេចដកទ័ព ។ ក្រោយមក ខ្មែរក្រហមភ័យខ្លាចប្រទេសវៀតណាមធ្វើការលបវាយប្រយុទ្ធមកលើខ្លួន ក៏មានសង្គ្រាមនៅតាមព្រំដែនរវាងកម្ពុជា និង វៀតណាម ។ សាក្សីគិតថា មេដឹកនាំកម្ពុជាប្រជាធិបតេយ្យ ចូលរួមពាក់ព័ន្ធក្នុងការភ័យខ្លាច គឺកាលណាយើងនិយាយអំពីការដើរនៅតាមដងផ្លូវ មានការភ័យខ្លាចអ្វីមួយនោះមេដឹកនាំខ្មែរក្រហមខ្លាចរបៀបហ្នឹង ។ បញ្ហានៃការពិភាក្សាគ្នាកាន់តែអាក្រក់ទៅៗ មេដឹកនាំខ្មែរក្រហមបានធ្វើការស្តីបន្ទោសទៅលើវៀតណាម ដូច្នេះពួកគេគិតថាបើបុគ្គលណាមួយប្រព្រឹត្តកំហុស ត្រូវគេចោទថាជាវៀតណាម ឬជាប់ពាក់ព័ន្ធជាមួយវៀតណាម ។ ពុំមានប្រព័ន្ធយុត្តិសាស្ត្រណាមួយ ឬតុលាការ ដើម្បីបង្ហាញថា បុគ្គលណាម្នាក់ជាអ្នកប្រព្រឹត្តកំហុសនោះទេ ។ ដូច្នេះវាជារឿងសោកនាដកម្មមួយដ៏គួរឲ្យសោកស្តាយ ។ មេធាវីបានលើកឡើងពីលោក ហ៊ុន សែន (ជានាយករដ្ឋមន្ត្រីនាពេលបច្ចុប្បន្ន) និង ហេង សំរិន (ប្រធានរដ្ឋសភា) មានមុខងារនៅក្នុងរបបខ្មែរក្រហមនៅចន្លោះឆ្នាំ១៩៧៥-១៩៧៩នោះ ថាតើសាក្សីយល់ថាអ្នកទាំងនោះជាអតីតខ្មែរក្រហមដែលកំពុងកាន់អំណាចបច្ចុប្បន្ន ឬសាក្សីធ្វើការបែងចែកខុសពីនេះ ។ សាក្សីបានឆ្លើយតបថា ខ្លួនគិតថាបុគ្គលទាំងពីរជាអតីតខ្មែរក្រហម ប៉ុន្តែមេធាវីប្រហែលជាចាំខុសថា សហការីខ្លួនបាននិយាយថា កម្ពុជាប្រជាធិបតេយ្យត្រូវគេផ្តួលរំលំដោយសារ តែសម្តេច ហ៊ុន សែន និងសម្តេច ជា ស៊ីម គឺជាខ្មែរក្រហម ។ ការពិត ពួកគាត់ជាអតីតរណសិរ្ស ដែលបានជំរុញឲ្យមានការឈ្លានពានពីវៀតណាម ។ សាក្សីគិតថា វាគ្រាន់តែជាផ្នែកមួយផ្សេងតែប៉ុណ្ណោះ ។ សាក្សីបានបន្ថែមថា ពួកគាត់ជាអតីតខ្មែរក្រហម សូម្បី គាត ឈន់ ដែលជាអ្នកបកប្រែរបស់ខ្ញុំកាលពីមុនក៏ជាផ្នែកនៃរបបខ្មែរក្រហមដែរ ។ **ឌី សុជាតា**

# សវនាការស្តីពីការស្តាប់សក្ខីកម្មសាក្សី សំ សិទ្ធី

*ថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០១៥*

## ១) ប្រវត្តិសាវតាររបស់សាក្សី



សាក្សី សំ សិទ្ធី ផ្តល់សក្ខីកម្មនៅសាលាក្តីខ្មែរក្រហម

ចៅក្រម គង់ ស្រ៊ឹម ជាប្រធានអង្គជំនុំជម្រះ បានចាប់ផ្តើមសាកសួរសាក្សីនូវសំណួរមួយចំនួនទាក់ទងនឹងប្រវត្តិសាវតាររបស់សាក្សី ។ សាក្សីមានឈ្មោះ សំ សិទ្ធី កើតនៅថ្ងៃទី១៥ ខែខសភា ឆ្នាំ១៩៦១ នៅភូមិផ្អេរ ឃុំផ្អេរ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ។ ឪពុកឈ្មោះ សំ អឿន ម្តាយឈ្មោះ អ៊ឹ នី និងភរិយាឈ្មោះ ប្រាក់ សៅនី ។ បច្ចុប្បន្ន សាក្សីមានមុខងារជាអធិការក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង ។ បន្ទាប់មក អង្គជំនុំជម្រះបានផ្តល់វេទិកាជូនមេធាវីការពារក្តីដើម្បីសួរដេញដោលសាក្សី ។

## ២) ការសាកសួរដោយមេធាវីការពារក្តី នួន ជា

មេធាវីការពារក្តីអន្តរជាតិ វិកទ័រ កូប៉េ បានចាប់ផ្តើមតាំងសំណួរទៅកាន់សាក្សី ទាក់ទងនឹងការផ្តល់ការសម្ភាសន៍ និងការជម្លៀសសាក្សី និងក្រុមគ្រួសារចេញពីភូមិកំណើត ។ សាក្សី និងប្រជាជនដទៃទៀតរាប់ពាន់នាក់ ត្រូវជម្លៀសពីភូមិផ្អេរ ទៅវត្តប្រកស្តេច ដោយចំណាយពេលប្រមាណ១០ថ្ងៃ ។ ពេលទៅដល់ទីនោះ ខ្មែរក្រហមបានឃោសនាស្វែងរកអតីតទាហាន និងមន្ត្រីរដ្ឋការនៃរបប លន់ នល់ ដើម្បីចុះឈ្មោះបើកអង្ករ និងឲ្យត្រឡប់ទៅធ្វើការងារដើមវិញ ។ ក្រោយពេលសរសេរប្រវត្តិរូប និងចុះឈ្មោះបើកអង្ករ រួចមក សាក្សី និក្រុមគ្រួសារ ព្រមទាំងសាច់ញាតិរបស់សាក្សីចំនួនប្រាំពីរគ្រួសារផ្សេងទៀតត្រូវបាននាំយកទៅសម្លាប់នៅក្នុងរណ្តៅសាកសពស្ថិតនៅព្រៃរូងខ្លា ដែលសាក្សីអះអាងថា មានចម្ងាយប្រមាណជាពីរគីឡូម៉ែត្រពីវត្តប្រកស្តេច ។ ទោះបីជា សហមេធាវីអន្តរជាតិ កូប៉េ បានសួរបញ្ជាក់ថា មានចម្ងាយប្រមាណ៧០គីឡូម៉ែត្រពីទីតាំងនោះក៏ដោយ ។

សាក្សីក៏បានបន្តទៀតថា នៅពេលនោះខ្លួនមានវ័យ១៨ឆ្នាំ និងនៅចាំបានថា ខ្លួនបានធ្វើពុតជាស្លាប់ បន្ទាប់ពីម្តាយរបស់សាក្សីត្រូវយោធាខ្មែរក្រហមបាញ់សម្លាប់ក្នុងចំណោមសាកសពប្រាំពីរគ្រួសារទៀត ដែលធ្លាប់ជាទាហាន គ្រូបង្រៀន និងគ្រូពេទ្យនៅក្នុងរបប លន់ នល់ ។ សមាជិកគ្រួសារនីមួយៗ មានចំនួនមិនតិចជាងប្រាំពីរនាក់ឡើយ ។

ជាការកត់សម្គាល់ នៅពេលចាប់ផ្តើមសួរដេញដោលសាក្សី មេធាវី កូប៉េ បានរំឭកដល់សាក្សីថា នៅក្នុងកំណត់ហេតុស្តាប់ចម្លើយដែលសាក្សីបានធ្វើជាមួយសហចៅក្រមស៊ើបអង្កេតបានបញ្ជាក់ពីកាលបរិច្ឆេទនៅក្នុងឆ្នាំ២០០៨ គឺប្រហែលជាប្រាំពីរឆ្នាំមុន ។ ប៉ុន្តែសាក្សីបានអះអាងយ៉ាងច្បាស់ថា ខ្លួនបានផ្តល់បទសម្ភាសន៍ប្រហែលជាពីរឆ្នាំមុនប៉ុណ្ណោះ ។ បន្ទាប់ពីការសួរដេញដោលសាក្សីនូវសំណួរមួយចំនួនរួចមក មេធាវី កូប៉េ បានលើកឡើងថា សាក្សីបានផ្តល់សក្ខីកម្មប្រឌិត ។ សំណួររបស់មេធាវី ក៏បានផ្តោតតែលើការពណ៌នារបស់សាក្សីទាក់ទងនឹងការធ្វើពុតជាស្លាប់នៅព្រៃរូងខ្លាប៉ុណ្ណោះ ។

ប្អូនស្រីរបស់សាក្សីត្រូវយោធាខ្មែរក្រហមវាយចំត្រង់កពេលដែលធ្វើការសម្លាប់គ្រួសាររបស់សាក្សីនៅព្រៃរូងខ្លា ដែលបង្កជាគេតាណុសមិនអាចព្យាបាលជា ហើយក្រោយមកប្អូនរបស់សាក្សីមានជំងឺសសៃប្រសាទ និងធ្វើអត្តឃាតខ្លួនឯង ។

### ៣) ការសាកសួរដោយមេធាវីការពារក្តី ខៀវ សំផន

មេធាវីការពារក្តី ខៀវ សំផន បានសួរបញ្ជាក់បន្ថែមពីការផ្តល់ការសម្ភាសន៍របស់សាក្សីនាពេលកន្លងមក និងរបៀបដែលកងកម្លាំងសម្លាប់គ្រួសាររបស់សាក្សី និងប្រជាជនដទៃទៀត ។ សាក្សីបានជម្រាបជូនថា សាក្សីធ្លាប់បានផ្តល់ការសម្ភាសន៍កាលពី២ឆ្នាំមុន ជាមួយអ្នកសម្ភាសន៍៤នាក់ នៅការិយាល័យធ្វើការរបស់សាក្សីក្នុងខេត្តកំពង់ឆ្នាំង ។ សាក្សីពុំធ្លាប់ស្គាល់ក្រុមការងារដែលចុះទៅសម្ភាសន៍នោះទេ ។ តាមការបញ្ជាក់ពីមេធាវីតាមរយៈខ្សែអាត់ដែលបានចាក់ជូនអង្គជំនុំជម្រះបង្ហាញថា សាក្សីបានផ្តល់ការសម្ភាសន៍តែម្តងគត់កាលពី៧ឆ្នាំមុន ពុំមែន២ឆ្នាំមុន ដូចការអះអាងរបស់សាក្សីឡើយ ។

សាក្សី សំ សិទ្ធី បញ្ជាក់សាជាថ្មីថា ពេលដែលខ្មែរក្រហមបើករបបអង្គរឲ្យប្រាំពីរគ្រួសារ ដែលបានចុះឈ្មោះ ហើយក្នុងចំណោមនោះធ្លាប់ជា គ្រូពេទ្យ គ្រូបង្រៀន ឬទាហាន រួចហើយ ឈ្លបពនាក់បាននាំប្រាំពីរគ្រួសារនោះដោយកុហកថា ទៅសហករណ៍ដើម្បីរស់នៅ ។ ពេលធ្វើដំណើរដល់អូរមួយ ឈ្លប២នាក់នៅយាមប្រពន្ធកូន ហើយឈ្លបម្នាក់បាននាំប្រុសៗឆ្លងអូរ ហើយកុហកថា ទៅកាប់ព្រៃធ្វើកន្លែងស្នាក់ ។ ពេលនោះសាក្សីបានតាមឪពុកទៅជាមួយ ប៉ុន្តែត្រូវកងឈ្លបទាំងនោះដេញត្រឡប់មកវិញ ។ នៅពេលដល់ត្រើយម្ខាងទៀតក៏មានយោធាខ្មែរក្រហមមួយក្រុមចេញមកហើយបណ្តើរប្រុសៗទាំងអស់ទៅ ។ បន្ទាប់មក សាក្សីបានឮសំឡេងកាំភ្លើង ក៏ប្រញាប់រត់មកប្រាប់ម្តាយថា «គេបាញ់សម្លាប់ពុកហើយ ឲ្យនាំគ្នារត់ទៅ» ប៉ុន្តែគ្មានអ្នកណាជឿទេ ។ បន្តិចក្រោយមក កងឈ្លបក៏នាំស្ត្រី និងក្មេងៗឆ្លងអូរជាបន្តបន្ទូលដល់ព្រៃរូងខ្លា កងកម្លាំងក៏ភ្ជង់ពួកគាត់ទាំងអស់ និងបង្គាប់ឲ្យអង្គុយចុះ រួចបាញ់សម្លាប់ ។ សាកសពទាំងអស់ត្រូវអូសទម្លាក់ក្នុងរណ្តៅ ។ សាក្សីបន្តទៀតថា ជាភ័ព្វសំណាងខ្លួនអង្គុយនៅក្រោយម្តាយ ពេលដែលកងកម្លាំងបាញ់មកត្រូវចំដើមទ្រូងម្តាយដែលនៅពីមុខ ហើយម្តាយសាក្សីក៏ដួលពីលើខ្លួន ទើបសាក្សីធ្វើពុតជាស្លាប់ ហើយបានរួចរស់ជីវិត ។ សាក្សីបានបន្ថែមថា បន្ទាប់ពីកងកម្លាំងទៅអស់ ខ្លួនបានបម្រះចេញពីគំនរសាកសព និងបានស្រែកហៅក្រែងមានអ្នកណានៅរស់ ។ ជាសំណាងល្អ នៅមានបងប្អូនជីដូនមួយ២នាក់ និងប្អូនស្រីបង្កើតរបស់សាក្សីម្នាក់ដែលនៅរស់រានមានជីវិត ។

### ៤) ការសាកសួរដោយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី

ឆ្លើយតបនឹងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី បន្ទាប់ពីសាក្សីរួចជីវិតត្រឡប់មកដល់វត្តប្រកស្តេច បានជួបនឹងមិត្តភក្តិរបស់ឪពុកម្តាយសាក្សី ហើយអ្នកទាំងនោះបានសួររកពួកគាត់ ។ សាក្សីបានប្រាប់ថា ឪពុកម្តាយខ្លួនត្រូវគេសម្លាប់អស់ហើយ ។ ក្រោយពីឮដំណឹងនេះក៏មានការជ្រួលច្របល់ បន្ទាប់មក យោធាខ្មែរក្រហមបានប្រកាសថា «កុំឲ្យជឿឃោសនារបស់ សេ.អ៊ី.អា ព្រោះយើងកំពុងតាមចាប់ពួកគេ» ។

### ៥) ការសាកសួរដោយសហព្រះរាជអាជ្ញា

បន្ទាប់ពីការសាកសួរពីមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីតំណាងសហព្រះរាជអាជ្ញាជាតិបានសួរសាក្សីថា សក្ខីកម្មដែលសាក្សីផ្តល់ជូននេះជាការពិត ឬប្រឌិត ។ សាក្សីបានបញ្ជាក់ថា ខ្លួនមិនបានឆ្លើយប្រឌិតដូចដែលមេធាវីការពារក្តីលើកឡើងទេ ព្រោះសាក្សីបានឃើញ និងឆ្លងកាត់ដោយផ្ទាល់ ហើយសាក្សីក៏បានស្បថរួចហើយមុនចូលមកផ្តល់សក្ខីកម្មនេះ ។

សាក្សី សំ សិទ្ធី បានឆ្លើយតបជូនសហព្រះរាជអាជ្ញាអន្តរជាតិ នីកូឡាស គុំជាន ស្តីពីស្ថានភាពរបស់ខ្លួន បន្ទាប់ពីសាក្សីចាកចេញពីវត្តប្រកស្តេច តាមការដឹកនាំបែងចែករបស់កម្មាភិបាលខ្មែរក្រហម ។ នៅពេលដែលសាក្សីមករស់នៅឃុំក្រាំងល្វា សហករណ៍ត្រាំងគ្រោះមេកងចាត់ឲ្យសាក្សីនៅមណ្ឌលកុមារ និងធ្វើកិច្ចការដូចជា រើសអាចម៍គោ កាប់ទន្ទ្រានខែត្រចិញ្ច្រាំធ្វើជីដាក់ស្រែ និងឃ្វាលគោ ។ នៅឆ្នាំ១៩៧៥ សាក្សីបានចងគោបង្អត់ស្មៅ មេកងក៏ចាប់សាក្សីឃុំនៅមន្ទីរឃុំក្រាំងល្វា ។ នៅមន្ទីរឃុំឃាំងក្រាំងល្វា មានអ្នកទោសសុទ្ធតែជាមនុស្សប្រុសប្រហែល១០ ទៅ១២នាក់ ។ សាក្សីត្រូវឃុំនៅមន្ទីរឃុំឃាំងរយៈពេលប្រមាណ២ខែ ពេលប្រធានសហករណ៍មកមន្ទីរបានឃើញសាក្សី ក៏បញ្ជាឲ្យមេឈ្លបដោះលែង ហើយឲ្យសាក្សីមើលគោរបស់គាត់នៅសហករណ៍វិញ ។

សាក្សីជាប្រជាជនថ្មីពុំមានសិទ្ធិសេរីភាពដូចអ្នកមូលដ្ឋានចាស់ទេ ។ ក្នុងពេលធ្វើការអ្នកមូលដ្ឋានចាស់គ្រប់គ្រងលើប្រជាជនថ្មី ហើយសាក្សីគ្មានសិទ្ធិឈប់សម្រាកតាមចិត្ត ឬទៅផ្ទះដាច់ខាត ។ ក្នុងអំឡុងពេលនីតិវិធីសវនាការ មានការជំទាស់ជាច្រើនដងពី

មេធាវីការពារជនជាប់ចោទថា រាល់សំណួរដែលលើកឡើងដោយសហព្រះរាជអាជ្ញា មិនមានពាក់ព័ន្ធនឹងអង្គហេតុ ។

សហព្រះរាជអាជ្ញាបានសួរឲ្យសាក្សីបញ្ជាក់ពីពាក្យថា ខ្មាំង ។ សាក្សីបានបង្ហាញថា "ខ្មាំង" គ្រាន់តែល្មួចដំឡូង ក៏គេចាត់ថា ជាខ្មាំងដែរ ។ សាក្សីបានឃើញខ្មែរក្រហមប្រមូលអ្នកទោសជាច្រើននាក់ដើរជាខ្សែៗ ពេលសាក្សីមើលគោនៅចុងភូមិតាំងគ្រោះ ។

## ៦) ការសាកសួរបញ្ចប់ដោយអង្គជំនុំជម្រះតុលាការ

អង្គជំនុំជម្រះ បានសួរសាក្សីពីរបៀបដែលកងកម្លាំងខ្មែរក្រហមបាញ់សម្លាប់គ្រួសារសាក្សី និងប្រជាជនផ្សេងទៀតនៅព្រៃរូងខ្លា កម្រិតនៃការសិក្សារបស់សាក្សី និងរបបអាហារក្នុងការធ្វើដំណើរពេលជម្លៀស ។

សាក្សីបានរៀបរាប់ពីវិធីដែលខ្មែរក្រហមសម្លាប់ប្រជាជនទាំងប្រាំពីរគ្រួសារថា កងកម្លាំងខ្មែរក្រហមបណ្ដើរក្រុមបុរសៗដែលពេញកម្លាំងយកទៅសម្លាប់ជាមុន រួចទើបត្រឡប់មកយកក្រុមស្ត្រី និងក្មេងៗទៅតាមក្រោយ ។ នៅពេលចូលដល់ព្រៃរូងខ្លា យោធាខ្មែរក្រហមទាំងនោះបញ្ជាឲ្យប្រជាជនទាំងប្រាំពីរគ្រួសារអង្គុយជារង្វង់ ហើយពួកខ្មែរក្រហមឈរភ្ជង់កាំភ្លើងព័ទ្ធជុំវិញ ទើបបាញ់សម្លាប់ និងអូសសាកសពទាំងអស់ទម្លាក់ចូលរណ្ដៅរួម ។

ចំណែកឯការរៀនសូត្រ សាក្សីរៀនបានត្រឹមថ្នាក់ទី៨ ពីសម័យ លន់ នល់ ដែលកាលពីសម័យនោះ ប្រព័ន្ធអប់រំគេគិតរាប់ចាប់ពីថ្នាក់ទី១២ បន្តមកថ្នាក់ទី១១ ទី១០ជាបន្តបន្ទាប់ ។ ក្រោយពីជម្លៀសថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ សាក្សីក៏ដូចជាប្រជាជនផ្សេងៗទៀត ក៏ត្រូវបញ្ឈប់ការសិក្សា ហើយប្រព័ន្ធអប់រំពីរបប លន់ នល់ ត្រូវបំផ្លាញចោលទាំងស្រុង ។ សាក្សីបានប្រាប់ទៀតថា នៅពេលធ្វើដំណើរជម្លៀសពីភូមិផ្សេរ ទៅវត្តប្រកស្ដេច ក្នុងខេត្តកំពង់ឆ្នាំង សាក្សី និងក្រុមគ្រួសារទទួលបានអាហារតែ២ពេល គឺថ្ងៃត្រង់ និងល្ងាច មានជាប្រហុក ត្រីឆ្អើរ អំបិល ដែលរៀបចំធ្វើដោយឪពុកម្ដាយរបស់សាក្សី ។ អង្គជំនុំជម្រះបានបញ្ចប់ការសាកសួរសាក្សី សំ សិទ្ធី នៅល្ងាចថ្ងៃដដែល និងប្រកាសបន្តស្ដាប់សក្ខីកម្មសាក្សី១រូបទៀត នៅថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០១៥ ។

**ឌី សុជាតា និង ឌិន ជួងចន្ទ្រាកែវលក្ខីនារីរតន៍**



នួន ជា (រូបពាក់វ៉ែនតាខ្មៅ) ជនសង្ស័យនៅក្នុងសំណុំរឿង០០២ នៅក្នុងបន្ទប់សវនាការ

# សវនាការស្តីពីការស្តាប់សក្ខីកម្មសាក្សី ទ័ត ធឿន

***ថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០១៥***

**១) ការតាំងសំណួរដោយប្រធានអង្គជំនុំជម្រះ**

ប្រធានអង្គជំនុំជម្រះតុលាការកំពូល ចៅក្រម គង់ ស្រ៊ីម បានចាប់ផ្តើមតាំងសំណួរទាក់ទងនឹងប្រវត្តិសាវតា និងអត្តសញ្ញាណខ្លះៗរបស់សាក្សី ។ សាក្សីមាន ឈ្មោះ ទ័ត ធឿន កើតនៅខែមករា ឆ្នាំ១៩៥៥ នៅភូមិកង់ហត ឃុំកន្ទួល ស្រុកបាណន់ ខេត្តបាត់ដំបង ។ បច្ចុប្បន្ន សាក្សីមានតួនាទីជាឧត្តមសេនីយ៍ត្រី នៅកងយុទ្ធពលខេមរភូមិន្ទ ។ ឪពុកឈ្មោះ ឡឹក ទ័ត (ស្លាប់) ម្តាយឈ្មោះ យុង សៀម (ស្លាប់) និងភរិយាទី១ឈ្មោះ យុង សួរ (ស្លាប់) មានកូន ៥នាក់ ។ ភរិយាបច្ចុប្បន្ន ឈ្មោះ ជូ ចាន់ថន មានកូន២នាក់ ។ សព្វថ្ងៃ សាក្សីរស់នៅ ភូមិចម្ការសំរោង២ សង្កាត់ចម្ការសំរោង ក្រុងបាត់ដំបង ខេត្តបាត់ដំបង ។

**២) ការសួរដេញដោលដោយមេធាវីការពារក្តី**

**២.(១) មេធាវីការពារក្តី នួន ជា**

សហមេធាវីអន្តរជាតិ វ៉ិចទ័រ កូប៉េ ជាមេធាវីការពារក្តី នួន ជា បានចាប់ផ្តើមសំណួររបស់ខ្លួនទាក់ទងនឹងឈ្មោះដើមរបស់សាក្សី ព្រមទាំងប្រវត្តិ និងតួនាទីរបស់សាក្សី នៅមុន និងក្រោយរបបកម្ពុជាប្រជាធិបតេយ្យ ។ សាក្សីមានឈ្មោះកំណើត ឈ្មោះ ធូ ម៉ាង ក្រោយមកមានឈ្មោះ ហំ និងឈ្មោះ ធឿន នាពេលបច្ចុប្បន្ន ។ សាក្សីធ្លាប់ជាកូនធម៌របស់ រស់ ញឹម អតីតលេខាភូមិភាគពាយ័ព្យ ។ សាក្សីបានស្គាល់ រស់ ញឹម តាំងពីឆ្នាំ១៩៦០ ដែលកាលនោះ រស់ ញឹម បានទៅស្នាក់នៅចម្ការស្ថិតនៅក្នុងព្រៃរបស់សាក្សីជាញឹកញាប់ ហើយសាក្សីគោរព រស់ ញឹម ដូចជាឪពុកបង្កើតដែរ ។

សាក្សីដឹងថា រស់ ញឹម មានកូនបង្កើតបីនាក់ ឈ្មោះ ដាល ហៅ ឆ្នាំង ឈ្មោះ ធី និងឈ្មោះ កញ្ច្រែង (ស្រី) ។ រស់ ញឹម មានកូនធម៌ និងកូនចិញ្ចឹមជាច្រើននាក់រួមមានឈ្មោះ ឡឹក សឿត ហៅ វង្ស, ឈ្មោះ ខួង, ឈ្មោះ ណាម, ឈ្មោះ ធូ ឈ្មោះ ហ៊ីង និងសាក្សី ។ ឡឹក សឿត មានតួនាទីជាមេបញ្ជាការនៅភូមិភាគពាយ័ព្យ និងក្រោយមកជាលេខាតំបន់លេខ៤ ។ ដាល ជាកូនប្រុសច្បងរបស់ រស់ ញឹម ជាអនុលេខាតំបន់លេខ៥ និងត្រូវជាកូនប្រសាររបស់ សោ ភឹម ជាអតីតលេខាភូមិភាគបូព៌ា ។



*សាក្សី ទ័ត ធឿន ផ្តល់សក្ខីកម្មនៅសាលាក្តីខ្មែរក្រហម*

សាក្សីបានរៀបរាប់ពីប្រវត្តិតួនាទីរបស់ខ្លួនដូចតទៅ នៅខែមីនា ឆ្នាំ១៩៧០ សាក្សីធ្វើជាទាហាន ឆ្នាំ១៩៧៣ សាក្សីបានធ្វើជាប្រធាននីរសារ រត់សំបុត្រពីភូមិភាគទៅតំបន់ និងមានសមាជិក៣នាក់ ។ ក្នុងតួនាទីនេះសាក្សីក៏ទទួលបន្ទុកការពារ រស់ ញឹម នៅមន្ទីរ-២០ ដែលជាសមរភូមិក្រោយដែរ ។ នៅឆ្នាំ១៩៧៥ សាក្សីបានក្លាយជាអនុប្រធានសេនាធិការប្រចាំភូមិភាគពាយ័ព្យ ទទួលខុសត្រូវផ្នែកភស្តុភារ និងដាំដុះស្រូវ ។ នៅឆ្នាំ១៩៧៦ ថ្នាក់លើបានបញ្ជូនសាក្សីទៅប្រទេសចិនដើម្បីបណ្តុះបណ្តាលឲ្យក្លាយជាអាកាសយានិក ។

សាក្សីបានឆ្លើយប្រាប់ជូនមេធាវីការពារក្តីអន្តរជាតិ ពាក់ព័ន្ធនឹងអ្នកដឹកនាំក្នុងការវាយរំដោះ និងដោតវាសនារបស់ទាហាន លន់ នល់ ក្រោយទទួលបរាជ័យថា នៅខែមេសា ឆ្នាំ១៩៧៥ រស់ ញឹម ជាអ្នកដឹកនាំកងទ័ពវាយចូលស្វាយសីសុផុន ពោធិ៍សាត់ និងបាត់ដំបង ដោយមានឈ្មោះ ខ្វៃង ជាសេនាធិការ និងមានកងពលប្រយុទ្ធបែងចែកគ្នាជាពីរកងពល គឺកងពល១០០៧ និង១០០៦ ។ ក្រោយថ្ងៃរំដោះ តាវ៉ាញ បានអំពាវនាវតាមវិទ្យុឲ្យទាហានលន់នល់ដាក់អាវុធ ហើយប្រជាជនក៏បានអបអរសាទរចំពោះសេចក្តីប្រកាសនេះ ។ បន្ទាប់មកទៀត ប្រជាជនក៏ត្រូវជម្លៀសឲ្យធ្វើដំណើរចូលទៅក្នុងព្រៃ ហើយក៏មានការប្រកាសប្រមូលទាហាន លន់ នល់ ដឹកតាមរថយន្តជាច្រើនគ្រឿង ដោយបញ្ឆោតថានាំទៅទទួលសម្តេចសីហនុ ។ ពេលនោះសាក្សីមានការអាក់អន់ចិត្ត ដែលខ្លួនខំតស៊ូប្រយុទ្ធវាយរំដោះប្រទេស តែមិនទទួលបានឱកាសទៅចូលរួមទទួលព្រះមហាក្សត្រ ក្រោយមកទើបសាក្សីដឹងថា ទាហានលន់នល់ ដែលអង្គការឲ្យទៅទទួលសម្តេចនោះ តាមពិតគឺយកទៅសម្លាប់នៅទួលពោធិ៍ជ្រៃ ។ សាក្សីមិនបានដឹងថា អ្នកណាជាអ្នកបញ្ជា ឬសម្លាប់ទាហាន លន់នល់ ព្រោះនៅពេលនោះសាក្សីជានីសារទទួលខុសត្រូវតែការរត់សំបុត្រ ។ ទោះជាយ៉ាងនេះក្តី សាក្សីក៏បានឮតាមរយៈកិច្ចប្រជុំដែលធ្វើឡើង ក្រោយថ្ងៃរំដោះ នៅប្រាបក្រសាំងខាងលិចខេត្តបាត់ដំបង ស្តីពីផែនការកម្ទេចពួកអតីតចក្រពត្តិ និងពួកសក្តិភូមិ ។ បន្ទាប់ពីមេធាវីការពារក្តីបានបង្ហាញរូបថតស្តីពីព្រឹត្តិការណ៍ជាក់លាក់មួយ នៅទួលពោធិ៍ជ្រៃ ដែលមានការកាត់ក្បាលទាហានខ្មែរក្រហម ពីសំណាក់ទាហាន លន់ នល់ នៅក្នុងអំឡុងពេលសង្គ្រាមស៊ីវិលឆ្នាំ១៩៧០ ដល់១៩៧៥ ព្រោះវានឹងមានភាពពាក់ព័ន្ធនៅក្នុងសំណុំរឿងដែលអាចជាមូលហេតុនាំឲ្យមានការសងសឹកក្រោយពីទាហានខ្មែរក្រហមទទួលបានជ័យជម្នះ ជាការឆ្លើយតបសាក្សីមិនបានដឹងពីហេតុការណ៍នោះឡើយ ។

យោងតាមចម្លើយដែលសាក្សីបានផ្តល់ជូនសហចៅក្រមស៊ើបអង្កេតពាក់ព័ន្ធនឹងការយល់ឃើញរបស់គណៈភូមិភាគពាយ័ព្យក្រោយប្រទេសបានរំដោះពីរបប លន់ នល់ បង្ហាញថា មុនសន្និបាតនៅភ្នំពេញ សាក្សីបានឮគណៈភូមិភាគពាយ័ព្យរួមមាន តាញឹម តាតុំ តាគី តាម៉ៃ ជជែកគ្នារាល់ពេលជួបជុំគ្នាក្រៅផ្លូវការ ពីការមិនពេញចិត្តបន្ទាប់ពីការរំដោះ ចំពោះការជម្លៀសប្រជាជនចេញ ហើយពួកគាត់ថែមទាំងបានលើកឡើងថា «លើពិភពលោកចប់សង្គ្រាម វាមានតែវិនាសកម្មហិនហោច» ។

មេធាវីការពារក្តីអន្តរជាតិបានសួរសាក្សីជាបន្តទាក់ទងនឹងការប្រមូលអាវុធយកទៅលាក់ទុក និងគោលបំណងនៃការលាក់នេះ ។ សាក្សីបានរៀបរាប់តបទៅកាន់មេធាវីថា បន្ទាប់ពីការវាយរំដោះទទួលបានជោគជ័យនាឆ្នាំ១៩៧៥ រស់ ញឹម បានឲ្យសាក្សីប្រមូលអាវុធប្រមាណ២ម៉ឺនដើមរបស់ទាហាន លន់ នល់ ដែលបានដាក់អាវុធចុះចាញ់ទាហានខ្មែរក្រហមយកទៅរក្សាទុកនៅឃ្លាំងក្នុងព្រៃឫស្សី ព្រោះនៅពេលនោះរដូវវស្សាជិតចូលមកដល់ បន្ទាប់មកដើមឫស្សីនឹងដុះពពាក់ពពូនគ្នាជាច្រើនដើម ដែលអាចជារនាំងបិទបាំងឃ្លាំងសម្រាប់រក្សាទុកអាវុធទាំងនោះ មិនងាយឲ្យអ្នកណាដឹងនិងចូលមកដល់បាន ។

សាក្សីបានប្រាប់ជាបន្តថា នៅឆ្នាំ១៩៧៨ សាក្សីត្រូវបានអង្គការបញ្ជាឲ្យចាប់ខ្លួនពីរលើក ។ លើកទី១ អង្គការចាប់ច្រឡំអ្នកផ្សេងដែលមិនមែនជាសាក្សី ហើយលើកទី២ សាក្សីក៏ត្រូវបានចាប់ខ្លួន ដោយអង្គការចោទប្រកាន់សាក្សីថា ជាខ្សែរយៈរបស់វៀតណាម ។ បន្ទាប់ពីសាកសួរចម្លើយសាក្សី អង្គការមិនមានអ្វីជាមូលដ្ឋាននិងភស្តុតាងដែលកំណត់ថា សាក្សីជាគិញរបស់វៀតណាម ទើបសម្រេចដោះលែងសាក្សីឲ្យមានសេរីភាពឡើងវិញ ។ បន្ទាប់ពីត្រូវបានដោះលែងសាក្សីក៏មកសួរឪពុកធម៌ថា «ម៉េចបានចាប់ខ្ញុំ» រស់ ញឹម តបថា «មិនដឹងទេ ពុកមិនដែលចាប់កូនខ្លួនឯងទេ» ។ បន្ទាប់ពីថ្ងៃនោះមក សាក្សីគិតថា មិនអាចរស់នៅ និងគោរពតាមការណែនាំក្រោមរបបកម្ពុជាប្រជាធិបតេយ្យតទៅទៀតបានទេ ព្រោះសាក្សីអស់ទំនុកចិត្តជាមួយអង្គការបដិវត្តន៍ ហើយសាក្សីក៏បានមើលឃើញថា យុទ្ធមិត្តដែលជាអ្នកតស៊ូជាមួយសាក្សីជាច្រើននាក់ត្រូវបានបាត់ខ្លួន ។ ដូច្នេះ សាក្សីបានទៅប្រមូលអាវុធដែលលាក់ទុកក្នុងព្រៃឫស្សីមកចែកចាយ កសាងជាកម្លាំងជាមួយអតីតកងទ័ពដែលស្ម័គ្រចិត្តចូលរួមជាមួយសាក្សីមានចំនួនប្រហែល២ម៉ឺននាក់ ។ ដំបូងសាក្សីដឹកនាំកងទ័ពដើម្បីទៅលួចយកអង្ករពីសហករណ៍សម្រាប់ផ្គត់ផ្គង់តម្រូវការអាហារក្នុងមូលដ្ឋានរបស់សាក្សីតែប៉ុណ្ណោះ តែក្រោយពីបានឃើញពីភាពអមនុស្សធម៌នៃគោល

នយោបាយដឹកនាំរបស់អង្គការបដិវត្តន៍ ទើបសាក្សីកសាងជាកម្លាំង ដើម្បីបះបោរប្រឆាំងនឹងថ្នាក់មជ្ឈិម ។ សាក្សីស្នើសុំ តាប៉ែត តាគី និង តាញឹម ដែលជាគណៈភូមិភាគពាយ័ព្យ ឲ្យមកធ្វើមេដឹកនាំប្រមូលកម្លាំងតស៊ូក្នុងព្រៃរួមគ្នាប្រឆាំងអង្គការបដិវត្តន៍ តែពួកគាត់បដិសេធមិនចូលរួមជាមួយសាក្សី ។ បន្ទាប់ពីថ្នាក់លើដកយកទាហានដែល រស់ ញឹម គ្រប់គ្រងទៅអស់ រស់ ញឹម ក៏បានមកជួបសាក្សី នៅព្រៃឬស្សី ដើម្បីស្នើសុំទាហានរបស់សាក្សីចំនួន៣០០នាក់ សម្រាប់ទុកការពារខ្លួន បារម្ភខ្លាចអង្គការបដិវត្តន៍ចេញបញ្ជាចាប់ខ្លួន ។

## ៣) ការសួរដេញដោលដោយមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី

សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ម៉ារី ហ្គីរេ បានតាំងសំណួរទៅសាក្សី ទាក់ទងនឹងបទពិសោធន៍ដែលសាក្សីធ្លាប់បានទទួលការបណ្តុះបណ្តាលនៅបរទេស ។ សាក្សីបានប្រាប់ថា នៅខែមករា ឆ្នាំ១៩៧៦ សាក្សីត្រូវបានអង្គការបញ្ជូនទៅសិក្សានៅប្រទេសចិន រៀនបើកបរយន្តហោះទម្លាក់គ្រាប់បែក ។ ក្រោយមកសាក្សីបានត្រឡប់មកប្រទេសវិញ ហើយមិនព្រមទៅបន្តការសិក្សាដែលជាហេតុធ្វើឲ្យ រស់ ញឹម ដែលជាឳពុកធម៌ខកបំណង និងមិនសប្បាយចិត្ត ។ រស់ ញឹម បានព្យាយាមជំរុញសាក្សី ឲ្យទៅបន្តការសិក្សាផ្នែកបើកបរយន្តហោះទម្លាក់គ្រាប់បែកនេះឲ្យបានចប់ ដើម្បីវាយរំដោះយកទឹកដីកម្ពុជាដែលបាត់បង់មានដូចជា ទឹកដីកម្ពុជាក្រោម ទឹកដីសុរិន្ទ និងនគររាជដូនមាតុភូមិវិញ ។ ទោះបីជាយ៉ាងណាសាក្សីបដិសេធមិនទៅបន្តការសិក្សាជាដាច់ខាត ដោយបាននិយាយទៅកាន់ រស់ ញឹម ថា "មិនទៅទេ ព្រោះយុទ្ធមិត្តបាត់អស់ហើយ ខ្ញុំមិនទៅងាប់ចោលឆ្អឹងស្រុកគេទេ ខ្ញុំគ្មានចិត្តអីនឹងរៀនតទៀតទេ ទោះបីសម្លាប់ខ្ញុំ ក៏ខ្ញុំមិនទៅដែរ" ។ បន្ទាប់ពីការបដិសេធដាច់ខាតរបស់សាក្សី រស់ ញឹម ក៏បានបញ្ជាឲ្យសាក្សីទៅធ្វើជីលាមក ។ ក្រោយមកនៅឆ្នាំ១៩៧៩ ទ័ត ធឿន មានឱកាសបានទៅបន្តការសិក្សានៅសហភាពសូវៀត រយៈពេល១០ខែ ។

ទាក់ទងនឹងកម្មាភិបាលជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ សាក្សី ទ័ត ធឿន បានប្រាប់ឲ្យដឹងថា នៅមុនពេលលោកចេញទៅរៀននៅប្រទេសចិន ក្នុងឆ្នាំ១៩៧៦ ធ្លាប់មានកម្មាភិបាលមកពីថ្នាក់មជ្ឈិមចុះមកពិនិត្យនៅភូមិភាគពាយ័ព្យ តែលោកមិនបានឃើញឲ្យច្បាស់ថា មានវត្តមានបុគ្គលណាខ្លះទេ ព្រោះពួកគាត់ជិះក្នុងរថយន្តបិទកញ្ចក់ពណ៌ខ្មៅជិត ។ សាក្សីបានឲ្យដឹងបន្ថែមស្តីពីទំនាក់ទំនងរវាង រស់ ញឹម និង នួន ជា ដែលជាអនុលេខាបក្សកុម្មុយនីស្តកម្ពុជាថា នួន ជា និង រស់ ញឹម ជាមិត្តភក្តិនឹងគ្នាដែលធ្លាប់បួសរៀននៅប្រទេសថៃ ។

## ៤) ការសាកសួរដោយតំណាងសហព្រះរាជអាជ្ញាជាតិ

តំណាងសហព្រះរាជអាជ្ញាជាតិ បានសួរទៅកាន់សាក្សីឲ្យឆ្លើយបញ្ជាក់បន្ថែមទាក់ទងនឹងសេចក្តីប្រកាសជូនដំណឹងក្រោយថ្ងៃរំដោះ ។ សាក្សីបានឆ្លើយប្រាប់ថា តាវ៉ាញ ជាប្រធានតំបន់២ និងជាសាស្ត្រាចារ្យទទួលបន្ទុកបញ្ជូនវិទ្យុក្នុង ទើបថ្នាក់លើចាត់ឲ្យនិយាយផ្សព្វផ្សាយតាមប្រព័ន្ធឃោសនាស័ព្ទថា "ប្រទេសបានរំដោះហើយរបបចក្រពត្តិដួលរលំហើយ សម្តេច សីហនុ បានមកគ្រប់គ្រងប្រទេសវិញហើយ សង្គ្រាមបានចប់ត្រឹមណឹង ហើយសូមឲ្យស្តាប់តាមការអំពាវនាវរបស់រណសិរ្ស" ។ បន្ទាប់ពីបានឮការប្រកាសនេះ កងទាហាន លន់ នល់ នៅស្វាយត្រាណ ក្នុងខេត្តបាត់ដំបង បានដាក់អាវុធចុះចាញ់នៅ រប៉ាត់រប៉ាយពាសពេញផ្លូវ ។

សាក្សី ទ័ត ធឿន បានឆ្លើយតបជាបន្តចំពោះការសាកសួរបន្ថែមដោយតំណាងសហព្រះរាជអាជ្ញាជាតិ ទៅលើសកម្មការងាររបស់សាក្សីពេលធ្វើជានីរសារឲ្យកម្មាភិបាលភូមិភាគពាយ័ព្យថា នៅពេលបើកយុទ្ធនាការវាយរំដោះប្រទេស សាក្សីបានបញ្ជូនសំបុត្រពីភូមិភាគទៅមជ្ឈិមពីរដងទៅបីដងក្នុងមួយថ្ងៃ ។ សាក្សីក៏ធ្លាប់បានយកសំបុត្រ និងអាហារ មានដូចជា អង្ករ ផ្លែឈើ ពី រស់ ញឹម បញ្ជូនឲ្យឈ្មោះ ប៉ង់ នៅកន្លែងនីរសារស្ថិតនៅខាងមុខវាំង នៅក្រុងភ្នំពេញ ។ ទាក់ទងនឹងការបញ្ជូនជនជាតិវៀតណាម ក្រោយថ្ងៃរំដោះ សាក្សីបានប្រាប់ថា សាក្សីធ្លាប់បានអនុវត្តតាមការបញ្ជាពីថ្នាក់លើឲ្យបញ្ជូនជនជាតិវៀតណាម ត្រឡប់ទៅប្រទេសវៀតណាមវិញ តាមកាណូតពីសាលាតាខន ខេត្តបាត់ដំបង ឆ្លងកាត់តាមទន្លេសាប និងបានចូលជួប ប៉ង់ នៅភ្នំពេញ ដើម្បីទទួលលិខិតអនុញ្ញាត ទើបបន្តដំណើរឆ្ពោះទៅក្អមសំណ ប្រទេសវៀតណាម ។

## ៥) ការសាកសួរដោយសហចៅក្រមនៃអង្គជំនុំជម្រះ

នៅមុនបញ្ចប់ការផ្តល់សក្ខីកម្មរបស់ សាក្សី ទ័ត ធឿន សហចៅក្រមនៃអង្គជំនុំជម្រះ បានសាកសួរសាក្សីទាក់ទិននឹងការប្រជុំ

ស្តីពីគោលការណ៍ណែនាំរបស់ថ្នាក់ភូមិភាគមកថ្នាក់តំបន់ និងរចនាសម្ព័ន្ធគ្រប់គ្រងផ្សេងៗ ដែលសាក្សីបានដឹង ហើយនិងសកម្មភាពដែលសាក្សីប្រមូលផ្តុំទាហាននៅក្នុងព្រៃដើម្បីប្រឆាំងអង្គការ ។

ជាការឆ្លើយបញ្ជាក់ជូនសហចៅក្រម នៃអង្គជំនុំជម្រះ សាក្សី ទ័ត ធឿន បានរៀបរាប់ថា នៅពេលដែលសាក្សីជានីរសារ និងអនុសេនាធិការពុំដែលបានចូលរួមវគ្គបណ្តុះបណ្តាលទេ គ្រាន់តែបានឮ និងបានដឹងពីគោលនយោបាយរបស់គណៈភូមិភាគ ព្រោះសាក្សីតែងតែដើរតាមគណៈភូមិភាគជាប់ជាប្រចាំ ។ សាក្សីបានប្រាប់ថា គោលនយោបាយរបស់អង្គការមុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ បង្ហាញថា បដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យ មានគោលដៅរំដោះប្រទេសជាតិ ។ ក្រោយថ្ងៃរំដោះឆ្នាំ១៩៧៥ គណៈភូមិភាគបានចុះបង្រៀនថ្នាក់តំបន់ និយាយពីបដិវត្តន៍សង្គមនិយម មហាលោតផ្លោះ មហាអស្ចារ្យ ដោយណែនាំឲ្យបង្កើតជាសហករណ៍ ។ នៅក្នុងការប្រជុំក្រោយរំដោះមាន រស់ ញឹម ជាប្រធានអង្គប្រជុំ ដោយមាន តាកី ជាអ្នកអត្ថាធិប្បាយ និងកម្មាភិបាលភូមិភាគផ្សេងទៀតចូលរួម ។ គោលការណ៍នៃការប្រជុំ មានការបញ្ជាពីថ្នាក់លើថា ឲ្យប្រជាជនត្រឡប់ទៅផ្ទះវិញ ឈប់ឲ្យមានការវាយប្រយុទ្ធគ្នា ។

សាក្សីបានប្រាប់អំពីរចនាសម្ព័ន្ធរបស់កងកម្លាំងខ្មែរក្រហមជូនអង្គជំនុំជម្រះថា កងទ័ពមានស្នងការ ទទួលខុសត្រូវខាងចាត់តាំង និងបញ្ជាការទទួលបន្ទុកខាងដឹកនាំវាយប្រយុទ្ធ ហើយថ្នាក់ភូមិភាគមានលេខាសម្រាប់ដឹកនាំគ្រប់គ្រងប្រជាជន ។ សាក្សីបានឲ្យដឹងបន្ថែមថា មន្ទីរ-២០ ក្រោយមកបានប្តូរមកជាមន្ទីរ៥៦០ ស្ថិតនៅក្រោមការគ្រប់គ្រង និងណែនាំពីថ្នាក់ភូមិភាគ ។ ចំណែកនៅថ្នាក់មជ្ឈិមស្ថិតនៅក្រុងភ្នំពេញ មានមន្ទីរ៨៧០ ដែលគ្រប់គ្រងដោយ តាប៉ង់ ជាប្រធានមន្ទីរ ។

សាក្សី ទ័ត ធឿន ឆ្លើយបញ្ជាក់ជូនសហចៅក្រមបន្តថា ការប្រមូលប្រជាជនទៅចូលរួមបះបោរប្រឆាំងអង្គការ នៅក្នុងព្រៃឫស្សី នៅចុងឆ្នាំ១៩៧៨ ពេលដែលស្រូវចាប់ផ្តើមទុំ សាក្សីមិនបានធ្វើការអូសទាញប្រជាជន ឬទាហានណាទេ ។ ប្រជាជនស្ម័គ្រចិត្តចូលរួមជាកម្លាំងតស៊ូជាមួយសាក្សី ដោយសារប្រជាជនយល់ឃើញថា ទោះជាពួកគាត់នៅបន្តស្ថិតក្រោមការគ្រប់គ្រងរបស់អង្គការបដិវត្តន៍ ក៏ត្រូវប្រឈមនឹងសេចក្តីស្លាប់ ។ ដូច្នេះ បងប្អូនប្រជាជនទាំងនោះសុខចិត្តស្លាប់ឲ្យមានប្រយោជន៍ជាជាងស្លាប់ដោយពុំបានធ្វើអ្វីសោះ ។

សវនាការនៃការស្តាប់សក្ខីកម្មរបស់សាក្សី ទ័ត ធឿន បានបញ្ចប់ជាស្ថាពរនៅល្ងាចថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០១៥ ។ សវនាការក្នុងការស្តាប់សក្ខីកម្មសាក្សី៣រូប ត្រូវបានបញ្ចប់ក្នុងរយៈពេលបីថ្ងៃ ដោយមិនបន្តដល់ថ្ងៃទីបួន ដែលជាថ្ងៃបម្រុងទុកនោះទេ ។ ភាពឆាប់រហ័សនេះ បណ្តាលមកពីអង្គជំនុំជម្រះកាត់បន្ថយពេលវេលាសម្រាកនៅថ្ងៃទីបីនៃការស្តាប់សក្ខីកម្មសាក្សីទីបី ដោយមិនធ្វើការសម្រាកបន្ទាប់ពីបញ្ចប់វគ្គទី១ ដូចសព្វដង ហើយធ្វើការបន្ថែមម៉ោងសវនាការរហូតដល់ម៉ោងប្រាំ និងដប់បួននាទីល្ងាច ទើបប្រកាសបិទបញ្ចប់អង្គសវនាការ ។ អង្គជំនុំជម្រះតុលាការកំពូល នឹងជូនដំណឹងអំពីកាលបរិច្ឆេទនៃសវនាការជាបន្តនៅពេលក្រោយ ។ **ឌី សុជាតា និង ឌិន ដួងចន្ទ្រារ៉ែខលក្ស្មីនារីរតន៍**

## រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមបាន និងកំពុងសរសេរអត្ថបទ ឬ សៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន ហើយនឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានខាងក្រោម ៖


ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ ភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥

ទូរស័ព្ទលេខៈ (៨៥៥) (១២) ៩៩៦ ៧៥០

ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨

Email: truthbunthorn.s@dccam.org

Home page: www.dccam.org

# កេរដំណែលនៃសាលាក្តីខ្មែរក្រហមសម្រាប់ប្រព័ន្ធតុលាការកម្ពុជា

ចាប់តាំងពីការចាប់ផ្តើមនៃគម្រោងសង្កេតការណ៍ដំណើរកាត់ទោសមេដឹកនាំខ្មែរក្រហម នៅក្នុងខែមេសា ឆ្នាំ២០១១ សមាជិកក្រុមនៃគម្រោងនេះ បានចូលរួមសង្កេតការណ៍នៅគ្រប់សវនាការនៃសំណុំរឿង០០២ ដំណាក់កាលទី១ ឬហៅម្យ៉ាងទៀតថា សំណុំរឿង០០២/០១ ទាំង២១២ថ្ងៃ រហូតដល់ថ្ងៃដែលអង្គជំនុំជម្រះសាលាដំបូងបានចេញសាលក្រមផ្តន្ទាទោសអតីតមេដឹកនាំខ្មែរក្រហម នួន ជា និង ខៀវ សំផន ដាក់ពន្ធនាគារអស់មួយជីវិត នៅពីថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ ។ សវនាការជំនុំជម្រះក្តីលើបទឧក្រិដ្ឋកម្មអន្តរជាតិដែលមានការចូលរួមពីសំណាក់អ្នកច្បាប់ជាតិ និងអន្តរជាតិ បានឆ្លុះបញ្ចាំងឲ្យឃើញពីភាពខុសប្លែកគ្នាពីរបៀបនៃការគ្រប់គ្រងកិច្ចដំណើរការនីតិវិធីក្នុងសវនាការ និងយុទ្ធសាស្ត្ររបស់គូភាគី ដែលប្រើប្រាស់ក្នុងការលើកឡើងនូវអំណះអំណាងនៅចំពោះមុខតុលាការ ដែលកម្រឃើញមានអនុវត្តនៅក្នុងប្រព័ន្ធតុលាការក្នុងស្រុករបស់កម្ពុជា ។

អ្នកជំនាញ អ្នកច្បាប់អ្នកឃ្លាំមើលដំណើរការសវនាការទាំងជាតិ និងអន្តរជាតិជាច្រើនរូបបានបង្ហាញពីមតិយោបល់ផ្សេងគ្នាជុំវិញកេរដំណែលនៃសាលាក្តីខ្មែរក្រហម ដោយខ្លះយល់ឃើញថាសាលាក្តីកាត់ទោសអតីតមេដឹកនាំខ្មែរក្រហមនឹងក្លាយទៅជាតុលាការគំរូមួយសម្រាប់តុលាការជាតិកម្ពុជា និងខ្លះទៀតយល់ថា តុលាការចម្រុះមួយនេះនៅពុំទាន់អាចធ្វើជាតុលាការគំរូសម្រាប់ប្រព័ន្ធតុលាការក្នុងស្រុករបស់កម្ពុជាបានឡើយបាននៅឡើយ ។

យោងតាមបទពិសោធន៍នៃការសង្កេតជាក់ស្តែងរបស់គម្រោងសង្កេតការណ៍ដំណើរកាត់ទោសមេដឹកនាំខ្មែរក្រហម ទោះបីជាសាលាក្តីខ្មែរក្រហមពុំបានជះឥទ្ធិពលគ្របដណ្តប់ទាំងស្រុងលើទម្លាប់នៃការអនុវត្តច្បាប់នៅក្នុងប្រទេសកម្ពុជា ប៉ុន្តែវាពិតបានផ្តល់នូវផលជាវិជ្ជមានចំពោះប្រព័ន្ធច្បាប់របស់កម្ពុជា ដោយពុំអាចប្រកែកបាន ។ សាលាក្តីខ្មែរក្រហមបានផ្តល់នូវបទពិសោធន៍ និងគំរូនៃការអនុវត្តដល់មន្ត្រីអនុវត្តច្បាប់ និងបុគ្គលិកបម្រើការសម្រាប់ភាគីជាតិទាំងផ្នែកបច្ចេកទេស និងផ្នែកនីតិវិធី ហើយប្រភពធនធានទាំងនោះនឹងក្លាយជាទុនយ៉ាងសំខាន់សម្រាប់ប្រើប្រាស់នៅក្នុងប្រព័ន្ធតុលាការជាតិ នៅពេលដែលអ្នកទាំងនោះត្រឡប់ទៅបម្រើការងារនៅក្នុងស្ថាប័នរបស់ខ្លួនវិញ ។

ចំណុចខាងក្រោមនឹងពិភាក្សាអំពីតួនាទីរបស់សាលាក្តីខ្មែរក្រហមថាតើតុលាការចម្រុះមួយនេះ អាចនឹងដើរតួនាទីជាគំរូសម្រាប់ប្រព័ន្ធតុលាការក្នុងស្រុករបស់កម្ពុជាបានដែរឬយ៉ាងណា ។

### ក្តីរំពឹងអំពីកេរដំណែលនៃសាលាក្តីខ្មែរក្រហម

នៅស្របពេលដែលប្រព័ន្ធតុលាការកម្ពុជាបច្ចុប្បន្ន ត្រូវបានសាធារណជនទូទៅមើលឃើញថា នៅមានសភាពអន់ខ្សោយ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រូវបានរំពឹងថានឹងអាចក្លាយទៅជាតុលាការគំរូមួយសម្រាប់តុលាការក្នុងស្រុកក្នុងការចូលរួមចំណែកធ្វើឲ្យមានការផ្លាស់ប្តូរមួយក្នុងរយៈពេលវែងទាក់ទងនឹងការលើកកម្ពស់សមត្ថភាពរបស់មន្ត្រីអនុវត្តច្បាប់ក្នុងប្រព័ន្ធយុត្តិធម៌ និងទទួលបាននូវចំណេះដឹង និងជំនាញបន្ថែមពីសំណាក់សហគមន៍អន្តរជាតិ ។ អតីតអគ្គលេខាធិការអង្គការសហប្រជាជាតិ លោក កូហ្វី អាណាន់ ធ្លាប់បានថ្លែងនៅអំឡុងពេលនៃការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដោយព្យាករណ៍ទុកជាមុនថា សាលាក្តីខ្មែរក្រហមនឹងបន្សល់ទុកនូវកេរដំណែលដ៏មានតម្លៃមួយសម្រាប់ប្រទេសកម្ពុជា ហើយជំនាញ និងចំណេះដឹងដែលកើតចេញពីសាលាក្តីនេះនឹងត្រូវផ្ទេរទៅបុគ្គលិកជាតិ និងអ្នកពាក់ព័ន្ធ៖

យើងមានក្តីសង្ឃឹមថា ការបង្កើតឡើងនូវដំណើរការច្បាស់លាស់មួយដែលគោរពតាមបទដ្ឋានអន្តរជាតិ និងជះឥទ្ធិពលផ្នែកអប់រំទៅលើស្ថាប័នដែលកំពុងដំណើរការជួវការបច្ចុប្បន្ន និងបណ្តុះស្មារតីក្នុងចំណោមប្រជាជនទូទៅឲ្យយល់ដឹងពីការពិតពាក់ព័ន្ធនឹងអតីតកាលដែលពោរពេញដោយភាពវិនាសអន្តរាយរបស់កម្ពុជា និងការទាមទារបន្ថែមទៀតឲ្យមានប្រព័ន្ធតុលាការមួយដែលនឹងបំពេញមុខនាទីត្រឹមត្រូវ ។

អង្គជំនុំជម្រះសាលាដំបូង ក៏ធ្លាប់បានទទួលស្គាល់អំពីសារសំខាន់នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាចំពោះចំណុចនេះ ដោយបានកត់សម្គាល់ថា «ក្នុងនាមជាតុលាការគំរូ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានឹងដើរតួនាទីក្នុងការជំរុញ និងសង្កត់ធ្ងន់លើសារសំខាន់នៃការការពារឯករាជភាព និងសុចរិតភាពនៃប្រព័ន្ធតុលាការ ។ បន្ថែមពីលើនេះ មន្ត្រីជាន់ខ្ពស់នៅក្នុងជួររាជរដ្ឋាភិបាលកម្ពុជា បានបញ្ជាក់ជាច្រើនលើកច្រើនសាថា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គឺជាតុលាការគំរូ ។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានបង្ហាញពីគោលបំណងរបស់ខ្លួនក្នុងការប្រើប្រាស់លទ្ធភាព ដើម្បីបង្កើនការយល់ដឹងរបស់តុលាការក្នុងស្រុកពាក់ព័ន្ធនឹងបទដ្ឋានអន្តរជាតិ និងការប្រព្រឹត្តទៅនៃការជំនុំជម្រះក្តីដោយយោងតាមគោលការណ៍យុត្តិធម៌អន្តរជាតិ ។

ប្រធានការិយាល័យរដ្ឋបាលស្តីទីនៃសាលាក្តីខ្មែរក្រហម លោក ក្រាញ់ តូនី ធ្លាប់បានបញ្ជាក់ថា បុគ្គលិកជាតិដែលកំពុងធ្វើការនៅសាលាក្តីខ្មែរក្រហមនឹងក្លាយទៅជាធនធានដ៏មានតម្លៃសម្រាប់ប្រព័ន្ធច្បាប់កម្ពុជា នៅពេលដែលអ្នកទាំងនោះត្រឡប់ទៅបម្រើការងារនៅក្នុងស្ថាប័នក្នុងស្រុករបស់ខ្លួនវិញ ។ ចំណែកឯ លោកចៅក្រម យូ ប៊ុនឡេង ដែលមានតួនាទីជាសហចៅក្រមស៊ើបអង្កេតជាតិនៃសាលាក្តីខ្មែរក្រហម និងមានតួនាទីជាប្រធានតុលាការសាលាឧទ្ធរណ៍នៃតុលាការជាតិកម្ពុជា ធ្លាប់បានលើកឡើងទាក់ទងនឹងបន្ទប់សម្រាប់សាក្សី និងប្រព័ន្ធគ្រប់គ្រងសំណុំរឿងតាមរយៈកុំព្យូទ័រនៅសាលាក្តីខ្មែរក្រហមដែលរៀបចំឡើងដើម្បីជាការការពារដល់សិទ្ធិរបស់ជនរងគ្រោះ សាក្សី និងជនជាប់ចោទ និងមន្ត្រីតុលាការដែលទទួលបន្ទុកគ្រប់គ្រងកិច្ចការផ្នែករដ្ឋបាល រួមជាមួយនឹងការបោះពុម្ពផ្សាយសេចក្តីសម្រេចរបស់តុលាការតាមរយៈប្រព័ន្ធអ៊ីនធឺណែត ។

កិច្ចដំណើរការនីតិវិធីនៅសាលាក្តីខ្មែរក្រហមបានបង្រៀនអំពីវិជ្ជាជីវៈក្នុងការអនុវត្តច្បាប់ និងផ្តល់នូវគំរូក្នុងការរៀបចំឥរិយាបថនៅក្នុងសវនាការថាតើចៅក្រមគួរមានអាកប្បកិរិយាបែបណា ។ ប្រធានអង្គជំនុំជម្រះសាលាដំបូងនៃសាលាក្តីខ្មែរក្រហម លោកចៅក្រម និល ណុន ត្រូវបានមើលឃើញថា បានអនុវត្តយ៉ាងល្អប្រសើរនៅក្នុងការដឹកនាំកិច្ចដំណើរការនីតិវិធីសវនាការ ទាំងការប្រើប្រាស់សូរស័ព្ទ និងឥរិយាបថ ទោះបីជានៅមានចំណុចខ្វះខាតខ្លះៗក៏ដោយ ។ ការប្រើប្រាស់ឥរិយាបថ និងពាក្យសម្តីពុំសមរម្យចំពោះជនជាប់ចោទ សាក្សី ឬជនរងគ្រោះ ពីសំណាក់ចៅក្រមជំនុំជម្រះត្រូវបានមើលឃើញថា បានកើតឡើងជាញឹកញាប់នៅអំឡុងពេលនៃការជំនុំជម្រះក្តីនៅក្នុងស្ថាប័នតុលាការក្នុងស្រុក ។ គំរូក្នុងការដឹកនាំកិច្ចដំណើរការនីតិវិធីសវនាការនៅសាលាក្តីខ្មែរក្រហមពីសំណាក់ចៅក្រមដែលមានវិជ្ជាជីវៈនឹងអាចក្លាយជាបទពិសោធន៍ល្អសម្រាប់ស្ថាប័នតុលាការជាតិរៀនសូត្រ និងអនុវត្តតាមនៅពេលមានការជំនុំជម្រះក្តី ទាំងការរៀបចំឥរិយាបថ និងការប្រើប្រាស់ពាក្យសម្តីពីសំណាក់ចៅក្រមក្នុងការសួរដេញដោលចំពោះភាគី ។

ទោះបីជាមតិភាគច្រើនទទួលស្គាល់ថា សាលាក្តីខ្មែរក្រហមនឹងក្លាយជាតុលាការគំរូសម្រាប់ប្រព័ន្ធតុលាការក្នុងស្រុកក៏ដោយ អត្ថបទស្រាវជ្រាវមួយដែលមានចំណងជើងថា «បទពិសោធន៍នៅក្នុងវិស័យយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ ៖ មេរៀនពីសាលាក្តីខ្មែរក្រហម» បានរកឃើញថា នៅមានភស្តុតាងតិចតួចនៅឡើយ ដែលបង្ហាញថា សាលាក្តីខ្មែរក្រហមអាចជះឥទ្ធិពលវិជ្ជមានដល់ប្រព័ន្ធតុលាការក្នុងស្រុកកម្ពុជា ។ អត្ថបទនោះបានដកស្រង់សម្តីអ្នកវិភាគមួយរូប ដែលបានបង្ហាញពីការយល់ឃើញរបស់ខ្លួនថា ទោះបីជាសាលាក្តីខ្មែរក្រហមបានជួយអភិវឌ្ឍជំនាញ និងចំណេះដឹងដល់អ្នកអនុវត្តច្បាប់ក្នុងស្រុកក៏ដោយ ក៏ការផ្លាស់ប្តូរពិតប្រាកដនៅក្នុងប្រព័ន្ធច្បាប់កម្ពុជាប្រហែលជាមិនអាចទៅរួចឡើយ ប្រសិនបើគ្មានការផ្លាស់ប្តូរជាមូលដ្ឋានណាមួយពីសំណាក់រាជរដ្ឋាភិបាល ចំពោះការប្តេជ្ញាចិត្តក្នុងការអនុវត្តឲ្យបាននីតិរដ្ឋនៅក្នុងប្រទេសកម្ពុជា ។

ស្រដៀងគ្នានេះដែរ អ្នកឃ្លាំមើលសាលាក្តីខ្មែរក្រហមមួយរូបទៀតបានបង្ហាញពីការយល់ឃើញរបស់ខ្លួនថា «ស្របពេលដែលសាលាក្តីខ្មែរក្រហមបានជួយពង្រឹងជំនាញរបស់ចៅក្រម និងមេធាវីក្នុងស្រុកប្រព័ន្ធតុលាការក្នុងស្រុករបស់កម្ពុជានៅពុំទាន់មានការផ្លាស់ប្តូរនៅឡើយ ។»

## បទដ្ឋាននៃការអនុវត្តនីតិវិធីព្រហ្មទណ្ឌចំពោះបទឧក្រិដ្ឋអន្តរជាតិ

ពាក់ព័ន្ធនឹងការអនុវត្តនីតិវិធី សាលាក្តីខ្មែរក្រហមបានប្រើប្រាស់វិធានផ្ទៃក្នុងដែលបង្កើតឡើង ដោយផ្អែកលើក្រមនីតិវិធី

ព្រហ្មទណ្ឌកម្ពុជាឆ្នាំ២០០៧ ដើម្បីដំណើរការនីតិវិធីសំណុំរឿងក្តី ។ ការអនុវត្តជាទូទៅ បានធ្វើឡើងដោយអនុលោមតាមនីតិវិធីដែលមានចែងនៅក្នុងវិធានផ្ទៃក្នុង និងមានលក្ខណៈល្អប្រសើរ ។ បទពិសោធន៍ដែលទទួលបានពីការអនុវត្តនីតិវិធីព្រហ្មទណ្ឌនៅសាលាក្តីខ្មែរក្រហមនៅក្នុងសំណុំរឿងដែលមានលក្ខណៈស្មុគស្មាញ ដូចជាសំណុំរឿង០០២ នឹងអាចក្លាយជាគំរូសម្រាប់មន្ត្រីអនុវត្តច្បាប់នៃស្ថាប័នតុលាការក្នុងស្រុកសិក្សា និងដកស្រង់បទពិសោធន៍នៅក្នុងការដំណើរការនីតិវិធីនៃសំណុំរឿងក្តីប្រកបដោយប្រសិទ្ធភាព និងតម្លាភាព ។

វិធាននៃភស្តុតាងដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា នៅត្រង់មាត្រា៣២១ ហាក់បីដូចជាពុំបានចែងលម្អិតអំពីនីតិវិធីនៃការទទួលយកភស្តុតាង ហើយអត្ថន័យនៃវិធាននេះទៀតសោត នៅមានលក្ខណៈចង្អៀត ពុំទាន់អាចយកទៅអនុវត្តបាននៅក្នុងរឿងក្តីព្រហ្មទណ្ឌដែលមានលក្ខណៈស្មុគស្មាញ និងធំធេង ដូចជាករណីឧក្រិដ្ឋកម្មនៃរបបខ្មែរក្រហម ដែលមានភស្តុតាងយ៉ាងច្រើនលើសលុប ដែលដាក់ជូនដោយភាគី រង់ចាំអង្គជំនុំជម្រះធ្វើការវាយតម្លៃអំពីភាពជាប់ពាក់ព័ន្ធនឹងភាពអាចជឿជាក់បាន ។ ផ្ទុយពីក្រមនីតិវិធីព្រហ្មទណ្ឌ វិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នៅត្រង់មាត្រា៨៧ស្តីពីវិធាននៃភស្តុតាង បានចែងលម្អិតអំពីគោលការណ៍នីតិវិធីនៃការទទួលយកភស្តុតាងដាក់ចូលក្នុងសំណុំរឿង និងបុព្វសិទ្ធិរបស់អង្គជំនុំជម្រះក្នុងការវាយតម្លៃអំពី តម្លៃ និងទម្ងន់នៃភស្តុតាង ។ ដោយសារតែភស្តុតាងនៃឧក្រិដ្ឋកម្មដែលកើតឡើងក្នុងរបបខ្មែរក្រហម មានចំនួនច្រើនលើសលុប ដូច្នេះការចែងលម្អិតអំពីវិធាននៃភស្តុតាងនឹងអាចអនុញ្ញាតឲ្យអង្គជំនុំជម្រះ ងាយស្រួលក្នុងការកំណត់ថា តើភស្តុតាងណាដែលមានភាពជាប់ពាក់ព័ន្ធនឹងមានភាពគួរឲ្យជឿជាក់បាន និងភស្តុតាងប្រភេទណាគួរត្រូវបានបដិសេធ ។

ការអនុវត្តវិធាននៃភស្តុតាងនៅក្នុងបរិបទនៃសំណុំរឿងក្តីស្មុគស្មាញនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានឹងក្លាយជាបទពិសោធន៍ និងគំរូសម្រាប់ការអនុវត្តនីតិវិធីទាក់ទងនឹងវិធានភស្តុតាងនៅក្នុងតុលាការក្នុងស្រុក ។ ការធ្វើវិសោធនកម្មលើវិធាននៃភស្តុតាងដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌរបស់កម្ពុជា គួរតែត្រូវបានធ្វើឡើងដើម្បីបង្កលក្ខណៈងាយស្រួលដល់អ្នកអនុវត្តច្បាប់ អាចយកវិធានទាំងនេះទៅអនុវត្តប្រកបដោយប្រសិទ្ធភាពតាមគំរូបទដ្ឋានអន្តរជាតិ ។

## សេចក្តីសម្រេចសំខាន់ៗ ដែលអាចក្លាយជាយុត្តិសាស្ត្រសម្រាប់តុលាការក្នុងស្រុក

នៅក្នុងដំណាក់កាលមុនសវនាការ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ស្តីពីបញ្ហាពាក់ព័ន្ធនឹងការសុំនៅក្រៅឃុំ និងលក្ខណៈវិនិច្ឆ័យសំខាន់ៗដើម្បីធ្វើយុត្តិកម្មចំពោះការសម្រេចឃុំខ្លួនបណ្តោះអាសន្ន ដោយយោងតាមសិទ្ធិក្នុងការទទួលបានសេរីភាពដូចមានចែងនៅក្នុងមាត្រា៩នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ គឺជាគោលការណ៍ណែនាំសម្រាប់តុលាការក្នុងស្រុក ។ ឧទាហរណ៍ នៅក្នុងសំណុំរឿង ០០១ អង្គបុរេជំនុំជម្រះបានបញ្ជាក់លើបណ្តឹងឧទ្ធរណ៍ថា ការសម្រេចឃុំខ្លួនបណ្តោះអាសន្នលើរូបជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច មានសារសំខាន់ពាក់ព័ន្ធនឹងមាត្រា៩នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងវិធានផ្ទៃក្នុងក្រោយពីធ្វើការពិចារណាយ៉ាងល្អិតល្អន់លើយុត្តិកម្មដែលបានប្រើប្រាស់ជាមូលដ្ឋាននៃការឃុំខ្លួន ។ ទោះបីជាច្បាប់ក្នុងស្រុកមានចែងអំពីការសុំនៅក្រៅឃុំដោយមានការធានាក៏ដោយ ក៏ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌនៅកម្ពុជានៅតែបន្តពឹងផ្អែកលើការដាក់ពន្ធនាគារ ដែលជាជំហរដាច់ណាត់សម្រាប់ជនជាប់ចោទដែលរង់ចាំការជំនុំជម្រះក្តី ហើយសំណើសុំនៅក្រៅឃុំដោយមានការធានាកម្រនឹងទទួលបានការអនុញ្ញាតណាស់ ។

សវនាការស្តីពីការស្នើសុំនៅក្រៅឃុំនៅសាលាក្តីខ្មែរក្រហម គឺជាឧទាហរណ៍មួយយ៉ាងសំខាន់ សម្រាប់តុលាការក្នុងស្រុក នៅពេលដែលព្រះរាជអាជ្ញាចាំបាច់ត្រូវតែស្វែងរកហេតុផលរឹងមាំដើម្បីស្នើសុំឲ្យមានការឃុំខ្លួនបណ្តោះអាសន្ន ហើយមេធាវីការពារក្តីឲ្យជនត្រូវចោទត្រូវតែមានសមត្ថភាពក្នុងការបង្ហាញអំពីអំណះអំណាង និងការជជែកតតាំងដើម្បីស្វែងរកមូលដ្ឋានប្រឆាំងនឹងការសម្រេចឃុំឃាំងកូនក្តីរបស់ខ្លួន ។ រីឯ ចៅក្រមត្រូវតែពិនិត្យពិច័យលើអំណះអំណាងទាំងនោះឲ្យបានគ្រប់ជ្រុងជ្រោយ និងចេញសេចក្តីសម្រេចមួយដែលមានសំអាងហេតុសមរម្យ ដោយផ្អែក

លើការសន្មតអំពីសេរីភាពថាជាចំណុចចាប់ផ្តើម ។

សាលាក្តីខ្មែរក្រហម ក៏បានបង្កើតយុត្តិសាស្ត្រដ៏មានសារប្រយោជន៍មួយចំនួន ស្តីពីលក្ខខណ្ឌដែលដាក់ឲ្យជនជាប់ចោទស្ថិតនៅក្រោមការឃុំខ្លួន ដោយរាប់បញ្ចូលទាំងការកំហិតរបស់តុលាការពាក់ព័ន្ធនឹងការទាក់ទងរវាងជនជាប់ចោទជាមួយភរិយា និងសិទ្ធិរបស់ជនជាប់ចោទដើម្បីចូលមើលឯកសារក្នុងសំណុំរឿងដោយអនុលោមតាមសិទ្ធិក្នុងការចូលរួមក្នុងការការពារខ្លួន និងដើម្បីធានាអំពីភាពស្មើគ្នាក្នុងការតតាំងក្តីជាមួយនឹងព្រះរាជអាជ្ញា ។ សេចក្តីសម្រេចដែលមានសារសំខាន់មួយទៀតនោះ គឺក្រមនីតិវិធីព្រហ្មទណ្ឌបានហាមប្រាមមេធាវីមិនឲ្យផ្តល់សំណៅ ឬផ្នែកណាមួយនៃឯកសារក្នុងសំណុំរឿងទៅកូនក្តីរបស់ខ្លួន ដែលបានបង្កឲ្យមានការព្រួយបារម្ភជាខ្លាំងទាក់ទងនឹងសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ និងចូលរួមក្នុងការការពារខ្លួន ជាពិសេសជនជាប់ចោទទាំងឡាយដែលពុំទាន់មានអ្នកតំណាង ។

## គោលការណ៍ជាសារវន្តនៅក្នុងការសម្រេចសេចក្តីពីសំណាក់ចៅក្រមវិជ្ជាជីវៈ

ការតម្រូវឲ្យចៅក្រមត្រូវតែចេញសេចក្តីសម្រេចដែលមានសំអាងហេតុពេញលេញនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ត្រូវបានអង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថាជា "ការគោរពនូវសិទ្ធិជាមូលដ្ឋានរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌" ដែលជាយុត្តិសាស្ត្រមួយដ៏សំខាន់សម្រាប់តុលាការក្នុងស្រុក ពីព្រោះជារឿយៗការផ្តល់សំអាងហេតុរបស់តុលាការ នៅមានលក្ខណៈពុំទាន់ពេញលេញ ឬពេលខ្លះពុំមានតែម្តង ។ សេចក្តីសម្រេចជាច្រើនរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានបង្ហាញអំពីសមត្ថភាពរបស់តុលាការនេះក្នុងការធ្វើការប្រកបដោយ ឯករាជ្យ មិនលម្អៀង និងការវិភាគយ៉ាងល្អិតល្អន់អំពីគោលការណ៍ច្បាប់អន្តរជាតិដែលមានលក្ខណៈស្មុគស្មាញ ជាជាងការទទួលយកភ្លាមៗនូវការបកស្រាយចំពោះអត្ថន័យនៃបទបញ្ញត្តិទាំងនោះដោយតុលាការព្រហ្មទណ្ឌអន្តរជាតិដទៃផ្សេងទៀត ។ ឧទាហរណ៍ នៅក្នុងការពិចារណាអំពីភាពចម្រូងចម្រាសនៃការពង្រីកទម្រង់នៃសហឧក្រិដ្ឋកម្មរួម "សហឧក្រិដ្ឋកម្មរួមប្រភេទទី៣" ថាជាទម្រង់មួយនៃការទទួលខុសត្រូវអង្គបុរេជំនុំជម្រះបានធ្វើការវិភាគស៊ីជម្រៅអំពីសមត្ថកិច្ចដែលធ្លាប់បានយកមកប្រើប្រាស់ពីពេលមុនដើម្បីគាំទ្រអត្ថិភាពនៃសហឧក្រិដ្ឋរួមប្រភេទទី៣ក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ជាជាងការទទួលយកភ្លាមៗនូវអំណះអំណាងរបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីលើបញ្ហាដូចគ្នានេះ ។ ចំណុចនេះបានបង្ហាញពីភាពផ្ទុយគ្នានឹងសេចក្តីសម្រេចរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ដែលរកឃើញថាទំនួលខុសត្រូវប្រភេទនេះអាចអនុវត្តបាននៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដោយធ្វើការសន្និដ្ឋានថា សហឧក្រិដ្ឋកម្មរួមប្រភេទទីបីមិនបានឆ្លុះបញ្ចាំងពីច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅចន្លោះពីឆ្នាំ១៩៧៥ ដល់១៩៧៩នោះឡើយ ។ អង្គជំនុំជម្រះសាលាដំបូងបានគាំទ្រចំពោះសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ។

## ការអនុវត្តគោលការណ៍សិទ្ធិទទួលបានការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌

កិច្ចដំណើរការនីតិវិធីរបស់សាលាក្តីខ្មែរក្រហម បានផ្តោតជាសំខាន់ទៅលើគោលការណ៍ស្តីពីសិទ្ធិទទួលបានការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ ដែលក្នុងនោះមានដូចជា គោលការណ៍សន្មតថាគ្មានទោស ដរាបណាពុំត្រូវបានផ្តន្ទាទោស គោលការណ៍ទទួលបានសិទ្ធិស្មើភាពគ្នាក្នុងការតទល់ក្តី ការតម្រូវឲ្យមានតម្លាភាពនៅក្នុងកិច្ចដំណើរការនីតិវិធី និងជាពិសេសការតម្រូវឲ្យមានការផ្តល់សំអាងហេតុផលគ្រប់គ្រាន់ និងច្បាស់លាស់នៅក្នុងការសម្រេចឃុំខ្លួនបណ្តោះអាសន្ន និងការសម្រេចផ្តន្ទាទោស ។ ការអនុវត្តគោលការណ៍ទាំងអស់នេះនៅក្នុងប្រព័ន្ធតុលាការក្នុងស្រុក ត្រូវបានមើលឃើញថាមានកម្រិត ហេតុដូច្នេះ ការអនុវត្តគោលការណ៍ទាំងនេះ នៅសាលាក្តីខ្មែរក្រហមនឹងអាចក្លាយជាគំរូល្អប្រសើរសម្រាប់ស្ថាប័នតុលាការជាតិ ជាពិសេសការអនុវត្តពាក់ព័ន្ធនឹងសិទ្ធិទទួលបានការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ ។

សិទ្ធិទទួលបានការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ គឺជា "ធាតុសំខាន់"ក្នុងការធ្វើឲ្យមាននីតិរដ្ឋដែលមានរួមបញ្ចូលនូវគោលការណ៍ស្តីអំពីសិទ្ធិមនុស្ស ដែលចែងថា មនុស្សគ្រប់រូបមានសិទ្ធិស្មើភាពគ្នានៅចំពោះមុខច្បាប់ និងស្ថិតនៅក្រោមច្បាប់ និងគោរពតាមច្បាប់ ។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានបង្ហាញឲ្យ

ឃើញនូវសមត្ថភាពក្នុងការបកស្រាយ និងអនុវត្តបទដ្ឋានអន្តរជាតិនៃការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ ជាពិសេសពាក់ព័ន្ធនឹងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលជាផ្នែកមួយយ៉ាងសំខាន់សម្រាប់ធ្វើជាកេរដំណែលរបស់ខ្លួន ។

ឧទាហរណ៍ទាក់ទងនឹងការពិចារណាលើសិទ្ធិទទួលបានពេលវេលានិងមធ្យោបាយគ្រប់គ្រាន់សម្រាប់ត្រៀមដើម្បីការពារខ្លួន និងសិទ្ធិក្នុងការទំនាក់ទំនងជាមួយមេធាវីដែលខ្លួនបានជ្រើសរើសដោយយោងតាមមាត្រា១៤ នៃកតិកាសញ្ញាអន្តរជាតិស្តីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ អង្គបុរេជំនុំជម្រះបានបង្គាប់ថា ដីការបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតដែលបដិសេធមិនឲ្យក្រុមមេធាវីការពារក្តីធ្វើការថតសំឡេងពីជំនួបរវាង ជនជាប់ចោទនិងមេធាវីរបស់ខ្លួននៅមន្ទីរឃុំឃាំង បានរំលោភបំពានលើសិទ្ធិក្នុងការទទួលបានការជំនុំជម្រះក្តីប្រកបដោយភាពយុត្តិធម៌ ។ យោងតាមយុត្តិសាស្ត្រនៃតុលាការសិទ្ធិមនុស្សអឺរ៉ុប អង្គបុរេជំនុំជម្រះបានស្រាយយ៉ាងក្បោះក្បាយលើមាត្រា១៤ ដោយសម្រេចថា វិធីដែលការិយាល័យសហចៅក្រមស៊ើបអង្កេតអនុវត្តសិទ្ធិនេះក្នុងន័យចង្អៀត គឺ«ពុំស្របនឹងកម្មវត្ថុ និងគោលបំណងនៃការធានាការជំនុំជម្រះក្តីប្រកបដោយភាពយុត្តិធម៌ទេ ។» ស្រដៀងគ្នានេះដែរសាលាក្តីខ្មែរ ក្រហមបានចេញសេចក្តីសម្រេចដ៏សំខាន់មួយទៀតស្តីពីសម្បទារបស់ជនជាប់ចោទក្នុងការចូលរួមក្នុងសវនាការ និងនីត្យានុកូលក្នុងការបន្តឃុំឃាំងដោយគ្មានការជំនុំជម្រះក្តី ដែលអាចនឹងអនុវត្តដោយតុលាការក្នុងស្រុក ដើម្បីពង្រឹងសិទ្ធិក្នុងការទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌របស់ជាប់ចោទ ។

## សន្និដ្ឋាន

តាមរយៈបទពិសោធន៍ផ្ទាល់ទាក់ទងនឹងកិច្ចការសង្កេតការណ៍អំពីកិច្ចដំណើរការនីតិវិធី និងការអនុវត្តការងារនៅសាលាក្តីខ្មែរក្រហម ខ្ញុំជឿជាក់ថា សាលាក្តីខ្មែរក្រហមនឹងក្លាយជាគំរូដ៏ល្អសម្រាប់ការធ្វើកំណែទម្រង់តុលាការ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលតុលាការនៅក្នុងស្រុក ។ ជាពិសេស ការធ្វើកំណែទម្រង់លើការអនុវត្តពាក់ព័ន្ធនឹងកិច្ចដំណើរការនីតិវិធីដែលផ្តោតលើការគោរពសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ ។

ថ្វីត្បិតមានការរំពឹងទុកខ្ពស់ទាក់ទងនឹងកេរដំណែល ប៉ុន្តែគេពុំត្រូវមើលរំលងឧបសគ្គចម្បងៗដែលអាចនឹងគំរាមកំហែងដល់កិច្ចដំណើរការនីតិវិធី ដំណើរប្រព្រឹត្តទៅនិងកេរ្តិ៍ឈ្មោះនៃសាលាក្តីមួយនេះឡើយ ដូចជា បញ្ហាវ័យចាស់ជរា និងសុខភាពកាន់តែទ្រុឌទ្រោមរបស់ជនជាប់ចោទ និងជនរងគ្រោះ បញ្ហាថវិកា និងការចោទប្រកាន់អំពីការទទួលរងឥទ្ធិពលនយោបាយពីសំណាក់រាជរដ្ឋាភិបាលចំពោះការស៊ើបអង្កេតនៅក្នុងសំណុំរឿង០០៣ និងសំណុំរឿង០០៤ ។ អង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ដែលជាភាគីនៃកិច្ចព្រមព្រៀងស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចាំបាច់ត្រូវធានាឲ្យបាននូវឯករាជភាព សុចរិតភាពនិងដំណើរប្រព្រឹត្តទៅរបស់តុលាការ ដើម្បីស្វែងរកយុត្តិធម៌ ជូនជនរងគ្រោះ និងដើម្បីបន្សល់ទុកនូវកេរដំណែលគតិយុត្តិដ៏មានតម្លៃទាំងសម្រាប់ស្ថាប័នតុលាការជាតិរបស់កម្ពុជា និងស្ថាប័នតុលាការឧក្រិដ្ឋកម្មអន្តរជាតិដទៃផ្សេងទៀតក្នុងឋានៈជាតុលាការគំរូ ។

**លឹម ជ័យផ័ត្ត**

# ដំណឹងស្វែងរកប្អូនស្រី

ខ្ញុំបាទឈ្មោះ ហង់ ខេត ភេទប្រុស អាយុ៦០ឆ្នាំ បច្ចុប្បន្នរស់នៅភូមិជ្រៃ ឃុំបឹងបេង ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ។ សូមប្រកាសស្វែងរក ហង់ សាម៉ូត ភេទស្រី ត្រូវជាប្អូនស្រីពៅ (បច្ចុប្បន្ន អាយុប្រហែល៥៤-៥៥ឆ្នាំ) មានស្រុកកំណើតនៅភូមិត្រពាំងអណ្តើក ឃុំបឹងស្រងែ ស្រុកត្រាំកក់ ខេត្តតាកែវ ។ កាលពីសម័យខ្មែរក្រហម សាម៉ូត ធ្វើជាកងនារីតំបន់ ស្រុកត្រាំកក់ មានឪពុកឈ្មោះ ជ័យ ឃុន និងម្តាយ ឈឹម ណេង ។ មានបងប្អូនបង្កើត៧នាក់ (ប្រុស២ ស្រី៥នាក់) ។

បងប្អូនណាបានឮសូមទាក់ទងមេភូមិជ្រៃ ទូរស័ព្ទលេខ ០៩៧ ៣ ១៧៤ ៩៦៧ ឬ ទំនាក់ទំនងមកមជ្ឈមណ្ឌលឯកសារកម្ពុជា ផ្ទះលេខ៦៦, មហាវិថីព្រះសីហនុ, រាជធានី ភ្នំពេញ ឬ តាមរយៈទូរស័ព្ទ ០២៣ ២១១ ៨៧៥ ។ ***សូមអរគុណ!***

# ការចូលរួមចំណែកក្នុងការរកយុត្តិធម៌ជូនជនរងគ្រោះ គួរតែទទួលបានការគាំទ្រ

នៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៥ នេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានចេញសេចក្តីថ្លែងការណ៍ទាក់ទងនឹងការដាក់លិខិតស្នើសុំឲ្យប្រទេសវៀតណាមជួយជ្រោមជ្រែងផ្តល់ឯកសារពាក់ព័ន្ធនឹងកិច្ចស៊ើបសួរ និងផ្តល់លទ្ធភាពចូលមើលបណ្ណសារ ដែលអាចមានឯកសារពាក់ព័ន្ធនឹងការចោទប្រកាន់ក្នុងសំណុំរឿង០០៣ និង០០៤ និងការដាក់លិខិតស្នើសុំទៅព្រះរាជាណាចក្រថៃ ឲ្យមានការជួយជ្រែងជៀងគ្នានេះ ។ ការស្នើឡើងបែបនេះបានធ្វើឡើងជាយូរមកហើយ ។

ការស្នើសុំនេះ បានអនុលោមតាមវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលបង្កើតឡើងរវាងអង្គការសហប្រជាជាតិ និងព្រះរាជាណាចក្រកម្ពុជា បានចែងថា សហចៅក្រមស៊ើបអង្កេតអាចស្នើសុំឲ្យរដ្ឋមិនមែនជាភាគីនៃកិច្ចព្រមព្រៀង ផ្តល់ការជួយជ្រោមជ្រែងតាមតុលាការជូនដល់អង្គជំនុំជម្រះ ។

ទន្ទឹមនេះ ការចោទប្រកាន់នៅក្នុងសំណុំរឿង០០៣ និង ០០៤ មិនមែនជាប់ពាក់ព័ន្ធតែការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជាប៉ុណ្ណោះទេ តែក៏មានជាប់ពាក់ព័ន្ធនឹងការរំលោភលើច្បាប់មនុស្សធម៌អន្តរជាតិ និងទម្លាប់អន្តរជាតិ ដែលប្រទេសមិនមែនជាភាគីក្នុងកិច្ចព្រមព្រៀង ដូចជា ប្រទេសវៀតណាម និង ថៃ បានទទួលស្គាល់ដែរ ។

រហូតមកពេលនេះ មានរយៈពេលជាងពីរឆ្នាំហើយដែលប្រទេសវៀតណាម និង ប្រទេសថៃ ពុំបានសហការជាមួយការិយាល័យស៊ើបអង្កេត ទោះបីកន្លងមកប្រទេសទាំងពីរដឹងថា មានជនជាតិខ្លួន ស្លាប់នៅក្នុងមន្ទីរសន្តិសុខស-២១ ឬ (គុកទួលស្លែង) ក្នុងរបបកម្ពុជាប្រជាធិបតេយ្យក៏ដោយ ។ រដ្ឋាភិបាលទាំងពីរនៅតែធ្វើមិនដឹងមិនឮ ចំពោះការចូលរួមចំណែកក្នុងការរកយុត្តិធម៌ដល់ជនជាតិរបស់ខ្លួន ។ មិនតែប៉ុណ្ណោះ រដ្ឋាភិបាលទាំងពីរបានខកខានពុំបានសហការផ្តល់ឯកសារដែលពាក់ព័ន្ធអាចជួយដល់កិច្ចស៊ើបសួរ ហើយក៏ពុំបានអនុញ្ញាតឲ្យសហចៅក្រមស៊ើបអង្កេតចូលពិនិត្យបណ្ណសារ ដូចមានកំណត់យ៉ាងជាក់លាក់នៅក្នុងឯកសារដែលពាក់ព័ន្ធដែរ ។

ក្នុងកិច្ចខិតខំប្រឹងប្រែង ចាប់តាំងពីឆ្នាំ២០០៦ កន្លងមក អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា បានធ្វើការជំនុំជម្រះទៅលើអតីតប្រធានមន្ទីរសន្តិសុខស-២១ ឬ មេគុកទួលស្លែង កាំង ហ្កេកអ៊ាវ ហៅ ឌុច ក្នុងករណី០០១ និងបានប្រកាសសាលក្រមស្ថាពរ នៅថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១២ ឲ្យជនជាប់ចោទជាប់គុកអស់មួយជីវិត ។

អង្គជំនុំជម្រះបានរកឃើញបទឧក្រិដ្ឋជាច្រើន ដែលជនជាប់ចោទបានពាក់ព័ន្ធ ដូចជា ឧក្រិដ្ឋសង្គ្រាម អំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយក្នុងករណីនេះ តុលាការបានរកឃើញពីការជាប់ពាក់ព័ន្ធជាច្រើន ដូចជា ការឃុំឃាំង ការធ្វើទារុណកម្ម និងការសម្លាប់ជនជាតិថៃ និងឈ្លើយសឹកវៀតណាម ។ ឈ្មោះរបស់ជនរងគ្រោះបរទេសទាំងនោះ ក៏មាននៅក្នុងកំណត់ហេតុចោទប្រកាន់របស់អង្គជំនុំជម្រះអង្គវិសាមញ្ញក្នុងតុលាការកម្ពុជាដែរ ហើយអង្គជំនុំជម្រះ ក៏បើកទូលាយដល់គ្រប់ភាគីដែលត្រូវជាសាច់ញាតិរបស់ជនរងគ្រោះបរទេសទាំងនោះ មានសិទ្ធិដាក់ពាក្យបណ្តឹងប្រឆាំងនឹងជនដៃដល់ដែរ ។

ទាំងអស់នេះ ជាកិច្ចខិតខំប្រឹងរបស់អង្គជំនុំជម្រះអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាក្នុងការរកយុត្តិធម៌ជូនរងគ្រោះទូទៅ ក្នុងអំឡុងរបបកម្ពុជា ប្រជាធិបតេយ្យ ពីឆ្នាំ១៩៧៥-១៩៧៩ ។ ដូច្នេះ រាល់កិច្ចដំណើររបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គួរទទួលការគាំទ្រ និងការសហការឲ្យបានទូលំទូលាយ ។

**សោម ប៊ុនថន**

# រសាត់តាមខ្យល់

***(តពីលេខមុន)***

យប់នោះ ឪពុកខ្ញុំគាត់បានសម្រាន្តលក់ទៅហើយមែន តែគាត់នៅបានមមើស្រែកដេរបណ្ដេញខ្ញុំចេញពីផ្ទះទាំងកណ្ដាលអាធ្រាត្រ ខ្ញុំដេកពុំលក់ទេ ព្រោះតែឈឺចាប់នឹងស្នាមរំពាត់ពេញសព្វទាំងខ្លួន ។

ក្នុងចំណោមមិត្តភក្ដិទាំងអស់របស់ខ្ញុំ មានតែ អាខេម ម្នាក់គត់ ដែលជាមិត្តមានអាធ្យាស្រ័យយ៉ាងល្អ វាបានយល់ពីទុក្ខលំបាក និងយល់ពីទុក្ខលំបាក និងយល់ពីចិត្តថ្លើមខ្ញុំយ៉ាងច្បាស់ ។ ខ្ញុំក៏តែងតែនិយាយប្រាប់វាពីរឿងរ៉ាវដែលកើតមានឡើងនៅក្នុងផ្ទះរបស់ខ្ញុំ អាខេម វាអាណិតខ្ញុំ រហូតមានពេលខ្លះវាបានបបួលខ្ញុំឲ្យទៅរស់នៅជាមួយវា ដោយវាហ៊ានធានាសុំឪពុកម្ដាយវា ។ ខ្ញុំបានអរគុណអាខេម ហើយបាននិយាយប្រាប់វាតាមត្រង់វិញថា ខ្ញុំមិនអាចទៅណាឆ្ងាយបោលអ្នកម្ដាយខ្ញុំបានឡើយ ។

ភូមិត្រពាំងឫស្សី ដែល អាខេម រស់នៅចម្ងាយប្រមាណបីគីឡូម៉ែត្រពីថ្នល់ជាតិ ។ តាំងពីពេលមុនរដ្ឋប្រហារឆ្នាំ១៩៧០មកម្ល៉េះ ពួកកងទ័ពខ្មែរក្រហមដែលមានមូលដ្ឋានបង្អែកនៅក្រាំងល្វានិងអមលាំង បានចេញចូលមកធ្វើការវាយប្រហារប្លន់យកទ្រព្យសម្បត្តិ ស្រូវអង្ករអ្នកស្រុក និងស្ទាក់បាញ់រថយន្តអ្នកដំណើរតាមផ្លូវជាតិជាញឹកញយ ។ បន្ទាប់ពីរដ្ឋប្រហារឆ្នាំ១៩៧០មក ពួកទ័ពខ្មែរក្រហមបានចូលមកនៅពាសពេញ និងបានកាន់កាប់ភូមិត្រពាំងឫស្សីតែម្ដង ។ តាំងពីពេល នោះមក ខ្ញុំបាត់ដំណឹងសូន្យឈឹងពីអាខេម ។

ក្រោយមក អ្នកម៉ែក៏បានយកខ្ញុំទៅផ្ញើឲ្យរស់នៅជាមួយម្ដាយមីងខ្ញុំម្នាក់ជាប្អូនបង្កើតរបស់គាត់ ហើយដែលគាត់បានខស្បាហ៍ទៅមកមើលខ្ញុំជារឿយៗ ។

ពេលដែលបានជួបគ្នាម្ដងៗ ម៉ែ និងអ្នកមីងតែងតែជជែកគ្នាដោយស្ងៀមស្ងាត់ ខ្ញុំពុំដែលបានដឹងថាតើនាក់ទាំងពីរនាក់ជជែកគ្នាពីរឿងអ្វីឡើយ ហើយរាល់ព្រឹកព្រហាមស្រាងៗឡើង ម៉ែ និងអ្នកមីង តែងតែក្រោកឡើងសូត្រធម៌ក្រាបថ្វាយបង្គំព្រះ ដោយអាការៈស្ងប់ស្ងៀមក្រៀមក្រំ មានពេលខ្លះទៀត ខ្ញុំបានលបឃើញអ្នកម៉ែ សម្ងំពួនយំខ្សឹកខ្សួលតែម្នាក់ឯង ហើយនៅពេលដែលខ្ញុំបានសួរទៅគាត់ គាត់បែជាឆ្លើយតបមកខ្ញុំវិញថា ៖ «កូនឯងនៅក្មេងណាស់ កុំចង់ដឹងអី គិតតែពីខំរៀនទៅ...» ។

ជាច្រើនខែកន្លងមកហើយ តាំងពីពេលដែលខ្ញុំបានមករស់នៅជាមួយអ្នកមីង ខ្ញុំពុំដែលបានឃើញមុខឪពុកខ្ញុំទាល់តែសោះ ។ ថ្ងៃមួយ បន្ទាប់ពីខ្ញុំបានទទូចសួរជាញឹកញយ អ្នកម៉ែបានប្រាប់ខ្ញុំថា ៖ «គាត់ឈឺធ្ងន់ កំពុងតែសម្រាកនៅឯពេទ្យ ដោយក្រពះ និងថ្លើមរបស់គាត់ស្ថិតក្នុងស្ថានភាពយ៉ាងយ៉ាប់យ៉ឺនបំផុត...» ។

ខ្ញុំពុំដែលបានទៅមើលសួរសុកទុក្ខគាត់នៅឯមន្ទីរពេទ្យម្ដងណាឡើយ ទោះជាខ្ញុំទទូចសុំយ៉ាងណាក៏ដោយ ក៏ត្រូវបានអ្នកម៉ែបដិសេធមកខ្ញុំវិញថា ៖ «មិនចាំបាច់» ទៅវិញ... ។

អ្នកម៉ែបានអញ្ជើញទៅមើលគាត់នៅឯមន្ទីរពេទ្យជារៀងរាល់ថ្ងៃ ។ ពេលត្រឡប់មកវិញ គាត់មិនដែលបាននិយាយស្អីប្រាប់ខ្ញុំមួយម៉ាត់ឡើយ ហើយមានពេលខ្លះខ្ញុំបានលឺគាត់និយាយប្រាប់អ្នកមីងថា ៖ «ជំងឺរបស់គាត់មិនបានធូរស្រាលឡើយ».... ។

ប្រមាណពីរខែក្រោយមក ខ្ញុំបានសង្កេតឃើញផ្ទៃមុខរបស់អ្នកម៉ែ ហាក់ដូចជាមានពន្លឺរស្មីជាងមុន ថ្វីត្បិតតែគាត់ហត់នឿយស្គមស្គាំងបន្តិចមែន តែអ្នកម៉ែពេលនេះហាក់ដូចជាមានជីវិតថ្មីមួយ...គឺ នៅពេលនោះហើយទើបខ្ញុំបានដឹងថា ឪពុករបស់ខ្ញុំគាត់បានធ្វើមរណកាលបាត់ទៅហើយ... ។

ពេលមុន គ្រប់ដង្ហើមចេញចូលរបស់អ្នកម៉ែ ពោរពេញទៅដោយទុក្ខកង្វល់ និងក្ដីអស់សង្ឃឹម ជីវិតអ្នកម៉ែជាជីវិតដ៏រងកម្មអ្នកម៉ែពុំដែលស្គាល់អ្វីដែលជាសេចក្ដីសុខឡើយ...តែពេលនេះគ្រាដែលអ្នកម៉ែបានសើចញញឹមមករកខ្ញុំម្ដងៗ វាប្រៀបបាននឹងឱសថទិព្វយ៉ាងស័ក្តិសិទ្ធិជួយជំរុញទឹកចិត្តខ្ញុំ ឲ្យខិតខំតស៊ូយ៉ាងខ្លាំងក្លាក្នុងការរៀនសូត្រ... ។

## យុវវ័យក្នុងភពអន្ធការ

ឆ្នាំដំបូង ដែលខ្ញុំមានជីវិតជាកូនសិស្សនៅវិទ្យាល័យ ខ្ញុំបានទទួលការយល់ដឹង និងចេះគិតគូគ្រាន់បើ ក្នុងថ្នាក់រៀន ខ្ញុំរៀនបានពូកែ... តែគួរឲ្យស្តាយដោយស្រុកបែរជាធ្លាក់ក្នុងភ្នក់ភ្លើងសង្គ្រាម ធ្វើឲ្យការសិក្សា និងជីវភាពរស់នៅជួបការលំបាកលំបិន ការភ័យខ្លាច... តែអ្នកម៉ែនៅតែតស៊ូដើម្បីការរៀនសូត្ររបស់ខ្ញុំជានិច្ច ។

ភ្លើងសង្គ្រាមស៊ីវិលដ៏សាហាវ ដែលបានរាលដាលកាន់តែសន្ធោរសន្ធៅទៅៗពីមួយថ្ងៃទៅមួយថ្ងៃនោះ បណ្តាលឲ្យប្រជាជនស៊ីវិលរាប់ម៉ឺនរាប់សែននាក់ បានលះបង់ផ្ទះសម្បែង ភូមិឋានភៀសខ្លួនចេញពីតំបន់ដែលកំពុងតែរងការវាយប្រហារ និងពីតំបន់ដែលបានកាន់កាប់ដោយពួកខ្មែរក្រហម ។ នាពាក់កណ្តាលឆ្នាំ ១៩៧១ ដោយការភ័យខ្លាច ខ្ញុំ និងអ្នកម៉ែរួមជានឹងប្រជាជនជាច្រើនគ្រួសារទៀត ដែលភាគច្រើនប្រកបមុខរបរជាជាងទងស៊ីឈ្នួលឆ្លាក់រចនាក្បាច់ខ្មែរលើជើងពាន ផ្តិលធ្វើអំពីស្ពាន់ និងប្រាក់ឲ្យពួកមេទាហានដែលទទួលផ្តាច់មុខយកទៅលក់ឲ្យឈ្មួញនៅឯស្រុកសៀម ។

ចំណែកឯខ្ញុំក៏បានចូលរៀនសាលាថ្មី ព្រលឹមស្រាងៗឡើងមុនពេលទៅរៀនខ្ញុំបានជូនអ្នកម៉ែទៅទទួលទិញបន្លែបង្ការស្រស់ៗថ្មីៗពីអ្នកស្រុកអរិយក្សត្រ ដែលដាក់ទូកយកមកលក់នៅឯមាត់ទន្លេ ។

ថ្ងៃមួយអ្នកម៉ែបានសួរមកកាន់ខ្ញុំថា តើខ្ញុំមាននឹកឪពុកខ្ញុំឬទេ? ខ្ញុំក៏បានឆ្លើយទៅគាត់វិញថា អត់ទេ... ។ នៅតាមផ្លូវឆ្ពោះទៅកាន់វិទ្យាល័យខ្ញុំ មានតូបស្រាមួយកន្លែងដែលមានមនុស្សចេញចូលស៊ីផឹកពុំឈប់ឈរ.... រាល់ពេលដែលខ្ញុំបានដើរកាត់ទីនោះ បេះដូងខ្ញុំញ័ររន្ធត់លោតខុសសង្វាក់ ហើយខ្ញុំហាក់ដូចជានឹកឃើញដល់សម្រែករបស់ឪពុកខ្ញុំ និងសំណោកយំខ្សឹកខ្សួលរបស់អ្នកម៉ែជាថ្មីទៀត ។

ពេលទំនេរពីការសិក្សា ខ្ញុំបានជួយបន្ធូរបន្ថយការងាររបស់អ្នកម៉ែជាច្រើន ។ ពេលចប់ការសិក្សាខ្ញុំតែងតែប្រញាប់ប្រញាល់ទៅផ្ទះដើម្បីជម្រាបអ្នកម៉ែពីលទ្ធផលនៃការរៀនសូត្រ និងពីរឿងរ៉ាវផ្សេងៗទៀតជាច្រើន ដែលបានកើតឡើងក្នុងវិទ្យាល័យរបស់ខ្ញុំ ហើយដែលរាល់ៗលើក ខ្ញុំសម្គាល់ឃើញអ្នកម៉ែរង់ចាំខ្ញុំរៀបរាប់ដោយយកចិត្តទុកដាក់ ។

ថ្ងៃមួយ ពេលដែលខ្ញុំបានយក "រង្វាន់" យ៉ាងច្រើនពីការប្រលងនិពន្ធអត្ថបទអក្សរសិល្ប៍របស់ខ្ញុំមកជូនអ្នកម៉ែ អ្នកម៉ែញញឹមដោយបានយកដៃដ៏កក់ក្តៅរបស់គាត់មកអង្អែលក្បាលខ្ញុំថ្នមៗ គាត់សម្លឹងមកកាន់ខ្ញុំដោយក្រសែភ្នែកដ៏ស្លូតបូត រួចស្រវាឱបខ្ញុំយ៉ាងណែន ក្នុងវិនាទីជាមួយគ្នានោះ ស្រាប់តែអ្នកម៉ែទ្រហោយំ...ខ្ញុំសែនរំភើប...ក្តុកក្តួលក្នុងចិត្តឥតឧបមា ពេលនោះគឺជាលើកដំបូងបង្អស់ហើយ ដែលខ្ញុំហាក់ដូចជាបានទទួលអារម្មណ៍រីករាយនៅពេលដែលបានឃើញទឹកភ្នែកអ្នកម៉ែស្រក់ធ្លាក់មកក្នុងសភាពបែបនេះ... ។

ពីមួយឆ្នាំទៅមួយឆ្នាំ សភាពការណ៍ក្នុងទីក្រុង និងនៅតាមខេត្តកាន់តែតានតឹង កងកម្លាំងខ្មែរក្រហមបានពង្រឹងការវាយប្រហារកាន់តែខ្លាំងក្លាហើយរំដោះបានស្ទើរតែទូទាំងប្រទេស ចំណែកកងទ័ពរដ្ឋាភិបាលវិញ នៅបានឈរជើងតែត្រង់ចំណុចទីរួមខេត្ត និងទីរួមក្រុងតែប៉ុណ្ណោះ ។

អំពើពុករលួយដល់ឆ្អឹងនៃរដ្ឋាភិបាល លន់ នល់ ពិសេសក្នុងជួរមេបញ្ជាការកងទ័ពកាន់តែស៊ីរូងជ្រៅទៅៗ ទាហានរដ្ឋាភិបាលភាគច្រើនដែលពុំបានទទួលប្រាក់ខែទៀងទាត់អស់កម្លាំងចិត្ត រត់ចោលជួរ លះបង់ការប្រយុទ្ធ និងទទួលបរាជ័យស្ទើរតែគ្រប់សមរភូមិទាំងអស់ ។

ប៉ុន្មានឆ្នាំចុងក្រោយនេះ សង្គ្រាមបានបំផ្លិចបំផ្លាញអាយុជីវិតមនុស្ស សត្វ ឲ្យស្លាប់ព្រាត់ ប្រាសនិរាសន៍ជារៀងរាល់ថ្ងៃរាប់មិនអស់ ជាពិសេសប្រជាជនស៊ីវិលស្លូតត្រង់ដែលគ្មានអាវុធ ។ ក្រៅពីនោះ សង្គ្រាមបានបំផ្លាញភូមិឋាន សាលារៀន ទីផ្សារ ស្ពាន ថ្នល់ផ្លូវអយស្ម័យយាន ឲ្យបាក់ឆេះ រលំខ្ទេចខ្ទីជាគំនរផេះផង់ ។

ឆ្នាំដែលខ្ញុំបានប្រឡងជាប់មធ្យមសិក្សាបឋមភូមិ អ្នកម៉ែគាត់សប្បាយរីករាយក្នុងចិត្តយ៉ាងខ្លាំងដោយក្តីត្រេកអរ គាត់ញញឹមពុំឈប់ រូបខ្ញុំខ្លួនឯងក៏ដូច្នោះដែរ ហើយមិនតែប៉ុណ្ណោះខ្ញុំបានប្តេជ្ញាចិត្តថា នឹងបំពេញអ្វីៗសព្វបែបយ៉ាងទាំងអស់តាមបំណងរបស់អ្នកម៉ែ.... ។

នៅក្នុងវិទ្យាល័យរបស់ខ្ញុំ ក៏ដូចជានៅវិទ្យាល័យនានាផ្សេងទៀតដែរ ក្នុងទីក្រុងភ្នំពេញ ដោយមានសិស្សភៀសខ្លួនមកពី

បណ្តាខេត្តទូទាំងប្រទេសច្រើនពេក ស្ទើរតែគ្រប់វិទ្យាល័យទាំងអស់ចំនួនសិស្សបានកើនឡើងយ៉ាងច្រើនឥតគណនារហូតដល់វិទ្យាល័យខ្លះមានសិស្សដល់ទៅប្រាំពាន់ ឬប្រាំមួយពាន់នាក់ ។

គួរឲ្យសោកស្តាយបំផុត ដោយសារតែហេតុផលខាងលើការរៀនសូត្រក្នុងរយៈពេលប៉ុន្មានខែដើមឆ្នាំនេះ ពុំសូវបានលទ្ធផលអ្វីឡើយ ព្រោះត្រូវបែងចែកពេលរៀនក្នុងមួយថ្ងៃជាពីរវេន ។

ក្រោយមក ការរៀនសូត្ររិតតែជួបនឹងការលំបាកទ្វេឡើងថែមទៀត មានថ្ងៃខ្លះបានត្រឹមតែចេញពីផ្ទះទៅសាលា ពីសាលាមកផ្ទះវិញតែប៉ុណ្ណោះ គ្មានបានរៀនមួយម៉ោងឡើយ ដោយជាញឹកញយលោកគ្រូៗ ....នាំគ្នាធ្វើកូដកម្មមិនព្រមចូលបង្រៀនប្រឆាំងតវ៉ានឹងអំពើពុករលួយ កេងប្រវ័ញ្ចកិបឡឹបបំបាត់ប្រាក់ខែគ្រូ ដែលបើកឲ្យមិនទៀតទាត់ ធ្វើឲ្យប៉ះពាល់ដល់ជីវភាពរស់នៅរបស់ពួកគាត់យ៉ាងខ្លាំង ។

មានលោកគ្រូៗច្រើនណាស់ដែលបានភៀសខ្លួនមកពីខេត្តគ្មានការងារធ្វើ គ្មានប្រាក់ខែ រស់នៅក្នុងភាពយ៉ាងលំបាកវេទនាពួកគាត់គ្មានជម្រើសអ្វីក្រៅពីប្រកបរបរជាអ្នកធាក់ស៊ីក្លូ រត់រ៉ឺម៉កដើម្បីដោះស្រាយបញ្ហាក្រពះ ។

ចាប់ពីដើមឆ្នាំ១៩៧៥ កងទ័ពខ្មែរក្រហមបានបើកយុទ្ធនាការវាយប្រហារបែបទ្រង់ទ្រាយធំ សំដៅមកកាន់ទីក្រុងភ្នំពេញ ។ តំបន់ជាយុទ្ធសាស្ត្រនានាជុំវិញក្រុង ត្រូវបានកាន់កាប់ដោយកងកម្លាំងខ្មែរក្រហម ពេលនោះប្រជាជនដែលរស់នៅក្នុងទីក្រុង រស់នៅក្នុងភាពអាសន្នភ័យខ្លាច ហើយសភាពការណ៍កាន់តែច្របូកច្របល់ដោយពួកខ្មែរក្រហមបានបាញ់គ្រាប់ផ្លោង គ្រាប់ផ្គត់ចូលទីក្រុងភ្នំពេញស្ទើរតែរាល់ថ្ងៃធ្វើឲ្យប្រជាជនស៊ីវិលស្លូតត្រង់ស្លាប់ និងរបួសគ្មានលោះពេលណា ។

ចុងខែមីនា ឆ្នាំ១៩៧៥ មិត្តនារីរួមវិទ្យាល័យខ្ញុំម្នាក់ដែលឪពុកនាងជាវេជ្ជបណ្ឌិតផ្ទាល់របស់លោកសេនាប្រមុខ លន់ នល់ បានមកលាពួកខ្ញុំនៅសាលា ព្រោះគ្រួសារនាង និងគ្រួសារមេទាហានមួយចំនួនទៀតនឹងត្រូវហែហមលោកសេនាប្រមុខចាកចេញទៅសហរដ្ឋអាមេរិក នៅដើមខែមេសា ខាងមុខ.... ។

ដើមខែមេសា ស្ថានការណ៍ជុំវិញទីក្រុងភ្នំពេញ កាន់តែតានតឹងមែនទែនហើយ ដោយភ័យខ្លាច ប្រជាជនសឹងតែមិនហ៊ានចេញពីផ្ទះ នៅឯព្រលានយន្តហោះពោធិ៍ចិនតុង គ្រាប់ផ្លោងចូលរាល់ថ្ងៃ ការហោះហើរពុំអាចដំណើរការទៀតបានឡើយ ។

ព្រឹកថ្ងៃ១២ ខែមេសា ប្រជាជនដែលរស់នៅមាត់ទន្លេ និងនៅម្តុំផ្សារកាប់គោ មានការភ្ញាក់ផ្អើលយ៉ាងខ្លាំង បាននាំគ្នារត់ទៅមើលឧទ្ធម្ភាគចក្រចម្បាំងធំៗរបស់ទាហានអាមេរិកកាំងជាច្រើនគ្រឿង ដែលបានចុះចតយ៉ាងគគ្រឹកគគ្រេង ឡើងហុយដីទ្រលោមនៅទីងទីធ្លាខាងក្រោយស្ថានទូតអាមេរិក ។

ដោយមានការការពារសន្តិសុខយ៉ាងមាំទាំ ពួកកងទ័ពអាកាសអាមេរិកបានចុះមករំដោះ ឯកអគ្គរដ្ឋទូតលោក *Jonh Gunther Dean* ក្នុងសភាពយ៉ាងប្រញាប់ប្រញាល់ តក់ក្រហល់បំផុត... ។ លោក ឧត្តមសេនីយ៍ សូខាំខូយ ប្រធានាធិបតីស្តីទីដែលទើបតែនឹងត្រូវបានតែងតាំងជំនួសលោកសេនាប្រមុខ លន់ នល់ កាលពីដើមខែមេសា ក៏មានវត្តមានចាកចេញក្នុងឱកាសនេះដែរ ។

ក្នុងចំណោមមនុស្សយ៉ាងច្រើនកុះករខ្ញុំឈរមើលពីក្រៅរបងដែលមានដាក់សំណាញ់ដែកយ៉ាងខ្ពស់ ។ តាមមាត់ទ្វារច្រកចូលដែលមានទាហានអាមេរិកកាំងនៅឈរត្រៀបត្រា និងកងកម្លាំងការពារសន្តិសុខជាច្រើននាក់ទៀតកំពុងតែរុញច្រានហ្វូងមនុស្សដ៏ពពាក់ពពូន ដែលកំពុងតែដណ្តើមប្រជ្រៀតគ្នាចូល អ្នកខ្លះកំពុងតែប្រវេរប្រវាប្រតេងប្រតោងលោតឡើងផ្លោះរបងរត់ចូលសំដៅទៅកាន់ឧទ្ធម្ភាគចក្រ ដែលមានទាហានអាមេរិកកាំងនៅឈរតម្រៀបគ្នាជាខ្សែក្រវ៉ាត់ការពារ ដៃកាន់កាំភ្លើងត្រៀមលក្ខណៈប្រយុទ្ធជាស្រេច បែរចុងកាណុងមកកាន់ប្រជាជន លាយឡំនឹងសូរសន្ធឹកយន្តហោះលាន់ឮយ៉ាងខ្លាំង ។

តាំងពីពេលនោះមក ខ្ញុំលែងហ៊ានទៅណាឆ្ងាយចោលអ្នកម៉ែហើយ ទៅសាលារៀនក៏ឈប់ទៅដែរ ព្រោះសភាពការណ៍ដ៏តានតឹងមួយថ្ងៃពីរថ្ងៃមុនពេលចូលឆ្នាំខ្មែរនេះ ទាំងគ្រូទាំងសិស្សបែកខ្ញែកគ្នាអស់ហើយ សូម្បីតែពួកទាហាន និងកងអាវុធហត្ថជាច្រើនកងដែលប្រចាំការនៅទីងភូមិគ្រឹះលោកសក្តិ៥ ឈឹម ឈួន ខាងកើតវត្តប្រយូរវង្សក៏បែកខ្ញែកគ្នាអស់ហើយដែរ ។ ចំណែកអ្នកម៉ែទៅលក់តែមួយភ្លែតៗ ហើយប្រញាប់ប្រញាល់មកផ្ទះវិញ ។ ចូលឆ្នាំខ្មែរថ្ងៃទីមួយ និងថ្ងៃទីពីរ បំរាមគោចរត្រូវបានប្រកាសបិទម្ភៃបួនម៉ោងរួចបន្ថែមម្ភៃបួនម៉ោងទៀត ។ ថ្ងៃដដែលនោះនៅខាង

លិចទីក្រុងទីក្រុងភ្នំពេញ កងទ័ពខ្មែរក្រហមបានសំរុកចូលមកដល់អូបែកក្អមហើយស្នូរកាំភ្លើងធំតូចលាន់សូរកាន់តែកៀក តាមផ្លូវនានា ក្នុងទីក្រុងមានសភាពស្ងាត់ឈឹង យូរៗម្តងឃើញមានរថយន្តដឹកកងទ័ពរដ្ឋាភិបាល និងរថក្រោះបើកត្រឡប់ចូលមកទីក្រុងវិញ ។ យប់ថ្ងៃទី១៥ ចូលថ្ងៃទី១៦ ខែមេសានៅត្រើយម្ខាងទន្លេបាសាក់ នៅម្តុំផ្សារច្បារអំពៅ និងនៅគល់ស្ពានក្បាលថ្នល់ ផ្ទះអ្នកផ្សារ ផ្ទះប្រជាជនតាមបណ្តោយមាត់ទន្លេ និងឃ្លាំងសាំងក្បាលថ្នល់ រងគ្រាប់ផ្លោងរបស់ពួកខ្មែរក្រហម ត្រូវបានឆេះរាលដាលយ៉ាងសន្ធោរសន្ធៅ ភ្លើងឆាបឆេះក្រហមមួយចំហៀងមេឃ ។ ស្នូរគ្រាប់កាំភ្លើងដៃតូចធំបាញ់ប្រយុទ្ធតតាំងគ្នាលាន់ព្រាកាន់តែរន្ថើន... ។

យប់នោះគឺជាដំណាក់កាលប្រយុទ្ធតស៊ូចុងក្រោយហើយរបស់កងទ័ពរដ្ឋាភិបាល ដែលក្រាញនទៀល មិនព្រមលះបង់ការប្រយុទ្ធមិនព្រមចុះចាញ់នៅតាមខ្សែក្រវ៉ាត់ការពារជុំវិញទីក្រុងភ្នំពេញនោះ ។ រំលងអាធ្រាត្រយប់ថ្ងៃ១៦ ខែមេសា ខ្ញុំបានឃើញទាហានរដ្ឋាភិបាលជាច្រើននាក់ "បាក់ទ័ព" រត់យ៉ាងប្រសេចប្រសាចចូលវត្តប្រយូរវង្ស ខ្លះទៀតចូលទៅពួនជ្រកតាមផ្ទះប្រជាជនខាងកើតវត្ត ដោយនាំគ្នាដោះឯកសណ្ឋានទាហានគ្រវាត់ចោលយ៉ាងរួសរាន់ ហើយប្រញាប់បែកខ្ញែកគ្នាអស់ទៅ... ។ នៅឯគល់ស្ពានក្បាលថ្នល់ ផ្ទះប្រជាជនរាប់សិបខ្នង និងឃ្លាំងសាំងកំពុងតែឆេះយ៉ាងពេញទំហឹងនៅឡើយ ។

ព្រឹកថ្ងៃទី១៧ ខែមេសា ពូផន កូនប្រសារលោកយាយកំពង់សៀម ខ្ញុំមិនបានស្គាល់ឈ្មោះគាត់ពិតប្រាកដទេ តែដោយគាត់ភៀសខ្លួនមកពីស្រុកកំពង់សៀម ខេត្តកំពង់ចាម ហើយដែលបានរស់នៅនឹងខ្ទមមួយក្បែរខាងខ្ញុំនោះ អ្នកម៉ែក៏ហៅឈ្មោះគាត់ថា យាយកំពង់សៀមតែម្តងទៅ ជាទាហានថ្មើរជើងពាក់សក្តិមួយ នៅកងពលធំទីពីរ ខោអាវរហែកដាច់ប្រឡាក់ភក់ឲ្យស្រមក ដៃគាត់ម្ខាងយួរកាំភ្លើងអាការ៤៧មួយដើម និងមានគ្រាប់បែកជាច្រើនគ្រាប់ព្យួររណោងជុំវិញចង្កេះផង បានរត់ចូលមកក្នុងខ្ទមយ៉ាងត្រហេបត្រហបស្ទន់ស្ទោ ។ ក្រោយពីបានដោះឯកសណ្ឋានទាហានចោលភ្លាម គាត់បានប្រញាប់ប្រញាល់ប្រមូលគ្រាប់បែក និងកាំភ្លើងយកទៅបោះទម្លាក់ចោលក្នុងអណ្តូងទឹក អ្នកជិតខាងក្បែរនោះអស់ទៅ ។

គ្រាដែលខ្ញុំជួយទម្លាក់កាំភ្លើង គ្រាប់បែករបស់ពូផនចូលទៅក្នុងអណ្តូង លាយឡំនឹងស្នូរកាំភ្លើង ដែលលាន់ព្រាកាន់តែទ្រហឹង ខ្ញុំនៅបានព្រួបទចម្រៀងគុកស្នេហា ច្រៀងដោយលោក ស៊ិន ស៊ីសាមុត យ៉ាងពិរោះគ្រលួចពីចម្ងាយ ដែលកំពុងចាក់ផ្សាយដោយវិទ្យុសំឡេងសាធារណរដ្ឋខ្មែរ ។

គ្រាប់ផ្លោងជាច្រើនគ្រាប់បានធ្លាក់ផ្ទុះផ្ទួនៗគ្នា លាន់សឹងតែបែកក្រដាសត្រចៀក ខ្ញុំនឹងអ្នកម៉ែ ភិតភ័យស្លុតយ៉ាងខ្លាំង នាំគ្នាក្រាបផ្ទាល់ទៅនឹងដី ។ មួយស្របក់ធំក្រោយមក ស្នូរគ្រាប់ហាក់ដូចជាស្ងប់បន្តិចទៅវិញ ប្រជាជននាំគ្នាផ្អើលរត់ទៅមើលរថក្រោះ និងរថយន្តកងទ័ពខ្មែរក្រហមជាច្រើនគ្រឿងកំពុងតែបើកសំរុកលាន់សន្ធឹកស្ទើររញ្ជួយដីតម្រង់ចូលទៅក្នុងទីក្រុង ។ សម្រែកជ័យឃោសលាន់ព្រាយ៉ាងកងរំពងពីសំណាក់ប្រជាជនរាប់ម៉ឺននាក់ ដែលកំពុងឈរប្រជ្រៀតគ្នាយ៉ាងពពាក់ពពូនតាមបណ្តោយសងខាងផ្លូវ ខ្ញុំ និង ពូផន ឈរពីក្រោមខ្លោងទ្វារវត្ត លើកដៃគ្រវីដោយទឹកមុខសប្បាយរីករាយ អបអរសាទរ ទទួលស្វាគមន៍ "ពួកមិត្តរំដោះ" ។

ក្នុងធ្លាវត្តក្បែរចេតិយធំមួយ ក្រោមម្លប់ដូងដែលនៅមិនឆ្ងាយប៉ុន្មានពីខ្ញុំ មានប៉េអឹមពីរនាក់ ម្នាក់ឈ្មោះ ឃ្លោក ផល្លីពាក់សក្តិ១ ធ្វើការនៅប៉ុស្តិ៍ទួលគោក និងគ្នាគាត់ម្នាក់ទៀតកំពុងនាំគ្នាស្រាតឯកសណ្ឋាន "អ.ហ" គ្រវាត់ចោល ហើយប្រញាប់នាំគ្នាគេចខ្លួនបាត់ពីទីនោះទៅ.... ។

ក្រោមក្រសែភ្នែកអ្នកទីក្រុងរាប់ម៉ឺនរាប់សែននាក់ កងទ័ពខ្មែរក្រហមជាច្រើនកងក្នុងសម្លៀកបំពាក់ពណ៌ខ្មៅបង់កក្រមាខ្លះជួតក្បាល ខ្លះពាក់មួកកន្តិបចិនប្រជាមានិត ពាក់ស្បែកជើងកង់ឡាន ខ្លះទៀតដើរដោយជើងទទេជាមួយនឹងទឹកមុខយ៉ាងម៉ឺងម៉ាត់ដាច់ខាត ដែលហាក់ដូចជាមិនសូវសប្បាយរីករាយនឹងសម្រែកស្វាគមន៍អបអរសាទរពីសំណាក់អ្នកក្រុងយ៉ាងប្រុងប្រយ័ត្ន ។

ក្បួនរថយន្តហ្ស៊ីប រថក្រោះដែលមានកងទ័ពរំដោះ និងទាហានរដ្ឋាភិបាលអង្គុយប្រកៀកស្មាគ្នា ដៃកាន់បាច់ផ្កា និងទង់ពណ៌សគ្រវីពុំឈប់ឈរ លាយឡំនឹងសម្រែកអបអរសាទរយ៉ាងខ្ញៀវខ្ញារ "ជ័យយោ! កងទ័ពមិត្តរំដោះ" កំពុងតែបើករំកិលយឺតៗ ឆ្ពោះទៅកាន់វិមានឯករាជ្យ ។ **(តទៅលេខក្រោយ)**

**ប៉ុក ប៊ុនសូម៉ាឌ**

# ដំណើរភៀសខ្លួនឆ្លងដែនពីរបបកម្ពុជាប្រជាធិបតេយ្យ

***រឿងពិតរបស់ ជា សីហា***

**(តចប់)**

កិច្ចការដ៏ធ្ងន់ហួសកម្លាំងទាំងនេះ ដែលខ្ញុំអាចទ្រាំទ្របាន ក៏ព្រោះតែសេចក្តីឈឺចាប់ដែលបណ្តាលមកពីការគិតថា បាត់បង់ប្រទេសជាតិ បាត់បង់ប្រពន្ធកូន និងគ្រួសារ តើរស់នៅតែម្នាក់ឯងមានន័យអ្វីទៅ? មានពេលមួយ ខ្ញុំកើតមានសង្វេគដោយខ្វឹកខ្វលចំពោះវាសនាអនាគតរបស់ប្រទេសជាតិ ព្រោះតែខ្ញុំយល់ថា វៀតណាមពិតជាយកប្រទេសយើងទៅធ្វើជាខេត្តរបស់គេជាស្ថាពរមិនខានឡើយ ។ ស្រាប់តែមានទម្ងន់ដៃមួយប្រត់លើស្មាខ្ញុំ ខ្ញុំងាកទៅរកម្ចាស់ដៃ ឃើញលោកបណ្ឌិតច្បាប់ដើងចាស់ម្នាក់ ដែលត្រូវជាប្អូនរបស់អតីតអ្នកគ្រូខ្ញុំ ។ គាត់ពោលមកកាន់ខ្ញុំថា ប្រទេសយើងប្រៀបបាននឹងសត្វហ្វេនីកស៍ ។ សត្វហ្វេនីកស៍ កាលបើរស់នៅយូរៗទៅក៏ដុតខ្លួនឯងនឹងភ្លើងឆេះព្រៃ ។ ដល់ពេលខ្លួនឆេះទៅជាផេះអស់ហើយ នៅសល់រោមកែវមួយសរសៃ ។ រោមកែវនោះក៏ចាប់កំណើតជាសត្វហ្វេនីកស៍ថ្មីមួយទៀត ដែលខ្លាំងក្លាជាងមុន ។ ប្រទេសយើង ក៏ដូច្នោះដែរ គឺមានជីវិតជាអមតៈ ។

ភារកិច្ចរបស់ខ្ញុំមួយទៀត ដែលសំខាន់លើសពីជីវិតរបស់ខ្ញុំទៅទៀត គឺការស្វែងរកដំណឹងពីប្រពន្ធ និងកូនរបស់ខ្ញុំ ។ បើមានហេតុមិនល្អឯណាមួយប៉ះពាល់ដល់ពួកគេ ខ្ញុំមុខជានឹងមានវិប្បដិសារៈអស់មួយជីវិត ព្រោះតែកំហុសរបស់ខ្ញុំដែលបានរត់ចោលពួកគេ ។ ខ្ញុំតែងតែឆ្លៀតធ្វើដំណើរទៅស៊ើបសួរដំណឹងពីអ្នកភៀសខ្លួនដែលទើបមកដល់ នៅតាមមជ្ឈមណ្ឌលសម្រាប់ជនភៀសខ្លួននានា នៅក្រុងប៉ារីស និងនៅតាមជាយក្រុង ។ ដំណឹងចុងក្រោយមួយគួរឲ្យតក់ស្លុតក្រៃលែង គឺសៀមបានបញ្ជូនអ្នកភៀសខ្លួនខ្មែរចំនួនជាច្រើនម៉ឺននាក់ឲ្យចុះតាមភ្នំព្រះវិហារមកប្រទេសកម្ពុជាវិញ ។ កាកបាទក្រហមនៃប្រទេសម៉ូណាកូ ដែលគេបានដឹង និងបានថតពីលើយន្តហោះនូវជនអភ័ព្វទាំងអស់នោះ ។ ភ្នាក់ងារនៃកាកបាទក្រហមម៉ូណាកូ បានប៉ាន់ប្រមាណថា ចំនួនមនុស្សស្លាប់អាចស្មើនឹងពាក់កណ្តាលនៃចំនួនមនុស្សដែលគេទម្លាក់ទៅតាមភ្នំនោះ ព្រោះជាតំបន់ដែលសម្បូរទៅដោយគ្រាប់មីន ។ ខ្ញុំបានពឹងពាក់គេតាមជំរុំអ្នកភៀសខ្លួននៅតាមព្រំដែនខ្មែរ-សៀម ឲ្យបិទប្រកាសស្វែងរកគ្រួសារ ។

ដំណឹងដ៏អស្ចារ្យដែលខ្ញុំនឹកស្មានមិនដល់ គឺមានព្រះសង្ឃមួយអង្គសរសេរសំបុត្រភ្ជាប់នឹងរូបថតផង ផ្ញើមកដល់ដៃខ្ញុំ ដោយប្រាប់ជាដំណឹងមកខ្ញុំថា ប្រពន្ធ និងកូនរបស់ខ្ញុំបានមកដល់ជាយដែនហើយ ។ ដំណឹងដ៏មហារីករាយនេះ ធ្វើឲ្យខ្ញុំបាត់បង់ភាពអំណត់ គឺធ្វើឲ្យចិត្តខ្ញុំអន្ទះសារ ឆ្លេឆ្លារកមិត្តភក្តិឲ្យជួយ ។ មានមិត្តម្នាក់ធានានឹងខ្ញុំថា ទៅរកប្រពន្ធកូនឲ្យខ្ញុំ ហើយនឹងរត់ការឲ្យឆាប់បានមកដល់ប្រទេសបារាំង ។ តាមពិតទៅ មិត្តនោះពុំបានជួបនឹងប្រពន្ធកូនរបស់ខ្ញុំទេ ពីព្រោះកូនខ្ញុំឈ្មោះ យុពា បានឃើញប្រកាសរបស់ខ្ញុំដែលបិទតាមព្រំដែន ហើយយកប្រកាសនោះមកជូនម្តាយរបស់វា ហើយម្តាយរបស់វា យកប្រកាសនោះទៅជូនលោកឪពុក វ៉ីណេ ។ លោកឪពុកមិនបង្អែបង្អង់ ក៏រូតរះធ្វើសំបុត្រស្នាមឲ្យគ្រួសារខ្ញុំបានចេញពីជំរំមួយទៅកាន់ជំរំមួយទៀត ។ មិនយូរប៉ុន្មាន គ្រួសារខ្ញុំទាំងអស់បានចាកចេញពីប្រទេសថៃ មកដល់ប្រទេសបារាំងនៅរវាងខែតុលា ឆ្នាំ១៩៨០ ។ ខ្ញុំទៅទទួលពួកគេនៅអាកាសយានដ្ឋានស្ទាលដឺហ្គោល ជិតក្រុងប៉ារីស ។ ពេលឃើញពួកគេពីដំបូងខ្ញុំស្ទុះទៅឱបកូនពៅរបស់ខ្ញុំមុនគេ ។ នៅពេលនោះនាងមានអាយុ២ឆ្នាំ នាងបានរុញខ្ញុំចេញដោយពោលពាក្យថា "ពូឯងមិនមែនប៉ាខ្ញុំទេ ប៉ាខ្ញុំនៅប៉ារីសឯណោះ" ។ ក្រៅពីកូនពៅយើងបានឱបរឹតគ្នាដោយសេចក្តីអាឡោះអាល័យពន់ពេកណាស់ ។ ខ្ញុំឃើញកូនខ្ញុំនៅគ្រប់ចំនួន ខ្ញុំឥតមានអ្វីត្រូវសង្ស័យទៀតទេ ។ នេះហើយដែលវិប្បដិសារៈរបស់ខ្ញុំត្រូវបានលើកលែង ។ ខ្ញុំមានកូន៧នាក់ថែមកូនចិញ្ចឹមម្នាក់ទៀតទៅជា៨នាក់ ។ កិច្ចការសម្រាប់ចិញ្ចឹមកូនទាំង៨នាក់ ពុំមែនជាការងារតូចតាចទេ ។ ដោយសេចក្តីស្រឡាញ់ និង

អាណិតចំពោះភរិយា និងកូនដែលបានឆ្លងផុតវាលពិឃាដ ខ្ញុំត្រូវយកចិត្តទុកដាក់ជាទីបំផុតទៅលើពួកគេ ដើម្បីបំពេញចិត្តពួកគេក្នុងនាមខ្ញុំជាប្ដី និងជាឪពុកដ៏ល្អបំណាច់ពួកគេខំប្ដូរជីវិតដើម្បីស្វែងរក និងម្យ៉ាងទៀត ឲ្យសមស្របនឹងចិត្តរបស់ខ្ញុំដែលបានទន្ទឹងរង់ចាំពួកគេអស់រយៈពេលជាង២ឆ្នាំយ៉ាងលំបាកបំផុត ។ ការព្រាត់ស្លាប់គង់មានថ្ងៃបំភ្លេចបាន ប៉ុន្តែការព្រាត់រស់វិញនឹងបំភ្លេចមិនបានរហូតដល់ថ្ងៃស្លាប់ ។ ខ្ញុំរកជួលផ្ទះថ្មីឲ្យត្រូវតាមចំណុះ ។ ខ្ញុំរើផ្ទះពីក្នុងមន្ទីរព្យាបាលមកនៅទីប្រជុំជនប៉ូហ្វម៉ុងវិញ ។ លោកគ្រូរបស់ខ្ញុំម្នាក់ជាវេជ្ជបណ្ឌិតបានឃើញបន្ទុកដ៏ធ្ងន់របស់ខ្ញុំ គាត់បានសុំយកកូនចិញ្ចឹមរបស់ខ្ញុំទៅបីបាច់រក្សាជាកូនចិញ្ចឹមរបស់គាត់ ។ ខ្ញុំបន្ថយបានកូនមួយ ប៉ុន្តែនៅសល់កូន៧នាក់ទៀតដែលត្រូវបីបាច់រក្សា ។ ជីវិតរបស់ពួកយើងបានសុខសាន្ត និងរីកចម្រើនជាលំដាប់ ។ យើងបានស្គាល់សុភមង្គលយ៉ាងពេញបរិបូរណ៍ ។ សំណើចក្អាកក្អាយរបស់កូនជាតន្ត្រីកំដរបរិយាកាសក្នុងគ្រួសារឲ្យស្រស់ស្រាយ និងពោរពេញដោយក្ដីសង្ឃឹម ។

ភរិយាខ្ញុំចង់បានមុខរបរមួយបន្ថែមទៀត ។ គាត់ប្រកបមុខរបរជាសិប្បការិនីខាងសម្លៀកបំពាក់ ។ គាត់គ្រប់គ្រងរោងសិប្បកម្មមួយដែលមានជាងដេរទាំងក្នុង ទាំងក្រៅ ប្រមាណ១០នាក់ ។ មុខរបររបស់គាត់ហត់នឿយណាស់ តម្រូវឲ្យគាត់ធ្វើការជាច្រើនម៉ោង មិនសមនឹងកម្រៃដែលបានទទួល ។ ខ្ញុំ និងកូនៗត្រូវឆ្លៀតជួយការងាររបស់គាត់ខ្លះដែរ ។ ចំណែកខ្ញុំ ខ្ញុំធ្វើការតែមួយកន្លែងទាំង១៥ឆ្នាំនៅប្រទេសបារាំង ។ ជីវភាពរបស់យើងជាទូទៅបានគ្រប់គ្រាន់ ។ កូនៗរៀនបានជ្រៅជ្រះគ្រប់ៗគ្នា ។ មានកូនខ្លះរៀនដល់ក្រោយឧត្ដមសិក្សាទៀតផង ។

១៥ឆ្នាំនៅប្រទេសបារាំង ជាពេលវេលាដ៏មានតម្លៃបំផុតក្នុងជីវិតរបស់ខ្ញុំ ។ នៅទីនោះហើយ ដែលខ្ញុំបានស្គាល់រស់ជាតិនៃជីវិតពិតប្រាកដ ។ នៅទីនោះហើយ ដែលខ្ញុំបានរស់ឡើងវិញក្នុងសេចក្ដីថ្លៃថ្នូរ និងសុខដុម ។ នៅទីនោះហើយ ដែលខ្ញុំស្គាល់សិទ្ធិសេរីភាពពិតប្រាកដ ក្រោមកិច្ចធានារបស់ច្បាប់ ។ ប្រទេសបារាំងបានផ្ដល់ចំណេះដឹង ផ្ដល់សម្បជញ្ញៈ ផ្ដល់សេចក្ដីក្លាហានដល់ខ្ញុំ ។ ខ្ញុំមានមនោសញ្ចេតនាដ៏ជ្រាលជ្រៅចំពោះប្រជាជនបារាំងដែលជាគំរូនៃការតស៊ូក្នុងជីវិតផ្ទាល់ខ្លួន និងការជួយយកអាសា និងជួយឈឺឆ្អាលដល់អ្នកដទៃ ។ មានពាក្យមួយឃ្លា ដែលមនុស្សអភ័ព្វទាំងឡាយតែងតែពោល នៅគ្រាមានទុក្ខលំបាកថា ប្រទេសបារាំងជាទឹកដីនៃជម្រកដ៏សុខសាន្ត ។ ជនជាតិបារាំងសុទ្ធជាអ្នកស្នេហាជាតិដ៏ម៉ឺងម៉ាត់ទាំងក្នុងអតីតកាល និងបច្ចុប្បន្ននេះ ។ មានអង្គការអនាមិកមួយរបស់បារាំងបានបន្ដផ្ដល់ប្រាក់ឲ្យខ្ញុំចំនួន៥ម៉ឺនហ្វ្រង់ ។ ដោយសារប្រាក់ដែលមានចំនួនដ៏ច្រើននេះ បានជួយខ្ញុំឲ្យទប់ទល់ និងចំណាយទៅលើការបោះពុម្ព និងការផ្សព្វផ្សាយសារព័ត៌មានរបស់យើងបានគ្រប់ទិសទី ។

កិច្ចការរបស់ខ្ញុំនឿយហត់មែន ប៉ុន្តែខ្ញុំពេញចិត្តនឹងធ្វើ គឺធ្វើដើម្បីបំពេញចិត្តខ្លួនឯង ដើម្បីឲ្យអនាគតរបស់កូនចៅបានសុខសាន្ត និងដើម្បីឲ្យប្រទេសជាតិបានឯករាជ្យ និងសន្តិភាព ។

ស្រាប់តែមកដល់ចុងឆ្នាំ១៩៨៧ មានដំណឹងរហិចរហៀងថា សម្ដេចនរោត្ដម សីហនុ និងលោក ហ៊ុន សែន នឹងជួបចរចាគ្នាក្នុងពេលឆាប់ៗខាងមុខនេះហើយ ។ ទោះបីជាដំណឹងរហិចរហៀង ប៉ុន្តែមានសារសំខាន់ណាស់សម្រាប់ប្រជាជនខ្មែរគ្រប់រូប ។ យើងមានសេចក្ដីសង្ឃឹមឡើងវិញហើយ ។ នៅដើមខែធ្នូឆ្នាំ១៩៨៧ សម្ដេចនរោត្ដម សីហនុ និងឯកឧត្ដម ហ៊ុន សែន បានជួបចរចាគ្នា ។ ជាងមួយខែក្រោយមកទៀត គឺនៅខែមករា ឆ្នាំ១៩៨៨ បានជួបចរចាគ្នាម្ដងទៀតជាលើកទីពីរ ។ ក្រោយជំនួបនៃអ្នកទាំងពីរ ចំនួនពីលើកនេះ ខ្ញុំគិតថា អ្នកដឹកនាំជាតិទាំងពីររូបបានចាប់ផ្ដើមសម្រុះសម្រួលគ្នា ហើយចំណែកខ្ញុំជាពលរដ្ឋខ្មែរម្នាក់ ហើយគ្មានមហិច្ឆតាក្នុងរឿងនយោបាយទាល់តែសោះ គ្រាន់តែចង់ឲ្យប្រទេសជាតិមានឯករាជ្យ និងសន្តិភាពតែប៉ុណ្ណោះ ដូច្នេះ អ្វីដែលខ្ញុំបានធ្វើថា សម្រាប់ប្រទេសជាតិនោះ នឹងបានប្រយោជន៍អ្វីទៀតទេ គឺទុកឱកាសថ្វាយ និងជូនអ្នកដឹកនាំជាន់ខ្ពស់របស់ខ្មែរសម្រេចតាមការគួរទៅចុះ ។ ដោយយល់ឃើញដូច្នេះហើយ ខ្ញុំក៏ចាប់ផ្ដើមដកខ្លួនចេញពីសកម្មភាពដែលទាក់ទងទៅនឹងសារព័ត៌មាន និងមជ្ឈមណ្ឌលខ្មែរបន្តិចម្ដងៗរហូតដល់រវាងខែកក្កដា ឆ្នាំ១៩៨៨ ខ្ញុំសម្រេចដកខ្លួនឈប់រវល់រឿងនយោបាយជាស្ថាពរ ។ ក្នុងខែវិច្ឆិកា ឆ្នាំ១៩៨៨ ខ្ញុំ និងភរិយាមានកិត្តិយសបានចូលជួបឯកឧត្ដម ហ៊ុន សែន នៅក្នុងសណ្ឋាគារមួយនៅក្រុងប៉ារីស ។ ជាលើកដំបូងដែលខ្ញុំបានស្ដាប់ប្រសាសន៍ឯកឧត្ដម ហ៊ុន សែន ។ ខ្ញុំសង្កេតឃើញមានលក្ខណៈសម្បត្តិរបស់អ្នកនយោបាយរូបនេះ ។ លោកជាមនុស្សសាមញ្ញរសរាយរាក់ទាក់ មានប្រសាសន៍

ដោយត្រង់ៗ ហើយស្មោះ ។ នៅពេលនោះហើយដែលខ្ញុំបានឃើញ សម្បជញ្ញៈជាតិដ៏ខ្ពង់ខ្ពស់ និងញាណទស្សនៈក្នុងបញ្ហាជាតិរបស់ ឯកឧត្តម ។ ខ្ញុំនឹកកោតសរសើរក្នុងចិត្តថា ឯកឧត្តមមានអតីតកាល ជាមេទ័ពតស៊ូ ប៉ុន្តែ ឯកឧត្តមមានវោហាកោសល្យដូចអ្នកនយោបាយអាជីពក៏ល្បីម្នាក់ ។

នៅខែតុលា ឆ្នាំ១៩៨៩ ខ្ញុំ និងភរិយាបានមកកាន់មាតុភូមិជាថ្មីឡើងវិញ ។ កងទ័ពស្ម័គ្រចិត្តវៀតណាមបានដកចេញទាំងស្រុងពីទឹកដីកម្ពុជាតាំងពីខែមុន ។ រហូតដល់ថ្ងៃ២៣ ខែតុលា ឆ្នាំ១៩៩១ ទើបមានសន្និសីទអន្តរជាតិស្ដីពីប្រទេសកម្ពុជានៅទីក្រុងប៉ារីស ដើម្បីសម្រេចកិច្ចព្រមព្រៀងក្នុងបង្កើតយន្តការសម្រាប់សម្រុះសម្រួលភាគីជម្លោះទាំងបួនរបស់កម្ពុជាឲ្យចូលរួមបង្កើតរដ្ឋាភិបាលបណ្ដោះអាសន្នមួយ នៅទីក្រុងភ្នំពេញ និងឧត្តមក្រុមប្រឹក្សាជាតិ ក្រោមការត្រួតពិនិត្យនៃអង្គការសហប្រជាជាតិ ។

ទម្រាំបានសន្តិភាពពេញលេញនៅកម្ពុជា ប្រជាជនខ្មែរត្រូវរង់ចាំរហូតដល់ឆ្នាំ១៩៩៨ ។ កម្ពុជាពិតជាបានកើតឡើងវិញពីដៃរបស់ខ្លួន ។ កម្ពុជាពិតជាមានជីវិតអមតៈ ។

**អវសានកថា**

ព្រះសម្មាសម្ពុទ្ធជាម្ចាស់មានព្រះបន្ទូលថា កតញ្ញូកតាធម៌ជាធម៌ដ៏ឧត្តម ជាឫសគល់នៃសីលធម៌ទាំងពួង ។ បុគ្គលគ្រប់រូបតែងមាន អ្នកមានឧបការគុណលើខ្លួនជានិច្ចគរាប់តាំងពីឪពុកម្ដាយ គ្រូអាចារ្យ ញាតិសាច់សាលោហិត អ្នកភូមិផងរបងជាមួយអ្នកគ្រប់គ្រងប្រទេសដែលមានសុចរិត យុត្តិធម៌ អាជ្ញាធរដែលប្រកាន់ច្បាប់ត្រឹមត្រូវ និងជនានុជនដែលធ្លាប់ជួយឈឺឆ្អាលខ្លួននៅពេលមានទុក្ខ ជួនស្គាល់ ជួនមិនស្គាល់ ។ ក្នុងមួយថ្ងៃៗ ការជួយយកអាសាគ្នាមានរាប់មិនអស់ ព្រោះអ្នកមានសាមគ្គីធម៌ អ្នកមានមេត្តា និងករុណាធម៌ ចង់ឲ្យមនុស្សគ្រប់ៗរូបបានសុខរួចចាកពីទុក្ខ ។ ការជួយគ្នាទៅវិញទៅមកនេះហើយបង្កើតជាឧបការគុណលើគ្នាទៅវិញទៅមកមិនចេះចប់ មិនចេះហើយ ដែលហៅដោយខ្លីថា “គុណ ឬជាមនុស្សធម៌” ។ ចំណែកមនុស្សម្នាក់ៗទម្រាំរស់មកដល់សព្វថៃនេះតើម្នាក់ៗត្រូវមានអ្នកឧបការគុណលើខ្លួនប៉ុន្មាននាក់ទៅ? តើខ្លួនត្រូវធ្វើបដិការចំពោះអ្នកទាំងនោះវិញយ៉ាងដូម្ដេច?

ការធ្វើបដិការចំពោះអ្នកមានគុណដែលស្គាល់មុខ គេអាចប្រព្រឹត្តបានទៅតាមធនធានរបស់ខ្លួន ចំពោះអ្នកនោះទៅតាមទំហំនៃគុណ ឬទៅតាមចិត្តជ្រះថ្លា ។ ចំពោះអ្នកមានគុណដែលមិនស្គាល់មុខ គេពុំអាចធ្វើបដិការបានឡើយ ប៉ុន្តែ យើងអាចមានមេត្តាធម៌ ឬករុណាធម៌ចំពោះមនុស្សទូទៅ គឺជាការធ្វើគុណមិនរើសមុខឲ្យដូចអ្នកមានគុណមិនស្គាល់មុខរបស់យើងដែរ គឺជាបដិការចំពោះអ្នកមានគុណទាំងនោះហើយ ។

ចំពោះរឿងរបស់ខ្ញុំតាំងពីខ្ញុំរត់ចេញពីសហករណ៍ស្ពួលកោង នៅថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៧៨ មកដល់សព្វថ្ងៃនេះ ខ្ញុំសូមធ្វើបញ្ជីឈ្មោះអ្នកមានគុណដ៏វែង ប៉ុន្តែ មិនគ្រប់សព្វរបស់ខ្ញុំ ដើម្បីថ្លែងអំណរគុណចំពោះសប្បុរសដែលបានញុំាងជីវិតរបស់ខ្ញុំ និងរបស់គ្រួសារខ្ញុំឲ្យបានដូចសព្វថ្ងៃនេះ ៖

១) ថៅកែ ស៊ិន និងភរិយារបស់គាត់ដែលជួយគ្រួសាររបស់ខ្ញុំពីភូមិនិមិត្តទៅបន្ទាយនាង ហើយមកភូមិគាគង់វិញ ។

២) បុរសឥតស្គាល់ឈ្មោះនៅតូបតូចដែលលួចលាក់ផ្ដល់បាយ បបរ និងខោមួយ ព្រមទាំងជួយផ្ញើ និងប្រឡាក់សាច់ទាឲ្យខ្ញុំនៅយប់ថ្ងៃទី១២ ខែកក្កដា ឆ្នាំ១៩៧៥ ។

៣) ពុកគីម បានជូនដំណើរខ្ញុំ និងហ៊ាឡាយ ពីសហករណ៍ស្ពួលកោងមកដោយពុំគិតពីគ្រោះថ្នាក់លើខ្លួនគាត់ រហូតដល់ថ្ងៃដែលគាត់បានលាចាកលោកនេះទៅ ព្រោះតែមូលហេតុនេះ គឺមួយអាទិត្យក្រោយថ្ងៃចេញដំណើរប្រហែលត្រូវនឹងថ្ងៃទី១២ ខែមេសា ឆ្នាំ១៩៧៨ ។ ហ៊ាឡាយ ក៏ស្លាប់នៅពេលជាមួយគ្នានោះដែរ ។ សូមវិញ្ញាណក្ខន្ធលោកទាំងពីរបានទៅសោយក្នុងសុគតិភពកុំបីអាក់ខានឡើយ ។

៤) ពួកអមនុស្ស ឬទេវតាដែលរក្សាព្រឹក្សព្រៃនោះ រាប់ទាំងសត្វព្រៃដែលត្រាយផ្លូវឲ្យខ្ញុំដោយចេតនាក្ដី ឬអចេតនាក្ដី មានទាំងសត្វខ្ទីងមេ និងកូនជង ដែលខ្ញុំបានឃើញ ។ ខ្ញុំគិតឃើញថា បើគ្មានអន្តរាគមន៍ពីពួកអមនុស្ស និងសត្វទាំងនោះទេ ខ្លួនខ្ញុំពិតជាពុំមានសមត្ថភាពឆ្លងកាត់ព្រៃភ្នំ កាត់វាលដាច់សង្វែងនោះបានទេ ក្នុងរយៈពេល១៦ថ្ងៃ ដោយគ្មានអាហារ ។

៥) កសិករសៀមដែលយកខ្ញុំពីមាត់ព្រៃមកប្រគល់ឲ្យទាហានសៀម ។

៦) វេជ្ជបណ្ឌិត និងគិលានុបដ្ឋាកសៀមនៅមន្ទីរពេទ្យទាហាន

នៃស្រុកអារញ្ញដែលបានព្យាបាលរបួសឲ្យខ្ញុំ ។

៧) មិត្ត សារ៉ាន់, មិត្ត ម៉ន និងមិត្ត ទី ដែលបានជួយខ្ញុំនៅក្នុងគុកទាហានដើមស្ពួលក្នុងស្រុកអារញ្ញ ប្រទេសថៃ ។

៨) ម៉ាត់រឿង និងអតីតយុវជនកងចល័តស្ពួលកោងដែលបានជួយខ្ញុំនៅជំរំឃុំឃាំងបូរីរាំ ប្រទេសថៃ ។

៩) លោកវេជ្ជបណ្ឌិតស្គាល់រ៉ា ជនជាតិកាណាដា ដែលបានខ្នះខ្នែងជួយកិច្ចការរបស់ខ្ញុំ ។

១០) លោកឪពុក រ៉ូប៊ែររឿណេ សង្ឃកាតូលិកបារាំងបានជួយខ្ញុំ ជួយភរិយា និងកូនខ្ញុំឲ្យបានទៅដល់ប្រទេសបារាំង ។

១១) អង្គការ អាយ.អូ.អ៊ឹម ដែលបានជួយចេញថ្លៃសំបុត្រយន្តហោះឲ្យអ្នកភៀសខ្លួន ដែលមានរូបខ្ញុំ និងគ្រួសាររបស់ខ្ញុំផង ។

១២) លោកប្រធានាធិបតីបារាំង ហ្សីស្ការដេស្តាំង និងរដ្ឋាភិបាលរបស់លោក ដែលបានស្រោចស្រង់ជីវិតអ្នកភៀសខ្លួនឲ្យបានទៅរស់នៅប្រទេសបារាំង ។

១៣) លោកប្រធានាធិបតីបារាំង ហ្វ្រង់ស្វាស់មីតេរ៉ង់ និងរដ្ឋាភិបាលរបស់លោកដែលបានស្រោចស្រង់ជីវិតអ្នកភៀសខ្លួនឲ្យបានទៅរស់នៅប្រទេសបារាំង ។

១៤) ប្រទេស និងប្រជាជនបារាំងដែលបានជួយ និងអនុគ្រោះដល់អ្នកភៀសខ្លួនគ្រប់ទិសទីឲ្យបានសុខសាន្តលើទឹកដីបារាំង ។

១៥) លោក ណៃវសៃ និងភរិយា, លោក ប៉ែន វ៉ាណូ និងភរិយា, លោក កង វ៉ែន, លោក នូវ សាម៉ូវ ដែលបានទៅទទួល និងឧបត្ថម្ភខ្ញុំនៅអាកាសយានដ្ឋានស្ហាលជឺហ្គោល ប្រទេសបារាំង ។ លោកទាំងអស់គ្នាជាមិត្តចាស់របស់ខ្ញុំ និងជាមិត្តរៀងរហូត ។ លោក នូវ សាម៉ូវ បានលាចាកលោកនេះទៅហើយ តាំងពីអំឡុងឆ្នាំ១៩៨០ ។ សូមវិញ្ញាណក្ខន្ធរបស់លោកបានទៅកាន់សុគតិភព កុំបីឃ្លៀងឃ្លាតឡើយ ។

១៦) មិត្ត លី គាវសេង មិត្តដ៏កម្សត់កម្ររបស់ខ្ញុំដែលមានអនុស្សាវរីយ៍ច្រើនអនេកជាមួយគ្នា តាំងពីប្រទេសថៃដល់ប្រទេសបារាំង ។

១៧) អ្នកស្រី ម៉ូនិកបែលឡង់ ជាមិត្តភក្តិរបស់ខ្ញុំ ដែលបានជួយខ្ញុំគ្រប់គ្រាក្នុងប្រទេសបារាំង ។

១៨) អ្នកគ្រូ ហ្វ្រង់ស្វាស់គកណេ ជាគ្រូរបស់ខ្ញុំអំឡុងទសវត្សរ៍ឆ្នាំ៦០ នៅប្រទេសកម្ពុជា ហើយបន្តជួយខ្ញុំនៅប្រទេសបារាំងទៀត ។

១៩) សមាគមសម្រាប់ជួយជនភៀសខ្លួននៅប៉ូហ្សុម៉ុង វ៉ាល់ដូស៍ ប្រទេសបារាំង ។

២០) សមាគមក្វាឡាហ្សូរ៉េ ដែលមានលោក និងអ្នកស្រីវីវរនីញេ ជាអ្នកដឹកនាំ ។ លោកមានសមានចិត្តរាប់អានគ្រួសាររបស់ខ្ញុំ ។ តាមរយៈសមាគមនេះ ខ្ញុំបានស្គាល់រាប់អានគ្រួសារបឺតទែរ គ្រួសារប៉ូឡេ ជាមិត្តដ៏ជិតស្និទ្ធរបស់គ្រួសារខ្ញុំរហូតមកដល់សព្វថ្ងៃនេះ ។

២១) លោកវេជ្ជបណ្ឌិត ហ្សូស្សូម ប្រធានមជ្ឈមណ្ឌលព្យាបាល នៅប៉ូហ្សុម៉ុង ដេប៉ាតឺម៉ង់៩៥ ដែលបានផ្តល់ការងារ និងលំនៅស្ថានឲ្យខ្ញុំ និងកូនចិញ្ចឹមរបស់ខ្ញុំ ។ គុណូបការៈរបស់លោកខ្ញុំ ពុំអាចបំភ្លេចបានឡើយ ទោះបីលោកបានលាចាកលោកនេះក្តី សូមវិញ្ញាណក្ខន្ធរបស់លោកបានស្ថិតក្នុងសុគតិភព កុំបីឃ្លៀងឃ្លាតឡើយ ។

២២) លោក បេរូដ៍ នាយករដ្ឋបាល និងបុគ្គលិកការិយាល័យរបស់លោកនៅមជ្ឈមណ្ឌលព្យាបាលនៅប៉ូហ្សុម៉ុង ដែលបានជួយសម្រួលកិច្ចការរដ្ឋបាលឲ្យខ្ញុំ ។

២៣) លោកវេជ្ជបណ្ឌិត គេវ ណាំង គ្រូពេទ្យនាយកនៃអគារបេ ដែលលោកបានផ្តល់ចំណេះដឹង និងរាប់អានខ្ញុំស្មើមុខក្នុងការងារ ។

២៤) មិត្តភក្តិរួមការងារទាំងអស់នៅមជ្ឈមណ្ឌលព្យាបាលនៅប៉ូហ្សុម៉ុង ដែលមានសមានចិត្តចំពោះខ្ញុំ និងមានអនុស្សាវរីយ៍ល្អជាមួយគ្នា ។

២៥) លោក ថៅ ប៉េងលាត និងលោកស្រី ជាភរិយារបស់គាត់ ដែលបានជួយធានាលើប្រាក់កម្ចីពីធនាគារដើម្បីឲ្យខ្ញុំបានទិញលំនៅស្ថាននៅសាកសែល និងជួយឧបត្ថម្ភជាមធ្យោបាយធ្វើដំណើរដល់កូនរបស់ខ្ញុំ ។

២៦) មិត្តខ្មែរ មិត្តបារាំង និងមិត្តនៃជាតិសាសន៍ដទៃទៀតដែលពុំបានរាប់ឈ្មោះនៅក្នុងបញ្ជីនេះ ដែលមានចំណែកក្នុងការជួយជ្រោមជ្រែងដល់ជីវភាពរបស់ខ្ញុំ និងគ្រួសារខ្ញុំ ។

២៧) សម្តេចអគ្គមហាសេនាបតីតេជោហ៊ុន សែន ដែលលោកបានប្តូរជីវិតដើម្បីរកសន្តិភាព និងធ្វើឲ្យប្រទេសជាតិមានការអភិវឌ្ឍដ៏ត្រចះត្រចង់រហូតមកដល់សព្វថ្ងៃនេះ ។ ដោយឡែក ខ្ញុំសូមថ្លែងអំណរគុណដ៏ខ្ពង់ខ្ពស់ជូនសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន និងបុត្រាបុត្រីរបស់លោកដែលបានជួយឧបត្ថម្ភរូបខ្ញុំ និងគ្រួសារ

របស់ខ្ញុំជាប់មិនដាច់ ហើយរាប់រកគ្រួសាររបស់ខ្ញុំជាសាច់ញាតិពេញមុខរបស់សម្តេច ។

២៨) លោកជំទាវ ប៊ុន សុជា និងឯកឧត្តមឧត្តមសេនីយ៍តាន់បញ្ញាវុឌ្ឍ ។ លោកតែងឧបត្ថម្ភរូបខ្ញុំគ្រប់ពេលមានបុណ្យទានធំម្តងៗ ។ លោកមានសមានចិត្តរាប់រករូបខ្ញុំ ក៏ដូចជាគ្រួសាររបស់ខ្ញុំជាញាតិពេញមុខរបស់លោក ។

២៩) បងប្អូនកូនក្មួយដ៏ឧត្តមទាំងខាងសម្តេចអគ្គមហាសេនាបតីតេជោ និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ដែលលោកមានមេត្តារាប់រកគ្រួសាររបស់ខ្ញុំជាញាតិរបស់លោកពេញមុខ ។ កាយវិការរបស់អស់លោក ទាំងប្រុសទាំងស្រីនាំមកនូវមោទកភាពដ៏កក់ក្តៅបំផុតដល់គ្រួសារខ្ញុំ ។

៣០) អតីតសហសេវិករបស់ខ្ញុំ នៃអតីតមជ្ឈមណ្ឌលខ្មែរ និងសារព័ត៌មាន “ស្រុកខ្មែរ” នៅក្រុងប៉ារីស ។ យើងទាំងអស់គ្នាបង្កើតបានអនុស្សាវរីយ៍ល្អៗជាមួយគ្នា ។

៣១) វិញ្ញាណក្ខន្ធរបស់លោកឪពុក និងអ្នកម្តាយដែលលោកបានបង្កើតរូបខ្ញុំឲ្យមានចិត្តសប្បុរស និងចិត្តតស៊ូ ។

៣២) វិញ្ញាណក្ខន្ធរបស់មាតាបិតាក្មេកកាលលោកនៅមានជីវិត លោកមានព្រហ្មវិហារលើកូន លើចៅជាប់ជានិច្ច ។

៣៣) មាមីង បងប្អូន ញាតិសាច់សាលោហិត មិត្តសម្លាញ់ទាំងអស់ដែលផ្តល់នូវភាពកក់ក្តៅ និងកម្លាំងចិត្តដល់ខ្លួនខ្ញុំ ។

៣៤) ភរិយា និងកូនដែលផ្តល់កម្លាំងចិត្ត និងសេចក្តីសុខសាន្តឲ្យប្តី និងឪពុក ។ ប៉ុន្តែកាលកូនៗនៅតូច កូនត្រូវការសេចក្តីថ្នាក់ថ្នម និងការអប់រំពីឪពុក ។ ឪពុកពុំបានបំពេញករណីកិច្ចនោះឲ្យបានពេញលេញទេ ចូរកូនទាំងអស់យោគយល់ និងអភ័យទោសឲ្យឪពុក ។

“សូមសុខសន្តិភាពមានដល់មាតុភូមិរបស់ខ្ញុំជាភិយ្យោភាព”

សរសេរចប់នៅភ្នំពេញថ្ងៃទី៤ ខែឧសភា ឆ្នាំ២០១៤

**ថា សីហា**

# ដំណឹងស្វែងរកឪពុកមា

ខ្ញុំបាទឈ្មោះ ច័ន្ទ រិទ្ធី បច្ចុប្បន្នរស់នៅខណ្ឌសែនសុខ សង្កាត់ភ្នំពេញថ្មី ក្រុងភ្នំពេញ ។ ខ្ញុំបាទសូមប្រកាសរកឪពុកមា ឈ្មោះ សាប់ សំផន ដែលបានបាត់ខ្លួនក្នុងឆ្នាំ១៩៧៥ ក្រោយខ្មែរក្រហមរំដោះទីក្រុងភ្នំពេញ ។ លោកមា សាប់ សំផន មានស្រុកកំណើតនៅភូមិព្រៃលាភ ខេត្តកណ្តាល ។ គាត់មានឪពុកឈ្មោះ សាប់ ឈុន (ស្លាប់) និងម្តាយ ផ្លូន វ៉ាន់ (រស់) និងមានបងប្អូនប្រុសស្រី៦នាក់រួមមាន ៖ ១) សាប់ សេរីឈុំ ភេទស្រី (ស្លាប់ក្នុងរបបខ្មែរក្រហម), ២) សាប់ សំផន ភេទប្រុស (បាត់ខ្លួនក្នុងរបបខ្មែរក្រហម), ៣) សាប់ ធីគន្ធ ភេទស្រី (ស្លាប់ក្នុងរបបខ្មែរក្រហម), ៤) សាប់ សុខារី ភេទស្រី, ៥) សាប់ វ៉ាន់នីន ភេទប្រុស, ៦) សាប់ ភូមិរិន្ទ ភេទស្រី ។

សូមបញ្ជាក់ថា ក្នុងរបបសាធារណរដ្ឋខ្មែរ លោកមា សាប់ សំផន ជាទាហាននៅបន្ទាយស្ទឹងមានជ័យ និងក្រោយមក ផ្លាស់ទៅធ្វើជាទាហានជើងទឹកនៅកំពង់សោម ខេត្តព្រះសីហនុ ។ ក្រោយថ្ងៃរំដោះ១៧មេសា ឆ្នាំ១៩៧៥ កូនទាហានម្នាក់បានជូនគាត់ឡើងគោកក្នុងគោលបំណងជូនលោកមាមករកក្រុមគ្រួសារ ហើយក៏បាត់ដំណឹងតាំងពីពេលនោះមក ។

អាស្រ័យហេតុនេះ បើបងប្អូនណាបានឃើញ និងស្គាល់លោកមារបស់ខ្ញុំឈ្មោះ សាប់ សំផន ដូចដែលបានរៀបរាប់ខាងលើ សូមទាក់ទងមកខ្ញុំបាទតាមទូរស័ព្ទលេខៈ ០១៦ ៨៧៩ ៣៩៨ ឬ ទំនាក់ទំនងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជា ផ្ទះលេខ៦៦, មហាវិថីព្រះសីហនុ, រាជធានីភ្នំពេញ ឬ តាមរយៈទូរស័ព្ទ ០២៣ ២១១ ៨៧៥ ។

***សូមអរគុណ!***

# សៀវភៅរំឭកវិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់
# នៅក្នុងរបបខ្មែរក្រហម










មជ្ឈមណ្ឌលឯកសារកម្ពុជា គ្រោងនឹងបោះពុម្ពផ្សាយនូវសៀវភៅមានកត់ត្រាឈ្មោះរបស់អ្នកដែលស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ។ កន្លងមក មជ្ឈមណ្ឌលឯកសារកម្ពុជាបានចងក្រងនូវឈ្មោះអ្នកដែលស្លាប់ជាង១លាននាក់រួចមកហើយ ។ ប្រសិនបើលោកយាយ លោកតា អ៊ំ ពូ មីង ប្រាថ្នាចង់ឲ្យឈ្មោះសមាជិកក្រុមគ្រួសារដែលបានស្លាប់បាត់បង់ជីវិតមាននៅក្នុងសៀវភៅនេះ សូមទាក់ទងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈ អេង កុកថាយ ទូរស័ព្ទលេខ ០១២ ៧៩៧ ៣៩៤ ឬ អ៊ីម៉ែល ៖ truthkokthay@dccam.org ឲ្យបានឆាប់រហ័សតាមពេលវេលាដែលអាចធ្វើទៅបាន ។

***សូមផ្តល់ព័ត៌មានដូចខាងក្រោមៈ***

១) ឈ្មោះអ្នកប្រកាសប្រាប់, ២) តើមានបងប្អូនបង្កើតរួមទាំងឪពុកម្តាយស្លាប់ប៉ុន្មាននាក់នៅក្នុងសម័យខ្មែរក្រហម? ៣) ឈ្មោះអ្នកស្លាប់, ៤) ភេទអ្នកស្លាប់, ៥) អាយុអ្នកស្លាប់ (បើអាចចាំបាន), ៦) ត្រូវជាអ្វីនឹងអ្នកប្រកាស (ឧទាហរណ៍ៈ ឪពុក ម្តាយ បងប្រុស ប្អូនប្រុស បងស្រី ឬប្អូនស្រី), ៧) សាច់រឿងទាក់ទងនឹងការស្លាប់ (ឧទាហរណ៍ ៖ ស្លាប់នៅទីណា? មូលហេតុអ្វី?), ៨) វត្ថុតាងទាក់ទងនឹងអ្នកស្លាប់ (ឧទាហរណ៍ៈ រូបថត ឯកសារ ឬវត្ថុផ្សេងៗ), ៩) ព័ត៌មានសម្រាប់មជ្ឈមណ្ឌលទាក់ទង (ឧទាហរណ៍ៈ លេខទូរស័ព្ទ អាស័យដ្ឋាន) ។

***ប្រសិនបើចង់ស្វែងរកអ្នកដែលបាត់ខ្លួនសូមផ្តល់ព័ត៌មានខាងក្រោមៈ***

១) ឈ្មោះអ្នកបាត់ខ្លួន, ២) ភេទ, ៣) អាយុ, ៤) ត្រូវជាអ្វី, ៥) សាច់រឿងទាក់ទងនឹងការបែកគ្នា, ៦) វត្ថុតាងទាក់ទងនឹងអ្នកបាត់ខ្លួន (ឧទាហរណ៍ៈ រូបថត ឯកសារ ឬវត្ថុផ្សេងៗ) ។

ដើម្បីយុត្តិធម៌និងការចងចាំ
ដែលជាមូលដ្ឋានដ៏សំខាន់ក្នុងការផ្សះផ្សាជាតិ

ឧបត្ថម្ភការបោះពុម្ពផ្សាយដោយ ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិ សហរដ្ឋអាមេរិក (USAID)
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម.៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ ៖ (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ ៖ (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 187, 2015 ◆ Funded by USAID.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.